# សុត្តន្តបិដក





៣៨

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ មហាវារវគ្គ
# ទសមភាគ
# ៣៨



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## SAṂYUTTANIKĀYA

## MAHĀVĀRAVAGGA

## DASAMABHĀGA

## 38

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# អំព៌នអេអ

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

*ឧទាហរណ៍*

-ពាក្យខ្មែរៈ **សម៑ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស៑ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្កឹកាប្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## សំយុត្តនិកាយ មហាវារវគ្គ

## ទសមភាគ

៣៨

ព. ស. ២៤៩៦

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស មហាវារវគ្គោ

# ទសមោ ភាគោ

---

## សតិប្បដ្ឋានសំយុត្តំ

## អម្ពបាលិវគ្គោ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ អម្ពចាលិវនេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ។

# សុត្តន្តបិដក

# សំយុត្តនិកាយ  មហាវារវគ្គ

# ទសមភាគ

---

## សតិប្បដ្ឋានសំយុត្ត

## អម្ពបាលិវគ្គ

*[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងអម្ពបាលិវន[១] ជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះ ។*

---

១ អម្ពបាលិវននេះ គឺព្រៃស្វាយដែលនាងអម្ពបាលីបានដាំទុកធ្វើសួនឧទ្យានរបស់នាង ។ តមក នាងបានស្តាប់ធម្មទេសនារបស់ព្រះសាស្តា មានចិត្តជ្រះថ្លា ទើបឲ្យកសាងព្រះវិហារក្នុងឧទ្យាននោះ ហើយវេរថ្វាយចំពោះព្រះអង្គ ។ អដ្ឋកថា ។

[២] ឯកាយន្វាយំ[១] ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។

[៣] ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ[២] លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

---

១ ឯកាយនោ អយន្តិបិ ទិស្សតិ ។ ២ វិនយ ឥតិ អម្ហាកំ មតិ ។

[២] ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋាន ៤ ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបានសម្រេចនូវការត្រាស់ដឹង (អរិយមគ្គប្រកបដោយអង្គ ៨ ប្រការ) ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ សតិប្បដ្ឋានទាំង ៤ គឺអ្វីខ្លះ ។

[៣] ម្នាលភិក្ខុទាំងឡាយ គឺភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ជាអ្នកពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។

៣

អម្ពបាលិវគ្គោ

[៤] ឯកាយន្វាយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិ-
យា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ
អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិ-
កិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានាតិ ។ ឥទមវោច
ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អ-
ភិនន្ទុន្តិ ។

[៥] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ
អម្ពចាលិវនេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ
ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោ-
សុំ ។ ភគវា ឯតទវោច សតោ ភិក្ខវេ ភិក្ខុ វិហ-
រេយ្យ សម្បជានោ អយំ វោ អម្ហាកំ អនុសាសនីតិ ។

## អម្ពបាលិវគ្គ

[៤] ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបានសម្រេចនូវការត្រាស់ដឹង (អរិយមគ្គប្រកបដោយអង្គ ៨) ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវពុទ្ធភាសិតនេះ ។ ភិក្ខុទាំងនោះ ក៏ត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។

[៥] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពបាលិវនជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក៏ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវជាអ្នកមានស្មារតី ជាអ្នកដឹងខ្លួន នេះជាអនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[៦] កថញ្ច ភិក្ខវេ ភិក្ខុ សតោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ បេ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សតោ ហោតិ ។

[៧] កថញ្ច ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ

[៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ក្នុងវេទនាទាំងឡាយ ។ បេ ។ ក្នុងចិត្ត ។ ជាអ្នកពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក-ចេញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតីយ៉ាងនេះឯង ។

[៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងការដើរទៅខាងមុខ និងថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលក្រឡេកមើលទៅខាងមុខ និងក្រឡេកមើលទៅទិសផ្សេង ៗ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលបត់ដៃជើង និងលាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលទ្រទ្រង់នូវសំពត់សង្ឃាដិ បាត្រនិងចីវរ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកាលបរិភោគភោជន ផឹកទឹក ទំពាស៊ី (ខាទនីយវត្ថុ) ជញ្ជាបរស

៤

## អម្ពបាលិវគ្គោ

ឧច្ចារប្បស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្ប-ជានការី ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ សតោ ភិក្ខវេ ភិក្ខុ វិហរេយ្យ សម្បជា-នោ អយំ វោ អម្ហាកំ អនុសាសនីតិ ។

[៨] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេ-តវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញ-តរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និ-សិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ។

[៩] សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូប-កដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ ឯវមេវ បនិធេកច្ចេ មោឃបុរិសា មមញ្ញេវ អជ្ឈេសន្តិ

ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលដើរ ឈរ អង្គុយ លក់ ភ្ញាក់ឡើង និយាយ និងនៅស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងខ្លួន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវជាអ្នកមានស្មារតី មានសេចក្តីដឹងខ្លួន នេះជាអនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[៨] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ។

[៩] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់នូវធម៌ឯណា របស់ព្រះដ៏មានព្រះភាគហើយ ជាបុគ្គលម្នាក់ឯង ចៀសចេញទៅ មិនប្រមាទ មានព្យាយាមដុតកម្តៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សូមព្រះដ៏មានព្រះភាគសម្តែងនូវធម៌នោះឲ្យទាន ដល់ខ្ញុំព្រះអង្គដោយសង្ខេប ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា យ៉ាងនេះឯង មានពួកមោឃបុរសជំពូកខ្លះក្នុងលោកនេះ គ្រាន់តែអារាធនាតថាគត

ធម្មេ ច ភាសិតេ មមេវ អនុពន្ធិតព្វំ មញ្ញន្តីតិ ។ ទេសេតុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ សុគតោ សង្ខិត្តេន ធម្មំ អប្បេវ នាមាហំ ភគវតោ ភាសិតស្ស អត្ថំ អាជានេយ្យំ អប្បេវ នាមាហំ ភគវតោ ភាសិតស្ស ទាយាទោ អស្សន្តិ ។

[១០] តស្មាតិហ ត្វំ ភិក្ខុ អាទិមេវ វិសោធេហិ កុសលេសុ ធម្មេសុ ។ កោ ចាទិ កុសលានំ ធម្មានំ ។ សីលំ ច សុវិសុទ្ធំ ទិដ្ឋិ ច ឧជុកា ។ យតោ ខោ តេ ភិក្ខុ សីលំ ច សុវិសុទ្ធំ ភវិស្សតិ ទិដ្ឋិ ច ឧជុកា ។ តតោ ត្វំ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សតិប្បដ្ឋានេ តិវិធេន ភាវេយ្យាសិ ។ កតមេ ចត្តារោ ។

មួយទៀត គ្រាន់តែសម្គាល់តថាគតថាជាបុគ្គលគួរប្រព្រឹត្តតាមក្នុងធម៌ដែលតថាគតសម្តែងហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់សម្តែងនូវធម៌ដោយសង្ខេប សូមព្រះសុគតទ្រង់សម្តែងនូវធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ធ្វើដូចម្តេចហ្ន៎ ឲ្យខ្ញុំព្រះអង្គគប្បីដឹងច្បាស់នូវអត្ថនៃភាសិតរបស់ព្រះដ៏មានព្រះភាគបាន ធ្វើដូចម្តេចហ្ន៎ ឲ្យខ្ញុំព្រះអង្គគប្បីជាអ្នកទទួលនូវមត៌កនៃភាសិតរបស់ព្រះដ៏មានព្រះភាគបាន ។

[១០] ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរជម្រះក្នុងកុសលធម៌ទាំងឡាយជាខាងដើមបង្អស់សិនចុះ ។ ចុះអ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ ។ គឺសីលដ៏បរិសុទ្ធ ១ ទិដ្ឋិត្រង់ ១ ម្នាលភិក្ខុ កាលណាសីលរបស់អ្នកបរិសុទ្ធផង ទិដ្ឋិត្រង់ផង ។ ម្នាលភិក្ខុ កាលនោះ អ្នកអាស្រ័យសីលតាំងនៅក្នុងសីល ហើយគប្បីចម្រើនសតិប្បដ្ឋានទាំង ៤ ដោយចំណែក ៣ ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។

៧

អម្ពបាលិវគ្គោ

[១១] ឥធ ត្វំ ភិក្ខុ អជ្ឈត្តំ វា កាយេ កាយា-
នុបស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិ-
នេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ពហិទ្ធា វា
កាយេ កាយានុបស្សី វិហរាហិ អាតាបី សម្បជានោ
សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អជ្ឈត្ត-
ពហិទ្ធា វា កាយេ កាយានុបស្សី វិហរាហិ អាតាបី
សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-
នស្សំ ។ អជ្ឈត្តំ វា វេទនាសុ ។ ពហិទ្ធា វា វេទ-
នាសុ ។ អជ្ឈត្តពហិទ្ធា វា វេទនាសុ វេទនានុបស្សី
វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ
លោកេ អភិជ្ឈាទោមនស្សំ ។ អជ្ឈត្តំ វា ចិត្តេ ។

អម្ពបាលិវគ្គ

[១១] ម្នាលភិក្ខុ ក្នុងសាសនានេះ អ្នកចូរពិចារណាឲ្យឃើញនូវកាយក្នុងកាយជាខាងក្នុងជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញក្តី ។ អ្នកចូរពិចារណាឲ្យឃើញនូវកាយក្នុងកាយជាខាងក្រៅជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញក្តី ។ អ្នកចូរពិចារណាឲ្យឃើញនូវកាយក្នុងកាយទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញក្តី ។ ក្នុងវេទនាទាំងឡាយជាខាងក្នុងក្តី ។ ក្នុងវេទនាទាំងឡាយជាខាងក្រៅក្តី ។ អ្នកចូរពិចារណាឲ្យឃើញនូវវេទនាក្នុងវេទនាទាំងឡាយទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញក្តី ។

ពហិទ្ធា វា ចិត្តេ ។ អជ្ឈត្តពហិទ្ធា វា ចិត្តេ ចិត្តានុ-
បស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ
លោកេ អភិជ្ឈាទោមនស្សំ ។ អជ្ឈត្តំ វា ធម្មេសុ ។
ពហិទ្ធា វា ធម្មេសុ ។ អជ្ឈត្តពហិទ្ធា វា ធម្មេសុ
ធម្មានុបស្សី វិហរាហិ អាតាបី សម្បជានោ សតិមា
វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[១២] យតោ ខោ ត្វំ ភិក្ខុ សីលំ និស្សាយ
សីលេ បតិដ្ឋាយ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ
តិវិធេន ភាវេស្សសិ ។ តតោ តុយ្ហំ ភិក្ខុ យា រត្តិ
វា ទិវសោ វា អាគមិស្សតិ វុឌ្ឍិយេវ បាដិកង្ខា
កុសលេសុ ធម្មេសុ នោ បរិហានីតិ ។

ក្នុងចិត្តជាខាងក្នុងក្តី ។ ក្នុងចិត្តជាខាងក្រៅក្តី ។ អ្នកចូរពិចារណាឲ្យឃើញនូវចិត្តក្នុងចិត្តទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញក្តី ក្នុងធម៌ទាំងឡាយជាខាងក្នុងក្តី ។ ក្នុងធម៌ទាំងឡាយជាខាងក្រៅក្តី ។ អ្នកចូរពិចារណាឲ្យឃើញនូវធម៌ក្នុងធម៌ទាំងឡាយទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញក្តី ។

[១២] ម្នាលភិក្ខុ កាលណាអ្នកបានអាស្រ័យសីល តាំងនៅក្នុងសីល នឹងចម្រើននូវសតិប្បដ្ឋានទាំង ៤ នេះដោយ ៣ ចំណែកយ៉ាងនេះ ។ ម្នាលភិក្ខុ កាលនោះ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ នឹងមានប្រាកដដល់អ្នកទាំងយប់ទាំងថ្ងៃ ឯសេចក្តីសាបសូន្យមិនមានឡើយ ។

៩

អម្ពបាលិវគ្គោ

[១៣] អថខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សោ ភិក្ខុ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហារតិ[១] ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ[២] ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

១ ឱ. វិហរសិ ។ ២ អភិញ្ញាសិ ។

អម្ពបាលិវគ្គ

[១៣] គ្រានោះឯង ភិក្ខុនោះក៏រីករាយ អនុមោទនា ចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណាចៀសចេញទៅ ។ លំដាប់នោះ ភិក្ខុនោះចៀសចេញទៅតែម្នាក់ឯង មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកម្តៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ឯណា មិនយូរប៉ុន្មាន ក៏បានត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះដែលជាទីបំផុតនៃព្រហ្មចរិយៈដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ទើបដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះក៏បានជាព្រះអរហន្តមួយអង្គដែរ ។

[១៤] ឯកំ សមយំ ភគវា កោសលេសុ វិហរតិ កោសលាយំ ព្រាហ្មណគ្គាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ។ បេ ។ ឯតទវោច យេ តេ ភិក្ខវេ ភិក្ខូ នវា អចិរប្បព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេ វោ ភិក្ខវេ ភិក្ខូ ចតុន្នំ សតិប្បដ្ឋានានំ ភាវនាយ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ កតមេសំ ចតុន្នំ ។

[១៥] ឯថ តុម្ហេ អាវុសោ កាយេ កាយានុបស្សិនោ វិហរថ អាតាបិនោ សម្បជានា ឯកោទិភូតា វិប្បសន្នចិត្តា សមាហិតា ឯកគ្គចិត្តា កាយស្ស យថាភូតំ ញាណាយ ។ វេទនាសុ វេទនានុបស្សិនោ វិហរថ អាតាបិនោ សម្បជានា ឯកោទិភូតា វិប្បសន្នចិត្តា សមាហិតា ឯកគ្គចិត្តា វេទនានំ យថាភូតំ ញាណាយ ។ ចិត្តេ ចិត្តានុបស្សិនោ វិហរថ

[១៤] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រាហ្មណ-គ្រាមឈ្មោះកោសល ក្នុងដែនពួកអ្នកកោសល ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ។ បេ ។ ទ្រង់ត្រាស់នូវភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាជាភិក្ខុថ្មី ទើបនឹងបួស ទើបតែនឹងមកកាន់ធម្មវិន័យនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ អ្នកទាំងឡាយគប្បីឲ្យសមាទាន ឲ្យសេពគប់ ឲ្យតាំងនៅក្នុងការចម្រើនសតិប្បដ្ឋានទាំង ៤ ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។

[១៥] ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរមកអាយ ចូរពិចាណាឲ្យឃើញនូវកាយក្នុងកាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក ប្រព្រឹត្តទៅដើម្បីសេចក្តីដឹងនូវកាយ តាមសភាវៈពិត ។ អ្នកទាំងឡាយចូរពិចារណាឲ្យឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក ប្រព្រឹត្តទៅដើម្បីសេចក្តីដឹងនូវវេទនា តាមស-ភាវៈពិត ។ អ្នកទាំងឡាយចូរពិចារណាឲ្យឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី

អាតាបិនោ សម្បជានា ឯកោទិភូតា វិប្បសន្នចិត្តា ស-
មាហិតា ឯកគ្គចិត្តា ចិត្តស្ស យថាភូតំ ញាណាយ ។
ធម្មេសុ ធម្មានុបស្សិនោ វិហរថ អាតាបិនោ សម្បជានា
ឯកោទិភូតា វិប្បសន្នចិត្តា សមាហិតា ឯកគ្គចិត្តា
ធម្មានំ យថាភូតំ ញាណាយ ។

[១៦] យេបិ តេ ភិក្ខវេ ភិក្ខូ សេក្ខា អប្ប-
ត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា វិហរន្តិ
តេបិ កាយេ កាយានុបស្សិនោ វិហរន្តិ អាតាបិនោ
សម្បជានា ឯកោទិភូតា វិប្បសន្នចិត្តា សមាហិតា
ឯកគ្គចិត្តា កាយស្ស បរិញ្ញាយ ។ វេទនាសុ វេ-
ទនានុបស្សិនោ វិហរន្តិ អាតាបិនោ សម្បជានា ឯ-
កោទិភូតា វិប្បសន្នចិត្តា សមាហិតា ឯកគ្គចិត្តា

ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯកប្រព្រឹត្តទៅដើម្បីសេចក្តីដឹងនូវចិត្ត តាមសភាវៈពិត ។ អ្នកទាំងឡាយចូរពិចារណាឲ្យឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក ប្រព្រឹត្តទៅដើម្បីដឹងនូវធម៌ទាំងឡាយ តាមសភាវៈពិត ។

[១៦] ម្នាលភិក្ខុទាំងឡាយ ពួកសេក្ខភិក្ខុឯណា ជាអ្នកមិនទាន់ដល់នូវអរហត្តមគ្គ ជាគ្រឿងផ្តាច់បង់នូវមានៈនៅឡើយ ហើយប្រាថ្នានូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ សេក្ខភិក្ខុទាំងអម្បាលនោះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវកាយ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រ-ក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក

វេទនានំ បរិញ្ញាយ ។ ចិត្តេ ចិត្តានុបស្សិនោ វិហរន្តិ អាតាបិនោ សម្បជានា ឯកោទិភូតា វិប្បសន្នចិត្តា សមាហិតា ឯកគ្គចិត្តា ចិត្តស្ស បរិញ្ញាយ ។ ធម្មេសុ ធម្មានុបស្សិនោ វិហរន្តិ អាតាបិនោ សម្បជានា ឯ-កោទិភូតា វិប្បសន្នចិត្តា សមាហិតា ឯកគ្គចិត្តា ធម្មានំ បរិញ្ញាយ ។

[១៧] យេបិ តេ ភិក្ខវេ ភិក្ខូ អរហន្តោ ខី-ណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អ-នុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញា វិមុត្តា តេបិ កាយេ កាយានុបស្សិនោ វិហរន្តិ អាតាបិនោ សម្បជានា ឯកោទិភូតា វិប្បសន្នចិត្តា សមាហិតា

ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវវេទនាទាំងឡាយ ។ ជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវចិត្ត ។ ជាអ្នកពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវធម៌ទាំងឡាយ ។

[១៧] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុឯណាជាអរហន្តខីណាស្រព ដែលមានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចបានធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយដោយលំដាប់ មានសញ្ញោជនៈក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះត្រាស់ដឹងដោយប្រពៃ ភិក្ខុទាំងនោះ តែងពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់

១៣

អម្ពបាលិវគ្គោ

ឯកគ្គចិត្តា កាយេន វិសំយុត្តា ។ វេទនាសុ វេទនានុ-
បស្សិនោ វិហរន្តិ អាតាបិនោ សម្បជានា ឯកោទិភូ-
តា វិប្បសន្នចិត្តា សមាហិតា ឯកគ្គចិត្តា វេទនាហិ
វិសំយុត្តា ។ ចិត្តេ ចិត្តានុបស្សិនោ វិហរន្តិ អាតាបិនោ
សម្បជានា ឯកោទិភូតា វិប្បសន្នចិត្តា សមាហិតា ឯ-
កគ្គចិត្តា ចិត្តេន វិសំយុត្តា ។ ធម្មេសុ ធម្មានុបស្សិនោ
វិហរន្តិ អាតាបិនោ សម្បជានា ឯកោទិភូតា វិប្ប-
សន្នចិត្តា សមាហិតា ឯកគ្គចិត្តា ធម្មេហិ វិសំយុត្តា ។

[១៨] យេបិ តេ ភិក្ខវេ ភិក្ខូ ឥមា អចិរប្បព្វជិតា
អធុនាគតា ឥមំ ធម្មវិនយំ តេ វោ ភិក្ខវេ ភិក្ខូ ឥមេ-
សំ ចតុន្នំ សតិប្បដ្ឋានានំ ភាវនាយ សមាទបេតព្វា
និវេសេតព្វា បតិដ្ឋាបេតព្វាតិ ។

មានចិត្តខ្ពស់ឯក មិនជំពាក់ដោយកាយ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក មិនជំពាក់ដោយវេទនាទាំង-ឡាយ ។ ជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក មិនជំពាក់ដោយចិត្ត ។ ជាអ្នកពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានចិត្តមានអារម្មណ៍មូលតែមួយ មានចិត្តជ្រះថ្លា មានចិត្តតាំងខ្ជាប់ មានចិត្តខ្ពស់ឯក មិនជំពាក់ដោយធម៌ទាំងឡាយ ។

[១៨] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុឯណាជាភិក្ខុថ្មី ទើបតែនឹងបួស ទើបនឹងមកកាន់ធម្មវិន័យនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនោះ អ្នកទាំងឡាយគប្បីឲ្យសមាទាន ឲ្យសេពគប់ ឲ្យតាំងនៅក្នុងការបម្រើនសតិប្បដ្ឋានទាំង ៤ នេះ ។

[១៩] សាវត្ថីនិទានំ ។ តត្រ ខោ ភគវា ។ បេ ។ ឯតទវោច អកុសលរាសីតិ ភិក្ខវេ វទមានោ បញ្ច នីវរណេ សម្មា វទមានោ វទេយ្យ ។ កេវលោ ហាយំ ភិក្ខវេ អកុសលរាសិ យទិទំ បញ្ច នីវរណា ។ កតមេ បញ្ច ។ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ។ អកុសលរាសីតិ ភិក្ខវេ វទមានោ ឥមេ បញ្ច នីវរណេ សម្មា វទមានោ វទេយ្យ ។ កេវលោ ហាយំ ភិក្ខវេ អកុសលរាសិ យទិទំ បញ្ច នីវរណា ។

[២០] កុសលរាសីតិ ភិក្ខវេ វទមានោ ចត្តារោ សតិប្បដ្ឋានេ សម្មា វទមានោ វទេយ្យ ។ កេវលោ ហាយំ ភិក្ខវេ កុសលរាសិ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[១៩] *សាវត្ថីនិទាន ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ។ បេ ។ បានត្រាស់នូវភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលពោលថា គំនរនៃអកុសលដូច្នេះ បើពោលដោយត្រឹមត្រូវ ត្រូវពោលចំពោះនីវរណៈទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ គំនរនៃអកុសលទាំងអស់នេះ គឺនីវរណៈទាំង ៥ នេះឯង ។ នីវរណៈទាំង ៥ តើអ្វីខ្លះ ។ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលពោលថា គំនរនៃអកុសលដូច្នេះ កាលបើពោលដោយត្រឹមត្រូវ ត្រូវពោលចំពោះនីវរណៈទាំង ៥ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ គំនរនៃអកុសលទាំងអស់នេះ គឺនីវរណៈទាំង ៥ នេះឯង ។*

[២០] *ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលពោលថា គំនរនៃកុសលដូច្នេះ កាលបើពោលដោយត្រឹមត្រូវ ត្រូវពោលចំពោះសតិប្បដ្ឋានទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ គំនរនៃកុសលទាំងអស់នេះ គឺសតិប្បដ្ឋានទាំង ៤ នេះឯង ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។*

វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ កុសលរាសីតិ ភិក្ខវេ វទមានោ ឥមេ ចត្តារោ សតិប្បដ្ឋានេ សម្មា វទមានោ វទេយ្យ ។ កេវលោ ហាយំ ភិក្ខវេ កុសលរាសិ យទិទំ ចត្តារោ សតិប្បដ្ឋានាតិ ។

[២១] ភូតបុព្វំ ភិក្ខវេ សកុណគ្ឃី លាបំ សកុណំ សហសា អជ្ឈប្បត្តា អគ្គហេសិ ។ អថខោ ភិក្ខវេ លាបោ សកុណោ សកុណគ្ឃិយា ហរិយមានោ ឯវំ បរិទេវេសិ មយមេវម្ហ អលក្ខិកា មយំ អប្បបុញ្ញា យេ មយំ អគោចរេ ចរិម្ហ បរវិសយេ ។

ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី នូវចិត្ត ក្នុងចិត្តជាប្រក្រតី នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គល ពោលថា គំនរនៃកុសលដូច្នេះ កាលបើពោលដោយត្រឹមត្រូវ ត្រូវ ពោលចំពោះសតិប្បដ្ឋានទាំង ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ គំនរ នៃកុសលទាំងអស់នេះ គឺសតិប្បដ្ឋានទាំង ៤ នេះឯង ។

[២១] ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងពីដើមមកថា មាន សត្វខ្មែង ១ បានឆាបសត្វប្រចៀចដោយរហ័ស ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វប្រចៀច កាលដែលសត្វខ្មែងកំពុងនាំយកទៅ ក៏ ស្រែកបម្រះនឿលយ៉ាងនេះថា យើងជាសត្វឥតសិរី មានបុណ្យតិច បានជាត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែនរបស់អ្នកដទៃ ។

សចជ្ជ[១] មយំ គោចរេ ចរេយ្យាម សកេ បេត្តិកេ វិសយេ ន ម្យាយំ សកុណគ្ឃី អលំ អភវិស្ស យទិទំ យុទ្ធាយាតិ ។ កោ បន តេ លាប គោចរោ សកោ បេត្តិកោ វិសយោតិ ។ យទិទំ នង្គលកដ្ឋករណំ លេឌ្ឌុដ្ឋានន្តិ ។ អថខោ ភិក្ខវេ សកុណគ្ឃី សកេ ពលេ អបត្ថទ្ធា សកេ ពលេ អវទមានា[២] លាបំ សកុណំ បមុញ្ចិ គច្ឆ ខោ ត្វំ លាប តត្រាបិ មេ គន្ត្វា ន មោក្ខសីតិ ។ អថខោ ភិក្ខវេ លាបោ សកុណោ នង្គលកដ្ឋករណំ លេឌ្ឌុដ្ឋានំ គន្ត្វា មហន្តំ លេឌ្ឌុំ អភិរូហិត្វា សកុណគ្ឃឹ វទមានោ អដ្ឋាសិ ឯហិ ខោទានិ មេ សកុណគ្ឃិ ឯហិ ខោទានិ មេ សកុណគ្ឃីតិ ។ អថខោ សា ភិក្ខវេ សកុណគ្ឃី សកេ ពលេ អបត្ថទ្ធា សកេ ពលេ អវទមានា ឧភោ បក្ខេ សន្នាយ លាបំ សកុណំ សហសា អជ្ឈប្បត្តា ។ យទា ខោ ភិក្ខវេ អញ្ញាសិ លាបោ សកុណោ ពហុ អាគតា ខោ ម្យាយំ សកុលណគ្ឃីតិ អត្ថស្សេវ[៣] លេឌ្ឌុស្ស អន្តរំ បច្ចុបាទិ ។ អថខោ ភិក្ខវេ សកុណគ្ឃី

១ ឱ. ម. សចេជ្ជ ។ ២ ឱ. ម. អសំវទមានា ។ ៣ អថ តស្សេវ ។

*បើថ្ងៃនេះយើងត្រាច់ទៅក្នុងទីជាទីគោចរ ជាដែនរបស់បិតាខ្លួន សត្វខ្វែង នេះមិនអាចនឹងតយុទ្ធនឹងយើងបានឡើយ ។ សត្វខ្វែងឆ្លើយថា ម្នាល ប្រចៀច ចុះទីណាជាទីគោចររបស់ឯង ដែលជាដែនរបស់បិតារបស់ ខ្លួន ។ ប្រចៀចឆ្លើយថា ទីជាទីគោចរ គឺទីមានអាចម៍ដីដែលគេទើប នឹងភ្ជួរដោយនង្គ័ល ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វខ្វែង អាងកម្លាំងខ្លួន ពោលសរសើរកម្លាំងរបស់ខ្លួន ក៏លែងសត្វប្រចៀចទៅ ដោយពាក្យថា នែប្រចៀច ឯងហើរទៅចុះ ទុកជាឯងនៅក្នុងទីនោះ ក៏មិនរួចអំពីអញដែរ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វប្រ-ចៀចក៏ហើរទៅកាន់ទីមានអាចម៍ដីដែលគេទើបនឹងភ្ជួរដោយនង្គ័ល ហើយ ទំស៊ីលើដុំដីធំមួយដុំ និយាយនឹងសត្វខ្វែងថា នែខ្វែង ឯងចូរមករកយើង ក្នុងកាលឥឡូវនេះចុះ នែខ្វែង ឯងចូរមករកយើងក្នុងកាលឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ សត្វខ្វែងនោះអាងកម្លាំងខ្លួន ពោល សរសើរកម្លាំងរបស់ខ្លួន ហើយសម្ងបស្លាបទាំងពីរ ឆាបសត្វប្រចៀច ដោយរហ័ស ។ ម្នាលភិក្ខុទាំងឡាយ កាលណាសត្វប្រចៀចបានដឹង ច្បាស់ថាសត្វខ្វែងនេះ ហើរមកជិតអាត្មាអញហើយ ក៏រត់ចូលទៅ ក្នុងចន្លោះដុំដីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វខ្វែង*

តត្ថេវ ឧរំ បច្ចតាឡេសិ ។ ឯវញ្ហេតំ ភិក្ខវេ ហោតិ យោ អគោចរេ ចរតិ បរវិសយេ ។

[២២] តស្មាតិហ ភិក្ខវេ មា អគោចរេ ចរិត្ថ បរវិសយេ ។ អគោចរេ ភិក្ខវេ ចរតំ បរវិសយេ លច្ឆតិ មារោ ឱតារំ លច្ឆតិ មារោ អារម្មណំ ។ កោ ច ភិក្ខវេ ភិក្ខុនោ អគោចរោ បរវិសយោ ។ យទិទំ បញ្ច កាមគុណា ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ សោតវិញ្ញេយ្យា សទ្ទា ។ ឃានវិញ្ញេយ្យា គន្ធា ។ ជិវ្ហាវិញ្ញេយ្យា រសា ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ អយំ ភិក្ខវេ ភិក្ខុនោ អគោចរោ បរវិសយោ ។

ក៏ទន្ទិចទ្រូងត្រង់ដុំដីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំណើរដែលសត្វប្រចៀចត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែនរបស់អ្នកដទៃ ក៏មានដោយប្រការយ៉ាងនេះឯង ។

[២២] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយកុំត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែននៃបុគ្គលដទៃឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែននៃបុគ្គលដទៃ មារតែងបាននូវចន្លោះ មារតែងបាននូវអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ចុះទីមិនមែនជាទីគោចរ ជាដែននៃបុគ្គលដទៃ តើដូចម្តេច ។ គឺកាមគុណទាំង ៥ នេះឯង ។ កាមគុណទាំង ៥ តើអ្វីខ្លះ ។ គឺរូបទាំងឡាយដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ១ ។ សំឡេងទាំងឡាយដែលគប្បីដឹងដោយត្រចៀក ១ ។ ក្លិនទាំងឡាយដែលគប្បីដឹងដោយច្រមុះ ១ ។ រសទាំងឡាយដែលគប្បីដឹងដោយអណ្តាត ១ ។ ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទីមិនមែនជាទីគោចររបស់ភិក្ខុ ជាដែនរបស់បុគ្គលដទៃ ។

[២៣] គោចរេ ភិក្ខវេ ចរថ សកេ បេត្តិកេ វិស-
យេ ។ គោចរេ ភិក្ខវេ ចរតំ សកេ បេត្តិកេ វិសយេ
ន លច្ឆតិ មារោ ឱតារំ ន លច្ឆតិ មារោ អារម្មណំ ។
កោ ច ភិក្ខវេ ភិក្ខុនោ គោចរោ សកោ បេត្តិកោ
វិសយោ ។ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ
ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី
វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុ-
បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ
លោកេ អភិជ្ឈាទោមនស្សំ ។ អយំ ភិក្ខវេ ភិក្ខុនោ
គោចរោ សកោ បេត្តិកោ វិសយោតិ ។

[២៣] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅក្នុងទីជាទីគោចរ ជាដែននៃបិតារបស់ខ្លួនចុះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយត្រាច់ទៅក្នុងទីជាទីគោចរ ជាដែននៃបិតារបស់ខ្លួន មារនឹងមិនបាននូវចន្លោះ មារនឹងមិនបាននូវអារម្មណ៍ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះទីជាទីគោចររបស់ភិក្ខុ ជាដែននៃបិតារបស់ខ្លួន តើដូចម្តេច ។ គឺសតិប្បដ្ឋានទាំង ៤ នេះឯង ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ នេះទីជាទីគោចររបស់ភិក្ខុ ជាដែននៃបិតារបស់ខ្លួន ។

អម្ពបាលិវគ្គោ

[២៤] អត្ថិ ភិក្ខវេ ហិមវតោ បព្វតរាជស្ស ទុគ្គា វិសមា ទេសា យត្ថ នេវ មក្កដានំ ចារិ ន មនុស្សា-នំ ។ អត្ថិ ភិក្ខវេ ហិមវតោ បព្វតរាជស្ស ទុគ្គា វិសមា ទេសា យត្ថ មក្កដានញ្ហិ ខោ ចារិ ន មនុស្សានំ ។ អត្ថិ ភិក្ខវេ ហិមវតោ បព្វតរាជស្ស សមា ភូមិភាគា រមណីយា យត្ថ មក្កដានញ្ចេវ ចារិ មនុស្សានំ ច ។ តត្រ ខោ ភិក្ខវេ លុទ្ទា មក្កដ-វីថីសុ លេបំ ឱឌ្ឌេន្តិ មក្កដានំ ពាធនាយ ។ តត្រ ភិក្ខវេ យេ តេ មក្កដា អពាលជាតិកា អលោល-ជាតិកា តេ តំ[១] លេបំ ទិស្វា អារកា បរិវជ្ជេន្តិ ។

---

១ ម. តេ តត្ថ ។

អម្ពបាលិវគ្គ

[២៤] ម្នាលភិក្ខុទាំងឡាយ ការត្រាច់ទៅនៃពួកស្វា និងពួកមនុស្ស មិនមានក្នុងប្រទេសឯណា ប្រទេសនោះ ជាប្រទេសនៃស្តេចភ្នំឈ្មោះហិមវន្ត ជាទីទៅបានដោយលំបាក ជាទីរដិបរដុបក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ពិតមែនតែការដែលត្រាច់ទៅបាននៃពួកស្វាក្នុងប្រទេសឯណា ប្រទេសនោះ ជាប្រទេសនៃស្តេចភ្នំឈ្មោះហិមវន្ត ជាទីទៅបានដោយលំបាក ជាទីមិនរាបស្មើ តែពួកមនុស្សត្រាច់ទៅមិនបានក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការត្រាច់ទៅបាននៃពួកស្វាក្តី ពួកមនុស្សក្តី ក្នុងប្រទេសឯណា ប្រទេសនោះ ជាប្រទេសនៃស្តេចភ្នំឈ្មោះហិមវន្ត មានភូមិភាគរាបស្មើល្អ ជាទីគួររីករាយក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទីនោះឯង ពួកព្រានដាក់នូវជ័រស្អិតក្នុងផ្លូវនៃស្វា ដើម្បីបៀតបៀននូវពួកស្វា ។ ម្នាលភិក្ខុទាំងឡាយ ពួកស្វាឯណាមានជាតិជាសត្វមិនល្ងង់ខ្លៅ មានជាតិជាសត្វមិនរលោភរលាំ នៅក្នុងទីនោះ ស្វាទាំងនោះ បានឃើញជ័រស្អិតនោះហើយ ក៏គេចចេញអំពីចម្ងាយ ។

យោ បន សោ ហោតិ មក្កដោ ពាលជាតិកោ លោលជាតិកោ សោ តំ លេបំ ឧបសង្កមិត្វា ហត្ថេន គណ្ហាតិ សោ តត្ថ ពជ្ឈតិ ហត្ថំ មោចេស្សាមីតិ ទុតិយេន ហត្ថេន គណ្ហាតិ សោ តត្ថ ពជ្ឈតិ ឧភោ ហត្ថេ មោចេស្សាមីតិ បាទេន គណ្ហាតិ សោ តត្ថ ពជ្ឈតិ ឧភោ ហត្ថេ មោចេស្សាមិ បាទំ ចាតិ ទុតិយេន បាទេន គណ្ហាតិ សោ តត្ថ ពជ្ឈតិ ឧភោ ហត្ថេ មោចេស្សាមិ បាទេ ចាតិ តុណ្ឌេន គណ្ហាតិ សោ តត្ថ ពជ្ឈតិ ។ ឯវំ ហិ សោ ភិក្ខវេ មក្កដោ បញ្ចោឌ្ឌិតោ ថុនំ សេតិ[១] អនយំ អាបន្នោ ព្យសនំ អាបន្នោ យថា កាមករណីយោ លុទ្ទស្ស ។ តមេនំ ភិក្ខវេ លុទ្ទោ វិជ្ឈិត្វា តស្មិំយេវ មក្កដំ ឧទ្ធរិត្វា អវិស្សជ្ជេត្វា យេន កាមំ បក្កមតិ ។ ឯវំ ហោតំ ភិក្ខវេ ហោតិ យោ អគោចរេ ចរតិ បរវិសយេ ។

១ ថនំ សេតិ។

ឯស្វាឯណាមានជាតិជាសត្វល្ងង់ខ្លៅ មានជាតិជាសត្វលោភលន់ ស្វានោះក៏ចូលទៅរកជ័រស្អិតនោះ ហើយចាប់ដោយដៃ ក៏ជាប់ដៃនឹងជ័រស្អិតនោះ ទើបគិតថា អាត្មាអញនឹងដោះដៃចេញ ហើយចាប់ដោយដៃមួយទៀត ក៏ជាប់ដៃនឹងជ័រស្អិតនោះទៀត ទើបគិតថា អាត្មាអញនឹងដោះដៃទាំងពីរចេញ ហើយក៏ចាប់ដោយជើង ក៏ជាប់ជើងនឹងជ័រស្អិតនោះ ទើបគិតថា អាត្មាអញនឹងដោះដៃទាំងពីរ និងជើងចេញ ហើយចាប់ដោយជើងមួយទៀត ក៏ជាប់ជើងនឹងជ័រស្អិតនោះទៀត ទើបគិតថា អាត្មាអញនឹងដោះដៃទាំងពីរផង ជើងទាំងពីរផង ហើយក៏ខាំដោយមាត់ ជាប់មាត់នឹងជ័រស្អិតនោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ឯស្វានោះក៏ជាប់ចំណង ៥ ប្រការ ដេកដកដង្ហើមធំ ដល់នូវសេចក្តីវិនាស ដល់នូវសេចក្តីហិនហោច ជាសត្វគួរធ្វើតាមសេចក្តីប្រាថ្នារបស់ព្រានបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រានក៏ចាក់ស្វានោះ ហើយចាប់កើចកន្ត្រាក់ស្វាឡើងអំពីទីនោះមិនលែង ហើយចេញទៅកាន់ទីតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ដំណើរដែលភិក្ខុត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែននៃបុគ្គលដទៃ រមែងមានដូច្នេះឯង ។

២១

អម្ពបាលិវគ្គោ

[២៤] តស្មាតិហ ភិក្ខវេ មា អគោចរេ ចរិត្ថ បរ-

វិសយេ ។ អគោចរេ ភិក្ខវេ ចរតំ បរវិសយេ លច្ឆតិ

មារោ ឱតារំ លច្ឆតិ មារោ អារម្មណំ ។ កោ ច ភិក្ខវេ

ភិក្ខុនោ អគោចរោ បរវិសយោ ។ យទិទំ បញ្ច កា-

មគុណា ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា

កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។

សោតវិញ្ញេយ្យា សទ្ទា ។ ឃានវិញ្ញេយ្យា គន្ធា ។

ជិវ្ហាវិញ្ញេយ្យា រសា ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា

កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។

អយំ ភិក្ខវេ ភិក្ខុនោ អគោចរោ បរវិសយោ ។

អម្ពបាលិវគ្គ

[២៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយកុំត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែនរបស់បុគ្គលដទៃឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយត្រាច់ទៅក្នុងទីមិនមែនជាទីគោចរ ជាដែនរបស់បុគ្គលដទៃ មាររមែងបាននូវចន្លោះ មាររមែងបាននូវអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ចុះទីមិនមែនជាទីគោចររបស់ភិក្ខុ ជាដែននៃបុគ្គលដទៃ តើដូចម្តេច ។ គឺកាមគុណទាំង ៥ នេះឯង ។ កាមគុណទាំង ៥ តើដូចម្តេច ។ គឺរូបទាំងឡាយដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ១ ។ សំឡេងទាំង-ឡាយ ដែលគប្បីដឹងដោយត្រចៀក ១ ។ ក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ ១ ។ រសទាំងឡាយ ដែលគប្បីដឹងដោយអណ្តាត ១ ។ ផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរដល់តម្រេក ១ ។ ម្នាលភិក្ខុទាំងឡាយ នេះទីមិនមែនជាទីគោចររបស់ភិក្ខុ ជាដែនរបស់បុគ្គលដទៃ ។

[២៦] គោចរេ ភិក្ខវេ ចរថ សកេ បេត្តិកេ វិសយេ ។ គោចរេ ភិក្ខវេ ចរតំ សកេ បេត្តិកេ វិសយេ ន លច្ឆតិ មារោ ឱតារំ ន លច្ឆតិ មារោ អារម្មណំ ។ កោ ច ភិក្ខវេ ភិក្ខុនោ គោចរោ សកោ បេត្តិកោ វិសយោ ។ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទ-នាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-នស្សំ ។ អយំ ភិក្ខវេ ភិក្ខុនោ គោចរោ សកោ បេត្តិកោ វិសយោតិ ។

[២៦] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅក្នុងទីជាទីគោចរ ជាដែននៃបិតារបស់ខ្លួនចុះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយត្រាច់ទៅក្នុងទីជាទីគោចរ ជាដែននៃបិតារបស់ខ្លួន មារមិនបាននូវចន្លោះ មារមិនបាននូវអារម្មណ៍ឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះទីជាទីគោចររបស់ភិក្ខុ ជាដែននៃបិតារបស់ខ្លួន តើដូចម្តេច ។ គឺសតិប្បដ្ឋានទាំង ៤ នេះឯង ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ នេះទីជាទីគោចររបស់ភិក្ខុ ជាដែននៃបិតារបស់ខ្លួន ។

អម្ពបាលិវគ្គោ

[២៧] សេយ្យថាបិ ភិក្ខវេ ពាលោ អព្យត្តោ អកុ-
សលោ សូទោ រាជានំ វា រាជមហាមត្តំ វា នានច្ច-
យេហិ(១) សូបេហិ បច្ចុបដ្ឋិតោ អស្ស អម្ពិលគ្គេហិបិ
តិត្តកគ្គេហិបិ កដុកគ្គេហិបិ មធុរគ្គេហិបិ ខារិកេហិបិ
អខារិកេហិបិ លោណិកេហិបិ អលោណិកេហិបិ ។
សចេ ខោ សោ ភិក្ខវេ ពាលោ អព្យត្តោ អកុសលោ
សូទោ សកស្ស ភត្តុនិមិត្តំ ន ឧគ្គណ្ហាតិ ឥទំ វា
មេ អជ្ជ ភត្តុសូបេយ្យំ រុច្ចតិ ឥមស្ស វា អភិហរតិ
ឥមស្ស វា ពហុំ គណ្ហាតិ ឥមស្ស វា វណ្ណំ ភាសតិ
អម្ពិលគ្គំ វា មេ អជ្ជ ភត្តុសូបេយ្យំ រុច្ចតិ អម្ពិល-
គ្គស្ស វា អភិហរតិ អម្ពិលគ្គស្ស វា ពហុំ គណ្ហាតិ

១ ឱ. នានាច្ចយេហិ ។

អម្ពបាលិវគ្គ

[២៧] ម្នាលភិក្ខុទាំងឡាយ ដូចអ្នកចម្អិនភត្ត ជាអ្នកល្ងង់ មិនឈ្លាសវៃ មិនប៉ិនប្រសប់ ផ្គត់ផ្គង់នូវព្រះរាជា ឬមហាមាត្យរបស់ព្រះរាជា ដោយម្ហូបទាំងឡាយមានចំណែកប្លែក ៗ គឺមានឱជារសជូរខ្លះ មានឱជារសល្វីងខ្លះ មានឱជារសហឹរខ្លះ មានឱជារសផ្អែមខ្លះ មានឱជារសខារខ្លះ មានឱជារសមិនខារខ្លះ មានឱជារសប្រៃខ្លះ មានឱជា-រសមិនប្រៃខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ជនអ្នកចម្អិននូវភត្តនោះឯង ជាអ្នកល្ងង់ មិនឈ្លាសវៃ មិនប៉ិនប្រសប់ មិនរៀននូវវិធីចម្អិនភត្តរបស់ខ្លួនថា ថ្ងៃនេះ ភត្តនិងម្ហូបបែបនេះពេញចិត្តអញក្តី ព្រះរាជាឬមហាមាត្យរបស់ព្រះរាជាទ្រង់លាព្រះហស្តទទួលភត្តនិងម្ហូបបែបនេះក្តី ទ្រង់ទទួលហើយទទួលទៀត នូវភត្តនិងម្ហូបបែបនេះក្តី ទ្រង់ពោលសរសើរម្ហូបបែបនេះក្តី ថ្ងៃនេះ ភត្តនិងម្ហូបមានឱជារសជូរពេញចិត្តអញក្តី ព្រះរាជាឬមហាមាត្យរបស់ព្រះរាជាទ្រង់លាព្រះហស្តទទួលនូវភត្តនិងម្ហូបមានឱជារសជូរក្តី ទ្រង់ទទួលហើយទទួលទៀតនូវភត្តនិងម្ហូបមានឱជារសជូរក្តី

អម្ពិលគ្គស្ស វា វណ្ណំ ភាសតិ តិត្តកគ្គំ វា មេ អជ្ជ ។ កដុកគ្គំ វា មេ អជ្ជ ។ មធុរគ្គំ វា មេ អជ្ជ ។ ខារិកំ វា មេ អជ្ជ ។ អខារិកំ វា មេ អជ្ជ ។ លោណិកំ វា មេ អជ្ជ ។ អលោណិកំ វា មេ អជ្ជ ភត្តស្សូបេយ្យំ វុច្ចតិ អលោណិកស្ស វា អភិហរតិ អលោណិកស្ស វា ពហុំ គណ្ហាតិ អលោណិកស្ស វា វណ្ណំ ភាស-តីតិ ។ សខោ សោ ភិក្ខវេ ពាលោ អព្យត្តោ អកុ-សលោ សូទោ ន ចេវ លាភី ហោតិ អច្ឆាទនស្ស ន លាភី វេត្តនស្ស ន លាភី អភិហារានំ ។ តំ កិស្ស ហេតុ ។ តថា ហិ សោ ភិក្ខវេ ពាលោ អព្យត្តោ អកុសលោ សូទោ សកស្ស ភត្តនិមិត្តំ ន ឧគ្គណ្ហាតិ ។

ទ្រង់សរសើរភត្តនិងម្ហូបមានឱជារសជូរក្តី ថ្ងៃនេះ ឱជារសល្វីងពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសហឹរពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសផ្អែមពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសខារពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសមិនខារពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសប្រៃពេញចិត្តអញក្តី ។ ថ្ងៃនេះ ភត្តនិងម្ហូបមានឱជារសមិនប្រៃពេញចិត្តអញក្តី ព្រះរាជាឬមហាមាត្យរបស់ព្រះរាជាទ្រង់លាព្រះហស្តទទួលភត្តនិងម្ហូបមានឱជារសមិនប្រៃក្តី ទ្រង់ទទួលហើយទទួលទៀតនូវភត្តនិងម្ហូបមានឱជារសមិនប្រៃក្តី ទ្រង់ពោលសរសើរនូវភត្តនិងម្ហូបមានឱជារសមិនប្រៃក្តី ។ ម្នាលភិក្ខុទាំងឡាយ អ្នកចម្អិននូវភត្តនោះឯង ជាមនុស្សល្ងង់ មិនឈ្លាសវៃ មិនប៉ិនប្រសប់ រមែងមិនបាននូវគ្រឿងស្លៀកពាក់ មិនបាននូវថ្លៃឈ្នួល មិនបាននូវរង្វាន់ទាំងឡាយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាជនអ្នកចម្អិននូវភត្តនោះ ជាមនុស្សល្ងង់ មិនឈ្លាសវៃ មិនប៉ិនប្រសប់ មិនរៀននូវវិធីចម្អិនភត្តរបស់ខ្លួន យ៉ាងណាមិញ ។

អម្ពបាលិវគ្គោ

[២៨] ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ពាលោ អព្យត្តោ អកុសលោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស កាយេ កាយានុបស្សិនោ វិហរតោ ចិត្តំ ន សមាធិយតិ ឧបក្កិលេសា ន បហីយន្តិ សោ តំ និមិត្តំ ន ឧគ្គណ្ហាតិ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស ធម្មេសុ ធម្មានុបស្សិនោ វិហរតោ ចិត្តំ ន សមាធិយតិ ឧបក្កិលេសា ន បហីយន្តិ សោ តំ និមិត្តំ ន ឧគ្គណ្ហាតិ ។ ស ខោ សោ ភិក្ខវេ ពាលោ អព្យត្តោ អកុសលោ ភិក្ខុ ន ចេវ លាភី ហោតិ ទិដ្ឋេវ ធម្មេ សុខវិហារានំ ន លាភី សតិសម្បជញ្ញស្ស ។ តំ កិស្ស ហេតុ ។ តថា ហិ សោ ភិក្ខវេ ពាលោ អព្យត្តោ អកុសលោ ភិក្ខុ សកស្ស ចិត្តស្ស និមិត្តំ ន ឧគ្គណ្ហាតិ ។

អម្ពបាលិវគ្គ

[២៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកល្ងង់ មិនឈ្លាសវៃ មិនប៉ិនប្រសប់ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ កាលភិក្ខុនោះពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ចិត្តក៏មិនតាំងនៅមាំ ឧបក្កិលេសទាំងឡាយ ក៏ភិក្ខុនោះលះបង់មិនបាន ភិក្ខុនោះមិនរៀនឲ្យចេះនូវនិមិត្តនោះ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ កាលភិក្ខុនោះពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ចិត្តក៏មិនតាំងនៅមាំ ឧបក្កិលេសទាំងឡាយ ក៏ភិក្ខុនោះលះបង់មិនបាន ភិក្ខុនោះមិនរៀនឲ្យចេះនូវនិមិត្តនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង ជាមនុស្សល្ងង់ មិនឈ្លាសវៃ មិនប៉ិនប្រសប់ ជាអ្នកមិនបាននូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ននេះ និងមិនបាននូវសតិនិងសម្បជញ្ញៈឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាភិក្ខុនោះ ជាមនុស្សល្ងង់ មិនឈ្លាសវៃ មិនប៉ិនប្រសប់ មិនរៀនឲ្យចេះនូវនិមិត្តនៃចិត្តរបស់ខ្លួន ក៏យ៉ាងនោះដែរ ។

[២៩] សេយ្យថាបិ ភិក្ខវេ បណ្ឌិតោ ព្យត្តោ កុសលោ សូទោ រាជានំ វា រាជមហាមត្តំ វា នានច្ចយេហិ សូបេហិ បច្ចុបដ្ឋិតោ អស្ស អម្ពិលគ្គេហិបិ តិត្តកគ្គេហិបិ កដុកគ្គេហិបិ មធុរគ្គេហិបិ ខារិកេហិបិ អខារិកេហិបិ លោណិកេហិបិ អលោណិកេហិបិ ។ សខោ សោ ភិក្ខវេ បណ្ឌិតោ ព្យត្តោ កុសលោ សូទោ សកស្ស ភត្តុនិមិត្តំ ឧគ្គណ្ហាតិ ឥទំ វា មេ អជ្ជ ភត្តុសូបេយ្យំ រុច្ចតិ ឥមស្ស វា អភិហរតិ ឥមស្ស វា ពហុំ គណ្ហាតិ ឥមស្ស វា វណ្ណំ ភាសតិ អម្ពិលគ្គំ វា មេ អជ្ជ ភត្តុសូបេយ្យំ រុច្ចតិ អម្ពិលគ្គស្ស វា អភិហរតិ អម្ពិលគ្គស្ស វា ពហុំ គណ្ហាតិ អម្ពិលគ្គស្ស វា វណ្ណំ ភាសតិ តិត្តកគ្គំ វា មេ អជ្ជ ។ កដុកគ្គំ វា មេ អជ្ជ ។ មធុរគ្គំ វា មេ អជ្ជ ។

[២៩] ម្នាលភិក្ខុទាំងឡាយ ដូចជនអ្នកចម្អិនទូវភត្ត ជាអ្នកប្រាជ្ញ ឈ្លាសវៃ ប៉ិនប្រសប់ ផ្គត់ផ្គង់នូវព្រះរាជាឬមហាមាត្យរបស់ព្រះរាជា ដោយម្ហូបទាំងឡាយប្លែក ៗ មានឱជារសជូរខ្លះ មានឱជារសល្វីងខ្លះ មានឱជារសហឹរខ្លះ មានឱជារសផ្អែមខ្លះ មានឱជារសខារខ្លះ មានឱជារសមិនខារខ្លះ មានឱជារសប្រៃខ្លះ មានឱជារសសាបខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកចម្អិនទូវភត្តនោះឯង ជាអ្នកប្រាជ្ញ ឈ្លាសវៃ ប៉ិនប្រសប់ រមែងរៀនទូវវិធីចម្អិនភត្តរបស់ខ្លួនថា ថ្ងៃនេះ ភត្តនិងម្ហូបបែបនេះពេញចិត្តអញក្តី ព្រះរាជាឬមហាមាត្យរបស់ព្រះរាជា ទ្រង់លាព្រះហស្តទទួលនូវភត្តនិងម្ហូបនេះក្តី ទ្រង់ទទួលហើយទទួលទៀតនូវភត្តនិងម្ហូបនេះក្តី ទ្រង់ពោលសរសើរភត្តនិងម្ហូបនេះក្តី ថ្ងៃនេះ ភត្តនិងម្ហូបមានឱជារសជូរពេញចិត្តអញក្តី ព្រះរាជាឬមហាមាត្យរបស់ព្រះរាជា ទ្រង់លាព្រះហស្តទទួលភត្តនិងម្ហូបមានឱជារសជូរក្តី ទ្រង់ទទួលហើយទទួលទៀតនូវភត្តនិងម្ហូបមានឱជារសជូរក្តី ទ្រង់ពោលសរសើរភត្តនិងម្ហូបមានឱជា-រសជូរក្តី ថ្ងៃនេះ ភត្តនិងម្ហូបមានឱជារសល្វីងពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសហឹរពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសផ្អែមពេញចិត្តអញក្តី ។

២៧

## អម្ពបាលិវគ្គោ

ខារិកំ វា មេ អជ្ជ ។ អខារិកំ វា មេ អជ្ជ ។ លោណិកំ វា មេ អជ្ជ ។ អលោណិកំ វា មេ អជ្ជ ភត្តស្សូបេយ្យំ វុច្ចតិ អលោណិកស្ស វា អភិហរតិ អលោណិកស្ស វា ពហុំ គណ្ហាតិ អលោណិកស្ស វា វណ្ណំ ភាសតីតិ ។ សចេ សោ ភិក្ខវេ បណ្ឌិតោ ព្យត្តោ កុសលោ សូទោ លាភី ចេវ ហោតិ អច្ឆាទនស្ស លាភី វេតនស្ស លាភី អភិហារានំ ។ តំ កិស្ស ហេតុ ។ តថា ហិ សោ ភិក្ខវេ បណ្ឌិតោ ព្យត្តោ កុសលោ សូទោ សកស្ស ភត្តនិមិត្តំ ឧគ្គណ្ហាតិ ។

## ២៧

អម្ពបាលិវគ្គ

ថ្ងៃនេះ ឱជារសខារពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសមិនខារពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជារសប្រៃពេញចិត្តអញក្តី ។ ថ្ងៃនេះ ឱជា-រសសាបពេញចិត្តអញក្តី ព្រះរាជាឬមហាមាត្យរបស់ព្រះរាជា ទ្រង់លាព្រះហស្តទទួលនូវភត្តនិងម្ហូបមានឱជារសសាបក្តី ទ្រង់ទទួលហើយទទួលទៀតនូវភត្តនិងម្ហូបមានឱជារសសាបក្តី ទ្រង់ពោលសរសើរភត្តនិងម្ហូបមានឱជារសសាបក្តី ។ ម្នាលភិក្ខុទាំងឡាយ អ្នកចម្អិននូវភត្តនោះឯង ជាអ្នកប្រាជ្ញ ឈ្លាសវៃ ប៉ិនប្រសប់ តែងបាននូវគ្រឿងស្លៀកពាក់ផង បាននូវថ្លៃឈ្នួលផង បាននូវរង្វាន់ទាំងឡាយផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាអ្នកចម្អិនភត្តនោះជាអ្នកប្រាជ្ញ ឈ្លាសវៃ ប៉ិនប្រសប់ រៀននូវវិធីចម្អិនភត្តរបស់ខ្លួន យ៉ាងណាមិញ ។

[៣០] ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បណ្ឌិតោ ព្យត្តោ កុសលោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស កាយេ កាយានុបស្សិនោ វិហរតោ ចិត្តំ សមាធិយតិ ឧបក្កិលេសា បហីយន្តិ សោ តំ និមិត្តំឧគ្គណ្ហាតិ ។ វេទនាសុ វេទនានុបស្សី វិហរតិ ។ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស ធម្មេសុ ធម្មានុបស្សិនោ វិហរតោ ចិត្តំ សមាធិយតិ ឧបក្កិលេសា បហីយន្តិ សោ តំ និមិត្តំ ឧគ្គណ្ហាតិ ។ ស ខោ សោ ភិក្ខវេ បណ្ឌិតោ ព្យត្តោ កុសលោ ភិក្ខុ លាភី ចេវ ហោតិ ទិដ្ឋេវ ធម្មេ សុខវិហារានំ លាភី សតិសម្បជញ្ញស្ស ។

[៣០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកប្រាជ្ញ ឈ្លាសវៃ ប៉ិនប្រសប់ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ កាលភិក្ខុនោះពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ចិត្តក៏តាំងនៅមាំ ឧបក្កិលេសទាំងឡាយ ក៏ភិក្ខុនោះលះបង់ចេញបាន ភិក្ខុនោះឈ្មោះថារៀននូវនិមិត្តនោះ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី ។ ជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី ។ ជាអ្នកពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ កាលភិក្ខុនោះពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ចិត្តក៏តាំងនៅមាំ ឧបក្កិលេសទាំងឡាយ ក៏ភិក្ខុនោះលះបង់ចេញបាន ភិក្ខុនោះឈ្មោះថារៀននូវនិមិត្តនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង ជាអ្នកប្រាជ្ញ ឈ្លាសវៃ ប៉ិនប្រសប់ ជាអ្នកបាននូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ននេះឯង នឹងបាននូវសតិនិងសម្បជញ្ញៈ ។

តំ កិស្ស ហេតុ ។ តថា ហិ សោ ភិក្ខវេ បណ្ឌិតោ ព្យត្តោ កុសលោ ភិក្ខុ សកស្ស ចិត្តស្ស និមិត្តំ ឧគ្គណ្ហាតីតិ ។

[៣១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ វេលុវក្កាមកេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ឯថ តុម្ហេ ភិក្ខវេ សមន្តា វេសា-លិយា យថាមិត្តំ យថាសន្ទិដ្ឋំ យថាសម្ភត្តំ វស្សំ ឧបេថ(១) ឥធេវាហំ វេលុវក្កាមកេ វស្សំឧបគច្ឆាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា សមន្តា វេសាលិយា យថាមិត្តំ យថាសន្ទិដ្ឋំ យថាសម្ភត្តំ វស្សំ ឧបគច្ឆុំ(២) ។

---

១ ឱ. គច្ឆថ ។ ២ ឱ. ឧបគញ្ឆុំ ។ ម. ឧបគច្ឆន្តិ ។

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាភិក្ខុនោះ ជាអ្នកប្រាជ្ញ ឈ្លាសវៃ ប៉ិនប្រសប់ តែងរៀននូវនិមិត្តនៃចិត្តរបស់ខ្លួន ក៏យ៉ាងនោះដែរ ។

[៣១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវេលុវគ្រាម ទៀបក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយចូរមកអាយ ចូរទៅនៅចាំវស្សាដោយជុំវិញក្រុងវេសាលី តាមមិត្ត តាមសន្ទិដ្ឋមិត្ត (មិត្តធ្លាប់បានជួបគ្នា) តាមសម្ភត្តមិត្ត (មិត្តស្និទ្ធស្នាល) តថាគតក៏ចូលទៅចាំវស្សានៅក្នុងវេលុវគ្រាមនេះដែរ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅចាំវស្សាដោយជុំវិញក្រុងវេសាលី តាមមិត្ត តាមសន្ទិដ្ឋមិត្ត តាមសម្ភត្តមិត្ត ។

[៣៦] ភគវា បន តត្ថេវ វេឡុវគាមកេ វស្សំ ឧបគច្ឆិ ។ អថខោ ភគវតោ វស្សូបគតស្ស ខរោ អាពាធោ ឧប្បជ្ជតិ ពាឡ្ហា វេទនា វត្តន្តិ មរណាន្តិកា ។ តត្រ សុទំ ភគវា សតោ សម្បជានោ អធិវាសេតិ អវិហញ្ញមានោ ។ អថខោ ភគវតោ ឯតទហោសិ ន ខោ បន មេត្តប្បដិរូបំ យោហមនាមន្តេត្វា ឧបដ្ឋាកេ អនបលោកេត្វា ភិក្ខុសង្ឃំ បរិនិព្វាយេយ្យំ យន្នូនាហំ ឥមំ អាពាធំ វីរិយេន បដិប្បណាមេត្វា ជីវិតសង្ខារំ អធិដ្ឋាយ វិហរេយ្យន្តិ ។ អថខោ ភគវា តំ អាពាធំ វីរិយេន បដិប្បណាមេត្វា ជីវិតសង្ខារំ អធិដ្ឋាយ វិហាសិ ។ អថខោ ភគវា គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា[១] វិហារប្បច្ឆាឆាយាយំ បញ្ញត្តេ អាសនេ និសីទិ ។

១ ឱ. ម. វិហារា និក្ខមិត្វា ។

[៣២] ព្រះដ៏មានព្រះភាគ ស្តេចទៅចាំវស្សា ក្នុងវេលុវគ្រាមនោះឯង ។ គ្រានោះឯង កាលព្រះដ៏មានព្រះភាគស្តេចចូលទៅចាំវស្សាហើយ ព្រះអាពាធដ៏ក្លៀវក្លាកើតឡើង វេទនាក៏ខ្លាំងស្ទើរតែនឹងមរណៈក៏ប្រព្រឹត្តទៅ ។ ក្នុងកាលនោះ ព្រះដ៏មានព្រះភាគមានព្រះសតិសម្បជញ្ញៈ ទ្រង់អត់សង្កត់ មិនឲ្យវេទនាបៀតបៀនព្រះអង្គបាន ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់មានព្រះតម្រិះដូច្នេះថា តថាគតមិនប្រាប់ពួកឧបដ្ឋាក មិនលាភិក្ខុសង្ឃហើយបរិនិព្វាន ដោយមេត្តាចិត្តឯណា មេត្តាចិត្តនោះមិនសមគួរឡើយ បើដូច្នោះមានតែតថាគតបណ្តេញអាពាធនេះចេញដោយវីរិយៈ ហើយអធិដ្ឋានជីវិតសង្ខារទុក ។ ទើបព្រះដ៏មានព្រះភាគទ្រង់បណ្តេញព្រះអាពាធនោះចេញដោយវីរិយៈ ហើយទ្រង់អធិដ្ឋានជីវិតសង្ខារទុក ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់បានសះស្បើយចាកព្រះអាពាធ លុះទ្រង់សះស្បើយចាកព្រះអាពាធមិនយូរប៉ុន្មាន ក៏ស្តេចមកគង់លើអាសនៈដែលគេក្រាលថ្វាយ ក្នុងម្លប់ខាងក្រោយវិហារ ។

អម្ពបាលិវគ្គោ

[៣៣] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ទិដ្ឋំ[១] ភន្តេ ភគវតោ ខមនីយំ ទិដ្ឋំ ភន្តេ ភគវតោ យាបនីយំ អបិច មេ ភន្តេ មធុរកជាតោ វិយ កាយោ ទិសាបិ មេ ន បក្ខាយន្តិ ធម្មាបិ មំ នប្បដិភន្តិ ភគវតោ គេលញ្ញេន អបិច មេ ភន្តេ អហោសិ កាចិទេវ អស្សាសមត្តា ន តាវ ភគវា បរិនិព្វាយិស្សតិ ន តាវ ភគវា ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរតីតិ ។ កឹ បនទានិ អានន្ទ ភិក្ខុសង្ឃោ មយិ បច្ចាសឹសតិ ។ ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ ករិត្វា ។ នត្ថានន្ទ តថាគតស្ស ធម្មេសុ អាចរិយមុដ្ឋិ ។ យន្នូនានន្ទ[២]

---

១ ឱ. ទិដ្ឋា ។ ម. ទិដ្ឋោ មេ ភន្តេ ។ ២ ឱ. យស្ស នូនានន្ទ ។

អម្ពបាលិវគ្គ

[៣៣] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីអត់ធន់របស់ព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានឃើញហើយ បពិត្រព្រះអង្គដ៏ចម្រើន ការញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅរបស់ព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានឃើញហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត កាយរបស់ខ្ញុំព្រះអង្គហាក់ដូចជាមានទម្ងន់ពន់ពេក ទិសទាំងឡាយក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ ធម៌ទាំងឡាយក៏មិនភ្លឺច្បាស់ដល់ខ្ញុំព្រះអង្គ ព្រោះព្រះដ៏មានព្រះភាគទ្រង់ព្រះអាពាធ បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្ដែថា ខ្ញុំព្រះអង្គនៅមានសេចក្ដីសង្ឃឹមបន្តិចថា ព្រះដ៏មានព្រះភាគនឹងមិនទាន់បរិនិព្វាននៅឡើយទេ ព្រោះព្រះដ៏មានព្រះភាគមិនទាន់ប្រារព្ធភិក្ខុសង្ឃ ទ្រង់ព្រះរាជទានព្រះឱវាទណាមួយនៅឡើយ ។ ម្នាលអានន្ទ ក្នុងកាលឥឡូវនេះ ភិក្ខុសង្ឃនឹងសង្ឃឹមតថាគតអ្វីទៀត ។ ម្នាលអានន្ទ ធម៌ដែលតថាគតបានសម្ដែងហើយ ធ្វើមិនឲ្យមានក្នុង មិនឲ្យមានក្រៅហើយ ។ ម្នាលអានន្ទ ក្នុងធម៌ទាំងឡាយរបស់តថាគតមិននៅក្នុងកណ្ដាប់ដៃនៃអាចារ្យឡើយ ។ ម្នាលអានន្ទ គួរតែ

ឯវមស្ស អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ វា មមុទ្ទេសិកោ ភិក្ខុសង្ឃោតិ វា ។ សោ នូនានន្ទ ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរេយ្យ ។ តថាគតស្ស ខោ អានន្ទ ន ឯវំ ហោតិ អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ វា មមុទ្ទេសិកោ ភិក្ខុសង្ឃោតិ វា ។ ស កឹ អានន្ទ តថាគតោ ភិក្ខុសង្ឃំ អារព្ភ កិញ្ចិទេវ ឧទាហរិស្សតិ ។ ឯតរហិ ខោ បនាហំ អានន្ទ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោ អនុប្បត្តោ អសីតិកោ មេ វយោ[១] វត្តតិ ។ សេយ្យថាបិ អានន្ទ ជរសកដំ វេឡុមិស្សកេន[២] យាបេតិ ឯវមេវ ខោ អានន្ទ វេឡុមិស្សកោ មញ្ញេ តថាគតស្ស កាយោ យាបេតិ ។

---

១ ឱ. ម. វស្សោ ។ ២ វេធមិស្សកេន ។

តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា តថាគតនឹងរក្សាភិក្ខុសង្ឃដូច្នេះក្តី ថាភិក្ខុសង្ឃជាអ្នកពោលអាងចំពោះតថាគតដូច្នេះក្តី ។ ម្នាលអានន្ទ ដោយពិតនោះ តថាគតគួរប្រារព្ធភិក្ខុសង្ឃហើយសម្តែងឱវាទណាមួយទុក ។ ម្នាលអានន្ទ តថាគតមិនដែលមានសេចក្តីត្រិះរិះយ៉ាងនេះថា តថាគតនឹងរក្សាភិក្ខុសង្ឃដូច្នេះក្តី ថាភិក្ខុសង្ឃជាអ្នកពោលអាងចំពោះតថាគតដូច្នេះក្តី ។ ម្នាលអានន្ទ តថាគតនឹងប្រារព្ធភិក្ខុសង្ឃហើយសម្តែងឱវាទណាមួយធ្វើអ្វី ។ ម្នាលអានន្ទ ក្នុងកាលឥឡូវនេះ តថាគតគ្រាំគ្រា ចម្រើនវ័យ ចាស់ ដល់ហើយនូវសេចក្តីថមថយដោយលំដាប់ មានអាយុ ៨០ ឆ្នាំហើយ វ័យរបស់តថាគតក៏នៅតែប្រព្រឹត្តទៅបាន ។ ម្នាលអានន្ទ ដូចរទេះចាស់ ដែលបរទៅបានដោយរណបឫស្សី យ៉ាងណាមិញ ម្នាលអានន្ទ កាយរបស់តថាគតនៅប្រព្រឹត្តទៅបាន ដូចជារណបឫស្សី ដូច្នោះដែរ ។

៣៣

## អម្ពបាលិវគ្គោ

[៣៤] យស្មឹ អានន្ទ សមយេ តថាគតោ សព្វ-
និមិត្តានំ អមនសិការា ឯកច្ចានំ វេទនានំ និរោធា
អនិមិត្តំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ ផាសុតរំ
អានន្ទ តស្មឹ សមយេ តថាគតស្ស ហោតិ ។ តស្មា-
តិហានន្ទ អត្តទីបា វិហរថ អត្តសរណា អនញ្ញស-
រណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។

[៣៥] កថញ្ច អានន្ទ ភិក្ខុ អត្តទីបោ វិហរតិ
អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ
អនញ្ញសរណោ ។ ឥធានន្ទ ភិក្ខុ កាយេ កាយានុ-
បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ
លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ
ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ

អម្ពបាលិវគ្គ

[៣៤] ម្នាលអានន្ទ ក្នុងសម័យណា តថាគតបានចូលកាន់ចេតោសមាធិមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ព្រោះរំលត់នូវពួកវេទនាជំពូកខ្លះ ម្នាលអានន្ទ ក្នុងសម័យនោះ សេចក្តីសប្បាយដ៏ក្រៃលែង រមែងមានដល់តថាគត ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីរឭក កុំមានវត្ថុដទៃជាទីរឭកឡើយ ចូរមានធម៌ជាទីពឹង មានធម៌ជាទីរឭក កុំមានវត្ថុដទៃជាទីរឭកឡើយ ។

[៣៥] ម្នាលអានន្ទ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីរឭក មិនមានវត្ថុដទៃជាទីរឭក មានធម៌ជាទីពឹង មានធម៌ជាទីរឭក មិនមានវត្ថុដទៃជាទីរឭក តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន

សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ អានន្ទ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។

[៣៦] យេ ហិ កេចិ អានន្ទ ឯតរហិ វា មមច្ចយេ[១] វា អត្តទីបា វិហរិស្សន្តិ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។ តមតគ្គេមេ តេ អានន្ទ ភិក្ខូ ភវិស្សន្តិ យេ កេចិ សិក្ខាកាមាតិ ។

[៣៧] សាវត្ថិយំ ។ ភគវា ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន អញ្ញតរោ ភិក្ខុនូបស្សយោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សម្ពហុលា ភិក្ខុនិយោ យេនាយស្មា អានន្ទោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តា ភិក្ខុនិយោ អាយស្មន្តំ អានន្ទំ ឯតទវោចុំ

១ ម. មមច្ចយេន វា ។

មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលអានន្ទ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីរឭក មិនមានវត្ថុដទៃជាទីរឭក មានធម៌ជាទីពឹង មានធម៌ជាទីរឭក មិនមានវត្ថុដទៃជាទីរឭក យ៉ាងនេះឯង ។

[៣៦] ម្នាលអានន្ទ ពួកជនឯណានីមួយ មានខ្លួនជាទីពឹង មានខ្លួនជាទីរឭក មិនមានវត្ថុដទៃជាទីរឭក មានធម៌ជាទីពឹង មានធម៌ជាទីរឭក មិនមានវត្ថុដទៃជាទីរឭក ក្នុងកាលឥឡូវនេះឬ ឬថាក្នុងកាលជាអំណឹះអំពីតថាគតទៅហើយ ។ ម្នាលអានន្ទ ពួកភិក្ខុឯណានីមួយមានសេចក្ដីប្រាថ្នានូវការសិក្សា ភិក្ខុទាំងនោះនឹងប្រាកដមានក្នុងចំណែកដ៏ប្រសើរក្រៃលែង ។

[៣៧] ក្នុងក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ។ គ្រានោះឯងព្រះអានន្ទដ៏មានអាយុស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងវេលាព្រឹកព្រហាម ចូលទៅកាន់លំនៅភិក្ខុនីមួយរូប លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះឯង ពួកភិក្ខុនីច្រើនរូបចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនីទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា

៩៨ ភន្តេ អានន្ទ សម្ពហុលា ភិក្ខុនិយោ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា វិហរន្តិយោ ឧឡារំ បុព្វេនាបរំ វិសេសំ សញ្ជានន្តីតិ ។ ឯវមេតំ ភគិនិយោ ឯវមេតំ ភគិនិយោ យោ ហិ កោចិ ភគិនិយោ ភិក្ខុ វា ភិក្ខុនី វា ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តោ វិហរតិ តស្សេតំ បាដិកង្ខំ ឧឡារំ បុព្វេនាបរំ វិសេសំ សញ្ជានិស្សតីតិ ។ អថខោ អាយស្មា អានន្ទោ តា ភិក្ខុនិយោ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

[៣៨] អថខោ អាយស្មា អានន្ទោ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវា-ទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ

បពិត្រព្រះអានន្ទដ៏ចម្រើន ពួកភិក្ខុនីច្រើនរូបក្នុងទីនេះ មានចិត្តតាំងខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤ តែងដឹងច្បាស់នូវគុណវិសេសដ៏ក្រៃលែងដទៃទៀត ជាងគុណវិសេសខាងដើម ។ ម្នាលនាងទាំងឡាយ យ៉ាងនុ៎ះហើយ ម្នាលនាងទាំងឡាយ យ៉ាងនុ៎ះហើយ ម្នាលនាងទាំងឡាយ ព្រោះថាភិក្ខុឬភិក្ខុនីណាមួយមានចិត្តតាំងខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤ នុ៎ះជាគ្រឿងសង្ឃឹមរបស់ភិក្ខុឬភិក្ខុនីនោះ ភិក្ខុឬភិក្ខុនីនោះនឹងដឹងច្បាស់នូវគុណវិសេសដ៏ក្រៃលែងដទៃទៀត ជាងគុណវិសេសខាងដើម ។ លំដាប់នោះឯងព្រះអានន្ទដ៏មានអាយុ ក៏ធ្វើពួកភិក្ខុនីទាំងនោះ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយក្រោកចាកអាសនៈចៀសចេញទៅ ។

[៣៨] គ្រានោះឯង ព្រះអានន្ទដ៏មានអាយុត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់មកពីបិណ្ឌបាត ក្នុងពេលខាងក្រោយនៃភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏-មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គ

បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន អញ្ញតរោ ភិក្ខុនុបស្សយោ តេនុបសង្កមី ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ភន្តេ សម្ពហុលា ភិក្ខុនិយោ យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ ភន្តេ តា ភិក្ខុនិយោ មំ ឯតទវោចុំ ឥធ ភន្តេ អានន្ទ សម្ពហុលា ភិក្ខុនិយោ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា វិហរន្តិយោ ឧឡារំ បុព្វេនាបរំ វិសេ-សំ សញ្ជានន្តីតិ ។ ឯវំ វុត្តាហំ ភន្តេ តា ភិក្ខុ-និយោ ឯតទវោចំ ឯវមេតំភគិនិយោ ឯវមេតំ ភគិ-និយោ យោ ហិ កោចិ ភគិនិយោ ភិក្ខុ វា ភិក្ខុនី វា ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តោ វិហរតិ តស្សេតំ បាដិកង្ខំ ឧឡារំ បុព្វេនាបរំ វិសេសំ សញ្ជា-និស្សតីតិ ។

ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់លំនៅភិក្ខុនីមួយរូប លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះឯង ពួកភិក្ខុនីច្រើនរូបចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយអង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះពួកភិក្ខុនីទាំងនោះអង្គុយក្នុងទីសមគួរហើយ បានពោលនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ក្នុងទីនេះ មានពួកភិក្ខុនីច្រើនរូប មានចិត្តតាំងខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤ តែងដឹងច្បាស់នូវគុណវិសេសដ៏ក្រៃលែងដទៃទៀតជាងគុណវិសេសខាងដើម ។ បពិត្រព្រះអង្គដ៏ចម្រើន កាលភិក្ខុនីទាំងនោះ ពោលយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយទៅនឹងភិក្ខុនីទាំងនោះដូច្នេះថា ម្នាលនាងទាំងឡាយ យ៉ាងនុ៎ះឯង ម្នាលនាងទាំងឡាយយ៉ាងនុ៎ះឯង ម្នាលនាងទាំងឡាយ ព្រោះថាភិក្ខុឬភិក្ខុនីណាមួយ មានចិត្តតាំងខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤ នុ៎ះជាគ្រឿងសង្ឃឹមរបស់ភិក្ខុឬភិក្ខុនីនោះ ភិក្ខុឬភិក្ខុនីនោះ នឹងដឹងច្បាស់នូវគុណវិសេសក្រៃលែងដទៃទៀតជាងគុណវិសេសខាងដើម ។

៣៧

អម្ពបាលិវគ្គោ

[៣៩] ឯវមេតំ អានន្ទ ឯវមេតំ អានន្ទ យោ ហិ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តោ វិហរតិ តស្សេតំ បាដិកង្ខំ ឧឡារំ បុព្វេនាបរំ វិសេសំ សញ្ជានិស្សតីតិ ។ កតមេសុ ចតូសុ ។

[៤០] ឥធានន្ទ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស កាយេ កាយានុបស្សិនោ វិហរតោ កាយារម្មណោ វា ឧប្បជ្ជតិ កាយស្មឹ បរិឡាហោ ចេតសោ វា លីនត្តំ ពហិទ្ធា វា ចិត្តំ វិក្ខិបតិ ។ តេន អានន្ទ ភិក្ខុនា កិស្មិញ្ចិទេវ បសាទនីយេ និមិត្តេ ចិត្តំ បណិទហិតព្វំ ។ តស្ស កិស្មិញ្ចិទេវ បសាទនីយេ និមិត្តេ ចិត្តំ បណិទហតោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស

អម្ពបាលិវគ្គ

[៣៩] ម្នាលអានន្ទ យ៉ាងនុ៎ះឯង ម្នាលអានន្ទ យ៉ាងនុ៎ះឯង ម្នាលអានន្ទ ព្រោះថាភិក្ខុឬភិក្ខុនីណាមួយ មានចិត្តតាំងខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤ នុ៎ះជាគ្រឿងសង្ឃឹមរបស់ភិក្ខុឬភិក្ខុនីនោះ ភិក្ខុឬភិក្ខុនីនោះនឹងដឹងច្បាស់នូវគុណវិសេសដ៏ក្រៃលែងដទៃទៀត ជាងគុណវិសេសខាងដើម ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។

[៤០] ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានប្រក្រតីពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ កាលភិក្ខុនោះមានប្រក្រតីពិចារណាឃើញនូវកាយក្នុងកាយ សេចក្តីក្តៅក្រហាយដោយកិលេស មានកាយជាអារម្មណ៍ តែងកើតឡើងក្នុងកាយក្តី សេចក្តីរួញរានៃចិត្តក្តី ចិត្តតែងរសាត់អណ្តែតទៅកាន់អារម្មណ៍ខាងក្រៅក្តី ។ ម្នាលអានន្ទ ភិក្ខុនោះត្រូវតាំងចិត្តទុកក្នុងនិមិត្តគួរជាទីជ្រះថ្លាណាមួយចុះ ។ កាលភិក្ខុនោះតាំងចិត្តទុកក្នុងនិមិត្តគួរជាទីជ្រះថ្លាណាមួយបានហើយ បាមោជ្ជៈ (សេចក្តីរីករាយ) រមែងកើតឡើង កាលភិក្ខុមានបាមោជ្ជៈហើយ បីតិក៏កើតឡើង កាលមានចិត្តប្រកបដោយបីតិហើយ

កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យស្ស ខ្វាហំ អត្ថាយ ចិត្តំ បណិទហឹ សោ មេ អត្ថោ អភិនិប្ផន្នោ ហន្ទទានិ បដិសំហរាមីតិ ។ សោ បដិ-សំហរតិ ចេវ ន ច វិតក្កេតិ ន ច វិចារេតិ អវិ-តក្កោម្ហិ អវិចារោ អជ្ឈត្តំ សតិមា សុខមស្មីតិ បជា-នាតិ ។

[៤១] បុន ចបរំ អានន្ទ ភិក្ខុ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្ប-ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

កាយក៏ស្ងប់ ភិក្ខុដែលមានកាយស្ងប់ តែងសោយនូវសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលមានសេចក្តីសុខ រមែងតាំងនៅខ្ជាប់ខ្ជួន ។ ភិក្ខុនោះតែងពិចារណាឃើញច្បាស់ដូច្នេះថា អាត្មាអញបានតាំងចិត្តដើម្បីប្រយោជន៍ឯណា ប្រយោជន៍របស់អាត្មាអញនោះ ក៏បានសម្រេចហើយ ណ្ហើយចុះ ក្នុងកាលឥឡូវនេះ អាត្មាអញប្រមូលមកនូវចិត្ត (អំពីទីដែលគួរជ្រះថ្លា) ។ ភិក្ខុនោះរមែងប្រមូលមកនូវចិត្តបានផង មិនត្រិះរិះផង មិនពិ-ចារណាផង ទើបដឹងច្បាស់ថា អាត្មាអញមិនមានវិតក្កៈ មិនមានវិចារៈ មានតែស្មារតី និងសេចក្តីសុខប្រព្រឹត្តទៅក្នុងខាងក្នុង (អារម្មណ៍ជាទីគោចរ) ។

[៤១] ម្នាលអានន្ទ មួយទៀត ភិក្ខុមានប្រក្រតីពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ។ នូវចិត្តក្នុងចិត្ត ។ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។

៣៩

## អម្ពបាលិវគ្គោ

តស្ស ធម្មេសុ ធម្មានុបស្សិនោ វិហរតោ ធម្មារម្មណោ វា ឧប្បជ្ជតិ កាយស្មឹ បរិឡាហោ ចេតសោ វា លីនត្តំ ពហិទ្ធា វា ចិត្តំ វិក្ខិបតិ ។ តេន អានន្ទ ភិក្ខុនា កិស្មិញ្ចិទេវ បសាទនីយេ និមិត្តេ ចិត្តំ បណិទហិតព្វំ ។ តស្ស កិស្មិញ្ចិទេវ បសាទនីយេ និមិត្តេ ចិត្តំ បណិទហតោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ យស្ស ខ្វាហំ អត្ថាយ ចិត្តំ បណិទហឹ សោ មេ អត្ថោ អភិនិប្ផន្នោ ហន្ទទានិ បដិសំហរាមីតិ ។ សោ បដិសំហរតិ ចេវ ន ច វិតក្កេតិ ន ច វិចារេតិ អវិតក្កោម្ហិ អវិចារោ អជ្ឈត្តំ សតិមា សុខមស្មីតិ បជានាតិ ។ ឯវំ ខោ អានន្ទ បណិធាយ ភាវនា ហោតិ ។

អម្ពបាលិវគ្គ

កាលភិក្ខុនោះមានប្រក្រតីពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ សេចក្តីក្តៅ ក្រហាយដោយកិលេស មានធម៌ជាអារម្មណ៍ រមែងកើតឡើង ក្នុងកាយក្តី សេចក្តីរួញរានៃចិត្តក្តី ចិត្តរសាត់អណ្តែតទៅកាន់អារម្មណ៍ ខាងក្រៅក្តី ។ ម្នាលអានន្ទ ភិក្ខុនោះត្រូវតាំងចិត្តទុកក្នុងនិមិត្តដែលគួរ ជាទីជ្រះថ្លាណាមួយចុះ ។ កាលបើភិក្ខុនោះតាំងចិត្តទុកក្នុងនិមិត្តគួរជា ទីជ្រះថ្លាណាមួយបានហើយ បាមោជ្ជៈក៏កើតឡើង កាលភិក្ខុមាន បាមោជ្ជៈហើយ បីតិក៏កើតឡើង កាលមានចិត្តប្រកបដោយបីតិ កាយ ក៏ស្ងប់ ភិក្ខុដែលមានកាយស្ងប់ រមែងសោយនូវសេចក្តីសុខ ចិត្តរបស់ ភិក្ខុដែលមានសេចក្តីសុខ រមែងតាំងនៅខ្ជាប់ខ្ជួន ។ ភិក្ខុនោះរមែង ពិចារណាឃើញច្បាស់ដូច្នេះថា អាត្មាអញបានតាំងចិត្តដើម្បីប្រយោជន៍ ឯណា ប្រយោជន៍របស់អាត្មាអញនោះ បានសម្រេចហើយ ណ្ហើយចុះ ឥឡូវនេះ អាត្មាអញប្រមូលមកនូវចិត្ត ។ ភិក្ខុនោះទើបប្រមូលមកនូវ ចិត្តផង មិនត្រិះរិះផង មិនពិចារណាផង ទើបដឹងច្បាស់ថា អាត្មាអញ មិនមានវិតក្កៈ មិនមានវិចារៈ មានតែស្មារតី និងសេចក្តីសុខប្រព្រឹត្តទៅ ក្នុងខាងក្នុង (អារម្មណ៍ជាទីគោចរ) ។ ម្នាលអានន្ទ ការតាំងចិត្តហើយ ភាវនា យ៉ាងនេះឯង ។

[៤២] កថញ្ច អានន្ទ អប្បណិធាយ ភាវនា ហោតិ ។ ពហិទ្ធា អានន្ទ ភិក្ខុ ចិត្តំ អប្បណិធាយ អប្បណិហិតំ មេ ពហិទ្ធា ចិត្តន្តិ បជានាតិ អថ បច្ឆា បុរេ អសង្ខិត្តំ វិមុត្តំ អប្បណិហិតន្តិ បជានាតិ អថ ច បន កាយេ កាយានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា សុខមស្មីតិ បជានាតិ ។

[៤៣] ពហិទ្ធា អានន្ទ ភិក្ខុ ចិត្តំ អប្បណិធាយ អប្បណិហិតំ មេ ពហិទ្ធា ចិត្តន្តិ បជានាតិ អថ បច្ឆា បុរេ អសង្ខិត្តំ វិមុត្តំ អប្បណិហិតន្តិ បជានាតិ អថ ច បន វេទនាសុ វេទនានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា សុខមស្មីតិ បជានាតិ ។

[៤២] ម្នាលអានន្ទ ចុះការមិនតាំងចិត្តហើយភាវនា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុមិនបានតាំងចិត្តក្នុងអារម្មណ៍ខាងក្រៅ តែងដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានតាំងទុកក្នុងអារម្មណ៍ខាងក្រៅ មួយទៀត ដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានរាយមាយ ផុតស្រឡះហើយ មិនបានតាំងទុក (ក្នុងអារម្មណ៍ខាងក្រៅ) ទាំងក្រោយ ទាំងមុន មួយវិញទៀត ដឹងច្បាស់ថា អាត្មាអញពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី មានសេចក្តីសុខ ។

[៤៣] ម្នាលអានន្ទ ភិក្ខុមិនបានតាំងចិត្ត ក្នុងអារម្មណ៍ខាងក្រៅហើយ ក៏ដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានតាំងទុក្ខក្នុងអារម្មណ៍ខាងក្រៅ ទាំងដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានរាយមាយ ផុតស្រឡះហើយ មិនបានតាំងទុក (ក្នុងអារម្មណ៍ខាងក្រៅ) ទាំងក្រោយ ទាំងមុន មួយទៀត តែងដឹងច្បាស់ថា អាត្មាអញពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី មានសេចក្តីសុខ ។

៤១

## អម្ពបាលិវគ្គោ

[៤៤] ពហិទ្ធា អានន្ទ ភិក្ខុ ចិត្តំ អប្បណិធាយ អប្បណិហិតំ មេ ពហិទ្ធា ចិត្តន្តិ បជានាតិ អថ បច្ឆា បុរេ អសង្ខិត្តំ វិមុត្តំ អប្បណិហិតន្តិ បជានាតិ អថ ច បន ចិត្តេ ចិត្តានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា សុខមស្មីតិ បជានាតិ ។

[៤៨] ពហិទ្ធា អានន្ទ ភិក្ខុ ចិត្តំ អប្បណិធាយ អប្បណិហិតំ មេ ពហិទ្ធា ចិត្តន្តិ បជានាតិ អថ បច្ឆា បុរេ អសង្ខិត្តំ វិមុត្តំ អប្បណិហិតន្តិ បជានាតិ អថ ច បន ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្ប-ជានោ សតិមា សុខមស្មីតិ បជានាតិ ។

អម្ពបាលិវគ្គ

[៤៨] ម្នាលអានន្ទ ភិក្ខុមិនបានតាំងចិត្ត ក្នុងអារម្មណ៍ខាងក្រៅ រមែងដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានតាំងទុកក្នុងអារម្មណ៍ខាងក្រៅ មួយទៀត ដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានរាយមាយ រួចផុត ស្រឡះហើយ មិនបានតាំងទុក (ក្នុងអារម្មណ៍ខាងក្រៅ) ទាំងក្រោយ ទាំងមុន មួយវិញទៀត ដឹងច្បាស់ថា អាត្មាអញពិចារណាឃើញនូវ ចិត្តក្នុងចិត្តជាប្រក្រតី មានព្យាយាមដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី មានសេចក្ដីសុខ ។

[៤៩] ម្នាលអានន្ទ ភិក្ខុមិនបានតាំងចិត្តក្នុងអារម្មណ៍ខាងក្រៅ រមែងដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានតាំងទុក (ក្នុងអារម្មណ៍ខាង ក្រៅ) មួយទៀត ដឹងច្បាស់ថា ចិត្តអាត្មាអញមិនបានរាយមាយ រួចផុត ស្រឡះហើយ មិនបានតាំងទុក (ក្នុងអារម្មណ៍ខាងក្រៅ) ទាំងក្រោយ ទាំងមុន មួយវិញទៀត ដឹងច្បាស់ថា អាត្មាអញជាអ្នកពិចារណាឃើញ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្ដៅនូវកិលេស ជា អ្នកដឹងខ្លួន មានស្មារតី មានសេចក្ដីសុខ ។

[៤៦] ឯវំ ខោ អានន្ទ អប្បណិធាយ ភាវនា ហោតិ ។ ឥតិ ខោ អានន្ទ ទេសិតា មយា បណិធាយ ភាវនា ទេសិតា មយា អប្បណិធាយ ភាវនា ។ យំ អានន្ទ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ។ ឯតានិ អានន្ទ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថានន្ទ[១] មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ អយំ វោ អម្ហាកំ អនុសាសនីតិ ។ ឥទមវោច ភគវា ។ អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

អម្ពបាលិវគ្គោ បឋមោ ។

១ ឱ. ម. និជ្ឈាយថានន្ទ ។

[៤៦] ម្នាលអានន្ទ ការមិនតាំងចិត្តហើយភាវនា យ៉ាងនេះឯង ។ ម្នាលអានន្ទ ការតាំងចិត្តហើយភាវនា តថាគតសម្តែងហើយ ការមិនតាំងចិត្តហើយភាវនា តថាគតក៏បានសម្តែងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ កិច្ចឯណា ដែលព្រះសាស្តាជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ គប្បីធ្វើដល់សាវ័កទាំងឡាយ កិច្ចនោះ តថាគតបានធ្វើហើយ ដល់អ្នកទាំងឡាយ ។ ម្នាលអានន្ទ កិច្ចទាំងនុ៎ះ គឺម្ចប់ឈើ កិច្ចទាំងនុ៎ះ គឺទីស្ងាត់ ។ ម្នាលអានន្ទ អ្នកទាំងឡាយចូរពិចារណា ចូរកុំប្រមាទ កុំមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ នេះជាអនុសាសនីគឺពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវភាសិតនេះហើយ ។ ព្រះអានន្ទដ៏មានអាយុក៏ពេញចិត្តរីករាយចំពោះភាសិតព្រះដ៏មានព្រះភាគ ។

ចប់ អម្ពបាលិវគ្គ ទី ១ ។

៤៣

អម្ពបាលិវគ្គោ

# តស្សុទ្ទានំ

អម្ពចាលិសតោ ភិក្ខុ

សាលកុសលរាសិ ច

សាកុណគ្ឃី មក្កដោ សូចោ

តិលាដោ ភិក្ខុនី វាសកោតិ ។

អម្ពបាលិវគ្គ

# ឧទ្ទាននៃអម្ពបាលិវគ្គនោះគឺ

និយាយអំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងអម្ពបាលិវន មាន ២ លើកអំពីភិក្ខុមានស្មារតី ១ អំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រាហ្មណ៍គ្រាមឈ្មោះកោសល ក្នុងដែនកោសល ១ អំពីគំនរអកុសលនិងកុសល ១ អំពីសត្វខ្វែងធាបប្រចៀច ១ អំពីប្រទេសដែលសត្វស្វានិងមនុស្សទៅបានដោយលំបាក ១ អំពីជនអ្នកចម្អិនទូវភត្ត ១ អំពីព្រះដ៏មានព្រះភាគទ្រង់ព្រះប្រឈួនជាទម្ងន់ ១ អំពីព្រះអានន្ទដ៏មានអាយុចូលទៅកាន់លំនៅភិក្ខុនីមួយរូប ១ ។

# នាឡន្ទវគ្គោ

[៤៧] សាវត្ថីនិទានំ ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច មហាបុរិសោ មហាបុរិសោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ មហាបុរិសោ ហោតីតិ ។ វិមុត្តចិត្តត្តា ខ្វាហំ សារីបុត្ត មហាបុរិសោតិ វទាមិ អវិមុត្តចិត្តត្តា នោ មហាបុរិសោតិ វទាមិ ។

[៤៨] កថញ្ច សារីបុត្ត វិមុត្តចិត្តោ ហោតិ ។ ឥធ សារីបុត្ត ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស កាយេ កាយានុបស្សិនោ វិហរតោ

# នាឡន្ទវគ្គ

[៤៧] សារត្ថនិទាន ។ គ្រានោះឯង ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា មហាបុរស មហាបុរស បពិត្រព្រះអង្គដ៏ចម្រើន ចុះបុគ្គលជាមហាបុរសដោយហេតុដូចម្តេច ។ ម្នាលសារីបុត្ត តថាគតហៅថា មហាបុរស ព្រោះមានចិត្តរួចផុតស្រឡះហើយ មិនមែនហៅថា មហាបុរស ព្រោះមានចិត្តមិនទាន់រួចផុតស្រឡះទេ ។

[៤៨] ម្នាលសារីបុត្ត ភិក្ខុដែលឈ្មោះថាមានចិត្តរួចស្រឡះតើដូចម្តេច ។ ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ កាលភិក្ខុនោះពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី

ចិត្តំ វិរជ្ជតិ វិមុច្ចតិ អនុបាទាយ អាសវេហិ ។ វេទនា-
សុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្ប-
ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។
តស្ស ធម្មេសុ ធម្មានុបស្សិនោ វិហរតោ ចិត្តំ វិរជ្ជតិ
វិមុច្ចតិ អនុបាទាយ អាសវេហិ ។ ឯវំ ខោ សារីបុត្ត
វិមុត្តចិត្តោ ហោតិ ។ វិមុត្តចិត្តត្តា ខ្វាហំ សារីបុត្ត
មហាបុរិសោតិ វទាមិ អវិមុត្តចិត្តត្តា នោ មហាបុរិសោតិ
វទាមីតិ ។

[៤៩] ឯកំ សមយំ ភគវា នាឡន្ទាយំ វិហរតិ
បាវារិកម្ពវនេ ។ អថខោ អាយស្មា សារីបុត្តោ

ចិត្តក៏ប្រាសចាកតម្រេក រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ កាលភិក្ខុនោះពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ចិត្តក៏ប្រាសចាកតម្រេក រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ម្នាលសារីបុត្ត ភិក្ខុដែលឈ្មោះថាមានចិត្តរួចស្រឡះ យ៉ាងនេះឯង ។ ម្នាលសារីបុត្ត តថាគតហៅថា មហាបុរស ព្រោះមានចិត្តរួចស្រឡះ មិនមែនហៅថាមហាបុរស ព្រោះមិនមានចិត្តរួចស្រឡះទេ ។

[៤៩] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងបាវារិកម្ពវនជិតក្រុងនាឡន្ទា ។ គ្រានោះឯង ព្រះសារីបុត្តដ៏មានអាយុ

៤៦



យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឯវំ បសន្នោហំ ភន្តេ ភគវតិ ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយន្តិ ។ ឧឡារា ខោ ត្យាយំ សារីបុត្ត អាសភិវាចា ភាសិតា ឯកំសោ គហិតោ សីហនាទោ នទិតោ ឯវំ បសន្នោហំ ភន្តេ ភគវតិ ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយន្តិ ។

ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តជ្រះថ្លាចំពោះព្រះដ៏-មានព្រះភាគយ៉ាងនេះ សមណៈឬព្រាហ្មណ៍ដទៃ មានសេចក្តីត្រាស់ដឹងលើសជាងព្រះដ៏មានព្រះភាគ ក្នុងសម្ពោធិញ្ញាណនេះ មិនមានក្នុងអតីតកាលផង មិនមានក្នុងអនាគតកាលផង មិនមានក្នុងបច្ចុប្បន្នកាលផងឡើយ ។ ម្នាលសារីបុត្ត អាសភិវាចា (វាចាដ៏អង់អាច) នេះ ដែលអ្នកបានពោលហើយលើសលុបពេកណាស់ សីហនាទដែលខ្លួនកាន់យកតែមួយចំណែក អ្នកបានបន្លឺឡើងហើយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគយ៉ាងនេះ សមណៈឬព្រាហ្មណ៍ដទៃ មានសេចក្តីត្រាស់ដឹងក្រៃលែងជាងព្រះដ៏មានព្រះភាគក្នុងសម្ពោធិញ្ញាណនេះ មិនមានក្នុងអតីតកាលផង មិនមានក្នុងអនាគត-កាលផង មិនមានក្នុងបច្ចុប្បន្នកាលផង ។

៤៧

## នាឡន្ទវគ្គោ

[៥០] កិន្នុ តេ សារីបុត្ត យេ តេ អហេសុំ អតី-តមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ ចេតសា ចេតោ បរិច្ច វិទិតា ឯវំសីលា តេ ភគវន្តោ អហេសុំ ឥតិ វា ឯវំធម្មា តេ ភគវន្តោ អហេសុំ ឥតិ វា ឯវំបញ្ញា តេ ភគវន្តោ អហេសុំ ឥតិ វា ឯវំវិហារិនោ តេ ភគវន្តោ អហេសុំ ឥតិ វា ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិ វាតិ ។ នោ ហេតំ ភន្តេ ។

[៥១] កឹ បន តេ សារីបុត្ត យេ តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ ចេតសា ចេតោ បរិច្ច វិទិតា ឯវំសីលា តេ ភគវន្តោ ភវិស្សន្តិ ឥតិ វា ឯវំធម្មា តេ ភគវន្តោ ភវិស្សន្តិ ឥតិ វា ឯវំបញ្ញា តេ ភគវន្តោ ភវិស្សន្តិ ឥតិ វា ឯវំវិហារិនោ តេ ភគវន្តោ ភវិស្សន្តិ ឥតិ វា ឯវំវិមុត្តា តេ ភគវន្តោ ភវិស្សន្តិ ឥតិ វាតិ ។ នោ ហេតំ ភន្តេ ។

នាឡន្ទវគ្គ

[៥០] ម្នាលសារីបុត្ត ព្រះដ៏មានព្រះភាគទាំងឡាយឯណា ជាព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងអតីតកាល ព្រះដ៏មានព្រះភាគទាំងអស់នោះ អ្នកបានកំណត់ដឹងនូវចិត្តដោយចិត្តថា ព្រះដ៏មានព្រះភាគទាំងនោះ ព្រះអង្គមានសីលយ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងនោះ ព្រះអង្គមានធម៌យ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងនោះ ព្រះអង្គមានបញ្ញាយ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងនោះ ព្រះអង្គមានធម៌ជាគ្រឿងនៅយ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងនោះ ព្រះអង្គមានវិមុត្តិយ៉ាងនេះខ្លះ ដូច្នេះបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះកំណត់មិនបានទេ ។

[៥១] ម្នាលសារីបុត្ត ព្រះដ៏មានព្រះភាគទាំងឡាយឯណា ជាព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងអនាគតកាល ព្រះដ៏មានព្រះភាគទាំងអស់នោះ អ្នកកំណត់ដឹងនូវចិត្តដោយចិត្តថា ព្រះដ៏មានព្រះភាគទាំងឡាយនោះ ព្រះអង្គមានសីលយ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងឡាយនោះ ព្រះអង្គមានធម៌យ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងឡាយនោះ ព្រះអង្គមានបញ្ញាយ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងឡាយនោះ ព្រះអង្គមានធម៌ជាគ្រឿងនៅយ៉ាងនេះខ្លះ ព្រះដ៏មានព្រះភាគទាំងឡាយនោះ ព្រះអង្គមានវិមុត្តិយ៉ាងនេះខ្លះ ដូច្នេះបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះកំណត់មិនបានទេ ។

[៥២] កឹ បន ត្យាហំ សារីបុត្ត ឯតរហិ អរហំ សម្មាសម្ពុទ្ធោ ចេតសា ចេតោ បរិច្ច វិទិតោ ឯវំសីលោ ភគវា ឥតិ វា ឯវំធម្មោ ភគវា ឥតិ វា ឯវំបញ្ញោ ភគវា ឥតិ វា ឯវំវិហារី ភគវា ឥតិ វា ឯវំវិមុត្តោ ភគវា ឥតិ វាតិ ។ នោ ហេតំ ភន្តេ ។

[៥៣] ឯត្ថ ច តេ សារីបុត្ត អតីតានាគតប្បច្ចុប្បន្នេសុ អរហន្តេសុ សម្មាសម្ពុទ្ធេសុ ចេតោបរិយាយញ្ញាណំ នត្ថិ ។ អថ កិញ្ចរហិ ត្យាហំ សារីបុត្ត ឧឡារា អាសភិវាចា ភាសិតា ឯកំសោ គហិតោ សីហនាទោ នទិតោ ឯវំ បសន្នាហំ ភន្តេ ភគវតិ

[៥២] ម្នាលសារីបុត្ត ចុះតថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងបច្ចុប្បន្នកាលនេះ អ្នកកំណត់ដឹងនូវចិត្តដោយចិត្តថា ព្រះដ៏មានព្រះភាគ ព្រះអង្គមានសីលយ៉ាងនេះខ្វះ ព្រះដ៏មានព្រះភាគ ព្រះអង្គមានធម៌យ៉ាងនេះខ្វះ ព្រះដ៏មានព្រះភាគ ព្រះអង្គមានបញ្ញាយ៉ាងនេះខ្វះ ព្រះដ៏មានព្រះភាគ ព្រះអង្គមានធម៌ជាគ្រឿងនៅយ៉ាងនេះខ្វះ ព្រះដ៏មានព្រះភាគ ព្រះអង្គមានវិមុត្តិយ៉ាងនេះខ្វះ ដូច្នេះបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះកំណត់មិនបានទេ ។

[៥៣] ម្នាលសារីបុត្ត ការកំណត់ដឹងនូវចិត្តរបស់អ្នក មិនមានក្នុងព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ក្នុងកាលជាអតីត អនាគត បច្ចុប្បន្ននុ៎ះឡើយ ។ ម្នាលសារីបុត្ត ចុះហេតុដូចម្តេចក៏កាលឥឡូវនេះ អាសភិវាចាដ៏លើសលុប អ្នកបានពោលហើយ សីហនាទដែលខ្លួនកាន់យកដោយចំណែកមួយ អ្នកបានបន្លឺឡើងហើយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគយ៉ាងនេះ

៤៩

## នាឡន្ទវគ្គោ

ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញ-តរោ យទិទំ សម្ពោធិយន្តិ ។ ន ខោ មេ តំ ភន្តេ អតីតានាគតបច្ចុប្បន្នេសុ អរហន្តេសុ សម្មាសម្ពុទ្ធេ-សុ ចេតោបរិយាយញ្ញាណំ អត្ថិ អបិ ច ធម្មន្វយោ វិទិតោ ។

[៤៨] សេយ្យថាបិ ភន្តេ រញ្ញោ បច្ចន្តិមំ នគរំ ទឡ្ហុទ្ទាលំ[១] ទឡ្ហបាការតោរណំ ឯកទ្វារំ តត្រស្ស ទោវារិកោ បណ្ឌិតោ ព្យត្តោ មេធាវី អញ្ញាតានំ និវា-រេតា ញាតានំ បវេសេតា ។ សោ តស្ស នគរស្ស ស-មន្តា អនុបរិយាយបថំ អនុក្កមមានោ ន បស្សេយ្យ បាការសន្ធឹ វា បាការវិវរំ វា អន្តមសោ ពិឡារនិស្សក្ក-នមត្តំបិ ។ តស្ស ឯវមស្ស យេ ខោ កេចិ ឱឡារិកា បាណា ឥមំ នគរំ បវិសន្តិ វា និក្ខមន្តិ វា សព្វេ តេ

---

១ ឱ. ម. ទឡ្ហុទ្ធាបំ ។

សមណៈឬព្រាហ្មណ៍ដទៃ មានសេចក្តីត្រាស់ដឹងក្រៃលែងលើសជាង ព្រះដ៏មានព្រះភាគ ក្នុងសម្ពោធិញ្ញាណនេះ មិនមានក្នុងអតីតកាលផង មិនមានក្នុងអនាគតកាលផង មិនមានក្នុងបច្ចុប្បន្នកាលផង ។ បពិត្រ ព្រះអង្គដ៏ចម្រើន ពិតមែនតែការកំណត់ដឹងនូវចិត្តរបស់ខ្ញុំព្រះអង្គ ចំពោះ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ក្នុងអតីតកាល អនាគតកាល បច្ចុប្បន្នកាលនោះ មិនមានឡើយ ប៉ុន្តែការស្ទង់តាមធម៌ ខ្ញុំព្រះអង្គបានដឹង ច្បាស់ហើយ ។

[៥៤] បពិត្រព្រះអង្គដ៏ចម្រើន ដូចនគររបស់ព្រះរាជា នៅទីបំផុត ដែន មានជើងកំពែងដ៏មាំ មានកំពែងនិងសសរខឿនដ៏មាំ មានទ្វារ តែមួយ នាយទ្វាររបស់ព្រះរាជានោះជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា នៅប្រចាំត្រង់ទ្វារនោះ ចាំហាមឃាត់ជនទាំងឡាយដែលមិនស្គាល់- បើកឲ្យតែពួកជនដែលស្គាល់ចូលទៅបាន ។ នាយទ្វារនោះដើរត្រួត- ត្រាផ្លូវតាមជួរកំពែងដោយជុំវិញនគរនោះ ក៏មិនឃើញនូវទីតនៃកំពែងឬ ឬនូវចន្លោះនៃកំពែង ដោយហោចទៅសូម្បីតែសត្វឆ្មាក៏សសុលចូលពុំ បាន ។ នាយទ្វារនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសត្វធំ ៗ ណា- មួយ រមែងចូលទៅកាន់នគរនេះ ឬចេញមកវិញ ពួកសត្វទាំងអស់នោះ

ឥមិនា វ ទ្វារេន បវិសន្តិ វា និក្ខមន្តិ វាតិ ។ ឯវមេវ ខោ មេ ភន្តេ ធម្មន្វយោ វិទិតោ យេបិ តេ ភន្តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈឹសុ ។ យេបិ តេ ភន្តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈិស្សន្តិ ។ ភគវាបិ ភន្តេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តោ

រមែងចូលទៅ ឬចេញតាមទ្វារនេះឯង យ៉ាងណាមិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ការស្ទង់តាមធម៌ ខ្ញុំព្រះអង្គបានដឹងហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទាំងឡាយឯណាជាព្រះអរហន្តសម្មាសម្ពុទ្ធ មានក្នុងអតីតកាល ព្រះដ៏មានព្រះភាគទាំងអស់នោះ ទ្រង់លះបង់នូវនីវរណៈទាំង ៥ ដែលជាឧបក្កិលេសនៃចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយ ទ្រង់មានព្រះហឫទ័យតម្កល់ខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤ ទ្រង់សភាវៈពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទាំងឡាយឯណាជាព្រះអរហន្តសម្មាសម្ពុទ្ធ មានក្នុងអនាគតកាល ព្រះដ៏មានព្រះ-ភាគទាំងអស់នោះ ទ្រង់លះបង់នូវនីវរណៈទាំង ៥ ដែលជាឧបក្កិលេសនៃចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយ ទ្រង់មានព្រះហឫទ័យតម្កល់ខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤ ទ្រង់ចម្រើននូវពោជ្ឈង្គទាំង ៧ ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិធម៌តាមសភាវៈពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏-មានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងកាលជាបច្ចុប្បន្ននេះ ក៏ទ្រង់លះបង់នូវនីវរណៈទាំង ៥ ដែលជាឧបក្កិលេសនៃចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយ ទ្រង់មានព្រះហឫទ័យតម្កល់ខ្ជាប់ក្នុងសតិប្បដ្ឋានទាំង ៤

សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោ-
ធឹ អភិសម្ពុទ្ធោតិ ។

[៥៥] សាធុ សាធុ សារីបុត្ត តស្មាតិហ ត្វំ
សារីបុត្ត ឥមំ ធម្មបរិយាយំ អភិក្ខណំ ភាសេយ្យាសិ
ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ ។
យេសម្បិ ហិ សារីបុត្ត មោឃបុរិសានំ ភវិស្សតិ តថា-
គតេ កង្ខា វា វិមតិ វា តេសម្បិមំ ធម្មបរិយាយំ
សុត្វា យា តថាគតេ កង្ខា វា វិមតិ វា សា បហី-
យិស្សតីតិ ។

[៥៦] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ
ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ
បន សមយេន អាយស្មា សារីបុត្តោ មគធេសុ វិ-
ហរតិ នាឡកគាមកេ អាពាធិកោ ទុក្ខិតោ ពា-
ឡ្ហគិលានោ ។ ចុន្ទោ សមណុទ្ទេសោ អាយស្មតោ
សារីបុត្តស្ស ឧបដ្ឋាកោ ហោតិ ។ អថខោ អាយស្មា
សារីបុត្តោ តេនេវ អាពាធេន បរិនិព្វាយិ ។

ទ្រង់ចម្រើននូវពោជ្ឈង្គទាំង ៧ ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិធម៌ តាមសភាវៈពិត យ៉ាងនោះឯង ។

[៥៥] ម្នាលសារីបុត្ត ត្រូវណាស់ហើយ ម្នាលសារីបុត្ត ព្រោះហេតុនោះ អ្នកគប្បីពោលនូវធម្មបរិយាយនេះ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសកនិងឧបាសិកា ឲ្យរឿយៗចុះ ។ ម្នាលសារីបុត្ត ព្រោះថាសេចក្តីងឿងឆ្ងល់ ឬសេចក្តីសង្ស័យក្នុងព្រះតថាគត នឹងមានដល់មោឃបុរសឯណា មោឃបុរសទាំងនោះ បានស្តាប់នូវធម្មបរិយាយនេះហើយ មុខជានឹងលះបង់នូវសេចក្តីងឿងឆ្ងល់ ឬសេចក្តីសង្ស័យក្នុងព្រះតថាគតចេញបាន ។

[៥៦] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ មានអាពាធ មានសេចក្តីទុក្ខ មានជំងឺធ្ងន់ នៅក្នុងស្រុកនាឡកៈ ក្នុងដែនមគធៈ ។ មានសាមណេរឈ្មោះចុន្ទជាឧបដ្ឋាករបស់ព្រះសារីបុត្តដ៏មានអាយុ ។ គ្រានោះឯង ព្រះសារីបុត្តក៏បរិនិព្វានដោយអាពាធនោះ ។

[៥៧] អថខោ ចុន្ទោ សមណុទ្ទេសោ អាយស្មតោ សារីបុត្តស្ស បត្តចីវរមាទាយ យេន សាវត្ថីជេតវនំ អនាថបិណ្ឌិកស្ស អារាមោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចុន្ទោ សមណុទ្ទេសោ អាយស្មន្តំ អានន្ទំ ឯតទវោច អាយស្មា ភន្តេ សារីបុត្តោ បរិនិព្វុតោ ឥទមស្ស បត្តចីវរន្តិ ។ អត្ថិ ខោ ឥទំ អាវុសោ ចុន្ទ កថាបាភតំ ភគវន្តំ ទស្សនាយ អាយាមាវុសោ ចុន្ទ យេន ភគវា តេនុបសង្កមិស្សាម ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេស្សាមាតិ ។ ឯវំ ភន្តេតិ ខោ ចុន្ទោ សមណុទ្ទេសោ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។

[៩៧] លំដាប់នោះឯង ចុន្ទសាមណេរក៏កាន់យកបាត្រនិងចីវររបស់ព្រះសារីបុត្តដ៏មានអាយុ ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុឯវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះចុន្ទសាមណេរអង្គុយក្នុងទីសមគួរហើយ បានពោលនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុបរិនិព្វានហើយ នេះបាត្រចីវររបស់លោក ។ ម្នាលអាវុសោចុន្ទ នេះជាដំណឹងដែលអ្នកនាំមកជាដំបូង ម្នាលអាវុសោចុន្ទ មក យើងនឹងនាំគ្នាចូលទៅរកព្រះដ៏មានព្រះភាគ ដើម្បីគាល់ព្រះអង្គ លុះចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ចុន្ទសាមណេរក៏ទទួលពាក្យព្រះអានន្ទដ៏មានអាយុថា ករុណាលោកម្ចាស់ ។

៥៣

## នាឡន្ទវគ្គោ

[៤៨] អថខោ អាយស្មា ច អានន្ទោ ចុន្ទោ ច ស-
មណុទ្ទេសោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ
និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច
អយំ ភន្តេ ចុន្ទោ សមណុទ្ទេសោ ឯវមាហ អាយស្មា
ភន្តេ សារីបុត្តោ បរិនិព្វុតោ ឥទមស្ស បត្តចីវរន្តិ ។ អបិ
ច មេ ភន្តេ មធុរកជាតោ វិយ កាយោ ទិសាបិ មេ ន
បក្ខាយន្តិ ធម្មាបិ មំ នប្បដិភន្តិ អាយស្មា សារីបុត្តោ
បរិនិព្វុតោតិ សុត្វា ។

[៤៩] កឹ នុ ខោ អានន្ទ សារីបុត្តោ សីលក្ខន្ធំ វា
អាទាយ បរិនិព្វុតោ សមាធិក្ខន្ធំ វា អាទាយ បរិនិព្វុ-
តោ បញ្ញាខន្ធំ វា អាទាយ បរិនិព្វុតោ វិមុត្តិក្ខន្ធំ វា
អាទាយ បរិនិព្វុតោ វិមុត្តិញ្ញាណទស្សនក្ខន្ធំ វា អា-
ទាយ បរិនិព្វុតោតិ ។ ន ខោ មេ ភន្តេ អាយស្មា
សារីបុត្តោ សីលក្ខន្ធំ វា អាទាយ បរិនិព្វុតោ ។ បេ ។
វិមុត្តិញ្ញាណទស្សនក្ខន្ធំ វា អាទាយ បរិនិព្វុតោ ។

នាឡន្ទវគ្គ

[៥៨] គ្រានោះឯង ព្រះអានន្ទដ៏មានអាយុនិងចុន្ទសាមណេរ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុន្ទសាមណេរនេះ បាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុបរិនិព្វានហើយ នេះបាត្រចីវររបស់លោក ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត កាយរបស់ខ្ញុំព្រះអង្គហាក់ដូចជារឹងស្លុកស្ពឹង ទាំងទិសទាំងឡាយក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ ទាំងធម៌ទាំងឡាយក៏មិនភ្លឺច្បាស់ដល់ខ្ញុំព្រះអង្គដែរ ព្រោះបានឮថា ព្រះសារីបុត្តដ៏មានអាយុបរិនិព្វានទៅហើយ ។

[៥៩] ម្នាលអានន្ទ សារីបុត្តនាំយកសីលក្ខន្ធ បរិនិព្វានទៅហើយឬ នាំយកសមាធិក្ខន្ធ បរិនិព្វានទៅហើយឬ នាំយកបញ្ញាខន្ធ បរិនិព្វានទៅហើយឬ នាំយកវិមុត្តិក្ខន្ធ បរិនិព្វានទៅហើយឬ នាំយកវិមុត្តិញ្ញាណ-ទស្សនក្ខន្ធ បរិនិព្វានទៅហើយឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្តដ៏មានអាយុរបស់ខ្ញុំព្រះអង្គ នាំយកសីលក្ខន្ធ បរិនិព្វានទៅក៏ទេ ។ បេ ។ នាំយកវិមុត្តិញ្ញាណទស្សនក្ខន្ធ បរិនិព្វានទៅក៏ទេ ។

អបិ ច មេ ភន្តេ អាយស្មា សារីបុត្តោ ឱវាទកោ អហោសិ[១] វិញ្ញាបកោ សន្ទស្សកោ សមាទបកោ សមុត្តេជកោ សម្បហំសកោ អកិលាសុ ធម្មទេស-នាយ អនុគ្គាហកោ សព្រហ្មចារីនំ តំ មយំ អាយ-ស្មតោ សារីបុត្តស្ស ធម្មោជំ ធម្មភោគំ ធម្មានុគ្គហំ អនុស្សរាមាតិ ។

[៦០] ននុ តំ អានន្ទ មយា បដិកច្ចេវ អក្ខាតំ សព្វេហិ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ តំ កុតេត្ថ អានន្ទ លព្ភា ។ យន្តំ ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត បលុជ្ជីតិ នេតំ ឋានំ វិជ្ជតិ ។

---

១ ឱ. តិណ្ណោ។

បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែព្រះសារីបុត្តដ៏មានអាយុរបស់ខ្ញុំព្រះអង្គ លោកជាអ្នកប្រដៅ ជាអ្នកពន្យល់ ជាអ្នកបំភ្លឺ ជាអ្នកបបួល ជាអ្នកឲ្យអាចហាន ជាអ្នកឲ្យរីករាយ ជាអ្នកមិនខ្ជិលច្រអូស ជាអ្នកអនុគ្រោះដល់ពួកសព្រហ្មចារីដោយធម៌ទេសនា យើងខ្ញុំទាំងឡាយតែងរឭកតាមនូវធម្មឱជារស ធម្មសម្បត្តិ ធម្មានុគ្រោះ របស់ព្រះសារីបុត្តដ៏មានអាយុនោះ ។

[៦០] ម្នាលអានន្ទ ដំណើរនោះ តថាគតបានប្រាប់មុនហើយថា ការផ្សេងៗគ្នា ការព្រាត់ប្រាសគ្នា ការប្រព្រឹត្តិទៅទីទៃពីគ្នា ចាកសត្វនិងសង្ខារទាំងពួង ជាទីស្រឡាញ់ ជាទីពេញចិត្ត ម្នាលអានន្ទ អ្នកគប្បីបានដំណើរនោះអំពីទីឯណាដូច្នេះ មិនមែនឬ ។ របស់ឯណាដែលកើតហើយ ចម្រើនហើយ បច្ច័យតាក់តែងហើយ របស់នោះឯងតែងមានសេចក្តីវិនាសទៅជាធម្មតា បុគ្គលនឹងសង្ឃឹមថា សូមឲ្យរបស់នោះកុំបីវិនាសឡើយ ហេតុនុ៎ះមិនដែលមានឡើយ ។

## នាឡន្ទវគ្គោ

[៦១] សេយ្យថាបិ អានន្ទ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ យោ មហន្តតរោ ខន្ធោ សោ បលុជ្ជេយ្យ ។ ឯវមេវ ខោ អានន្ទ មហតោ ភិក្ខុសង្ឃស្ស តិដ្ឋតោ សារវតោ សារីបុត្តោ បរិនិព្វុតោ តំ កុតេត្ថ អានន្ទ លព្ភា ។ យន្តំ ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតិ ។ តស្មាតិហ អានន្ទ អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។

[៦២] កថញ្ចានន្ទ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។ ឥធានន្ទ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ

នាឡន្ទវគ្គ

[៦១] ម្នាលអានន្ទ ដូចដើមឈើធំក្រៃលែងជាងឈើធំ ដែលមានខ្លឹម កំពុងតាំងនៅ ស្រាប់តែរលំទៅ យ៉ាងណា ។ ម្នាលអានន្ទ កាលបើភិក្ខុសង្ឃជាច្រើន ប្រកបដោយសារធម៌ កំពុងឋិតនៅ ស្រាប់តែសារីបុត្តបរិនិព្វានទៅ ក៏យ៉ាងនោះឯង ម្នាលអានន្ទ ដំណើរនោះអ្នកគប្បីបានអំពីទីឯណា ។ របស់ឯណាដែលកើតហើយ ចម្រើនហើយ បច្ច័យតាក់តែងហើយ តែងមានសេចក្ដីវិនាសទៅជាធម្មតា បុគ្គលនឹងសង្ឃឹមថា សូមឲ្យរបស់នោះកុំវិនាសទៅឡើយ ហេតុនុ៎ះមិនដែលមានឡើយ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីរឭក កុំបីមានវត្ថុដទៃជាទីរឭកឡើយ ចូរមានធម៌ជាទីពឹង មានធម៌ជាទីរឭក កុំបីមានវត្ថុដទៃជាទីរឭកឡើយ ។

[៦២] ម្នាលអានន្ទ ភិក្ខុដែលមានខ្លួនជាទីពឹង មានខ្លួនជាទីរឭក មិនមានវត្ថុដទៃជាទីរឭក មានធម៌ជាទីពឹង មានធម៌ជាទីរឭក មិនមានវត្ថុដទៃជាទីរឭក តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ តែងពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់

លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ អានន្ទ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។

[៦៣] យេ ហិ កេចិ អានន្ទ ឯតរហិ វា មមច្ច-យេ វា អត្តទីបា វិហរិស្សន្តិ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។ តមតគ្គេមេតេ អានន្ទ ភិក្ខូ ភវិស្សន្តិ យេ កេចិ សិក្ខាកាមាតិ ។

នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលអានន្ទ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីរឭក មិនមានវត្ថុដទៃជាទីរឭក មានធម៌ជាទីពឹង មានធម៌ជាទីរឭក មិនមានវត្ថុដទៃជាទីរឭក យ៉ាងនេះឯង ។

[៦៣] ម្នាលអានន្ទ ពួកភិក្ខុឯណានីមួយ ក្នុងកាលឥឡូវនេះក្តី ក្នុងកាលអំណើះអំពីតថាគតទៅក្តី នឹងមានខ្លួនជាទីពឹង មានខ្លួនជាទីរឭក កុំបីមានវត្ថុដទៃជាទីរឭក មានធម៌ជាទីពឹង មានធម៌ជាទីរឭក កុំបីមានវត្ថុដទៃជាទីរឭកចុះ ។ ម្នាលអានន្ទ ពួកភិក្ខុឯណានីមួយជាអ្នកប្រាថ្នាការសិក្សា ភិក្ខុទាំងនោះនឹងប្រាកដមានក្នុងចំណោកដ៏ប្រសើរក្រៃលែង ។

៤៧

## នាឡន្ទវគ្គោ

[៦៤] ឯកំ សមយំ ភគវា វជ្ជីសុ វិហរតិ ឧក្ក-
ចេលាយំ គង្គាយ នទិយា តីរេ មហតា ភិក្ខុសង្ឃេន
សទ្ធឹ អចិរបរិនិព្វុតេសុ សារីបុត្តមោគ្គល្លានេសុ ។ តេន
ខោ បន សមយេន ភគវា ភិក្ខុសង្ឃបរិវុតោ អជ្ឈោ-
កាសេ និសិន្នោ ហោតិ ។ អថខោ ភគវា តុណ្ហីភូតំ
ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ អបិ ខោ
ម្យាយំ ភិក្ខវេ បរិសា សុញ្ញា វិយ ខាយតិ អបរិ-
និព្វុតេសុ សារីបុត្តមោគ្គល្លានេសុ ។ អសុញ្ញា មេ សា[១]
ភិក្ខវេ ទិសា ហោតិ អនបេក្ខា តស្សំ ទិសាយំ
ហោតិ យស្សំ ទិសាយំ សារីបុត្តមោគ្គល្លានា វិហរន្តិ ។

---

១ ឱ. ម. សាតិ បទំ ន ហោតិ ។

## នាឡន្ទវគ្គ

[៦៤] កាលដែលព្រះសារីបុត្ត និងព្រះមោគ្គល្លាន[១] បរិនិព្វាន ទៅហើយមិនយូរប៉ុន្មាន សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅ ទៀបឆ្នេរស្ទឹងគង្គា ជិតក្រុងឧក្កចេលា នាដែនវជ្ជី ជាមួយនឹងភិក្ខុសង្ឃ ច្រើនរូប ។ សម័យនោះឯង ព្រះដ៏មានព្រះភាគមានភិក្ខុសង្ឃចោមរោម ទ្រង់គង់នៅក្នុងទីវាល ។ ទើបព្រះដ៏មានព្រះភាគទ្រង់ក្រឡេកមើលទៅ ភិក្ខុសង្ឃនៅស្ងៀមហើយ ក៏ទ្រង់ត្រាស់ទៅនឹងភិក្ខុទាំងឡាយថា ម្នាល ភិក្ខុទាំងឡាយ កាលដែលសារីបុត្តនិងមោគ្គល្លានមិនទាន់បរិនិព្វាននៅ ឡើយ ក៏បរិសទ្យនេះឯង ប្រាកដជាហាក់ដូចជាសូន្យដល់តថាគត ។ ម្នាល ភិក្ខុទាំងឡាយ (បើ) សារីបុត្តនិងមោគ្គល្លាននៅក្នុងទិសឯណា ទិសនោះ មិនសូន្យដល់តថាគតទេ ទាំងសេចក្តីមិនព្រួយបារម្ភ (របស់តថាគត) ក៏មានក្នុងទិសនោះ ។

---

១ ព្រះថេរៈទាំងពីរអង្គនេះ បរិនិព្វានក្នុងខែកត្តិកជាមួយគ្នា ផ្សេងគ្នាតែមុននឹងក្រោយ គឺព្រះ សារីបុត្តបរិនិព្វានក្នុងថ្ងៃ ១៥ កើតខែកត្តិក ព្រះមហាមោគ្គល្លានបរិនិព្វានក្នុងថ្ងៃ ១៥ រោចខែកត្តិក (អដ្ឋកថា) ។

[៦៥] យេបិ តេ ភិក្ខវេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតបរមំយេវ សាវកយុគំ អហោសិ សេយ្យថាបិ មយ្ហំ សារីបុត្តមោគ្គល្លានា ។ យេបិ តេ ភិក្ខវេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតបរមំយេវ សាវកយុគំ ភវិស្សតិ សេយ្យថាបិ មយ្ហំ សារីបុត្តមោគ្គល្លានា ។

[៦៦] អច្ឆរិយំ ភិក្ខវេ សាវកានំ អព្ភុតំ ភិក្ខវេ សាវកានំ សត្ថុ ច នាម សាសនករា ភវិស្សន្តិ ឱវាទប្បដិករា ច ចតុន្នញ្ច បរិសានំ បិយា ភវិស្សន្តិ មនាបា គរុ(១) ភាវនីយា ច ។ អច្ឆរិយំ ភិក្ខវេ តថាគតស្ស អព្ភុតំ ភិក្ខវេ តថាគតស្ស ឯវរូបេបិ នាម សាវកានំ យុគេ បរិនិព្វុតេ នត្ថិ តថាគតស្ស សោកោ វា បរិទេវោ វា តំ កុតេត្ថ ភិក្ខវេ លព្ភា ។ យន្តំ ជាតំ

១ ឱ. ម. គរូ ច ។

[៦៥] ម្នាលភិក្ខុទាំងឡាយ ព្រះដ៏មានព្រះភាគទាំងឡាយឯណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលមានហើយក្នុងអតីតកាលក្តី សាវកទាំងគូរបស់ព្រះដ៏មានព្រះភាគទាំងនោះ ក៏មានប្រមាណប៉ុណ្ណោះ ដូចជាសារីបុត្តនិងមោគ្គល្លានរបស់តថាគតដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះដ៏មានព្រះភាគទាំងឡាយឯណា ជាអរហន្តសម្មាសម្ពុទ្ធ នឹងមានក្នុងអនាគតកាលក្តី សាវកទាំងគូរបស់ព្រះដ៏មានព្រះភាគទាំងនោះ ក៏មានប្រមាណប៉ុណ្ណោះ ដូចជាសារីបុត្តនិងមោគ្គល្លានរបស់តថាគតដែរ ។

[៦៦] ម្នាលភិក្ខុទាំងឡាយ (នេះ) ជាហេតុអស្ចារ្យរបស់ពួកសាវក ម្នាលភិក្ខុទាំងឡាយ (នេះ) ជាហេតុចម្លែករបស់ពួកសាវក ព្រោះពួកសាវកជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ នឹងធ្វើតាមឱវាទរបស់តថាគតជាគ្រូហើយ នឹងបានជាទីស្រឡាញ់ផង ជាទីគាប់ចិត្តផង ជាទីគោរពផង ជាទីសរសើរផង នៃពួកបរិសទ្យទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ (នេះ) ជាហេតុអស្ចារ្យរបស់តថាគត ម្នាលភិក្ខុទាំងឡាយ (នេះ) ជាហេតុចម្លែករបស់តថាគត ព្រោះថាកាលបើសាវកទាំងគូមានសភាពដូច្នេះ បរិនិព្វានទៅហើយ សេចក្តីសោកក្តី សេចក្តីខ្សឹកខ្សួលក្តី មិនមានដល់តថាគតឡើយ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ បុគ្គលគប្បីបាននូវហេតុនោះអំពីទីណា ។ ធម្មជាតឯណាដែលកើតហើយ

៤៩

## នាឡន្ទវគ្គោ

ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតិ ។

[៦៧] សេយ្យថាបិ ភិក្ខវេ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ យេ មហន្តតរា ខន្ធា តេ បលុជ្ជេយ្យុំ ។ ឯវមេវ ខោ ភិក្ខវេ មហតោ ភិក្ខុសង្ឃស្ស តិដ្ឋតោ សារវតោ សារីបុត្តមោគ្គល្លានា បរិនិព្វុតា តំ កុតេត្ថ ភិក្ខវេ លព្ភា ។ យន្តំ ជាតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតិ ។ តស្មាតិហ ភិក្ខវេ អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។

មានហើយ បច្ច័យប្រជុំតាក់តែងហើយ ក៏គង់មានកិរិយាទ្រុឌទ្រោមទៅជាធម្មតា (នឹងឃាត់) ថា ឱហ្ន៎ ធម្មជាតនោះចូរកុំទ្រុឌទ្រោមទៅ ហេតុនេះរមែងមិនមានឡើយ ។

[៦៧] ម្នាលភិក្ខុទាំងឡាយ កាលបើដើមឈើដែលធំ ជាឈើមានខ្លឹម កំពុងឋិតនៅ ឯមែកដែលធំ ៗ នៃឈើនោះក៏បាក់បែកទៅ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុសង្ឃដ៏ធំ មានខ្លឹមឋិតនៅ សារីបុត្តនិងមោគ្គល្លាន[១] បរិនិព្វានទៅហើយ សារីបុត្តនិងមោគ្គល្លាននោះ បុគ្គលគប្បីរកបានក្នុងភិក្ខុសង្ឃនេះអំពីទីណា ក៏យ៉ាងនោះឯង ។ ធម្មជាតឯណាដែលកើតហើយ មានហើយ បច្ច័យប្រជុំតាក់តែងហើយ (នឹងឃាត់) ថា ឱហ្ន៎ ធម្មជាតនោះចូរកុំទ្រុឌទ្រោមទៅ ហេតុនេះរមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក កុំយកវត្ថុដទៃជាទីពឹងទីរឭកឡើយ ចូរយកធម៌ជាទីពឹង យកធម៌ជាទីរឭក កុំយកវត្ថុដទៃជាទីពឹងទីរឭកឡើយ ។

---

១ ភិក្ខុសង្ឃទុកដូចជាដើមព្រឹងធំ កំពស់ ១០០ យោជន៍ ព្រះសារីបុត្តនិងព្រះមហាមោគ្គល្លានទុកដូចជាមែកធំទាំងគូ ដែលបែកចេញពីដើមទៅទិសខាងត្បូង ៥០ យោជន៍ ខាងជើង ៥០ យោជន៍ (អដ្ឋកថា) ។

[៦៨] កថញ្ច ភិក្ខវេ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។

[៦៨] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយកវត្ថុដទៃជាទីពឹងទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយកវត្ថុដទៃជាទីពឹងទីរឭក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយកវត្ថុដទៃជាទីពឹងទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយកវត្ថុដទៃជាទីពឹងទីរឭក យ៉ាងនេះឯង ។

## នាឡន្ទវគ្គោ

[៦៩] យេ ហិ កេចិ ភិក្ខវេ ឯតរហិ វា មមច្ចយេ វា អត្តទីបា វិហរិស្សន្តិ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។ តមតគ្គេមេតេ[១] ភិក្ខវេ ភិក្ខូ ភវិស្សន្តិ យេ កេចិ សិក្ខាកាមាតិ ។

[៧០] សាវត្ថីនិទានំ ។ អថខោ អាយស្មា ពាហិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវា-ទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ពាហិយោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ តស្មាតិហ ត្វំ ពាហិយ អាទិមេវ វិសោ-ធេហិ កុសលេសុ ធម្មេសុ ។ កោ ចាទិ កុសលានំ ធម្មានំ ។ សីលញ្ច សុវិសុទ្ធំ ទិដ្ឋិ ច ឧជុកា ។

---

១ ឱ. តមតគ្គេ ភិក្ខវេ ។ ម. តមំតគ្គេមេតេ ភិក្ខវេ ។

នាឡន្ទវគ្គ

[៦៩] ម្នាលភិក្ខុទាំងឡាយ មែនពិត ពួកភិក្ខុឯណានីមួយ ក្នុងកាលឥឡូវនេះក្តី ក្នុងកាលជាអំណើះអំពីតថាគតទៅក្តី នឹងយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយកវត្ថុដទៃជាទីពឹងទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយកវត្ថុដទៃជាទីពឹងទីរឭក ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុឯណានីមួយ ជាសិក្ខាកាម (អ្នកប្រាថ្នានូវការសិក្សា) ភិក្ខុទាំងនុ៎ះ នឹងមានសេចក្តីចម្រើនដរាបដល់កាលជាទីបំផុត ។

[៧០] សាវត្ថីនិទាន ។ គ្រានោះ ព្រះពាហិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះពាហិយៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ព្រោះថាខ្ញុំព្រះអង្គបើបានស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគហើយ ជាបុគ្គលម្នាក់ឯង ចៀសចេញទៅ មិនបានប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ម្នាលពាហិយៈ ក្នុងសាសនានេះ អ្នកចូរជម្រះនូវដើមនៃកុសលធម៌សិន ។ ចុះអ្វីជាដើមនៃកុសលធម៌ ។ គឺសីលស្អាតល្អ ១ ទិដ្ឋិត្រង់ ១ ។

[៧១] យតោ ខោ[១] តេ ពាហិយ សីលញ្ច សុវិសុទ្ធំ ភវិស្សតិ ទិដ្ឋិ ច ឧជុកា តតោ ត្វំ ពាហិយ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សតិប្បដ្ឋានេ ភាវេយ្យាសិ ។ កតមេ ចត្តារោ ។ ឥធ ត្វំ ពាហិយ កាយេ កាយានុបស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យតោ ខោ ត្វំ ពាហិយ សីលំ និស្សាយ សីលេ បតិដ្ឋាយ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេស្សសិ តតោ តុយ្ហំ ពាហិយ យា រត្តិ វា ទិវសោ វា អាគមិស្សតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានីតិ ។

---

១ ឱ. ម. យតោ ចខោ ។

[៧១] ម្នាលពាហិយៈ កាលណាបើអ្នកនឹងមានសីលស្អាតល្អ មានទិដ្ឋិត្រង់ល្អហើយ ម្នាលពាហិយៈ លំដាប់អំពីនោះទៅ អ្នកគប្បីអាស្រ័យសីល តម្កល់នៅក្នុងសីល ហើយចម្រើននូវសតិប្បដ្ឋាន ៤ ចុះ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលពាហិយៈ ក្នុងសាសនានេះ អ្នកចូរពិចារណាឲ្យឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំ-ដៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ចូរពិចារណាឲ្យឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលពាហិយៈ កាលណាបើអ្នកនឹងអាស្រ័យសីល តម្កល់នៅក្នុងសីល ចម្រើននូវសតិប្បដ្ឋានទាំង ៤ នេះ យ៉ាងនេះឯង ម្នាលពាហិយៈ លំដាប់អំពីនោះទៅ យប់ក្តី ថ្ងៃក្តី នឹងមកដល់អ្នក សេចក្តីចម្រើននឹងប្រាកដក្នុងកុសលធម៌ទាំងឡាយ មិនបានសាបសូន្យឡើយ ។

៦៣

## នាឡន្ទវគ្គោ

[៧២] អថខោ អាយស្មា ពាហិយោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា ពាហិយោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ពាហិយោ អរហតំ អហោសីតិ ។

## នាឡន្ទវគ្គ

[៧២] គ្រានោះ ព្រះពាហិយៈដ៏មានអាយុត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចចេញទៅ ។ គ្រានោះ ព្រះពាហិយៈដ៏មានអាយុ ជាបុគ្គលម្នាក់ឯង ចៀសចេញចាកពួក មិនបានប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តទាំងឡាយចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ឯណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ដ៏ប្រសើរនោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះពាហិយៈដ៏មានអាយុ ក៏ជាព្រះអរហន្ត ១ អង្គដែរ ។

[៧៣] សាវត្ថីនិទានំ ។ អថខោ អាយស្មា ឧត្តិយោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧត្តិយោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ តស្មាតិហ ត្វំ ឧត្តិយ អាទិមេវ វិសោធេហិ កុសលេសុ ធម្មេសុ ។ កោ ចាទិ កុសលានំ ធម្មានំ ។ សីលញ្ច សុវិសុទ្ធំ ទិដ្ឋិ ច ឧជុកា ។

[៧៤] យតោ ខោ តេ ឧត្តិយ សីលញ្ច សុវិសុទ្ធំ ភវិស្សតិ ទិដ្ឋិ ច ឧជុកា តតោ ត្វំ ឧត្តិយ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សតិបដ្ឋានេ ភាវេយ្យាសិ ។ កតមេ ចត្តារោ ។ ឥធ ត្វំ ឧត្តិយ

[៧៣] សាវត្ថីនិទាន ។ គ្រានោះ ព្រះឧត្តិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ លុះព្រះឧត្តិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងធម៌ ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ព្រោះថាខ្ញុំព្រះអង្គកាលបើបានស្តាប់ធម៌ របស់ព្រះដ៏មានព្រះភាគហើយ ជាបុគ្គលម្នាក់ឯង ចៀសចេញចាកពួក មិនបានប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានចិត្ត ស្ទុងទៅរកព្រះនិព្វាន ។ ម្នាលឧត្តិយៈ បើដូច្នោះ ក្នុងសាសនានេះ អ្នកចូរជម្រះនូវដើមនៃកុសលធម៌ទាំងឡាយសិន ។ ចុះអ្វីជាដើមនៃ កុសលធម៌ទាំងឡាយ ។ គឺសីលស្អាតល្អ ១ ទិដ្ឋិត្រង់ ១ ។

[៧៤] ម្នាលឧត្តិយៈ កាលបើអ្នកនឹងមានសីលស្អាតល្អ មាន ទិដ្ឋិត្រង់ល្អហើយ ម្នាលឧត្តិយៈ លំដាប់អំពីនោះទៅ អ្នកត្រូវអា-ស្រ័យសីល តម្កល់នៅក្នុងសីល ហើយចម្រើននូវសតិប្បដ្ឋាន ៤ ចុះ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលឧត្តិយៈ ក្នុងសាសនានេះ អ្នក

## នាឡន្ទវគ្គោ

កាយេ កាយានុបស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យតោ ខោ ត្វំ ឧត្តិយ សីលំ និស្សាយ សីលេ បតិដ្ឋាយ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យាសិ តត ត្វំ ឧត្តិយ គមិស្សសិ មច្ចុធេយ្យស្ស បារន្តិ ។

[៧៨] អថខោ អាយស្មា ឧត្តិយោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា ឧត្តិយោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិ-

ចូរពិចារណាឲ្យឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ចូរពិចារណាឲ្យឃើញនូវវេទនាក្នុងវេទនាទាំង-ឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលឧត្តិយៈ កាលណាបើអ្នកអាស្រ័យនូវសីល តម្កល់នៅក្នុងសីល ចម្រើននូវសតិប្បដ្ឋានទាំង ៤ នេះយ៉ាងនេះហើយ លំដាប់អំពីនោះទៅ អ្នកនឹងបានដល់នូវត្រើយនៃវដ្តៈដែលជាលំនៅនៃមច្ចុ ។

[៧៥] គ្រានោះ ព្រះឧត្តិយៈដ៏មានអាយុត្រេកអរីករាយ ចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចចេញទៅ ។ លំដាប់នោះ ព្រះឧត្តិយៈដ៏មានអាយុ ជាបុគ្គលម្នាក់ឯង ចៀសចេញចាកពួក មិនបានប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានចិត្តស្ទុង

៦៦



តត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ឧត្តិយោ អរ-ហតំ អហោសីតិ ។

[៧៦] សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ ស-តិប្បដ្ឋានា ភាវិតា ពហុលីកតា អរិយា និយ្យានិកា និយ្យន្តិ តក្ករស្ស សម្មាទុក្ខក្ខយាយ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុ-បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា

ទៅរកព្រះនិព្វាន កុលបុត្តទាំងឡាយចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ឯណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ដ៏ប្រសើរនោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ក៏ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះឧត្តិយៈដ៏មានអាយុជាព្រះអរហន្ត ១ អង្គដែរ ។

[៧៦] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ជាគុណជាតិប្រសើរជាទីស្រោចស្រង់ រមែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃទុក្ខដោយប្រពៃដល់អ្នកធ្វើនោះ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ តែងពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី

៦៧

## នាឡន្ទវគ្គោ

វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានា ភាវិតា ពហុលីកតា អរិយា និយ្យានិកា និយ្យន្តិ តក្ករស្ស សម្មាទុក្ខក្ខ-យាយាតិ ។

[៧៧] ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិ-សម្ពុទ្ធោ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លី-នស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ឯកាយន្វា-យំ[១] មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញា-យស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ កាយេ វា ភិក្ខុ កាយានុបស្សី វិហរេយ្យ អាតាបី សម្ប-ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-នស្សំ ។ វេទនាសុ វា ភិក្ខុ ។ ចិត្តេ វា ភិក្ខុ ។ ធម្មេសុ វា ភិក្ខុ ធម្មានុបស្សី វិហរេយ្យ អាតាបី

១ ឯកាយនោ អយន្តិបិ ។

កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំង ៤ នេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ជាគុណជាតិប្រសើរ ជាទីស្រោចស្រង់ រមែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃទុក្ខដោយប្រពៃ ដល់អ្នកធ្វើនោះ ។

[៧៧] សម័យមួយ ព្រះដ៏មានព្រះភាគបានត្រាស់ដឹងជាដំបូង ទ្រង់គង់ក្រោមដើមអជបាលនិគ្រោធ ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលប្រទេស ។ គ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងទីស្ងាត់ សម្ងំនៅតែមួយព្រះអង្គឯង ទ្រង់មានព្រះហឫទ័យត្រិះរិះកើតឡើងយ៉ាងនេះថា ផ្លូវនេះជាផ្លូវតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្អាតនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនឹងទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ដែលបុគ្គលគប្បីដឹង គឺអរិយមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ គឺភិក្ខុពិចារណាឃើញនូវកាយក្នុងកាយក្តី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ភិក្ខុ (ពិចារណាឃើញនូវវេទនា) ក្នុងវេទនាទាំងឡាយក្តី ។ ភិក្ខុ (ពិចារណាឃើញនូវចិត្ត) ក្នុងចិត្តក្តី ។ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយក្តី មានព្យាយាម

សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោ-មនស្សំ ។ ឯកាយនាយំ មគ្គោ សត្តានំ វិសុទ្ធិយា លោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិ-កិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានាតិ ។

[៧៨] អថខោ ព្រហ្មា សហម្បតិ ភគវតោ ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិ-សោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ខោ ព្រហ្មលោកេ អន្តរហិតោ ភគ-វតោ បុរតោ ចាតុរហោសិ ។ អថខោ ព្រហ្មា សហម្បតិ ឯកំសមុត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្ប-ណាមេត្វា ភគវន្តំ ឯតទវោច

ជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ផ្លូវនេះជាផ្លូវតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្អាតនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្ដីសោកនិងសេចក្ដីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ដែលបុគ្គលគប្បីដឹង គឺអរិយមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺសតិប្បដ្ឋាន ៤ ។

[៧៨] គ្រានោះ ព្រហ្មឈ្មោះសហម្បតិ ដឹងច្បាស់នូវសេចក្ដីត្រិះរិះក្នុងព្រះហឫទ័យរបស់ព្រះដ៏មានព្រះភាគដោយចិត្ត (នៃខ្លួន) ហើយក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភាគនៃព្រះដ៏មានព្រះភាគ (រហ័ស) ដូចបុរសមានកម្លាំងលានូវដៃដែលបត់ ឬបត់នូវដៃដែលលាហើយ យ៉ាងនោះឯង ។ ទើបព្រហ្មឈ្មោះសហម្បតិ ដណ្ដប់សំពត់បង់កទៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

## ៦៩

### នាឡន្ទវគ្គោ

[៧៩] ឯវមេតំ ភគវា ឯវមេតំ សុគត ឯកាយន្វា-
យំ ភន្តេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ
សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញា-
យស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ
ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ កាយេ វា
ភន្តេ ភិក្ខុ កាយានុបស្សី វិហរេយ្យ អាតាបី សម្ប-
ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។
វេទនាសុ វា ភន្តេ ភិក្ខុ ។ ចិត្តេ វា ភន្តេ ភិក្ខុ ។
ធម្មេសុ វា ភន្តេ ភិក្ខុ ធម្មានុបស្សី វិហរេយ្យ អា-

នាឡន្ទវគ្គ

[៧៩] បពិត្រព្រះដ៏មានព្រះភាគ ព្រះពុទ្ធដីកានេះ យ៉ាងនេះឯង បពិត្រព្រះសុគត ព្រះពុទ្ធដីកានេះ យ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវនេះជាផ្លូវតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីស្អាតនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវធម៌ដែលបុគ្គលគប្បីដឹង គឺអរិយមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុត្រូវពិចារណាឲ្យឃើញនូវកាយក្នុងកាយក្តី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ (ពិចារណាឃើញនូវវេទនា) ក្នុងវេទនាទាំងឡាយក្តី ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ (ពិចារណាឃើញនូវចិត្ត) ក្នុងចិត្តក្តី ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយក្តី មានព្យាយាមជាគ្រឿងដុតកម្តៅ

តាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ ។ ឯកាយនោ្វាយំ ភន្តេ មគ្គោ សត្តានំ វិសុទ្ធិយា លោកបរិទេវានំ សមតិក្កមាយ ទុក្ខទោ-មនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វា-នស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានាតិ ។

[៨០] ឥទមវោច ព្រហ្មា សហម្បតិ ឥទំ វត្វា ព្រហ្មា សហម្បតិ អថាបរំ ឯតទវោច

ឯកាយនំ ជាតិខយន្តទស្សី
មគ្គំ បជានាតិ ហិតានុកម្បី
ឯតេន មគ្គេន តរឹសុ បុព្វេ
តរិស្សន្តិ យេ ច តរន្តិ ឱឃន្តិ ។

នូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិង ទោមនស្សក្នុងលោក ។ បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវនេះជាផ្លូវតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីស្អាតនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តី សោកនិងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោមនស្ស ដើម្បី ត្រាស់ដឹងនូវធម៌ដែលបុគ្គលគប្បីដឹង គឺអរិយមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វាន គឺសតិប្បដ្ឋាន ៤ ។

[៨០] ព្រហ្មឈ្មោះសហម្បតិ បានពោលនូវពាក្យនេះ លុះ ព្រហ្មឈ្មោះសហម្បតិបានពោលនូវពាក្យនេះហើយ ក៏ពោលនូវគាថា នេះតទៅទៀតថា

អ្នកមានប្រាជ្ញា ឃើញនូវព្រះនិព្វានជាទីបំផុតនៃកិរិយាអស់
ទៅនៃជាតិ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ រមែង
ដឹងច្បាស់នូវផ្លូវតែមួយ គឺបុព្វភាគសតិប្បដ្ឋាន ជនទាំងឡាយ
ឯណាបានឆ្លងហើយក្នុងកាលមុនក្តី ឆ្លងក្នុងកាលឥឡូវនេះក្តី
នឹងឆ្លងក្នុងខាងមុខក្តី នូវអន្លង់ (មានកាមជាដើម) តាមផ្លូវ
នេះឯង ។

៧១

នាឡន្ទវគ្គោ

[៨១] ឯកំ សមយំ ភគវា សុម្ភេសុ វិហរតិ សេទកំ នាម សុម្ភានំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភូតបុព្វំ ភិក្ខវេ ចណ្ឌាលវំសិកោ ចណ្ឌាលវំសំ ឧស្សាបេត្វា មេទកថាលិកំ អន្តេវាសឹ អាមន្តេសិ ឯហិ ត្វំ សម្ម មេទកថាលិកេ ចណ្ឌា-លវំសំ អភិរុហិត្វា មម ឧបរិក្ខន្ធេ តិដ្ឋាហីតិ ។ ឯវំ អាចរិយាតិ ខោ ភិក្ខវេ មេទកថាលិកា អន្តេវាសី ចណ្ឌាលវំសិកស្ស បដិស្សុត្វា ចណ្ឌាលវំ-សំ អភិរុហិត្វា អាចរិយស្ស ឧបរិក្ខន្ធេ អដ្ឋាសិ ។

នាឡន្ទវគ្គ

[៨១] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងសេទក-និគម របស់ពួកសុម្ភជន ក្នុងសុម្ភជនបទ ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា មានបុរសជាធំក្នុងល្បែងវ៉ារ[១] ចណ្ឌាល លើកឡើងនូវវ៉ារចណ្ឌាល ហើយហៅកូនសិស្សឈ្មោះមេទកថាលិកាថា នែមេទកថាលិកាជាសំឡាញ់ អ្នកចូរមកឡើងកាន់វ៉ារចណ្ឌាល ហើយឈរនៅលើករបស់យើងចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯកូនសិស្សឈ្មោះមេទកថាលិកា ទទួលស្តាប់ពាក្យបុរសជាធំក្នុងល្បែងវ៉ារចណ្ឌាលថា អើលោកអាចារ្យ ហើយក៏ឡើងកាន់វ៉ារចណ្ឌាល ឈរលើកអាចារ្យ ។

១ វ៉ារក្នុងទីនេះ សំដៅយកវ៉ារដែលគេយកឫស្សី ១ ដើមមកដាំបញ្ឈរ ហើយឲ្យមនុស្សដែលប៉ិនប្រសប់ឡើងទៅឈររាំលើឫស្សីនោះ មិនឲ្យធ្លាក់បាន រាំរួចហើយដល់វេលានឹងចុះមកវិញក៏ចុះយកក្បាលមកក្រោម ជើងឡើងលើ ដរាបដល់មកផែនដី មិនឲ្យមានច្លស់ការបាន ។ (ល្បែងនេះជាទំនៀមរបស់អ្នកស្រុកអ្នកនគរ) ។

អថខោ ភិក្ខវេ ចណ្ឌាលវំសិកោ មេទកថាលិកំ អន្តេវាសឹ ឯតទវោច ត្វំ សម្ម មេទកថាលិកេ មមំ រក្ខ អហំ តំ រក្ខិស្សាមិ ឯវំ មយំ អញ្ញ-មញ្ញគុត្តា អញ្ញមញ្ញរក្ខិតា សិប្បានិ ចេវ ទស្សិស្សាម លាភញ្ច លច្ឆាម សោត្ថិនា ច ចណ្ឌាលវំសា ឱ-រោហិស្សាមាតិ ។

[៨២] ឯវំ វុត្តេ ភិក្ខវេ មេទកថាលិកា អន្តេវាសី ចណ្ឌាលវំសិកំ ឯតទវោច ន ខោ បនេតំ អាចរិយ ឯវំ ភវិស្សតិ ត្វំ អាចរិយ អត្តានំ រក្ខ អហំ អត្តានំ រក្ខិស្សាមិ ឯវំ មយំ អត្តគុត្តា អត្តរក្ខិតា សិប្បា-និ ចេវ ទស្សិស្សាម លាភញ្ច លច្ឆាម សោត្ថិនា ច ចណ្ឌាលវំសា ឱរោហិស្សាមាតិ ។ សោ តត្ថ ញាយោតិ ។ ភគវា ឯតទវោច យថា មេទកថាលិ-កា អន្តេវាសី អាចរិយំ អវោច ។ អត្តានំ ភិក្ខវេ រក្ខិស្សាមីតិ សតិប្បដ្ឋានំ សេវិតព្វំ បរំ រក្ខិស្សាមីតិ

ម្នាលភិក្ខុទាំងឡាយ គ្រានោះ បុរសជាធំក្នុងល្បែងវ៉ាវចណ្ឌាល ពោលទៅនឹងកូនសិស្សឈ្មោះមេទកថាលិកាដូច្នេះថា នែមេទកថាលិកាជាសំឡាញ់ អ្នកចូររក្សាយើង យើងនឹងរក្សាអ្នក កាលបើយើងទាំងពីរនាក់គ្រប់គ្រងគ្នានិងគ្នា រក្សាគ្នានិងគ្នាយ៉ាងនេះហើយ នឹងសម្តែងសិល្បៈផង នឹងបាននូវលាភផងនឹងបានចុះអំពីវ៉ាវចណ្ឌាលដោយសួស្តីផង ។

[៨២] ម្នាលភិក្ខុទាំងឡាយ កាលបើបុរសជាធំក្នុងល្បែងវ៉ាវចណ្ឌាលពោលយ៉ាងនេះហើយ ឯកូនសិស្សឈ្មោះមេទកថាលិកាក៏ពោលតបទៅនឹងបុរសជាធំក្នុងល្បែងវ៉ាវចណ្ឌាលដូច្នេះថា បពិត្រលោកអាចារ្យ ហេតុនុ៎ះមិនទំនងទេ បពិត្រលោកអាចារ្យ លោកចូររក្សាខ្លួន (លោក) ចុះ ខ្ញុំនឹងរក្សាខ្លួន (ខ្ញុំ) ដែរ កាលបើយើងទាំងពីរនាក់បានគ្រប់គ្រងខ្លួន រក្សាខ្លួនយ៉ាងនេះហើយ នឹងបានសម្តែងសិល្បៈផង នឹងបាននូវលាភផង នឹងបានចុះអំពីវ៉ាវចណ្ឌាលដោយសួស្តីផង ។ នុ៎ះជាឧបាយក្នុងការរក្សាខ្លួននោះ ។ កូនសិស្សឈ្មោះមេទកថាលិកាពោលទៅនឹងអាចារ្យយ៉ាងណា ព្រះដ៏មានព្រះភាគក៏ទ្រង់ត្រាស់នូវរឿងនុ៎ះ (យ៉ាងនោះដែរ) ។ ម្នាលភិក្ខុទាំងឡាយ (បើភិក្ខុគិត) ថា អាត្មាអញនឹងរក្សាខ្លួន ត្រូវសេពសតិប្បដ្ឋាន (បើគិត) ថា អាត្មាអញនឹងរក្សាអ្នកដទៃ

## ៧៣

### នាឡន្ទវគ្គោ

សតិប្បដ្ឋានំ សេវិតព្វំ ។ អត្តានំ ភិក្ខវេ រក្ខន្តោ បរំ រក្ខតិ បរំ រក្ខន្តោ អត្តានំ រក្ខតិ ។

[៨៣] កថញ្ច ភិក្ខវេ អត្តានំ រក្ខន្តោ បរំ រក្ខតិ ។ អាសេវនាយ ភាវនាយ ពហុលីកម្មេន ។ ឯវំ ខោ ភិក្ខវេ អត្តានំ រក្ខន្តោ បរំ រក្ខតិ ។

[៨៤] កថញ្ច ភិក្ខវេ បរំ រក្ខន្តោ អត្តានំ រក្ខតិ ។ ខន្តិយា អវិហឹសាយ មេត្តចិត្តតាយ[១] អនុទយតាយ ។ ឯវំ ខោ ភិក្ខវេ បរំ រក្ខន្តោ អត្តានំ រក្ខតិ ។

[៨៥] អត្តានំ ភិក្ខវេ រក្ខិស្សាមីតិ សតិប្បដ្ឋានំ សេវិតព្វំ បរំ រក្ខិស្សាមីតិ សតិប្បដ្ឋានំ សេវិតព្វំ ។ អត្តានំ ភិក្ខវេ រក្ខន្តោ បរំ រក្ខតិ បរំ រក្ខន្តោ អត្តានំ រក្ខតីតិ ។

---

១ ឱ. មេត្តតាយ ។

ក៏ត្រូវសេពសតិប្បដ្ឋានដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលរក្សាខ្លួន ឈ្មោះថារក្សាអ្នកដទៃ កាលរក្សាអ្នកដទៃ ឈ្មោះថារក្សាខ្លួន ។

[៨៣] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលរក្សាខ្លួន ឈ្មោះថារក្សាអ្នកដទៃ តើដូចម្ដេច ។ គឺដោយការសេព (កម្មដ្ឋាន) ដោយការចម្រើន ដោយអំពើធ្វើរឿយ ៗ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលរក្សាខ្លួន ឈ្មោះថារក្សាអ្នកដទៃ យ៉ាងនេះឯង ។

[៨៤] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលរក្សាអ្នកដទៃ ឈ្មោះថារក្សាខ្លួន តើដូចម្ដេច ។ គឺដោយអំណត់ ដោយសេចក្ដីមិនបៀតបៀន ដោយមេត្តាចិត្ត ដោយសេចក្ដីអាណិត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលរក្សាអ្នកដទៃ ឈ្មោះថារក្សាខ្លួន យ៉ាងនេះឯង ។

[៨៥] ម្នាលភិក្ខុទាំងឡាយ (បើភិក្ខុគិត) ថា អាត្មាអញនឹងរក្សាខ្លួន ត្រូវសេពសតិប្បដ្ឋាន (បើគិត) ថា អាត្មាអញនឹងរក្សាអ្នកដទៃក៏ត្រូវសេពសតិប្បដ្ឋានដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលរក្សាខ្លួន ឈ្មោះថារក្សាអ្នកដទៃ កាលរក្សាអ្នកដទៃ ឈ្មោះថារក្សាខ្លួន ។

[៨៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សុម្ភេ-
សុ វិហរតិ សេទកន្នាម សុម្ភានំ និគមោ ។ តត្រ ខោ
ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ
ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច

[៨៧] សេយ្យថាបិ ភិក្ខវេ ជនបទកល្យាណី ជ-
នបទកល្យាណីតិ ខោ ភិក្ខវេ មហាជនកាយោ សន្និ-
បតេយ្យ ។ សា ខោ បន ជនបទកល្យាណី បរមបា-
សាវិនី នច្ចេ បរមបាសាវិនី គីតេ ជនបទកល្យាណី
នច្ចតិ គាយតីតិ ខោ ភិក្ខវេ ភិយ្យោសោ មត្តាយ ម-
ហាជនកាយោ សន្និបតេយ្យ ។ អថ បុរិសោ អាគច្ឆេយ្យ
ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិ-
ក្កូលោ តមេនំ ឯវំ វទេយ្យ អយន្តេ អម្ភោ បុរិស ស-
មតិត្តិកោ តេលប្បត្តោ អន្តរេន ច មហាសមជ្ជំ អន្ត-
រេន ច ជនបទកល្យាណិយា បរិហរិតព្វោ ។ បុរិសោ
ច តេន ឧក្ខិត្តាសិកោ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិស្សតិ

[៨៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងសេទកនិគម របស់ពួកសុម្ភជន ក្នុងសុម្ភជនបទ ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

[៨៧] ម្នាលភិក្ខុទាំងឡាយ ដូចពួកមហាជនប្រជុំគ្នាដោយគិតថា នាងជនបទកល្យាណី នាងជនបទកល្យាណី (ស្រីមានលំអក្នុងជនបទៗ) ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកមហាជនប្រជុំគ្នាច្រើនក្រៃលែងដោយគិតថា នាងជនបទកល្យាណីនោះឯង មានលំនាំកិរិយាឧត្តមក្នុងការរាំ មានលំនាំកិរិយាឧត្តមក្នុងការច្រៀង នាងជនបទកល្យាណីរាំឥឡូវនេះ ច្រៀងឥឡូវនេះ ។ គ្រានោះ មានបុរសដែលចង់រស់ មិនចង់ស្លាប់ មានប្រាថ្នាសេចក្តីសុខ ខ្ពើមទុក្ខ មកដល់ហើយ ក៏និយាយទៅនឹងបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន ភាជនៈប្រេងដ៏ពេញស្មើនេះ អ្នកត្រូវរក្សាទុកក្នុងចន្លោះមហាស្រពផង ក្នុងចន្លោះនាងជនបទកល្យាណីផង ។ បុរសក៏លើកដាវឡើងដើរតាមក្រោយ ៗ នែបុរសនោះ

នាឡន្ទវគ្គោ

យត្ថេវ នំ ថោកំបិ ឆឌ្ឌេស្សសិ តត្ថេវ តេ សិរោចា-តិស្សតីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ អមុំ តេលប្បត្តំ អមនសិករិត្វា ពហិទ្ធា បមាទំ អាហរេយ្យាតិ ។ នោ ហេតំ ភន្តេ ។

[៨៨] ឧបមា ខោ ម្យាយំ ភិក្ខវេ កតា អត្ថស្ស វិញ្ញាបនាយ អយមេវេត្ថ[1] អត្ថោ ។ សមតិត្តិកោ តេ-លប្បត្តោតិ ខោ ភិក្ខវេ កាយគតាយ ឯតំ សតិយា អធិវចនំ ។

[៨៩] តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ កា-យគតាសតិ[2] ភាវិតា ភវិស្សតិ ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមា-រទ្ធាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

នាឡន្ទវគ្គោ ទុតិយោ ។

---

១ ឱ. ម. អយំ ចេវេត្ថ ។ ២ ឱ. ម. ឯត្ថន្តរេ នោ ឥតិ សទ្ទោ អត្ថិ ។

ហើយពោលថា អ្នកនឹងធ្វើឲ្យកំពប់ប្រេងសូម្បីបន្តិចត្រង់ទីណា ក្បាលអ្នកនឹងធ្លាក់ចុះត្រង់ទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះដូចម្តេច បុរសនោះមិនគួរយកចិត្តទុកដាក់នឹងប្រេងឯ-ណោះ ហើយនាំមកនូវសេចក្តីធ្វេសប្រហែសខាងក្រៅដែរឬ ។ ហេតុនោះមិនគួរធ្វេសប្រហែសទេ ព្រះអង្គ ។

[៨៨] ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះឯង តថាគតធ្វើដើម្បីពន្យល់សេចក្តី នេះឯងជាសេចក្តីក្នុងរឿងនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយឯពាក្យថា ភាជនៈប្រេងដ៏ពេញស្មើនេះ ជាឈ្មោះនៃកាយគតាសតិ ។

[៨៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះអ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា កាយគតាសតិ យើងនឹងចម្រើននឹងធ្វើរឿយ ៗ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ តម្កល់ទុករឿយ ៗ សន្សំប្រារព្ធដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ

ចប់ នាឡន្ទវគ្គ ទី ២ ។

៧៦

សុត្តន្តបិដកេ សំយុត្តនិកាយស្ស មហាវារវគ្គោ

# តស្សុទ្ទានំ

មហាបុរិសោ ផាឡុឆ្ពំ
ចុន្ទោ ចេលញ្ច ពាហិយោ
ឧត្តិយោ អរិយោ ព្រហ្មា
ឆ្វយេន សេឌកោន ចាតិ[១] ។

១ សេទកំ ជនបទេន ចាតិ ។

សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ

# ឧទ្ទាននៃនាឡន្ទវគ្គនោះគឺ

និយាយអំពីមហាបុរស ១ អំពីរឿងដែលព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងក្រុងនាឡន្ទា ១ អំពីចុន្ទសាមណេរ ១ អំពីរឿងដែលព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងនគរឧក្កចេលា ១ អំពីព្រះពាហិយៈ ១ អំពីព្រះឧត្តិយៈ ១ អំពីសតិប្បដ្ឋានជារបស់ប្រសើរ ១ អំពីសហម្បតិព្រហ្ម ១ អំពីរឿងដែលព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងសេទកនិគម មានពីរលើក ។

# សីលដ្ឋិតិវគ្គោ

[៩០] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា ច អានន្ទោ អាយស្មា ច ភទ្ទោចាដលិបុត្តេ វិហរន្តិ កុក្កុដារាមេ ។ អថខោ អាយស្មា ភទ្ទោ សាយណ្ហ-សមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ភទ្ទោ អាយស្មន្តំ អានន្ទំ ឯតទវោច

[៩១] យានិមានិ អាវុសោ អានន្ទ កុសលានិ សីលានិ វុត្តានិ ភគវតា ឥមានិ កុសលានិ សីលានិ

# សីលដ្ឋិតិវគ្គ

[៩០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះអានន្ទដ៏មានអាយុ និងព្រះភទ្ទៈដ៏មានអាយុគង់នៅក្នុងកុក្កុដារាម ជិតក្រុងបាដលិបុត្ត ។ គ្រានោះ ព្រះភទ្ទៈដ៏មានអាយុចេញចាកទីស្ងាត់ ក្នុងវេលាសាយណ្ហសម័យហើយ ក៏ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា

[៩១] ម្នាលអានន្ទដ៏មានអាយុ សីល[១] ជាកុសលទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគទ្រង់ពោលហើយ សីលជាកុសល

---

១ អដ្ឋកថា សំដៅយកចតុបារិសុទ្ធិសីល ។

កិមត្ថិយានិ វុត្តានិ ភគវតាតិ ។ សាធុ សាធុ អាវុសោ ភទ្ទ ភទ្ទកោ ខោ តេ អាវុសោ ភទ្ទ ឧម្មង្គោ[១] ភទ្ទកំ បដិភាណំ កល្យាណី បរិបុច្ឆា ។ ឯវំ ហិ ត្វំ អាវុ-សោ ភទ្ទ បុច្ឆសិ យានិមានិ អាវុសោ អានន្ទ កុ-សលានិ សីលានិ វុត្តានិ ភគវតា ឥមានិ កុស-លានិ សីលានិ កិមត្ថិយានិ វុត្តានិ ភគវតាតិ ។ ឯវមាវុសោតិ ។

[៩២] យានិមានិ អាវុសោ ភទ្ទ កុសលានិ សីលានិ វុត្តានិ ភគវតា ឥមានិ កុសលានិ សីលានិ យាវទេវ ចតុន្នំ សតិប្បដ្ឋានានំ ភាវនាយ វុត្តានិ ភគវតា ។ កតមេសំ ចតុន្នំ ។ ឥធាវុសោ ភិក្ខុ

១ ឧម្មគ្គោតិបិ្បត្ថិ ។

ទាំងនេះ តើព្រះដ៏មានព្រះភាគទ្រង់ពោលដើម្បីអ្វី ។ ព្រះអានន្ទតប ថា ម្នាលភទ្ទៈដ៏មានអាយុ ប្រពៃណាស់ហើយ ម្នាលភទ្ទៈដ៏មានអាយុ ការស្វែងរកប្រស្នារបស់អ្នកល្អណាស់ ប្រាជ្ញាក៏ល្អ ការសាកសួរក៏សម ទំនង ។ ម្នាលភទ្ទៈដ៏មានអាយុ ព្រោះអ្នកបានសួរយ៉ាងនេះថា ម្នាល អានន្ទដ៏មានអាយុ សីលជាកុសលទាំងឡាយឯណា ដែលព្រះដ៏មាន ព្រះភាគទ្រង់ពោលហើយ សីលជាកុសលទាំងនេះ ព្រះដ៏មានព្រះភាគ ទ្រង់ពោលដើម្បីអ្វី ។ ករុណា អាវុសោ ។

[៩២] ម្នាលភទ្ទៈដ៏មានអាយុ សីលជាកុសលទាំងឡាយ ឯណា ដែលព្រះដ៏មានព្រះភាគទ្រង់ពោលហើយ សីលជាកុសលទាំង នេះ ព្រះដ៏មានព្រះភាគទ្រង់ពោលកំណត់ដើម្បីចម្រើននូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ

## សីលដ្ឋិតិវគ្គោ

កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យានិមានិ អាវុសោ ភទ្ទ កុសលានិ សីលានិ វុត្តានិ ភគវតា ឥមានិ កុសលានិ សីលានិ យាវទេវ ឥមេសំ ចតុន្នំ សតិបដ្ឋានានំ ភាវនាយ វុត្តានិ ភគវតាតិ ។

[៩៣] តំយេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ភទ្ទោ អាយស្មន្តំ អានន្ទំ ឯតទវោច

សីលដ្ឋិតិវគ្គ

ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភទ្ទៈដ៏មានអាយុ សីលជាកុសលទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគទ្រង់ពោលហើយ សីលជាកុសលទាំងនេះ ព្រះដ៏មានព្រះភាគទ្រង់ពោលកំណត់ដើម្បីចម្រើននូវសតិប្បដ្ឋានទាំង ៤ នេះឯង ។

[៩៣] និទានដដែលនោះ ។ លុះព្រះភទ្ទៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា

[៩៤] កោ នុ ខោ អាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិ-តិកោ ហោតិ ។ កោ បនាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។ សាធុ សាធុ អាវុសោ ភទ្ទ ភទ្ទកោ ខោ តេ អាវុសោ ភទ្ទ ឧម្មង្គោ ភទ្ទកំ ប-ដិភាណំ កល្យាណី បរិបុច្ឆា ។ ឯវញ្ហិ ត្វំ អាវុសោ ភទ្ទ បុច្ឆសិ កោ នុ ខោ អាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតិ ។ កោ បនាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។ ឯវមាវុសោតិ ។

[៩២] ម្នាលអានន្ទដ៏មានអាយុ ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនស្ថិតនៅអស់កាលយូរបាន ។ ម្នាលអានន្ទដ៏មានអាយុ ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មស្ថិតនៅអស់កាលយូរបាន ។ ម្នាលភទ្ទៈដ៏មានអាយុ ប្រពៃណាស់ហើយ ប្រពៃណាស់ហើយ ម្នាលភទ្ទៈដ៏មានអាយុ ការស្វែងរកប្រស្នារបស់អ្នកល្អណាស់ ប្រាជ្ញាក៏ល្អ ការសាកសួរក៏សមទំនង ។ ម្នាលភទ្ទៈដ៏មានអាយុ ព្រោះអ្នកបានសួរយ៉ាងនេះថា ម្នាលអានន្ទដ៏មានអាយុ ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនស្ថិតនៅអស់កាលយូរបាន ។ ម្នាលអានន្ទដ៏មានអាយុ ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មស្ថិតនៅអស់កាលយូរបាន ។ ករុណា អាវុសោ ។

## សីលដ្ឋិតិវគ្គោ

[៩៥] ចតុន្នំ ខោ អាវុសោ សតិប្បដ្ឋានានំ អភា-
វិតត្តា អពហុលីកតត្តា តថាគតេ បរិនិព្វុតេ សទ្ធម្មោ
ន ចិរដ្ឋិតិកោ ហោតិ ។ ចតុន្នំ ច ខោ អាវុសោ សតិ-
ប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា តថាគតេ បរិនិព្វុតេ
សទ្ធម្មោ ចិរដ្ឋិតិកោ ហោតិ ។ កតមេសំ ចតុន្នំ ។
ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អា-
តាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-
ទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី
វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ ឥមេសំ ខោ អាវុសោ ចតុន្នំ
សតិប្បដ្ឋានានំ អភាវិតត្តា អពហុលីកតត្តា តថាគតេ
បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតិ ។ ឥមេសំ
ច ខោ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុ-
លីកតត្តា តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ
ហោតីតិ ។

សីលដ្ឋិតិវគ្គ

[៩៥] ម្នាលអាវុសោ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុមិនចម្រើនមិនធ្វើឲ្យរឿយៗ នូវសតិប្បដ្ឋាន ៤ ។ ម្នាលអាវុសោ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុបានចម្រើន បានធ្វើឲ្យរឿយៗ នូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលអាវុសោ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុមិនបានចម្រើន មិនបានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ នេះឯង ។ ម្នាលអាវុសោ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុបានចម្រើន បានធ្វើឲ្យរឿយៗ នូវសតិប្បដ្ឋាន ៤ នេះឯង ។

[៩៦] ឯកំ សមយំ អាយស្មា ច អានន្ទោ អាយស្មា ច ភទ្ទោ ចាដលិបុត្តេ វិហរន្តិ កុក្កុដារាមេ ។ អថខោ អាយស្មា ភទ្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ភទ្ទោ អាយស្មន្តំ អានន្ទំ ឯតទវោច

[៩៧] កោ នុ ខោ អាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន សទ្ធម្មបរិហានំ ហោតិ ។ កោ នុ ខោ អាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន សទ្ធម្មអបរិហានំ ហោតីតិ ។ សាធុ សាធុ អាវុសោ ភទ្ទ ភទ្ទកោ ខោ តេ អាវុសោ ភទ្ទ ឧម្មង្គោ ភទ្ទកំ បដិភាណំ កល្យាណី បរិបុច្ឆា ។

[៩៦] សម័យមួយ ព្រះអានន្ទដ៏មានអាយុ និងព្រះភទ្ទៈដ៏មានអាយុគង់នៅក្នុងកុក្កុដារាម ជិតក្រុងបាដលិបុត្ត ។ គ្រានោះ ព្រះភទ្ទៈ-ដ៏មានអាយុចេញចាកទីស្ងាត់ ក្នុងវេលាសាយណ្ហសម័យ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា

[៩៧] ម្នាលអានន្ទដ៏មានអាយុ ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យព្រះសទ្ធម្មសាបសូន្យ ។ ម្នាលអានន្ទដ៏មានអាយុ ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យព្រះសទ្ធម្មមិនសាបសូន្យ ។ ម្នាលភទ្ទៈដ៏មានអាយុ ប្រពៃណាស់ហើយ ម្នាលភទ្ទៈដ៏មានអាយុ ការស្វែងរកប្រស្នារបស់អ្នកល្អណាស់ ប្រាជ្ញាក៏ល្អ ការសាកសួរក៏សមទំនង

ឯវញ្ហិ ត្វំ អាវុសោ ភទ្ទ បុច្ឆសិ កោ នុ ខោ អាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន សទ្ធម្មបរិហានំ ហោតិ ។ កោ បនាវុសោ អានន្ទ ហេតុ កោ បច្ចយោ យេន សទ្ធម្មអបរិហានំ ហោតីតិ ។ ឯវមាវុសោតិ ។

[៩៨] ចតុន្នំ ខោ អាវុសោ សតិប្បដ្ឋានានំ អភាវិតត្តា អពហុលីកតត្តា សទ្ធម្មបរិហានំ ហោតិ ។ ចតុន្នំ ច ខោ អាវុសោ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា សទ្ធម្មអបរិហានំ ហោតិ ។ កតមេសំ ចតុន្នំ ។ ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ អភាវិតត្តា អពហុលីកតត្តា សទ្ធម្មបរិហានំ ហោតិ ។

ម្នាលភទ្ទៈដ៏មានអាយុ ព្រោះអ្នកបានសាកសួរយ៉ាងនេះថា ម្នាលអានន្ទដ៏មានអាយុ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យព្រះសទ្ធម្មសាបសូន្យ ។ ម្នាលអានន្ទដ៏មានអាយុ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យព្រះសទ្ធម្មមិនសាបសូន្យ ។ ករុណា អាវុសោ ។

[៩៨] ម្នាលអាវុសោ ការដែលនាំឲ្យព្រះសទ្ធម្មសាបសូន្យ ព្រោះភិក្ខុមិនបានចម្រើន មិនបានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ ។ ម្នាលអាវុសោ ការដែលនាំឲ្យព្រះសទ្ធម្មមិនសាបសូន្យ ព្រោះភិក្ខុបានចម្រើន បានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

ឥមេសំ ច ខោ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិ-
តត្តា ពហុលីកតត្តា សទ្ធម្មអបរិហានំ ហោតីតិ ។

[៩៩] សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ សតិប្បដ្ឋា-
នា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ
កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា
វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ
ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ
សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេ
ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានាតិ ។

ម្នាលអាវុសោ ការដែលនាំឲ្យព្រះសទ្ធម្មសាបសូន្យទៅ ព្រោះភិក្ខុមិនបានចម្រើន មិនបានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ នេះឯង ។ ម្នាលអាវុសោ ការដែលនាំឲ្យព្រះសទ្ធម្មមិនសាបសូន្យ ព្រោះភិក្ខុបានចម្រើន បានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ នេះឯង ។

[៩៩] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះមាន ៤ យ៉ាង ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានមាន ៤ យ៉ាងនេះឯង ។

## សីលដ្ឋិតិវគ្គោ

[១០០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច

[១០១] កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតិ ។ កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។

សីលដ្ឋិតិវគ្គ

[១០០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ មានព្រាហ្មណ៍ម្នាក់ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

[១០១] បពិត្រព្រះគោតមដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនស្ថិតនៅយូរបាន ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មស្ថិតនៅអស់កាលយូរបាន ។

[១០២] ចតុន្នំ ខោ ព្រាហ្មណា សតិប្បដ្ឋានានំ អភាវិតត្តា អពហុលីកតត្តា តថាគតេ បរិនិព្ពុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតិ ។ ចតុន្នំ ច ខោ ព្រាហ្មណា សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា តថាគតេ បរិនិព្ពុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតិ ។ កតមេសំ ចតុន្នំ ។ ឥធ ព្រាហ្មណា ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ ព្រាហ្មណា ចតុន្នំ សតិប្បដ្ឋានានំ អភា-វិតត្តា អពហុលីកតត្តា តថាគតេ បរិនិព្ពុតេ សទ្ធ-ម្មោ ន ចិរដ្ឋិតិកោ ហោតិ ។ ឥមេសំ ច ខោ ព្រាហ្មណា ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលី-កតត្តា តថាគតេ បរិនិព្ពុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។

[១០២] ម្នាលព្រាហ្មណ៍ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុមិនបានចម្រើន មិនបានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ ។ ម្នាលព្រាហ្មណ៍ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុបានចម្រើន បានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលព្រាហ្មណ៍ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មមិនស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុមិនបានចម្រើន មិនបានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ នេះឯង ។ ម្នាលព្រាហ្មណ៍ កាលបើព្រះតថាគតបរិនិព្វានទៅហើយ ព្រះសទ្ធម្មស្ថិតនៅអស់កាលយូរបាន ព្រោះភិក្ខុបានចម្រើន បានធ្វើឲ្យរឿយ ៗ នូវសតិប្បដ្ឋាន ៤ នេះឯង ។

៨៧

## សីលដ្ឋិតិវគ្គោ

[១០៣] ឯវំ វុត្តេ សោ ព្រាហ្មណោ ភគវន្តំ ឯតទ-
វោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម
។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ
បាណុបេតំ សរណង្គតន្តិ ។

[១០៤] ឯកំ សមយំ អាយស្មា ច សារីបុត្តោ
អាយស្មា ច មហាមោគ្គល្លានោ អាយស្មា ច អនុរុទ្ធោ
សាកេតេ វិហរន្តិ កណ្ដកីវនេ ។ អថខោ អាយស្មា ច
សារីបុត្តោ អាយស្មា ច មហាមោគ្គល្លានោ សាយណ្ហ-
សមយំ បដិសល្លានា វុដ្ឋិតា យេនាយស្មា អនុរុទ្ធោ
តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អនុរុទ្ធេន
សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិ-
សារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ
ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច

សីលដ្ឋិតិវគ្គ

[១០៣] កាលបើព្រះដ៏មានព្រះភាគទ្រង់ពោលយ៉ាងនេះហើយ ព្រាហ្មណ៍នោះក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើនចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

[១០៤] សម័យមួយ ព្រះសារីបុត្តដ៏មានអាយុ ព្រះមហាមោគ្គល្លានដ៏មានអាយុ និងព្រះអនុរុទ្ធដ៏មានអាយុ គង់នៅក្នុងវត្តកណ្ដកីវន ជិតក្រុងសាកេត ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ និងព្រះមហាមោគ្គល្លានដ៏មានអាយុចេញចាកទីស្ងាត់ ក្នុងវេលាសាយណ្ហសម័យចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះអនុរុទ្ធដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា

[១០៥] សេក្ខោ សេក្ខោតិ[១] អាវុសោ អនុរុទ្ធ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ សេក្ខោ ហោតីតិ ។ ចតុន្នំ ខោ អាវុសោ សតិប្បដ្ឋានានំ បទេសំ ភាវិតត្តា សេក្ខោ ហោតិ ។ កតមេសំ ចតុន្នំ ។ ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ បទេសំ ភាវិតត្តា សេក្ខោ ហោតីតិ ។

១ សេខោ សេខោតិប្បត្តិ ។

[១០៥] ម្នាលអាវុសោអនុរុទ្ធ គេតែងពោលថា សេក្ខៈ សេក្ខៈ ដូច្នេះ ម្នាលអាវុសោ ចុះសេក្ខៈ តើដូចម្តេច ។ ព្រះអនុរុទ្ធឆ្លើយថា ម្នាលអាវុសោ បុគ្គលដែលឈ្មោះថាសេក្ខៈ ព្រោះបានចម្រើននូវចំណែក[១] នៃសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលអាវុសោ បុគ្គលដែលឈ្មោះថាសេក្ខៈ ព្រោះបានចម្រើននូវចំណែកនៃសតិប្បដ្ឋាន ៤ នេះឯង ។

---

១ សតិប្បដ្ឋានដែលភិក្ខុចម្រើនបានសម្រេចត្រឹមមគ្គ ៤ ផល ៣ ហៅថា ចំណែក (បទេសភាវនា) អដ្ឋកថា ។

សីលដ្ឋិតិវគ្គោ

[១០៦] តំយេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច

[១០៧] អសេក្ខោ អសេក្ខោតិ អាវុសោ អនុរុទ្ធ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ អសេក្ខោ ហោតីតិ ។ ចតុន្នំ ខោ អាវុសោ សតិប្បដ្ឋានានំ សមត្តំ ភាវិតត្តា អសេក្ខោ ហោតិ ។ កតមេសំ ចតុន្នំ ។ ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ សមត្តំ ភាវិតត្តា អសេក្ខោ ហោតីតិ ។

## សីលដ្ឋិតិវគ្គ

[១០៦] និទានដដែលនោះឯង ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា

[១០៧] ម្នាលអាវុសោអនុរុទ្ធ គេតែងពោលថា អសេក្ខៈ អសេក្ខៈ ដូច្នេះ ម្នាលអាវុសោ ចុះអសេក្ខៈ តើដូចម្តេច ។ ម្នាលអាវុសោ បុគ្គលដែលឈ្មោះថាអសេក្ខៈ ព្រោះបានចម្រើននូវសេចក្តីសម្រេច[១] នៃសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំង-ឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ម្នាលអាវុសោ បុគ្គលដែលឈ្មោះថាអសេក្ខៈ ព្រោះបានចម្រើននូវសេចក្តីសម្រេចនៃសតិប្បដ្ឋាន ៤ នេះឯង ។

---

១ សតិប្បដ្ឋានដែលភិក្ខុចម្រើនបានសម្រេចដល់អរហន្តផល ហៅថា ចម្រើននូវសេចក្តីសម្រេច ។ (សមត្តាភាវនា) អដ្ឋកថា ។

[១០៨] តំយេវ និទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច

[១០៩] កតមេសំ អាយស្មា អនុរុទ្ធោ ធម្មានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោតិ ។ ចតុន្នំ អាវុសោ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ កតមេសំ ចតុន្នំ ។ ឥធាហំ អាវុសោ កាយេ កាយានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខ្វាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ ឥមេសំ ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា សហស្សំ លោកំ អភិជានាមីតិ ។

[១០៨] និទានដដែលនោះទៀត ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា

[១០៩] ចុះអនុរុទ្ធដ៏មានអាយុ បានដល់នូវភាវៈនៃខ្លួនជាអ្នកមានអភិញ្ញាដ៏ធំ តើព្រោះបានចម្រើន បានធ្វើរឿយ ៗ នូវធម៌ដូចម្តេច ។ ម្នាលអាវុសោ ខ្ញុំបានដល់នូវភាវៈនៃខ្លួនជាអ្នកមានអភិញ្ញាដ៏ធំ ព្រោះបានចម្រើន បានធ្វើរឿយ ៗ នូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ក្នុងសាសនានេះ ខ្ញុំបានពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ខ្ញុំបានពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលអាវុសោ ខ្ញុំបានដល់នូវភាវៈនៃខ្លួនជាបុគ្គលមានអភិញ្ញាដ៏ធំ ព្រោះបានចម្រើន បានធ្វើរឿយ ៗ នូវសតិប្បដ្ឋាន ៤ នេះឯង ។ ម្នាលអាវុសោ មួយទៀត ខ្ញុំបានដឹងច្បាស់នូវលោកដ៏ច្រើន ព្រោះបានចម្រើន បានធ្វើរឿយៗ នូវសតិប្បដ្ឋាន ៤ នេះដែរ ។

៩១

# សីលដ្ឋិតិវគ្គោ

[១១០] ឯកំ សមយំ អាយស្មា អានន្ទោ រាជគ-ហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន សិរិវឌ្ឍោ គហបតិ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ សិរិវឌ្ឍោ គហបតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្ក-មិត្វា មម វចនេន អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទ សិរិវឌ្ឍោ ភន្តេ គហបតិ អាពាធិ-កោ ទុក្ខិតោ ពាឡ្ហគិលានោ សោ អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេហិ សាធុ កិរ ភន្តេ អាយស្មា អានន្ទោ យេន សិរិ-វឌ្ឍស្ស គហបតិស្ស និវេសនំ តេនុបសង្កមតុ អនុ-កម្បំ ឧបាទាយាតិ ។ ឯវំ ភន្តេតិ ខោ សោ បុរិសោ សិរិវឌ្ឍស្ស គហបតិស្ស បដិស្សុត្វា យេនាយស្មា អា-នន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ អានន្ទំ ឯតទវោច

## សីលដ្ឋិតិវគ្គ

[១១០] សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងវត្តវេ-ឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង សិរិវឌ្ឍគហបតីមានអាពាធដល់នូវសេចក្តីទុក្ខឈឺធ្ងន់ ។ គ្រានោះ សិរិវឌ្ឍគហបតី ហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន ចូរអ្នកចូលទៅរកព្រះអានន្ទដ៏មានអាយុលុះចូលទៅដល់ហើយអ្នកចូរក្រាបថ្វាយបង្គំព្រះបាទានៃព្រះអានន្ទដ៏មានអាយុ ដោយសិរសា តាមពាក្យរបស់យើងថា បពិត្រលោកម្ចាស់ដ៏ចម្រើន សិរិវឌ្ឍគហបតី មានអាពាធដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ គាត់សូមក្រាបថ្វាយបង្គំព្រះបាទានៃព្រះអានន្ទដ៏មានអាយុ ដោយសិរសា រួចហើយអ្នកចូរពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមមេត្តាប្រោស សូមព្រះអានន្ទដ៏មានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះចូលទៅកាន់លំនៅនៃសិរិវឌ្ឍគហបតី ។ បុរសនោះទទួលស្តាប់ពាក្យសិរិវឌ្ឍគហបតីថា បាទលោក ហើយក៏ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះបុរសនោះអង្គុយក្នុងទីសមគួរហើយទើបទូលព្រះអានន្ទដ៏មានអាយុដូច្នេះថា

សិរីវឌ្ឍោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហ-
គិលានោ សោ អាយស្មតោ អានន្ទស្ស បាទេ សិរសា
វន្ទតិ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ អាយស្មា អានន្ទោ
យេន សិរីវឌ្ឍស្ស គហបតិស្ស និវេសនំ តេនុបសង្ក-
មតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ
អាយស្មា អានន្ទោ តុណ្ហីភាវេន ។

[១១១] អថខោ អាយស្មា អានន្ទោ បុព្វណ្ហ-
សមយំ និវាសេត្វា បត្តចីវរមាទាយ យេន សិរីវឌ្ឍស្ស
គហបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា
បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ អាយស្មា
អានន្ទោ សិរីវឌ្ឍំ គហបតឹ ឯតទវោច

បពិត្រលោកម្ចាស់ដ៏ចម្រើន សិរិវឌ្ឍគហបតី មានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ គាត់សូមក្រាបថ្វាយបង្គំព្រះបាទានៃព្រះអានន្ទដ៏មានអាយុ ដោយសិរសា ហើយនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមមេត្តាប្រោស សូមព្រះអានន្ទដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ ចូលទៅកាន់លំនៅនៃសិរិវឌ្ឍគហបតី ។ ព្រះអានន្ទដ៏មានអាយុក៏ទទួលនិមន្តដោយតុណ្ហីភាព ។

[១១១] គ្រានោះ ព្រះអានន្ទដ៏មានអាយុស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ចូលទៅកាន់លំនៅនៃសិរិវឌ្ឍគហបតី លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយហើយ ក៏ពោលទៅនឹងសិរិវឌ្ឍគហបតីដូច្នេះថា

៩៣

## សីលដ្ឋិតិវគ្គោ

[១១២] កច្ចិ តេ គហបតិ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[១១៣] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ កាយេ កាយានុបស្សី វិហរិស្សាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរិស្សាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វន្តិ ។

សីលដ្ឋិតិវគ្គ

[១១២] ម្នាលគហបតី អ្នកល្មមអត់ទ្រាំបានដែរឬ អ្នកល្មមប្រព្រឹត្តទៅបានស្រួលដែរឬ ទុក្ខវេទនារមែងធូរថយទៅ មិនចម្រើនឡើងការថយទៅ (នៃទុក្ខវេទនា) រមែងប្រាកដ ការចម្រើនឡើងមិនប្រាកដទេឬ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនល្មមអត់ទ្រាំបានទេ មិនល្មមប្រព្រឹត្តទៅបានស្រួលទេ ទុក្ខវេទនារបស់ខ្ញុំករុណាខ្លាំងពេកណាស់ រមែងចម្រើនឡើង មិនបានធូរថយទេ ការចម្រើនឡើងរមែងប្រាកដ ឯការធូរថយទៅមិនប្រាកដទេ ។

[១១៣] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ អាត្មាអញនឹងពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលគហបតី អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។

[១១៤] យេមេ ភន្តេ ភគវតា ចត្តារោ សតិប្បដ្ឋានា ទេសិតា សំវិជ្ជន្តិ តេ ធម្មា មយិ អហំ ច តេសុ ធម្មេសុ សន្ទិស្សាមិ ។ អហញ្ហិ ភន្តេ កាយេ កាយានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[១១៥] យានិ ចិមានិ ភន្តេ ភគវតា បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ទេសិតានិ នាហំ ភន្តេ[១] យំ កិញ្ចិ អត្តនិ អប្បហីនំ សមនុបស្សាមីតិ ។ លាភា តេ គហបតិ សុលទ្ធំ តេ គហបតិ អនាគាមិផលន្តយា គហបតិ ព្យាកតន្តិ ។

---

១ ឱ. នាហំ តេសំ ។

[១១៤] បពិត្រលោកម្ចាស់ដ៏ចម្រើន សតិប្បដ្ឋាន ៤ ឯណា ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ធម៌ទាំងនោះ មានព្រមក្នុងសន្តានខ្ញុំករុណា ៗ នឹងប្រាកដក្នុងធម៌ទាំងនោះឯង ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះខ្ញុំករុណាពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

[១១៥] បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកសញ្ញោជនៈ ៥ ជាចំណែកខាងក្រោម ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនឃើញច្បាស់នូវសញ្ញោជនៈឯណានីមួយ ដែលខ្ញុំករុណាមិនទាន់លះបង់ ក្នុងខ្លួនសោះឡើយ ។ ម្នាលគហបតី ជាលាភរបស់អ្នកហើយ ម្នាលគហបតី ភាពជាមនុស្ស អ្នកបានល្អហើយ ម្នាលគហបតី អ្នកបានព្យាករនូវអនាគាមិផលហើយ ។

## សីលដ្ឋិតិវគ្គោ

[១១៦] តំយេវ និទានំ ។ តេន ខោ បន សម- យេន មានទិន្នោ គហបតិ អាពាធិកោ ហោតិ ទុក្ខិ- តោ ពាឡ្ហគិលានោ ។ អថខោ មានទិន្នោ គហបតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស ។ បេ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[១១៧] ឯវរូបាយ ចាហំ ភន្តេ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ កាយេ កាយានុបស្សី វិហរាមិ អា- តាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា- ទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

សីលដ្ឋិតិវគ្គ

[១១៦] និទានដដែលនោះទៀត ។ សម័យនោះឯង មាន-ទិន្នគហបតី មានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ ។ គ្រានោះ មានទិន្នគហបតី ហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន អ្នកចូរមកនេះ ។ បេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនល្មមអត់ទ្រាំបានទេ មិនល្មមប្រព្រឹត្តទៅបានស្រួលទេ ទុក្ខវេទនារបស់ខ្ញុំករុណាធ្ងន់ពេកណាស់ រមែងចម្រើនឡើង មិនធូរថយទៅទេ ការចម្រើនឡើងរមែងប្រាកដ ឯការធូរថយទៅ មិនប្រាកដទេ ។

[១១៧] បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាត្រូវទុក្ខវេទនាមានសភាពដូច្នេះប៉ះពាល់ហើយ ក៏ពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

[១១៨] យានិ ចិមានិ ភន្តេ ភគវតា បញ្ចោ-រម្ភាគិយានិ សញ្ញោជនានិ ទេសិតានិ នាហំ ភន្តេ យំ កិញ្ចិ អត្តនិ អប្បហីនំ សមនុបស្សាមីតិ ។ លាភា តេ គហបតិ សុលទ្ធន្តេ គហបតិ អនាគាមិផលំ តយា គហបតិ ព្យាកតន្តិ ។

សីលដ្ឋិតិវគ្គោ តតិយោ ។

តស្សុទ្ទានំ

សីលំ ឋិតិ បរិហានំ
សុទ្ធកំ ព្រាហ្មណោន ច
បទេសំ សមត្តំ លោកោ ច
សិរិវឌ្ឍោ មានទិន្នេន តេ ទសាតិ ។

[១១៨] បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកសញ្ញោជនៈ ៥ ជាចំណែកខាងក្រោម ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនឃើញច្បាស់នូវសញ្ញោជនៈឯណានីមួយ ដែលខ្ញុំករុណាមិនទាន់លះបង់ ក្នុងខ្លួនសោះឡើយ ។ ម្នាលគហបតី ជាលាភរបស់អ្នកហើយ ម្នាលគហបតី ភាពជាមនុស្ស អ្នកបានល្អហើយ ម្នាលគហបតី អ្នកបានព្យាករនូវអនាគាមិផលហើយ ។

ចប់ សីលដ្ឋិតិវគ្គ ទី ៣ ។

# ឧទ្ទាននៃសីលដ្ឋិតិវគ្គនោះគឺ

និយាយអំពីសីល ១ អំពីការស្ថិតនៅនៃព្រះសទ្ធម្ម ១ អំពីសេចក្តីសាបសូន្យនៃព្រះសទ្ធម្ម ១ អំពីសតិប្បដ្ឋានសុទ្ធ ១ អំពីព្រាហ្មណ៍ម្នាក់ចូលទៅទូលសួរព្រះដ៏មានព្រះភាគ ១ អំពីបទេសភាវនា ១ អំពីសមត្តាភាវនា ១ អំពីព្រះអនុរុទ្ធដឹងច្បាស់នូវលោក ១ អំពីសិរិវឌ្ឍគហបតី ១ អំពីមានទិន្នគហបតី ១ រួមជា ១០ ។

# អននុស្សុតវគ្គោ

[១១៩] សាវត្ថីនិទានំ ។ អយំ កាយេ កាយានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សា ខោ បនាយំ កាយេ កាយានុបស្សនា ភាវេតព្វាតិ មេ ភិក្ខវេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

# អននុស្សុតវគ្គ

[១១៩] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា នេះជាការពិចារណាឃើញនូវកាយក្នុងកាយ ។ ម្នាលភិក្ខុទាំង-ឡាយ (ចក្ខុជាដើមក៏កើតឡើង) ដល់តថាគតថា ការពិចារណាឃើញនូវកាយក្នុងកាយ នោះឯងជាធម៌ដែលត្រូវចម្រើន ។ ម្នាលភិក្ខុទាំង-ឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា (ការពិចារណាឃើញនូវកាយក្នុងកាយ) តថាគតបានចម្រើនហើយ ។

[១២០] អយំ វេទនាសុ វេទនានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទ-ចាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សា ខោ បនាយំ វេទនាសុ វេទនានុបស្សនា ភាវេតព្វាតិ មេ ភិក្ខវេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

[១២១] អយំ ចិត្តេ ចិត្តានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សា ខោ បនាយំ ចិត្តេ ចិត្តានុបស្សនា

[១២០] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា នេះជាការពិចារណាឃើញនូវវេទនាក្នុងវេទនា ។ ម្នាលភិក្ខុទាំងឡាយ (ចក្ខុជាដើម ក៏កើតឡើង) ដល់តថាគតថា ការពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នោះឯងជាធម៌ដែលត្រូវចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគត ក្នុងធម៌ដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា ការពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ តថាគតបានចម្រើនហើយ ។

[១២១] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា នេះជាការពិចារណាឃើញនូវចិត្តក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ (ចក្ខុជាដើមក៏កើតឡើង) ដល់តថាគតថា ការពិចារណាឃើញនូវចិត្តក្នុងចិត្ត នោះឯង

៩៩

អននុស្សុតវគ្គោ

ភាវេតព្វាតិ មេ ភិក្ខវេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទ-បាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

[១២២] អយំ ធម្មេសុ ធម្មានុបស្សនាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សា ខោ បនាយំ ធម្មេសុ ធម្មានុបស្សនា ភាវេតព្វាតិ មេ ភិក្ខវេ ។ ភាវិតាតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧ-ទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ ។

ជាធម៌ដែលត្រូវចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគតក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា ការពិចារណាឃើញនូវចិត្តក្នុងចិត្ត តថាគតបានចម្រើនហើយ ។

[១៦២] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា នេះជាការពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ (ចក្ខុជាដើមក៏កើតឡើង) ដល់តថាគតថា ការពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ នោះឯងជាធម៌ដែលត្រូវចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង ញាណកើតឡើង បញ្ញាកើតឡើង វិជ្ជាកើតឡើង ពន្លឺក៏កើតឡើង ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់ស្តាប់ហើយក្នុងកាលមុនថា ការពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ តថាគតបានចម្រើនហើយ ។

[១២៣] សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ សតិប្បដ្ឋានា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ។

[១២៣] *សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះដែលបុគ្គលបានចម្រើន បានធ្វើរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែម្យ៉ាង ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេសមានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះឯង ដែលបុគ្គលបានចម្រើន បានធ្វើរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែម្យ៉ាង ។*

១០១

អននុស្សុតវគ្គោ

[១២៤] យេសំ កេសញ្ចិ ភិក្ខវេ ចត្តារោ សតិ-
ប្បដ្ឋានា វិរទ្ធា វិរទ្ធោ តេសំ អរិយោ អដ្ឋង្គិកោ មគ្គោ
សម្មាទុក្ខក្ខយគាមី ។ យេសំ កេសញ្ចិ ភិក្ខវេ ចត្តារោ
សតិប្បដ្ឋានា អារទ្ធា អារទ្ធោ តេសំ អរិយោ អដ្ឋង្គិ-
កោ មគ្គោ សម្មាទុក្ខក្ខយគាមី ។ កតមេ ចត្តារោ ។
ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ
អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អ-
ភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុ-
បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ
លោកេ អភិជ្ឈាទោមនស្សំ ។ យេសំ កេសញ្ចិ ភិក្ខ-
វេ ឥមេ ចត្តារោ សតិប្បដ្ឋានា វិរទ្ធា វិរទ្ធោ តេសំ
អរិយោ អដ្ឋង្គិកោ មគ្គោ សម្មាទុក្ខក្ខយគាមី ។

អននុស្សុតវគ្គ

[១២៤] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ដែលបុគ្គលឯណានីមួយខ្វល់ខ្វាយហើយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ជាទីទៅកាន់ព្រះនិព្វាន ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ក៏ឈ្មោះថាបុគ្គលទាំងនោះបានខ្វល់ខ្វាយហើយដែរ ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ដែលបុគ្គលឯណានីមួយប្រារព្ធហើយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ជាទីទៅកាន់ព្រះនិព្វានជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ដ៏ឈ្មោះថាបុគ្គលទាំងនោះបានប្រារព្ធហើយដែរ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះឯង ដែលបុគ្គលឯណានីមួយខ្វល់ខ្វាយហើយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ជាទីទៅកាន់ព្រះនិព្វានជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ក៏ឈ្មោះថាបុគ្គលទាំងនោះបានខ្វល់ខ្វាយហើយដែរ ។

យេសំ កេសញ្ចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានា អារទ្ធា អារទ្ធោ តេសំ អរិយោ អដ្ឋង្គិកោ មគ្គោ សម្មា-ទុក្ខក្ខយគាមីតិ ។

[១២៥] សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ ស-តិប្បដ្ឋានា ភាវិតា ពហុលីកតា អចារា ចារំ គមនាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនា-សុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្ប-ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានា ភាវិតា ពហុ-លីកតា អចារា ចារំ គមនាយ សំវត្តន្តីតិ ។

ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះឯង ដែលបុគ្គលឯណានីមួយប្រារព្ធហើយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ជាទីទៅកាន់ព្រះនិព្វានជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃ ក៏ឈ្មោះថាបុគ្គលទាំងនោះបានប្រារព្ធហើយដែរ ។

[១២៥] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះដែលបុគ្គលបានចម្រើន បានធ្វើរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅព្រមដើម្បីឆ្លងចាកវដ្តៈដែលមិនមែនជាត្រើយ ហើយដល់នូវព្រះនិព្វានដែលជាត្រើយ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាក្នុងទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះឯង ដែលបុគ្គលបានចម្រើន បានធ្វើរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅព្រមដើម្បីឆ្លងចាកវដ្តៈដែលមិនមែនជាត្រើយ ហើយដល់នូវព្រះនិព្វានដែលជាត្រើយ ។

## អននុស្សុតវគ្គោ

[១២៦] សាវត្ថីនិទានំ ។ សតោ ភិក្ខវេ ភិក្ខុ វិហ-
រេយ្យ សម្បជានោ អយំ វោ អម្ហាកំ អនុសាសនី ។
កថញ្ច ភិក្ខវេ ភិក្ខុ សតោ ហោតិ ។ ឥធ ភិក្ខវេ
ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្ប-
ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-
នស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ
អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អ-
ភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សតោ
ហោតិ ។

[១២៧] កថញ្ច ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។
ឥធ ភិក្ខវេ ភិក្ខុនោ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា
ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ វិទិតា វិតក្កា
ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។
វិទិតា បញ្ញា[១] ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា

---

១ ឱ. សញ្ញា ។

អននុស្សុតវគ្គ

[១២៦] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានស្មារ-តី មានសេចក្តីដឹងខ្លួន នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានស្មារតី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានស្មារតី យ៉ាងនេះឯង ។

[១២៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសេចក្តីដឹងខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់ថា វេទនាកើតឡើង ដឹងច្បាស់ថា វេទនាតាំងនៅ ដឹងច្បាស់ថា វេទនាដល់នូវសេចក្តីវិនាសទៅ ។ ដឹងច្បាស់ថា វិតក្កៈកើតឡើង ដឹងច្បាស់ថា វិតក្កៈតាំងនៅ ដឹងច្បាស់ថា វិតក្កដល់នូវសេចក្តីវិនាសទៅ ។ ដឹងច្បាស់ថា បញ្ញាកើតឡើង ដឹងច្បាស់ថា បញ្ញាតាំងនៅ ដឹងច្បាស់ថា

អព្ភត្ថំ គច្ឆន្តិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សម្បជានោ ហោតិ ។ សតោ ភិក្ខវេ ភិក្ខុ វិហរេយ្យ សម្បជានោ អយំ វោ អម្ហាកំ អនុសាសនីតិ ។

[១២៨] សាវត្ថីនិទានំ ។ ចត្តារោមេ ភិក្ខវេ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានា ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

បញ្ញាដល់នូវសេចក្តីវិនាសទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសេចក្តីដឹងខ្លួនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានស្មារតី មានសេចក្តីដឹងខ្លួន នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។

[១២៨] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះមាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានមាន ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះ ដែលបុគ្គលបានចម្រើន បានធ្វើរឿយ ៗ ហើយ បណ្តាផលទាំង ២ ផលណាមួយនឹងបានជាប្រាកដ គឺនឹងបានសម្រេចនូវភាពជាព្រះអរហន្តក្នុងបច្ចុប្បន្នទាន់ភ្នែក ឬបើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាពជាព្រះអនាគាមីបុគ្គល ពុំខានឡើយ ។

អននុស្សុតវគ្គោ

[១២៩] ចត្តារោមេ ភិក្ខវេ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស កាយេ កាយានុបស្សិ-នោ វិហរតោ យោ កាយស្មឹ ឆន្ទោ សោ បហិយ្យតិ ឆន្ទស្ស បហានាយ អមតំ សច្ឆិកតំ ហោតិ ។

[១៣០] វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-នស្សំ ។ តស្ស វេទនាសុ វេទនានុបស្សិនោ វិហរតោ យោ វេទនាសុ ឆន្ទោ សោ បហិយ្យតិ ឆន្ទស្ស បហា-នាយ អមតំ សច្ឆិកតំ ហោតិ ។

អននុស្សុតវគ្គ

[១២៩] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះមាន ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះពិចារណាឃើញនូវកាយក្នុងកាយ ឆន្ទៈឯណាមានក្នុងកាយ ភិក្ខុក៏បានលះបង់ឆន្ទៈនោះចេញ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះលះបង់នូវឆន្ទៈ ។

[១៣០] ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះបានពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ឆន្ទៈឯណាមានក្នុងវេទនា ភិក្ខុក៏បានលះបង់ឆន្ទៈនោះចេញ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះលះបង់នូវឆន្ទៈ ។

[១៣១] ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស ចិត្តេ ចិត្តានុបស្សិនោ វិហរតោ យោ ចិត្តស្មឹ ឆន្ទោ សោ បហិយ្យតិ ឆន្ទស្ស បហានាយ អមតំ សច្ឆិកតំ ហោតិ ។

[១៣២] ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស ធម្មេសុ ធម្មានុបស្សិនោ វិហរតោ យោ ធម្មេសុ ឆន្ទោ សោ បហិយ្យតិ ឆន្ទស្ស បហានាយ អមតំ សច្ឆិកតំ ហោតីតិ ។

[១៣៣] ចត្តារោមេ ភិក្ខវេ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស កាយេ កាយានុ-

[១៣១] ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះ ពិចារណាឃើញនូវចិត្តក្នុងចិត្ត ឆន្ទៈឯណាមានក្នុងចិត្ត ភិក្ខុក៏បានលះបង់ឆន្ទៈនោះចេញ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះលះបង់នូវឆន្ទៈ ។

[១៣២] ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ឆន្ទៈឯណាមានក្នុងធម៌ ភិក្ខុក៏បានលះបង់ឆន្ទៈនោះចេញ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះលះបង់នូវឆន្ទៈ ។

[១៣៣] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះមាន ៤ ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះពិចារណាឃើញនូវកាយ

បស្សិនោ វិហរតោ កាយោ បរិញ្ញាតោ ហោតិ កាយស្ស បរិញ្ញាតត្តា អមតំ សច្ឆិកតំ ហោតិ ។

[១៣៤] វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស វេទនាសុ វេទនានុបស្សិនោ វិហរតោ វេទនា បរិញ្ញាតា ហោតិ[១] វេទនានំ បរិញ្ញាតត្តា អមតំ សច្ឆិកតំ ហោតិ ។

[១៣៥] ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស ចិត្តេ ចិត្តានុបស្សិនោ វិហរតិ ចិត្តំ បរិញ្ញាតំ ហោតិ ចិត្តស្ស បរិញ្ញាតត្តា អមតំ សច្ឆិកតំ ហោតិ ។

---

១ ឱ. ម. ហោន្តិ ។

ក្នុងកាយ កាយឈ្មោះថាភិក្ខុនោះបានកំណត់ដឹងហើយ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះបានកំណត់ដឹងនូវកាយ ។

[១៣៤] ភិក្ខុពិចារណាឃើញនូវវេទនា ក្នុងវេទានាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះបានពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ វេទនា ឈ្មោះថាភិក្ខុនោះបានកំណត់ដឹងហើយ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះកំណត់ដឹងនូវវេទនា ។

[១៣៥] ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះបានពិចារណាឃើញនូវចិត្តក្នុងចិត្ត ចិត្ត ឈ្មោះថាភិក្ខុនោះបានកំណត់ដឹងហើយ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះបានកំណត់ដឹងនូវចិត្ត ។

[១៣៦] ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តស្ស ធម្មេសុ ធម្មានុបស្សិនោ វិហរតោ ធម្មា បរិញ្ញាតា ហោន្តិ ធម្មានំ បរិញ្ញាតត្តា អមតំ សច្ឆិកតំ ហោតីតិ ។

[១៣៧] ចតុន្នំ ភិក្ខវេ សតិប្បដ្ឋានានំ ភាវនំ ទេសិស្សាមិ តំ សុណាថ ។ កាតមា ភិក្ខវេ ចតុន្នំ សតិប្បដ្ឋានានំ ភាវនា ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អយំ ខោ ភិក្ខវេ ចតុន្នំ សតិប្បដ្ឋានានំ ភាវនាតិ ។

[១៣៦] ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ កាលបើភិក្ខុនោះបានពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ធម៌ ឈ្មោះថាភិក្ខុនោះបានកំណត់ដឹងហើយ អមតនិព្វាន ក៏ឈ្មោះថាភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះបានកំណត់ដឹងនូវធម៌ ។

[១៣៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសតិប្បដ្ឋានភាវនាទាំង ៤ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានភាវនា ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសតិប្បដ្ឋានភាវនា ៤ ។

១០៩

## អននុស្សុតវគ្គោ

[១៣៨] សតិប្បដ្ឋានញ្ច វោ ភិក្ខវេ ទេសិស្សាមិ សតិប្បដ្ឋានភាវនញ្ច សតិប្បដ្ឋានភាវនាគាមិនិញ្ច បដិបទំ តំ សុណាថ ។ កតមញ្ច ភិក្ខវេ សតិប្បដ្ឋានំ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥទំ វុច្ចតិ ភិក្ខវេ សតិប្បដ្ឋានំ ។

[១៣៩] កតមា ច ភិក្ខវេ សតិប្បដ្ឋានភាវនា ។ ឥធ ភិក្ខវេ ភិក្ខុ សមុទយធម្មានុបស្សី កាយស្មឹ វិហរតិ វយធម្មានុបស្សី កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី កាយស្មឹ វិហរតិ អាតាបី

អននុស្សុតវគ្គ

[១៣៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសតិប្បដ្ឋានផង នូវសតិប្បដ្ឋានភាវនាផង នូវបដិបទាជាដំណើរទៅកាន់សតិប្បដ្ឋានភាវនាផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា សតិប្បដ្ឋាន ។

[១៣៩] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានភាវនា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវសភាពជាទីប្រជុំកើតឡើងក្នុងកាយ ពិចារណាឃើញនូវសភាពជាទីវិនាសទៅក្នុងកាយ ពិចារណាឃើញនូវសភាពជាទីប្រជុំកើតឡើងនិងសភាពជាទីវិនាសទៅក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស

សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោ-
មនស្សំ ។ សមុទយធម្មានុបស្សី វេទនាសុ វិហរតិ
វយធម្មានុបស្សី វេទនាសុ វិហរតិ សមុទយវយធម្មា-
នុបស្សី វេទនាសុ វិហរតិ ។ តថា ចិត្តេ ។ ធម្មេសុ
វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ ។ អយំ វុច្ចតិ ភិក្ខវេ សតិប្បដ្ឋា-
នភាវនា ។

[១៨០] កតមា ច ភិក្ខវេ សតិប្បដ្ឋានភាវនាគា-
មិនី បដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។
សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា
សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ
សម្មាសមាធិ ។ អយំ វុច្ចតិ ភិក្ខវេ សតិប្បដ្ឋានភាវ-
នាគាមិនី បដិបទាតិ ។

អននុស្សុតវគ្គោ ចតុត្ថោ ។

មានសេចក្តីដឹងខ្លួន មានស្មារតី កំចាតបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញនូវសភាពជាទីប្រជុំកើតឡើងក្នុងវេទនាទាំងឡាយ ពិចារណាឃើញនូវសភាពជាទីវិនាសទៅក្នុងវេទនាទាំងឡាយ ពិចារណាឃើញនូវសភាពជាទី ប្រជុំកើតឡើងនិងសភាពជាទីវិនាសទៅក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្តក៏ដូចគ្នា ។ ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសតិប្បដ្ឋានភាវនា ។

[១៤០] ម្នាលភិក្ខុទាំងឡាយ បដិបទាជាដំណើរទៅកាន់សតិប្បដ្ឋានភាវនា តើដូចម្តេច ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ហ្នឹងឯង ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេច ។ គឺសេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ ការនិយាយត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការឭកត្រូវ ១ ការតម្កល់ចិត្តមាំត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិបទាជាដំណើរទៅកាន់សតិប្បដ្ឋានភាវនា ។

ចប់ អននុស្សុតវគ្គ ទី ៤ ។

១១១

អននុស្សុតវគ្គោ

# តស្សុទ្ទានំ

អននុស្សុតំ វិភតោ ច
វិរត្តោ ភាវនា សតោ
អញ្ញំ ឆន្ទំ បរិញ្ញាយ
ភាវនា វិភង្គេន តេ ទសាតិ ។

អននុស្សុតវគ្គ

# ឧទ្ទាននៃអននុស្សុតវគ្គនោះគឺ

និយាយអំពីធម៌ដែលមិនធ្លាប់បានស្តាប់ ១ អំពីការប្រាស ចាកតម្រេក ១ អំពីសេចក្តីខ្វល់ខ្វាយ ១ អំពីសតិប្បដ្ឋាន ដែលបុគ្គលចម្រើនហើយ ១ អំពីកិច្ចត្រូវមានស្មារតី ១ អំពី អរហត្តផល ១ អំពីការលះបង់ឆន្ទៈ ១ អំពីការកំណត់ ដឹងនូវកាយ ១ អំពីសតិប្បដ្ឋានភាវនា ១ អំពីការចែកនៃ សតិប្បដ្ឋាន ១ នោះត្រូវជា ១០ ។

# អមតវគ្គោ

[១៤១] សាវត្ថីនិទានំ ។ ចតូសុ ភិក្ខវេ សតិប្បដ្ឋា-
នេសុ សុប្បតិដ្ឋិតចិត្តា វិហរថ មា វោ អមតំ ប-
នស្ស ។ កតមេសុ ចតូសុ ។ ឥធ ភិក្ខវេ ភិក្ខុ កា-
យេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ
សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទ-
នាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី
សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-
នស្សំ ។ ឥមេសុ ភិក្ខវេ ចតូសុ សតិប្បដ្ឋានេសុ សុប្ប-
តិដ្ឋិតចិត្តា វិហរថ មា វោ អមតំ បនស្សាតិ ។

# អមតវគ្គ

[១៤១] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ទុកជាព្រះនិព្វានមិនទាន់មានដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរមានចិត្តតាំងស៊ប់ក្នុងសតិប្បដ្ឋាន ៤ ចុះ ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ ទុកជាព្រះនិព្វានមិនទាន់មានដល់អ្នកទាំង-ឡាយ អ្នកទាំងឡាយចូរមានចិត្តតាំងស៊ប់ក្នុងសតិប្បដ្ឋាន ៤ នេះចុះ ។

១១៣

## អមតវគ្គោ

[១៤២] សាវត្ថីនិទានំ ។ ចតុន្នំ ភិក្ខវេ សតិបដ្ឋានានំ សមុទយញ្ច អត្ថង្គមញ្ច ទេសិស្សាមិ តំ សុណាថ ។ កោ ច ភិក្ខវេ កាយស្ស សមុទយោ ។ អាហារសមុទយា កាយស្ស សមុទយោ អាហារនិរោធា កាយស្ស អត្ថង្គមោ ផស្សសមុទយា វេទនានំ សមុទយោ ផស្សនិរោធា វេទនានំ អត្ថង្គមោ នាមរូបសមុទយា ចិត្តស្ស សមុទយោ នាមរូបនិរោធា ចិត្តស្ស អត្ថង្គមោ មនសិការសមុទយា ធម្មានំ សមុទយោ មនសិការនិរោធា ធម្មានំ អត្ថង្គមោតិ ។

[១៤៣] សាវត្ថីនិទានំ ។ ឯកមិទាហំ ភិក្ខវេ សមយំ ឧរុវេលាយំ វិហរាមិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ តស្ស មយ្ហំ ភិក្ខវេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ។

អមតវគ្គ

[១៤២] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវសេចក្ដីកើតឡើង នឹងសូន្យទៅនៃសតិប្បដ្ឋាន ៤ អ្នកទាំងឡាយចូរស្ដាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីកើតឡើងនៃកាយដូចម្ដេច ។ សេចក្ដីកើតឡើងនៃកាយ ព្រោះកើតឡើងនៃអាហារ សេចក្ដីរលត់នៃកាយ ព្រោះរលត់នៃអាហារ សេចក្ដីកើតឡើងនៃវេទនាទាំងឡាយ ព្រោះកើតឡើងនៃផស្សៈ សេចក្ដីរលត់នៃវេទនាទាំងឡាយ ព្រោះរលត់នៃផស្សៈ សេចក្ដីកើតឡើងនៃចិត្ត ព្រោះកើតឡើងនៃនាមរូប សេចក្ដីរលត់នៃចិត្ត ព្រោះរលត់នៃនាមរូប សេចក្ដីកើតឡើងនៃធម៌ទាំងឡាយ ព្រោះកើតឡើងនៃមនសិការៈ សេចក្ដីរលត់នៃធម៌ទាំង-ឡាយ ព្រោះរលត់នៃមនសិការៈ ។

[១៤៣] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ សម័យមួយតថាគតបានត្រាស់ដឹងជាដំបូង នៅក្រោមដើមអជបាលនិគ្រោធ ក្បែរច្រាំងស្ទឹងនេរញ្ជរាក្នុងឧរុវេលាប្រទេស ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះនៅក្នុងទីដ៏ស្ងាត់ សម្ងំនៅ មានបរិវិតក្កក្នុងចិត្តកើតឡើងយ៉ាងនេះថា

[១៤៤] ឯកាយនោ្វយំ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ កាយេ វា ភិក្ខុ កាយានុបស្សី វិហរេយ្យ ។ វេទនាសុ វា ភិក្ខុ វេទនានុបស្សី វិហរេយ្យ ។ ចិត្តេ វា ភិក្ខុ ចិត្តានុបស្សី វិហរេយ្យ ។ ធម្មេសុ វា ភិក្ខុ ធម្មានុបស្សី វិហរេយ្យ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯកាយនោ្វយំ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានាតិ ។

[១៤៤] ផ្លូវគឺសតិប្បដ្ឋាន ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកនិងខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវមគ្គប្រកបដោយអង្គ ៨ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ភិក្ខុពិចារណាឃើញកាយក្នុងកាយជាប្រក្រតីក្តី ។ ភិក្ខុពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតីក្តី ។ ភិក្ខុពិចា-រណាឃើញចិត្តក្នុងចិត្តជាប្រក្រតីក្តី ។ ភិក្ខុពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានសេចក្តីព្យាយាមដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបានក្តី ។ ផ្លូវគឺសតិប្បដ្ឋាន ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវមគ្គប្រកបដោយអង្គ ៨ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

អមតវគ្គោ

[១៤៥] អថខោ ភិក្ខវេ ព្រហ្មា សហម្បតិ មម ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ មម បុរតោ បាតុរហោសិ ។ អថខោ ភិក្ខវេ ព្រហ្មា សហម្បតិ ឯកំសំ ឧត្តរាសង្គំ ករិត្វា យេនាហំ តេនញ្ជលឹ បណាមេត្វា មំ ឯតទវោច

[១៤៦] ឯវមេតំ ភគវា ឯវមេតំ សុគត ឯកាយន្វាយំ ភន្តេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ កាយេ វា ភន្តេ ភិក្ខុ កាយានុបស្សី វិហរេយ្យ ។ វេទនាសុ វា ។ ចិត្តេ វា ។ ធម្មេសុ វា ភន្តេ ភិក្ខុ ធម្មានុបស្សី វិហរេយ្យ អាតាបី សម្បជានោ សតិមា

អមតវគ្គ

[១៤៥] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សហម្បតិព្រហ្ម ដឹងនូវបរិវិតក្កៈ ក្នុងចិត្តតថាគតដោយចិត្តខ្លួនហើយ ក៏បាត់អំពីព្រហ្មលោក មកប្រាកដចំពោះមុខតថាគត ដូចជាបុរសមានកម្លាំងលាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញ ដូច្នោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ គ្រានោះឯង សហម្បតិព្រហ្ម បង់កសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះតថាគត បានពោលនឹងតថាគតដូច្នេះថា

[១៤៦] បពិត្រព្រះដ៏មានព្រះភាគ ផ្លូវគឺសតិប្បដ្ឋាន ៤ នុ៎ះ យ៉ាងនេះហើយ បពិត្រព្រះសុគត ផ្លូវគឺសតិប្បដ្ឋាន ៤ នុ៎ះ យ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវគឺសតិប្បដ្ឋាន ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវមគ្គប្រកបដោយអង្គ ៨ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ សតិ-ប្បដ្ឋាន ៤ តើដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុពិចារណាឃើញកាយក្នុងកាយជាប្រក្រតីក្តី ។ ក្នុងវេទនាទាំងឡាយក្តី ។ ក្នុងចិត្តក្តី ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី

វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯកាយន្វាយំ ភន្តេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិបដ្ឋានាតិ ។

[១៤៧] ឥទមវោច ភិក្ខវេ ព្រហ្មា សហម្បតិ ឥទំ វត្វា អថាបរំ ឯតទវោច

ឯកាយនំ ជាតិខយន្តទស្សី
មគ្គំ បជានាតិ ហិតានុកម្បី
ឯតេន មគ្គេន អតរឹសុ[១] បុព្វេ
តរិស្សន្តិ យេ ច តរន្តិ ឱឃន្តិ ។

១ ឱ. អតំសុ ។

កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបានក្តី ។ បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវគឺសតិប្បដ្ឋាន ៤នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវមគ្គប្រកបដោយអង្គ ៨ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

[១៤៧] ម្នាលភិក្ខុទាំងឡាយ សហម្បតិព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ លំដាប់នោះ បានពោលពាក្យនេះតទៅទៀតថា

បុគ្គលឃើញនូវទីបំផុតនៃការអស់ទៅនៃជាតិ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ រមែងដឹងច្បាស់នូវផ្លូវមូលតែមួយ ជនទាំងឡាយបានឆ្លងហើយក្នុងកាលមុនក្តី នឹងឆ្លង (ក្នុងអនាគត)ក្តី កំពុងឆ្លងក្នុងកាលឥឡូវនេះក្តី នូវឱឃៈបានដោយផ្លូវនុ៎ះឯង ។

អមតវគ្គោ

[១៤៨] សាវត្ថីនិទានំ ។ សតោ ភិក្ខវេ ភិក្ខុ វិហរេយ្យ អយំ វោ អម្ហាកំ អនុសាសនី ។ កថញ្ច ភិក្ខវេ ភិក្ខុ សតោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សតោ ហោតិ ។ សតោ ភិក្ខវេ ភិក្ខុ វិហរេយ្យ អយំ វោ អម្ហាកំ អនុសាសនីតិ ។

[១៤៩] កុសលរាសីតិ ភិក្ខវេ វទមានោ ចត្តារោ សតិប្បដ្ឋានេ សម្មា វទមានោ វទេយ្យ ។ កេវលោ ហាយំ ភិក្ខវេ កុសលរាសិ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី

អមតវគ្គ

[១៤៨] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីមានស្មារតី នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកមានស្មារតីដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានស្មារតីយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីមានស្មារតី នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលថា កុសល-រាសីដូច្នេះ កាលបើពោលឲ្យត្រូវ គប្បីពោលចំពោះសតិប្បដ្ឋាន ៤ ។ ម្នាលភិក្ខុទាំងឡាយ ដ្បិតថាកុសលរាសីទាំងអស់នេះ ក៏គឺសតិប្បដ្ឋាន ៤ នេះឯង ។ សតិប្បដ្ឋាន ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស

សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ កុសលរាសីតិ ភិក្ខវេ វទមានោ ឥមេ ចត្តារោ សតិប្បដ្ឋានេ សម្មា វទមានោ វទេយ្យ ។ កេវលោ ហាយំ ភិក្ខវេ កុសលរាសិ យទិទំ ចត្តារោ សតិប្បដ្ឋានាតិ ។

[១៨០] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។

ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ចេញបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលពោលថា កុសលរាសី ដូច្នេះ កាលបើពោលឲ្យត្រូវ គប្បីពោលចំពោះសតិប្បដ្ឋាន ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ ដ្បិតថាកុសលរាសីទាំងអស់នេះ ក៏គឺសតិប្បដ្ឋាន ៤ នេះឯង ។

[១៥០] គ្រានោះឯង មានភិក្ខុមួយរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ធម៌ឯណារបស់ព្រះដ៏មានព្រះភាគហើយ គប្បីជាបុគ្គលតែម្នាក់ឯង ចៀសចេញទៅ មិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សូមព្រះដ៏មានព្រះភាគសម្តែងធម៌នោះ ឲ្យទានដល់ខ្ញុំព្រះអង្គដោយសង្ខេប ។

១១៩

អមតវគ្គោ

[១៨១] តស្មាតិហ ត្វំ ភិក្ខុ អាទិមេវ វិសោធេហិ កុសលេសុ ធម្មេសុ ។ កោ ចាទិ កុសលានំ ធម្មានំ ។ ឥធ ត្វំ ភិក្ខុ ចាតិមោក្ខសំវរសំវុតោ វិហរាហិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខស្សុ សិក្ខាបទេសុ ។

[១៨២] យតោ ខោ ត្វំ ភិក្ខុ ចាតិមោក្ខសំវរសំវុតោ វិហរិស្សសិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខស្ស សិក្ខាបទេសុ តតោ ត្វំ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សតិប្បដ្ឋានេ ភាវេយ្យាសិ ។ កតមេ ចត្តារោ ។ ឥធ ត្វំ ភិក្ខុ កាយេ កាយានុបស្សី វិហរាហិ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុ-

អមតវគ្គ

[១៥១] ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរជម្រះនូវហេតុជាខាងដើមក្នុងកុសលធម៌ទាំងឡាយចុះ ។ ចុះអ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុ ក្នុងសាសនានេះ អ្នកចូរសង្រួមក្នុងបាតិមោក្ខសំវរៈ ប្រកបព្រមដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីតែបន្តិចបន្តួចសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។

[១៥២] ម្នាលភិក្ខុ កាលណាអ្នកសង្រួម ក្នុងបាតិមោក្ខសំវរៈ ប្រកបព្រមដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុ កាលណោះអ្នកគប្បីអាស្រ័យនូវសីល ស្ថិតនៅក្នុងសីល ចម្រើននូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋានទាំង ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុ ក្នុងសាសនានេះ អ្នកចូរពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ

បស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យតោ ខោ ត្វំ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេស្សសិ តតោ តុយ្ហំ ភិក្ខុ យា រត្តិ វា ទិវសោ វា អាគមិស្សតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានីតិ ។

[១៨៣] អថខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវា-ទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សោ ភិក្ខុ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិ-យោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មច-

ជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាល ភិក្ខុ កាលណាអ្នកនឹងអាស្រ័យនូវសីល នឹងស្ថិតនៅក្នុងសីល នឹងចម្រើន នូវសតិប្បដ្ឋាន ៤ យ៉ាងនេះ ម្នាលភិក្ខុ កាលណោះ សេចក្ដីចម្រើនក្នុង កុសលធម៌ទាំងឡាយ នឹងមានប្រាកដដល់អ្នកពិត ទាំងយប់ទាំងថ្ងៃ ឯសេចក្ដីសាបសូន្យមិនមានឡើយ ។

[១៥៣] គ្រានោះឯង ភិក្ខុនោះត្រេកអរអនុមោទនាភាសិតរបស់ ព្រះដ៏មានព្រះភាគ ហើយក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះ ភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លំដាប់នោះឯង ភិក្ខុនោះ តែម្នាក់ឯង ចៀសចេញទៅ មិនមានសេចក្ដីប្រមាទ មានព្យាយាមជា គ្រឿងដុតកម្ដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុល-បុត្រចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរ-ធម៌ឯណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ម្រេចនូវអនុត្តរធម៌ នោះ មានព្រហ្មចរិយៈជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មា

១២១

## អមតវគ្គោ

វិយំ កាតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

[១៩៤] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា ។ បេ ។ សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។

[១៩៥] តស្មាតិហ ត្វំ ភិក្ខុ អាទិមេវ វិសោធេហិ កុសលេសុ ធម្មេសុ ។ កោ ចាទិ កុសលានំ ធម្មានំ ។ ឥធ ត្វំ ភិក្ខុ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេស្សសិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេស្សសិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេស្សសិ ។

អញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចបានធ្វើស្រេចហើយ កិច្ចដទៃដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំង-ឡាយ ភិក្ខុនោះក៏បានជាព្រះអរហន្តមួយអង្គដែរ ។

[១៥៤] គ្រានោះឯង មានភិក្ខុមួយរូបទៀត ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគមេត្តាសម្ដែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ លុះខ្ញុំព្រះអង្គបានស្ដាប់ធម៌របស់ព្រះដ៏មានព្រះភាគហើយ គប្បីជាបុគ្គលតែម្នាក់ឯង ចៀសចេញទៅ មិនមានសេចក្ដីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។

[១៥៥] ម្នាលភិក្ខុ ហេតុដូច្នោះ អ្នកចូរជម្រះហេតុជាខាងដើមក្នុងកុសលធម៌ទាំងឡាយចុះ ។ ចុះអ្វីជាខាងដើមនៃកុសលធម៌ទាំង-ឡាយ ។ ម្នាលភិក្ខុ ក្នុងសាសនានេះ អ្នកនឹងលះបង់កាយទុច្ចរិតចេញ ចម្រើនកាយសុចរិត នឹងលះបង់វចីទុច្ចរិតចេញ ចម្រើនវចីសុចរិត នឹងលះបង់មនោទុច្ចរិតចេញ ចម្រើនមនោសុចរិត ។

[១៨៦] យតោ ខោ ត្វំ ភិក្ខុ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេស្សសិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេស្សសិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេស្សសិ តតោ ត្វំ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សតិប្បដ្ឋានេ ភាវេយ្យាសិ(១) ។ កតមេ ចត្តារោ ។ ឥធ ត្វំ ភិក្ខុ កាយេ កាយានុបស្សី វិហរាហិ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរាហិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យតោ ខោ ត្វំ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេស្សសិ តតោ តុយ្ហំ ភិក្ខុ យា រត្តិ វា ទិវសោ វា អាគមិស្សតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានីតិ ។ បេ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

---

១ ឱ. ភាវេស្សសិ ។

[១៥៦] ម្នាលភិក្ខុ កាលណាអ្នកនឹងលះបង់កាយទុច្ចរិតចេញ ចម្រើនកាយសុចរិត នឹងលះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត នឹងលះបង់មនោ-ទុច្ចរិត ចម្រើនមនោសុចរិត ម្នាលភិក្ខុ កាលណោះ អ្នកគប្បីអាស្រ័យនូវសីល ស្ថិតនៅក្នុងសីល ចម្រើនសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុ ក្នុងសាសនានេះ អ្នកចូរពិចារណាឲ្យឃើញនូវកាយក្នុងកាយជាប្រក្រតីចុះ ។ ចូរពិចារណាឲ្យឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានឹងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុ កាលណាអ្នកនឹងអាស្រ័យនូវសីល ស្ថិតនៅក្នុងសីល ចម្រើននូវសតិប្បដ្ឋាន ៤ នេះ យ៉ាងនេះ ម្នាលភិក្ខុ កាលណោះ សេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ នឹងមានប្រាកដដល់អ្នកពិត ទាំងយប់ទាំងថ្ងៃ ឯសេចក្តីសាបសូន្យឥតមានឡើយ ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះបានជាព្រះអរហន្តមួយអង្គដែរ ។

អមតវគ្គោ

[១៨៧] យេ ភិក្ខវេ អនុកម្បេយ្យាថ យេ ច[១] សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ វោ ភិក្ខវេ ចតុន្នំ សតិប្បដ្ឋានានំ ភាវនាយ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វាតិ ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យេ ភិក្ខវេ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ វោ ភិក្ខវេ ឥមេសំ ចតុន្នំ សតិប្បដ្ឋានានំ ភាវនាយ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វាតិ ។

---

១ ឱ. យេ ច ខោ ។

អមតវគ្គ

[១៥៧] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរអនុគ្រោះពួកជនឯណា មួយវិញទៀត ពួកជនឯណាដែលជាមិត្ត អមាត្យ ញាតិ ឬសាលោហិត គប្បីសម្គាល់នូវពាក្យដែលខ្លួនគួរស្តាប់ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយគួរញ៉ាំងជនទាំងនោះឲ្យសមាទាន ឲ្យសេពគប់ ឲ្យស្ថិតនៅក្នុងការចម្រើនសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរអនុគ្រោះពួកជនឯណា មួយវិញទៀត ពួកជនឯណាដែលជាមិត្ត អមាត្យ ញាតិ ឬសា-លោហិត គប្បីសម្គាល់នូវពាក្យដែលខ្លួនគួរស្តាប់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរញ៉ាំងជនទាំងនោះឲ្យសមាទាន ឲ្យសេពគប់ ឲ្យស្ថិតនៅក្នុងការចម្រើនសតិប្បដ្ឋាន ៤ នេះ ។

[១៤៨] តិស្សោ ឥមា ភិក្ខវេ វេទនា ។ កតមា តិស្សោ ។ សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ ឥមា ខោ ភិក្ខវេ តិស្សោ វេទនា ។

[១៤៩] ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ វេទនានំ បរិញ្ញាយ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុ-បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ វេទនានំ បរិញ្ញាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

[១៥៨] ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ ប្រការ ។ វេទនា ៣ ប្រការគឺអ្វីខ្លះ ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខ-វេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ វេទនា៣ មានប្រការដូច្នេះឯង ។

[១៥៩] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ភិក្ខុគប្បីចម្រើន ដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ នេះឯង ។ សតិប្បដ្ឋាន ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះភិក្ខុគប្បីចម្រើន ដើម្បីកំណត់ដឹងនូវវេទនាទាំង ៣ នេះឯង ។

## អមតវគ្គោ

[១៦០] តយោមេ ភិក្ខវេ អាសវា ។ កតមេ តយោ ។ កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ ឥមេ ខោ ភិក្ខវេ តយោ អាសវា ។

[១៦១] ឥមេសំ ខោ ភិក្ខវេ តិណ្ណន្នំ អាសវានំ បហានាយ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណន្នំ អាសវានំ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។

អមតវគ្គោ បញ្ចមោ ។

អមតវគ្គ

[១៦០] ម្នាលភិក្ខុទាំងឡាយ អាសវៈនេះមាន ៣ ប្រការ ។ អាសវៈ ៣ ប្រការដូចម្ដេចខ្លះ ។ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈ ៣ មានប្រការដូច្នេះឯង ។

[១៦១] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ភិក្ខុគប្បីចម្រើនដើម្បីលះបង់អាសវៈទាំង ៣ នេះឯង ។ សតិប្បដ្ឋាន ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះ ភិក្ខុគប្បីចម្រើនដើម្បីលះបង់នូវអាសវៈទាំង ៣ នេះឯង

ចប់ អមតវគ្គ ទី ៥ ។

១២៦



# តត្រុទ្ទានំ

អមតំ   សមុទយោ   មគ្គោ
សតោ   កុសលរាសិ[១]   ច
ចាដិមោក្ខំ   ទុច្ចរិតំ   មិត្តា
វេទនា   អាសវេន   ចាតិ   ។

១   ឱ.   ម.   កុសលរាសិយា   ។

សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ

# ឧទ្ទានក្នុងអមតវគ្គនោះគឺ

*ពោលអំពីអមតនិព្វាន ១ អំពីសេចក្តីកើតឡើងនៃសតិប្បដ្ឋាន ១ អំពីផ្លូវប្រព្រឹត្តទៅដើម្បីបរិសុទ្ធ ១ អំពីភិក្ខុមានស្មារតី ១ អំពីកុសលរាសី ១ អំពីការសង្រួមក្នុងបាដិមោក្ខសំវរៈ ១ អំពីការលះបង់ទុច្ចរិត ១ អំពីពួកជនមានមិត្តអមាត្យជាដើម ១ អំពីវេទនា ៣ ប្រការ ១ អំពីអាសវៈ ៣ ប្រការ ១ ។*

---

# សតិប្បដ្ឋានសំយុត្តស្ស គង្គាទិបេយ្យាលោ

[១៦២] សេយ្យថាបិ ភិក្ខវេ គង្គា នទី ចាចីននិន្នា ចាចីនចោណា ចាចីនបព្ភារា ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ចត្តារោ សតិប្បដ្ឋានេ ភាវេន្តោ ចត្តារោ សតិប្បដ្ឋានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានចោណោ និព្វានបព្ភារោ ។

[១៦៣] កថញ្ច ភិក្ខវេ ភិក្ខុ ចត្តារោ សតិប្បដ្ឋានេ ភាវេន្តោ ចត្តារោ សតិប្បដ្ឋានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានចោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុ-

# សតិប្បដ្ឋានសំយុត្ត គង្គាទិបេយ្យាល

[១៦២] ម្នាលភិក្ខុទាំងឡាយ ដូចជាទន្លេគង្គាហូរទៅក្នុងទិសខាងកើត ទេរទៅក្នុងទិសខាងកើត ឈមទៅក្នុងទិសខាងកើត យ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើនសតិប្បដ្ឋាន ៤ កាលធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ រមែងឱនទៅរកព្រះនិព្វាន សសៀរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនោះឯង ។

[១៦៣] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចម្រើនសតិប្បដ្ឋាន ៤ កាលធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ រមែងជាអ្នកឱនទៅរកព្រះនិព្វាន សសៀរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ពិចា-រណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌

បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ចត្តារោ សតិប្បដ្ឋានេ ភាវេន្តោ ចត្តារោ សតិប្បដ្ឋានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានចោណោ និព្វានបព្ភារោតិ ។ បេ ។

[១៦៤] បញ្ចិមានិ ភិក្ខវេ ឱរម្ភាគិយានិ សញ្ញោ-ជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។

[១៦៥] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិ-យានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខ-យាយ បហានាយ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ចិត្តេ

ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើនសតិប្បដ្ឋាន ៤ កាលធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ រមែងជាអ្នកឱនទៅរកព្រះនិព្វាន សសៀរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ។ បេ ។

[១៦៤] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ ប្រការ ។ សញ្ញោជនៈ ៥ គឺអ្វីខ្លះ ។ គឺរូបរាគ (តម្រេកក្នុងរូប) ១ អរូបរាគ (តម្រេកក្នុងអរូប) ១ មានៈ (សេចក្តីប្រកាន់ខ្លួន) ១ ឧទ្ធច្ចៈ (សេចក្តីរាយមាយ) ១ អវិជ្ជា (សេចក្តីល្ងង់ខ្លៅ) ១ ។ ម្នាលភិក្ខុទាំង-ឡាយ នេះឯងជាសញ្ញោជនៈចំណែកខាងលើ ៥ ប្រការ ។

[១៦៥] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ភិក្ខុគប្បីចម្រើនដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់នូវសញ្ញោ-ជនៈជាចំណែកខាងលើ ៥ នេះឯង ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត

១២៩



ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមេ ចត្តារោ សតិប្បដ្ឋានា ភាវេតព្វាតិ ។ (យថា មគ្គសំយុត្តំ វិត្ថារិតំ ឯវំ សតិប្បដ្ឋានសំយុត្តំ វិត្ថារេតព្វំ) ។

គង្គាទិបេយ្យាលោ ឆដ្ឋោ ។

## តស្សុទ្ទានំ

ឆ ចាចីនតោ និន្នា<br>
ឆ និន្នា ច សមុទ្ទតោ<br>
ឯតេ ទ្វេ ឆ ទ្វាទស ហោន្តិ<br>
វគ្គោ តេន បវុច្ចតិ ។

សតិប្បដ្ឋានសំយុត្តំ និដ្ឋិតំ ។

នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះ ភិក្ខុគប្បីចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈដែលជាចំណែកខាងលើ ៥ ប្រការនេះឯង ។ (សតិប្បដ្ឋានសំយុត្ត បណ្ឌិតគប្បីឲ្យពិស្តារដូចជាមគ្គសំយុត្តដែលបានសម្តែងឲ្យពិស្តាររួចហើយ) ។

ចប់ គង្គាទិបេយ្យាល ទី ៦ ។

# ឧទ្ទាននៃគង្គាទិបេយ្យាលនោះគឺ

ពោលអំពីទន្លេហូរទៅកាន់ទិសខាងកើត ៦ លើក ហូរទៅកាន់សមុទ្រ ៦ លើក ប្រាំមួយលើកពីរដង នេះត្រូវជា ១២ ហៅជាវគ្គ ១ ។

ចប់ សតិប្បដ្ឋានសំយុត្ត ។

# ឥន្ទ្រិយសំយុត្តំ

## សុទ្ធិកវគ្គោ

[១៦៦] សាវត្ថីនិទានំ ។ តត្រ ខោ ភគវា ឯតទវោច បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

[១៦៧] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ យតោ ខោ ភិក្ខវេ អរិយសាវកោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

# ឥន្ទ្រិយសំយុត្ត

## សុទ្ធិកវគ្គ

[១៦៦] សាវត្ថីនិទាន ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាឥន្ទ្រិយ ៥ ប្រការ ។

[១៦៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាអរិយសាវ័កដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើងនិងរលត់ទៅ អានិសង្សនិងទោសនិងការរលាស់ចេញ នូវឥន្ទ្រិយទាំង ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះហៅថា សោតាបន្ន មានកិរិយាមិនធ្លាក់ចុះជាធម្មតា មានគតិទៀង មានការត្រាស់ដឹងទៅខាងមុខ ។

១៣១

## សុទ្ធិកវគ្គោ

[១៦៨] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ យតោ ខោ ភិក្ខវេ អរិយស្សាវកោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយស្សាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

[១៦៩] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ យតោ ខោ ភិក្ខវេ ភិក្ខុ[១] ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោតិ ។

---
១ ឱ. ម. អរិយសាវកោ ។

សុទ្ធិកវគ្គ

[១៦៨] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាអរិយសាវ័កដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើង រលត់ទៅ អានិសង្ស ទោស និង ការរលាស់ចេញ នូវឥន្ទ្រិយទាំង ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះហៅថា សោតាបន្ន មានការមិនធ្លាក់ចុះជាធម្មតា មានគតិទៀង មានការត្រាស់ដឹងទៅខាងមុខ ។

[១៦៩] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើង រលត់ទៅ អានិសង្ស ទោស និង ការរលាស់ចេញ នូវឥន្ទ្រិយទាំង ៥ នេះរមែងជាអ្នករួចស្រឡះ ព្រោះមិនមានសេចក្តីប្រកាន់មាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា អរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍នៃខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់ហើយ រួចស្រឡះហើយ ព្រោះត្រាស់ដឹងដោយប្រពៃ ។

១៣២



[១៧០] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ យតោ ខោ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទី-នវញ្ច និស្សរណាញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កាតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោតិ ។

[១៧០] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើង រលត់ទៅ អានិសង្ស ទោស នឹងការរលាស់ចេញ នូវឥន្ទ្រិយទាំង ៥ នេះ រមែងរួចស្រឡះ ព្រោះមិនមានសេចក្តីប្រកាន់មាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា អរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍នៃខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់ហើយ រួចស្រឡះហើយ ព្រោះត្រាស់ដឹងដោយប្រពៃ ។

## សុទ្ធិកវគ្គោ

[១៧១] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ។ ន មេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រាហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

សុទ្ធិកវគ្គ

[១៧១] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្ដេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណាមួយ មិនដឹងច្បាស់តាមពិត នូវសេចក្ដីកើតឡើង រលត់ទៅ អានិសង្ស ទោស និង ការរលាស់ចេញ នូវឥន្ទ្រិយទាំង ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះ ប៉ែកខាងពួកសមណៈ មិនសន្មតថាជាសមណៈ ប៉ែកខាងពួកព្រាហ្មណ៍ ក៏មិនសន្មតថាជាព្រាហ្មណ៍ទេ ដ្បិតថាអ្នកដ៏មានអាយុទាំងនុ៎ះ មិនបានធ្វើឲ្យជាក់ច្បាស់សម្រេចនូវប្រយោជន៍ ជារបស់សមណៈ ឬប្រយោជន៍ជារបស់ព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ឧត្ដម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[១៧២] យេ ច ខោ តេ[១] ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ ។ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រាហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[១៧៣] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា សទ្ធិន្ទ្រិយំ នប្បជានន្តិ សទ្ធិន្ទ្រិយសមុទយំ នប្បជានន្តិ សទ្ធិន្ទ្រិយនិរោធំ នប្បជានន្តិ សទ្ធិន្ទ្រិយនិរោធគាមិនីបដិបទំ នប្បជានន្តិ វីរិយិន្ទ្រិយំ នប្បជានន្តិ ។ បេ ។ សតិន្ទ្រិយំ នប្បជានន្តិ ។ សមាធិន្ទ្រិយំ នប្បជានន្តិ ។ បញ្ញិន្ទ្រិយំ នប្បជានន្តិ បញ្ញិន្ទ្រិយសមុទយំ នប្បជានន្តិ បញ្ញិន្ទ្រិយនិរោធំ នប្បជានន្តិ បញ្ញិន្ទ្រិយនិរោធគាមិនីបដិបទំ នប្បជានន្តិ ។

១ ឱ. យេ ច ខោ កេចិ ។

[១៧២] ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែថា សមណៈឬព្រាហ្មណ៍ឯណាដឹងច្បាស់តាមពិត នូវសេចក្តីកើតឡើង រលត់ទៅ អានិសង្ស ទោស និង ការរលាស់ចេញ នូវឥន្ទ្រិយទាំង ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះឯង ប៉ែកខាងពួកសមណៈ ទើបសន្មតថាជាសមណៈ ប៉ែកខាងពួកព្រាហ្មណ៍ ក៏សន្មតថាជាព្រាហ្មណ៍ បានដ្បិតថា អ្នកដ៏មានអាយុទាំងនោះ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវប្រយោជន៍ជារបស់សមណៈនិងប្រយោជន៍ជារបស់ព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[១៧៣] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណាមួយ មិនដឹងច្បាស់នូវសទ្ធិន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីកើតឡើងនៃសទ្ធិន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីរលត់នៃសទ្ធិន្ទ្រិយ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅ ដើម្បីរលត់នៃសទ្ធិន្ទ្រិយ មិនដឹងច្បាស់នូវវីរិយិន្ទ្រិយ ។ បេ ។ មិនដឹងច្បាស់នូវសតិន្ទ្រិយ ។ មិនដឹងច្បាស់នូវសមាធិន្ទ្រិយ ។ មិនដឹងច្បាស់នូវបញ្ញិន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីកើតឡើងនៃបញ្ញិន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីរលត់នៃបញ្ញិន្ទ្រិយ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅដើម្បីរលត់នៃបញ្ញិន្ទ្រិយ ។

ឯមេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សម-
ណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្ម-
ណសម្មតា ឯ ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ
វា ព្រាហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិ-
កត្វា ឧបសម្បជ្ជ វិហរន្តិ ។

[១៧៤] យេ ហិ កេចិ ភិក្ខវេ សមណា វា
ព្រាហ្មណា វា សទ្ធិន្ទ្រិយំ បជានន្តិ សទ្ធិន្ទ្រិយសមុទយំ
បជានន្តិ សទ្ធិន្ទ្រិយនិរោធំ បជានន្តិ សទ្ធិន្ទ្រិយនិរោធ-
គាមិនីបដិបទំ បជានន្តិ វីរិយិន្ទ្រិយំ បជានន្តិ វីរិយិន្ទ្រិ-
យសមុទយំ បជានន្តិ វីរិយិន្ទ្រិយនិរោធំ បជានន្តិ វីរិ-
យិន្ទ្រិយនិរោធគាមិនីបដិបទំ បជានន្តិ សតិន្ទ្រិយំ ប-
ជានន្តិ ។ សមាធិន្ទ្រិយំ បជានន្តិ ។ បញ្ញិន្ទ្រិយំ បជា-
នន្តិ បញ្ញិន្ទ្រិយសមុទយំ បជានន្តិ បញ្ញិន្ទ្រិយនិរោធំ
បជានន្តិ បញ្ញិន្ទ្រិយនិរោធគាមិនីបដិបទំ បជានន្តិ ។
តេ ខោមេ[១] ភិក្ខវេ សមណា វា ព្រាហ្មណា វា

១ ឱ. ម. តេ ខោ បន មេ ។

សុទ្ធិកវគ្គ

ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះ ប៉ែកខាងពួកសមណៈ ក៏មិនសន្មតថាជាសមណៈ ប៉ែកខាងពួកព្រាហ្មណ៍ ក៏មិនសន្មតថាជាព្រាហ្មណ៍ ដ្បិតថាអ្នកដ៏មានអាយុទាំងនុ៎ះ មិនបានធ្វើឲ្យជាក់ច្បាស់សម្រេចនូវប្រយោជន៍ជារបស់សមណៈ ឬប្រយោជន៍ជារបស់ព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[១៧៤] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណាមួយ ដឹងច្បាស់នូវសទ្ធិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃសទ្ធិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីរលត់នៃសទ្ធិន្ទ្រិយ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសទ្ធិន្ទ្រិយ ដឹងច្បាស់នូវវីរិយិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃវីរិយិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីរលត់នៃវីរិយិន្ទ្រិយ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃវីរិយិន្ទ្រិយ ដឹងច្បាស់នូវសតិន្ទ្រិយ ។ ដឹងច្បាស់នូវសមាធិន្ទ្រិយ ។ ដឹងច្បាស់នូវបញ្ញិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃបញ្ញិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីរលត់នៃបញ្ញិន្ទ្រិយ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃបញ្ញិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះ

សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថំ ច ព្រាហ្មញ្ញត្ថំ ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[១៧៥] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។

[១៧៦] កត្ថ ច ភិក្ខវេ សទ្ធិន្ទ្រិយំ ទដ្ឋព្វំ ។ ចតូសុ សោតាបត្តិយង្គេសុ ឯត្ថ សទ្ធិន្ទ្រិយំ ទដ្ឋព្វំ ។

[១៧៧] កត្ថ ច ភិក្ខវេ វិរិយិន្ទ្រិយំ ទដ្ឋព្វំ ។ ចតូសុ សម្មប្បធានេសុ ឯត្ថ វិរិយិន្ទ្រិយំ ទដ្ឋព្វំ

[១៧៨] កត្ថ ច ភិក្ខវេ សតិន្ទ្រិយំ ទដ្ឋព្វំ ។ ចតូសុ សតិប្បដ្ឋានេសុ ឯត្ថ សតិន្ទ្រិយំ ទដ្ឋព្វំ ។

ប៉ែកខាងពួកសមណៈ ក៏សន្មតថាជាសមណៈ ប៉ែកខាងពួកព្រាហ្មណ៍ ក៏សន្មតថាជាព្រាហ្មណ៍ ដ្បិតថាអ្នកដ៏មានអាយុទាំងនោះ បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវប្រយោជន៍ជារបស់សមណៈនិងប្រយោជន៍ជារបស់ព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[១៧៥] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។

[១៧៦] ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្តេច ។ បណ្តាឥន្ទ្រិយទាំង ៥ នុ៎ះ សទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ។

[១៧៧] ម្នាលភិក្ខុទាំងឡាយ ចុះវីរិយិន្ទ្រិយបណ្ឌិត គប្បីឃើញក្នុងទីដូចម្តេច ។ បណ្តាឥន្ទ្រិយទាំងនុ៎ះ វីរិយិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងសម្មប្បធានទាំង ៤ ។

[១៧៨] ម្នាលភិក្ខុទាំងឡាយ ចុះសតិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្តេច ។ បណ្តាឥន្ទ្រិយទាំងនុ៎ះ សតិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងសតិប្បដ្ឋានទាំង ៤ ។

១៣៧

សុទ្ធិកវគ្គោ

[១៧៩] កត្ថ ច ភិក្ខវេ សមាធិន្ទ្រិយំ ទដ្ឋព្វំ ។ ចតូសុ ឈានេសុ ឯត្ថ សមាធិន្ទ្រិយំ ទដ្ឋព្វំ ។

[១៨០] កត្ថ ច ភិក្ខវេ បញ្ញិន្ទ្រិយំ ទដ្ឋព្វំ ។ ចតូសុ អរិយសច្ចេសុ ឯត្ថ បញ្ញិន្ទ្រិយំ ទដ្ឋព្វំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

[១៨១] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។

[១៨២] កតមញ្ច ភិក្ខវេ សទ្ធិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធិន្ទ្រិយំ ។

សុទ្ធិកវគ្គ

[១៧៩] ម្នាលភិក្ខុទាំងឡាយ ចុះសមាធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្តេច ។ បណ្តាឥន្ទ្រិយទាំងនុ៎ះ សមាធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងឈានទាំង ៤ ។

[១៨០] ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្តេច ។ បណ្តាឥន្ទ្រិយទាំងនុ៎ះ បញ្ញិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងអរិយសច្ចទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[១៨១] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។

[១៨២] ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើទូន្មាននូវបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធិន្ទ្រិយ ។

[១៨៣] កាតមញ្ច ភិក្ខវេ វីរិយិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ អារទ្ធវីរិយោ វិហារតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ ឥទំ វុច្ចតិ ភិក្ខវេ វីរិយិន្ទ្រិយំ ។

[១៨៤] កាតមញ្ច ភិក្ខវេ សតិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកាតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតា ។ ឥទំ វុច្ចតិ ភិក្ខវេ សតិន្ទ្រិយំ ។

[១៨៥] កាតមញ្ច ភិក្ខវេ សមាធិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ វោស្សគ្គារម្មណំ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សមាធិន្ទ្រិយំ ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ ចុះវីរិយិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់ពួកអកុសលធម៌ នឹងការញុំាងពួកកុសលធម៌ឲ្យបរិបូណ៌ មានសេចក្តីប្រឹងប្រែង មានសេចក្តីខ្នះខ្នែងមាំ មិនដាក់ធុរៈក្នុងពួកកុសល-ធម៌ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីរិយិន្ទ្រិយ ។

[១៨៤] ម្នាលភិក្ខុទាំងឡាយ ចុះសតិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយបញ្ញាចាស់ក្លាដ៏ប្រសើរ រឭកបានចាំបាននូវកិច្ចដែលខ្លួនបានធ្វើយូរមកហើយ នឹងសម្តីដែលខ្លួននិយាយយូរមកហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិន្ទ្រិយ ។

[១៨៥] ម្នាលភិក្ខុទាំងឡាយ ចុះសមាធិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ធ្វើនូវព្រះនិព្វានជាអារម្មណ៌ហើយ បាននូវសមាធិ បាននូវឯកគ្គតាចិត្ត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមាធិន្ទ្រិយ ។

១៣៩

សុទ្ធិកវគ្គោ

[១៨៦] កាតមញ្ច ភិក្ខវេ បញ្ញិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញ វា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ ឥទំ វុច្ចតិ វុច្ចតិ ភិក្ខវេ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

[១៨៧] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។បេ។ បញ្ញិន្ទ្រិយំ ។

[១៨៨] កាតមញ្ច ភិក្ខវេ សទ្ធិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកាវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធិន្ទ្រិយំ ។

សុទ្ធិកវគ្គ

[១៨៦] ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញិន្ទ្រិយដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងកំណត់នូវសេចក្ដីកើតឡើងនិងរលត់ ជាចំណែកនៃសេចក្ដីនឿយណាយ ជាធម្មជាតិប្រព្រឹត្តទៅដើម្បីដល់នូវសេចក្ដីអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[១៨៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្ដេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។

[១៨៨] ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ មានសទ្ធា ជឿសេចក្ដីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណឥតមានបុគ្គលណាស្មើ ទូន្មាននូវបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធិន្ទ្រិយ ។

[១៨៩] កាតមញ្ច ភិក្ខវេ វីរិយិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ សោ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ កុសលានំ ធម្មានំ សមាបត្តិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ ចារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥទំ វុច្ចតិ ភិក្ខវេ វីរិយិន្ទ្រិយំ ។

[១៨៩] ម្នាលភិក្ខុទាំងឡាយ ចុះវីរិយិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រារព្ធព្យាយាមដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីញុំាំងពួកកុសលធម៌ឲ្យបរិបូណ៌ មានសេចក្តីប្រឹងប្រែង មានសេចក្តីខ្នះខ្នែងមាំ មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ អរិយសាវកនោះញុំាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមដើម្បីញុំាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលមិនទាន់កើតឡើងមិនឲ្យកើតឡើងបាន ។ ញុំាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមដើម្បីលះបង់អកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងហើយ ។ ញុំាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមដើម្បីញុំាំងកុសលធម៌ទាំងឡាយដែលមិនទាន់កើតឡើងឲ្យកើត ឡើងបាន ។ ញុំាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមដើម្បីញុំាំងកុសលធម៌ទាំងឡាយដែលកើតឡើងហើយឲ្យដល់ព្រម មិនឲ្យវិនាស ឲ្យចម្រើនជំទូលាយ ពេញបរិបូណ៌ក្រៃលែង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីរិយិន្ទ្រិយ ។

សុទ្ធិកវគ្គោ

[១៩០] កតមញ្ច ភិក្ខវេ សតិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិ-តា ។ សោ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-នស្សំ ។ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អ-ភិជ្ឈាទោមនស្សំ ។ ឥទំ វុច្ចតិ ភិក្ខវេ សតិន្ទ្រិយំ ។

[១៩១] កតមញ្ច ភិក្ខវេ សមាធិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ វោស្សគ្គារម្មណំ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ។ សោ វិវិច្ចេវ

សុទ្ធិកវគ្គ

[១៩០] ម្នាលភិក្ខុទាំងឡាយ ចុះសតិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ មានស្មារតី ប្រកបដោយបញ្ញាចាស់ក្លាដ៏ប្រសើរ រឭកបានចាំបាននូវកិច្ចដែលខ្លួនធ្វើយូរមកហើយ នឹងសម្តីដែលខ្លួននិយាយយូរមកហើយ ។ អរិយសាវ័កនោះពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានឹងទោមនស្សក្នុងលោកចេញបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិន្ទ្រិយ ។

[១៩១] ម្នាលភិក្ខុទាំងឡាយ ចុះសមាធិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ធ្វើនូវព្រះនិព្វានជាអារម្មណ៍ បាននូវសមាធិ បាននូវឯកគ្គតាចិត្ត ។ អរិយសាវ័កនោះ ស្ងប់ស្ងាត់

កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សមាធិន្ទ្រិយំ ។

ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កៈវិចារៈ រួចក៏ចូលកាន់ទុតិយជ្ឈានដែលកើតមានក្នុងសន្ដាន ជាទីផូរផង់ មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ ព្រោះប្រាសចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិសម្បជញ្ញៈផង រមែងសោយសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខាមានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណាក៏ចូលកាន់តតិយជ្ឈាននោះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សក្នុងកាលមុនអស់ទៅផង ក៏ចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខមិនមែនជាសុខមានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសមាធិន្ទ្រិយ ។

១៤៣

សុទ្ធិកវគ្គោ

[១៩២] កាតមញ្ច ភិក្ខវេ បញ្ញិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

សុទ្ធិកវគ្គោ បឋមោ ។

## តស្សុទ្ទានំ

សុទ្ធិកញ្ចេវ ទ្វេ សោតា
អរហន្តា អបរេ ទ្វេ
សមណព្រាហ្មណា ឧដ្ឋព្វំ
វិភង្គេ អបរេ ទុវេតិ ។

[១៩២] ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ មានប្រាជ្ញា ប្រកបដោយប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងកំណត់នូវសេចក្តីកើតនឹងរលត់ ប្រព្រឹត្តទៅដើម្បីទម្លុះទម្លាយ ប្រព្រឹត្តទៅដើម្បីដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ អរិយសាវ័កនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់នៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាហេតុឲ្យដល់នូវសេចក្តីរលត់នៃទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាបញ្ញិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

ចប់ សុទ្ធិកវគ្គទី ១ ។

## ឧទ្ទាននៃសុទ្ធិកវគ្គនោះគឺ

ពោលអំពីឥន្ទ្រិយសុទ្ធ ១ អំពីព្រះសោតាបន្នមានពីរលើក អំពីព្រះអរហន្តដទៃទៀតមានពីរលើក អំពីសមណព្រាហ្មណ៍ ១ អំពីឥន្ទ្រិយដែលបណ្ឌិតគប្បីយល់ឃើញក្នុងអង្គនៃសោតាបត្តិមគ្គជាដើម ១ អំពីការចែកឥន្ទ្រិយមានពីរលើកដទៃទៀត ។

# មុទុតរវគ្គោ

[១៩៣] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។

[១៩៤] កតមញ្ច ភិក្ខវេ សទ្ធិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយស្សាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សទ្ធិន្ទ្រិយំ ។

[១៩៥] កតមញ្ច ភិក្ខវេ វីរិយិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចត្តារោ សម្មប្បធានេ អារព្ភ វីរិយំ បដិលភតិ ។ ឥទំ វុច្ចតិ ភិក្ខវេ វីរិយិន្ទ្រិយំ ។

[១៩៦] កតមញ្ច ភិក្ខវេ សតិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានេ អារព្ភ សតឹ បដិលភតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សតិន្ទ្រិយំ ។

# មុទុតរវគ្គ

[១៩៣] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។

[១៩៤] ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ មានសទ្ធា ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទូន្មាននូវបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធិន្ទ្រិយ ។

[១៩៥] ម្នាលភិក្ខុទាំងឡាយ ចុះវីរិយិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវសម្មប្បធាន ៤ រមែងបាននូវសេចក្តីព្យាយាមឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីរិយិន្ទ្រិយ ។

[១៩៦] ម្នាលភិក្ខុទាំងឡាយ ចុះសតិន្ទ្រិយដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រារព្ធនូវសតិប្បដ្ឋាន ៤ រមែងបាននូវសតិឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិន្ទ្រិយ ។

# មុទុតរវគ្គោ

[១៩៧] កាតមញ្ច ភិក្ខវេ សមាធិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ វោស្សគ្គារម្មណំ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សមាធិន្ទ្រិយំ ។

[១៩៨] កាតមញ្ច ភិក្ខវេ បញ្ញិន្ទ្រិយំ ។ ឥធ ភិក្ខវេ អរិយសាវកោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មា-ទុក្ខក្ខយគាមិនិយា ។ ឥទំ វុច្ចតិ ភិក្ខវេ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

[១៩៩] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

មុទុតរវគ្គ

[១៩៧] ម្នាលភិក្ខុទាំងឡាយ ចុះសមាធិន្ទ្រិយដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ធ្វើនូវព្រះនិព្វានជាអារម្មណ៍ រមែងបាននូវសមាធិ បានឯកគ្គតាចិត្ត ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា សមាធិន្ទ្រិយ ។

[១៩៨] ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញិន្ទ្រិយដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ មានប្រាជ្ញា ប្រកបដោយប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងកំណត់នូវសេចក្ដីកើតនឹងរលត់ ប្រព្រឹត្តទៅដើម្បីទម្លុះទម្លាយ ជាហេតុឲ្យដល់នូវសេចក្ដីអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[១៩៩] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយទាំងនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្ដេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[២០០] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុតរេហិ អនាគាមី ហោតិ តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ ធម្មានុសារី ហោតិ តតោ មុទុតរេហិ សទ្ធានុសារី ហោតីតិ ។

[២០១] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កត-មានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

[២០២] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុតរេហិ អនាគាមី ហោតិ តតោ មុទុតរេហិ សកទា-គាមី ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ ធម្មានុសារី ហោតិ

[២០០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយ ៥ នេះ បានជាអនាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ បានជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អនាគាមីនោះ បានជាសោតាបន្ន ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ បានជាធម្មានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សោតាបន្ននោះ បានជាសទ្ធានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ធម្មានុ-សារីនោះ ។

[២០១] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[២០២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយ ៥ នេះឯង បានជាអនាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ បានជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អនាគាមីនោះ បានជាសោតាបន្ន ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ បានជាធម្មានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សោតាបន្ននោះ

តតោ មុទុតរេហិ សទ្ធានុសារី ហោតិ ។ ឥតិ ខោ ភិក្ខវេ ឥន្ទ្រិយវេមត្តតា ផលវេមត្តតា ហោតិ ផល-វេមត្តតា បុគ្គលវេមត្តតា[១] តិ ។

[២០៣] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

[២០៤] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុតរេហិ អនាគាមី ហោតិ តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ ធម្មានុសារី ហោតិ តតោ មុទុតរេហិ សទ្ធា-នុសារី ហោតិ ។ ឥតិ ខោ ភិក្ខវេ បរិបូរំ បរិបូរការី

១ ឱ. ពលវេមត្តតា បុគ្គលវេមត្តតា ហោតិ ។

បានជាសទ្ធានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ធម្មានុ-សារីនោះ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរផ្សេងគ្នានៃឥន្ទ្រិយ ដំណើរផ្សេងគ្នានៃផលក៏មាន ដំណើរផ្សេងគ្នានៃផល ដំណើរផ្សេងគ្នានៃបុគ្គលក៏មាន ដោយប្រការដូច្នេះឯង ។

[២០៣] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[២០៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយ ៥ នេះឯង បានជាអនាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ បានជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អនាគាមីនោះ បានជាសោតាបន្នព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ បានជាធម្មា-នុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សោតាបន្ននោះ បានជាសទ្ធានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ធម្មានុសារីនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកធ្វើមគ្គឲ្យពេញបរិបូណ៌

អាភាជេតិ បទេសំ បទេសការី អាភាជេតិ ។ អ-វញ្ឈានិត្វេវាហំ ភិក្ខវេ បញ្ចិន្ទ្រិយានិ វទាមីតិ ។

[២០៥] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាត-មានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

[២០៦] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុតរេហិ អន្តរាបរិនិព្វាយី ហោតិ តតោ មុទុតរេហិ ឧបហច្ចបរិ-និព្វាយី ហោតិ តតោ មុទុតរេហិ អសង្ខារបរិនិព្វាយី ហោតិ តតោ មុទុតរេហិ សសង្ខារបរិនិព្វាយី ហោតិ

រមែងសម្រេចនូវផលដ៏បរិបូណ៌ ជាអ្នកធ្វើនូវចំណែកនៃមគ្គ រមែងសម្រេចនូវចំណែកនៃផលដែរ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវឥន្ទ្រិយ ៥ ថា មិនមែនជាឥតផលទេ ។

[២០៥] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង។

[២០៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយ ៥ នេះឯង បានជាអន្តរាបរិនិព្វាយី (លោកដែលបរិនិព្វានក្នុងរវាងអាយុមិនទាន់ដល់ពាក់កណ្តាល) ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ បានជាឧបហច្ចបរិនិព្វាយី (លោកដែលបរិនិព្វានក្នុងកាលអាយុហួសពាក់កណ្តាលដរាបដល់ទីបំផុត) ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អន្តរាបរិនិព្វាយីនោះ បានជាអសង្ខារបរិនិព្វាយី (លោកដែលបរិនិព្វានដោយមិនខំធ្វើសេចក្តីព្យាយាម) ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧបហច្ចបរិនិព្វាយីនោះ បានជាសសង្ខារបរិនិព្វាយី (លោកដែលបរិនិព្វានដោយខំធ្វើសេចក្តីព្យាយាម) ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អសង្ខារបរិនិព្វាយីនោះ

មុទុតវគ្គោ

តតោ មុទុតរេហិ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ ធម្មានុសារី ហោតិ តតោ មុទុតរេហិ សទ្ធានុសារី ហោតីតិ ។

[២០៧] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

បានជាឧទ្ធំសោតអកនិដ្ឋគាមី (លោកដែលមានក្រសែធម៌ដ៏ខ្ពស់ទៅកាន់អកនិដ្ឋភពហើយបរិនិព្វានក្នុងទីនោះ) ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សសង្ខារបរិនិព្វាយីនោះ បានជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧទ្ធំសោតអកនិដ្ឋគាមីនោះ បានជាសោតាបន្ន ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ បានជាធម្មានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សោតាបន្ននោះ បានជាសទ្ធានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ធម្មានុសារីនោះ ។

[២០៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[២០៨] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុតរេហិ អន្តរាបរិនិព្វាយី ហោតិ តតោ មុទុតរេហិ ឧបហច្ចបរិនិព្វាយី ហោតិ តតោ មុទុតរេហិ អសង្ខារបរិនិព្វាយី ហោតិ តតោ មុទុតរេហិ សសង្ខារបរិនិព្វាយី ហោតិ តតោ មុទុតរេហិ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ ធម្មានុសារី ហោតិ តតោ មុទុតរេហិ សទ្ធានុសារី ហោតិ ។ ឥតិ ខោ ភិក្ខវេ ឥន្ទ្រិយវេមត្តតា ផលវេមត្តតា ហោតិ ផលវេមត្តតា បុគ្គលវេមត្តតាតិ ។

[២០៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយ ៥ នេះឯង បានជាអន្តរាបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ បានជាឧបហច្ចបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អន្តរាបរិនិព្វាយីនោះ បានជាអសង្ខារបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧបហច្ចបរិនិព្វាយីនោះ បានជាសសង្ខារបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អសសង្ខារបរិនិព្វាយីនោះ បានជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សសង្ខារបរិនិព្វាយីនោះ បានជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧទ្ធំសោតអកនិដ្ឋគាមីនោះ បានជាសោតាបន្ន ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ បានជាធម្មានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សោតាបន្ននោះ បានជាសទ្ធានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ធម្មានុសារីនោះ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរផ្សេងគ្នានៃឥន្ទ្រិយ ដំណើរផ្សេងគ្នានៃផលក៏មាន ដំណើរផ្សេងគ្នានៃផល ដំណើរផ្សេងគ្នានៃបុគ្គលក៏មាន ដោយប្រការដូច្នេះឯង ។

១៨១

មុទុតរវគ្គោ

[២០៩] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

[២១០] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុតរេហិ អន្តរាបរិនិព្វាយី ហោតិ តតោ មុទុតរេហិ ឧបហច្ច-បរិនិព្វាយី ហោតិ តតោ មុទុតរេហិ អសង្ខារបរិនិព្វាយី ហោតិ តតោ មុទុតរេហិ សសង្ខារបរិនិព្វាយី ហោតិ តតោ មុទុតរេហិ ឧទ្ធំសោតោ ហោតិ អកានិដ្ឋគាមី

មុទុតរវគ្គ

[២០៩] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[២១០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយ ៥ នេះឯង បានជាអន្តរាបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ បានជាឧបហច្ចបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អន្តរាបរិនិព្វាយីនោះ បានជាអសង្ខារបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧបហច្ចបរិនិព្វាយីនោះ បានជាសសង្ខារបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អសង្ខារបរិនិព្វាយីនោះ បានជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សសង្ខារបរិនិព្វាយីនោះ

តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ ធម្មានុសារី ហោតិ តតោ មុទុតរេហិ សទ្ធានុសារី ហោតិ ។ ឥតិ ខោ ភិក្ខវេ បរិបូរំ បរិបូរការី អារាធេតិ បទេសំ បទេសការី អារាធេតិ ។ អវញ្ឈានិត្វេវាហំ ភិក្ខវេ បញ្ចិន្ទ្រិយានិ វទាមីតិ ។

[២១១] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

បានជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧទ្ធំសោត-អកនិដ្ឋគាមីនោះ បានជាសោតាបន្ន ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ បានជាធម្មានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សោតាបន្ននោះ បានជាសទ្ធានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ធម្មានុសារីនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធ្វើមគ្គឲ្យបរិបូណ៌ រមែងបានសម្រេចផលដ៏បរិបូណ៌ ធ្វើនូវចំណែកនៃមគ្គ រមែងបានសម្រេចនូវចំណែកនៃផល ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវឥន្ទ្រិយ ៥ ថា មិនមែនជាឥតផលទេ ។

[២១១] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

១៨៣

## មុទុតរវគ្គោ

[២១២] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុតរេហិ អរហត្តផលសច្ឆិកិរិយាយ បដិបន្នោ ហោតិ តតោ មុទុតរេហិ អនាគាមី ហោតិ តតោ មុទុតរេហិ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ ហោតិ តតោ មុទុតរេហិ សកទាគាមី ហោតិ តតោ មុទុតរេហិ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ ហោតិ តតោ មុទុតរេហិ សោតាបន្នោ ហោតិ តតោ មុទុតរេហិ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ ហោតិ ។ យស្សខោ ភិក្ខវេ ឥមានិ បញ្ចិន្ទ្រិយានិ សព្វេន សព្វំ សព្វថា សព្វំ នត្ថិ តមហំ ពាហិរោ បុថុជ្ជនបក្ខេ ឋិតោតិ វទាមីតិ ។

មុទុតរវគ្គ

[២១២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយ ៥ នេះឯង ជាអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហន្តផល ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ បានជាអនាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលនោះ ជាអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អនាគាមីនោះ បានជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះ ជាអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ បានជាសោតាបន្ន ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសក-ទាគាមិផលនោះ ជាអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សោតាបន្ននោះ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ មិនមានដល់ភិក្ខុឯណាដោយបរិបូណ៌សព្វគ្រប់ទេ តថាគតហៅភិក្ខុនោះថា ជាអ្នកស្ថិតនៅក្នុងពួកបុថុជ្ជនជាខាងក្រៅ (បុគ្គលទាំង ៨ ពួក) ។

[២១៣] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥន្ទ្រិយសម្បន្នោ ឥន្ទ្រិយសម្បន្នោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ឥន្ទ្រិយសម្បន្នោ ហោតីតិ ។

[២១៤] ឥធ ភិក្ខុ ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ វីរិយិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ សតិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ សមាធិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ បញ្ញិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ ។ ឯត្តាវតា ខោ ភិក្ខុ ភិក្ខុ ឥន្ទ្រិយសម្បន្នោ ហោតីតិ ។

[២១៣] គ្រានោះឯង មានភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ដែលព្រះអង្គត្រាស់ថា ភិក្ខុបរិបូណ៌ដោយឥន្ទ្រិយ បរិបូណ៌ដោយឥន្ទ្រិយ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុជាអ្នកបរិបូណ៌ដោយឥន្ទ្រិយដោយហេតុដូចម្តេច ។

[២១៤] ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ចម្រើនសទ្ធិន្ទ្រិយដែលមានដំណើរទៅដើម្បីសេចក្តីស្ងប់រំងាប់ មានដំណើរទៅដើម្បីសេចក្តីត្រាស់ដឹង ចម្រើនវីរិយិន្ទ្រិយដែលមានដំណើរទៅដើម្បីសេចក្តីស្ងប់រំងាប់ មានដំណើរទៅដើម្បីសេចក្តីត្រាស់ដឹង ចម្រើនសតិន្ទ្រិយដែលមានដំណើរទៅដើម្បីសេចក្តីស្ងប់រំងាប់ មានដំណើរទៅដើម្បីសេចក្តីត្រាស់ដឹង ចម្រើនសមាធិន្ទ្រិយដែលមានដំណើរទៅដើម្បីសេចក្តីស្ងប់រំងាប់ មានដំណើរទៅដើម្បីសេចក្តីត្រាស់ដឹង ចម្រើនបញ្ញិន្ទ្រិយដែលមានដំណើរទៅដើម្បីសេចក្តីស្ងប់រំងាប់ មានដំណើរទៅដើម្បីសេចក្តីត្រាស់ដឹង ។ ម្នាលភិក្ខុ ភិក្ខុជាអ្នកបរិបូណ៌ដោយឥន្ទ្រិយ ដោយហេតុដូច្នេះឯង ។

មុទុតរវគ្គោ

[២១៥] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

[២១៦] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

មុទុតរវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

បដិលាភោ ច តយោ សង្ខិត្តា
វិត្ថារា អបរេ តយោ
បដិបន្នោ ចុបសមោ
អាសវានំ ខយោ ចិមេតិ ។

មុទុតរវគ្គ

[២១៥] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការដូច្នេះឯង ។

[២១៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានធ្វើឲ្យជាក់ច្បាស់សម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ព្រោះបានចម្រើន ធ្វើឲ្យច្រើន នូវឥន្ទ្រិយទាំង ៥ នេះឯង ក្នុងបច្ចុប្បន្ន ។

ចប់ មុទុតរវគ្គ ទី ២ ។

# ឧទ្ទាននៃមុទុតរវគ្គនោះគឺ

ពោលអំពីអ្នកបានសម្រេចឥន្ទ្រិយទាំងប្រាំ ១ អំពីឥន្ទ្រិយ
ទាំងប្រាំដោយសង្ខេបមាន ៣ លើក ដោយពិស្តារដទៃទៀត
មាន ៣ លើក អំពីអ្នកប្រតិបត្តិដើម្បីបានមគ្គផល ១ អំពី
ឥន្ទ្រិយទាំង ៥ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ១ អំពី
វិមុត្តិជាហេតុអស់ទៅនៃអាសវៈទាំងឡាយ ១ ។

# ឆឡិន្ទ្រិយវគ្គោ

[២១៧] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។

[២១៨] យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ ន អព្ភញ្ញាសឹ ។ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ[១] បច្ចញ្ញាសឹ ។

[២១៩] យតោ ច ខ្វាហំ ភិក្ខវេ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ អព្ភញ្ញាសឹ ។ អថាហំ[២] ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ ញាណញ្ច

---

១ ឱ. ម. អភិសម្ពុទ្ធោតិ ។ ២ អថខ្វាហំ ។

# ឆឡិន្ទ្រិយវគ្គ

[២១៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។

[២១៨] ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនទាន់ដឹងច្បាស់តាមពិត នូវសេចក្តីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញនូវឥន្ទ្រិយទាំង ៥ នេះ អស់កាលត្រឹមណា ។ ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស អស់កាលត្រឹមណោះ ។

[២១៩] ម្នាលភិក្ខុទាំងឡាយ លុះកាលណាតថាគតដឹងច្បាស់តាមពិត នូវសេចក្តីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវឥន្ទ្រិយទាំង ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ ទើបតថាគតប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវ-លោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណ-ព្រាហ្មណ៍និងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ។ សេចក្តីដឹង

## ឆឡិន្ទ្រិយវគ្គោ

បន មេ ឧស្សន្នំ ឧឧចានិ អកុប្បា មេ វិមុត្តិ[១]

អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[២២១] តីណិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ តីណិ ។ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ តីណិ ឥន្ទ្រិយានីតិ ។

[២២១] តីណិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ តីណិ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតាវិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ តីណិ ឥន្ទ្រិយានីតិ ។

១ ឱ. ម. ចេតោវិមុត្តិ ។

និងសេចក្តីឃើញកើតឡើងដល់តថាគតថា សេចក្តីរួចវិសេសរបស់តថា-គតមិនត្រឡប់កម្រើកទៀតឡើយ ជាតិនេះជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះភពថ្មីមិនមានឡើយ ។

[២២០] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៣ ប្រការ ។ ឥន្ទ្រិយ ៣ ប្រការដូចម្តេចខ្លះ ។ គឺឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិ-តិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៣ ប្រការដូច្នេះឯង ។

[២២១] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៣ ប្រការ ។ ឥន្ទ្រិយ ៣ ប្រការដូចម្តេចខ្លះ ។ គឺអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ[១] ១ អញ្ញិន្ទ្រិយ[២] ១ អញ្ញាតាវិន្ទ្រិយ[៣] ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៣ ប្រការដូច្នេះឯង ។

---

១គឺឥន្ទ្រិយដែលកើតឡើងក្នុងខណៈនៃសោតាបត្តិមគ្គប្រាកដច្បាស់ដល់អ្នកប្រតិបត្តិថា អាត្មាអញនឹងដឹងច្បាស់នូវធម៌ដែលខ្លួនមិនធ្លាប់ដឹងក្នុងសង្សារវដ្តនេះ ។ ២ គឺឥន្ទ្រិយដែលកើតឡើងក្នុងហេតុទាំង ៦ តាំងអំពីសោតាបត្តិផលជាដើមទៅ ដោយអាការត្រាស់ដឹងនូវធម៌ដែលខ្លួនមិនទាន់បានដឹង ។ ៣ គឺឥន្ទ្រិយដែលកើតឡើងក្នុងអរហត្តផលជាគុណដែលខ្លួនមិនធ្លាប់ដឹងអំពីមុន ។ អដ្ឋកថា ។

[២២២] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាត-
មានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។
ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។

[២២៣] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយា-
នំ សមត្តា បរិបូរត្តា អរហំ ហោតិ តតោ មុទុត-
រេហិ អន្តរាបរិនិព្វាយី ហោតិ តតោ មុទុតរេហិ
ឧបហច្ចបរិនិព្វាយី ហោតិ តតោ មុទុតរេហិ
អសង្ខារបរិនិព្វាយី ហោតិ តតោ មុទុតរេហិ ស-
សង្ខារបរិនិព្វាយី ហោតិ តតោ មុទុតរេហិ ឧទ្ធំ-
សោតោ ហោតិ តតោ មុទុតរេហិ ឯកពីជី
ហោតិ តតោ មុទុតរេហិ កោលង្កោលោ ហោតិ

[២២២] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ នេះមាន ៥ ប្រការ ។ ឥន្ទ្រិយ ៥ ប្រការ ដូចម្តេចខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការ ដូច្នេះឯង ។

[២២៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានជាអរហន្ត ព្រោះពេញលេញបរិបូណ៌ដោយឥន្ទ្រិយទាំង ៥ នេះឯង ជាអន្តរាបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អរហន្តនោះ ជាឧបហច្ចបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អន្តរាបរិនិព្វាយីនោះ ជាអសង្ខារបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧបហច្ចបរិនិព្វាយីនោះ ជាសសង្ខារបរិនិព្វាយី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់អសង្ខារបរិនិព្វាយីនោះ ជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សសង្ខារបរិនិព្វាយីនោះ ជាសកទាគាមី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឧទ្ធំសោតអកនិដ្ឋគាមីនោះ ជាឯកពីជី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សកទាគាមីនោះ ជាកោលង្កោលៈ ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ឯកពីជីនោះ

១៤៩

## ឆឡិន្ទ្រិយវគ្គោ

តតោ មុទុតរេហិ សត្តក្ខត្តុំបរមោ ហោតិ តតោ មុទុតរេហិ ធម្មានុសារី ហោតិ តតោ មុទុតរេហិ សទ្ធានុសារី ហោតីតិ ។

[២២៤] ឆយិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ ឆ ។ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ ឆ ឥន្ទ្រិយានីតិ ។

[២២៥] ឆយិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ ឆ ។ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ។

[២២៦] យតោ ខោ ភិក្ខវេ អរិយសាវកោ ឥមេសំ ឆន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

ជាសត្តក្ខត្តុំបរមៈ ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់កោលង្កោលៈ នោះ ជាធម្មានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់សត្តក្ខត្តុំ-បរមៈនោះ ជាសទ្ធានុសារី ព្រោះមានឥន្ទ្រិយ ៥ ទន់ជាងឥន្ទ្រិយរបស់ធម្មានុសារីនោះ ។

[២២៤] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៦ ប្រការ ។ ឥន្ទ្រិយ ៦ ប្រការដូចម្តេចខ្លះ ។ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃា-និន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ឥន្ទ្រិយមាន ៦ ប្រការដូច្នេះឯង ។

[២២៥] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៦ ប្រការ ។ ឥន្ទ្រិយ ៦ ប្រការដូចម្តេចខ្លះ ។ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃា-និន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ។

[២២៦] ម្នាលភិក្ខុទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់តាមពិត នូវសេចក្តីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញនូវឥន្ទ្រិយ ៦ នេះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកនេះ ហៅថាសោតាបន្ន មានកិរិយាមិនធ្លាក់ចុះជាធម្មតា មានគតិទៀត មានសេចក្តីត្រាស់ដឹងទៅខាងមុខ ។

[២២៧] ឆយិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ ឆ ។ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ។

[២២៨] យតោ ខោ ភិក្ខវេ ភិក្ខុ ឥមេសំ ឆន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុ-ចាទា វិមុត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កាតការណីយោ ឱហិត-ភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្ម-ទញ្ញាវិមុត្តោតិ ។

[២២៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៦ ប្រការ ។ ឥន្ទ្រិយ ៦ ប្រការដូចម្តេចខ្លះ ។ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ។

[២២៨] ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុដឹងច្បាស់តាមពិតនូវសេចក្តីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវឥន្ទ្រិយ ៦ នេះ ជាអ្នករួចស្រឡះ ព្រោះមិនមានសេចក្តីប្រកាន់មាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ហៅថាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់ហើយ រួចស្រឡះហើយ ព្រោះត្រាស់ដឹងដោយប្រពៃ ។

១៦១

## ឆឡិន្ទ្រិយវគ្គោ

[២២៩] ឆយិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ ឆ ។ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ។

[២៣០] យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ ឆន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អា-ទីនវញ្ច និស្សរណញ្ច យថាភូតំ ន អព្ភញ្ញាសឹ ។ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ ស-ទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។

## ឆឡិន្ទ្រិយវគ្គ

[៤២៩] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៦ ប្រការ ។ ឥន្ទ្រិយ ៦ ប្រការដូចម្ដេចខ្លះ ។ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ។

[៤៣០] ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅមិនទាន់ដឹងច្បាស់តាមពិត នូវសេចក្ដីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវឥន្ទ្រិយ ៦ នេះដរាបណា ។ ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនប្ដេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្ដីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ដរាបនោះ ។

[២៣១] យតោ ច ខ្វាហំ ភិក្ខវេ ឥមេសំ ឆន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ អព្ភញ្ញាសឹ ។ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[២៣២] ឆយិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ ឆ ។ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ។

[២៣១] ម្នាលភិក្ខុទាំងឡាយ កាលណាតថាគតដឹងច្បាស់តាមពិត នូវសេចក្តីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញនូវឥន្ទ្រិយ ៦ នេះ ។ ម្នាលភិក្ខុទាំងឡាយ កាលណោះទើបតថាគតប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។ មួយវិញទៀត សេចក្តីដឹងនឹងសេចក្តីឃើញ ក៏កើតឡើងដល់តថាគតថា សេចក្តីរួចស្រឡះរបស់តថាគតមិនត្រឡប់កម្រើកទៀតឡើយ ជាតិនេះជាទីបំផុត (ត្រឹមណោះហើយ) ឥឡូវនេះភពថ្មីមិនមានឡើយ ។

[២៣២] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៦ ប្រការ ។ ឥន្ទ្រិយ ៦ ប្រការដូចម្តេចខ្លះ ។ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ។

១៦៣

## ឆឡិន្ទ្រិយវគ្គោ

[២៣៣] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ ឆន្នំ ឥន្ទ្រិយានំ មុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ។ នមេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[២៣៤] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ ឆន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ ។ តេ ខោមេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

ឆឡិន្ទ្រិយវគ្គ

[២៣៣] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមពិត នូវសេចក្តីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវឥន្ទ្រិយ ៦ នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនុ៎ះ មិនសន្មតថាជាសមណៈក្នុងពួកសមណៈឬសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ ដ្បិតថាអ្នកដ៏មានអាយុទាំងនុ៎ះ មិនបានធ្វើឲ្យជាក់ច្បាស់សម្រេចនូវប្រយោជន៍ជារបស់សមណៈឬប្រយោជន៍ជារបស់ព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[២៣៤] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមពិត នូវសេចក្តីកើត រលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវឥន្ទ្រិយ ៦ នេះ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះ ទើបសន្មតថាជាសមណៈក្នុងពួកសមណៈផង សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ដ្បិតថាអ្នកដ៏មានអាយុទាំងនោះធ្វើឲ្យជាក់ច្បាស់សម្រេចនូវប្រយោជន៍ជារបស់សមណៈនិងប្រយោជន៍ជារបស់ព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[២៣៥] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ចក្ខុន្ទ្រិយំ នប្បជានន្តិ ចក្ខុន្ទ្រិយសមុទយំ នប្បជានន្តិ ចក្ខុន្ទ្រិយនិរោធំ នប្បជានន្តិ ចក្ខុន្ទ្រិយនិរោធគាមិនីបដិបទំ នប្បជានន្តិ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ នប្បជានន្តិ មនិន្ទ្រិយសមុទយំ នប្បជានន្តិ មនិន្ទ្រិយនិរោធំ នប្បជានន្តិ មនិន្ទ្រិយនិរោធគាមិនីបដិបទំ នប្បជានន្តិ ។ នមេតេ ភិក្ខវេ ។ បេ ។ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[២៣៦] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ចក្ខុន្ទ្រិយំ បជានន្តិ ចក្ខុន្ទ្រិយសមុទយំ បជានន្តិ ចក្ខុន្ទ្រិយនិរោធំ បជានន្តិ ចក្ខុន្ទ្រិយនិរោធគាមិនីបដិបទំ បជានន្តិ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ បជានន្តិ មនិន្ទ្រិយសមុទយំ បជានន្តិ មនិន្ទ្រិយនិរោធំ បជានន្តិ មនិន្ទ្រិយនិរោធគាមិនីបដិបទំ បជានន្តិ ។ តេ ខោមេ ភិក្ខវេ សមណា

[២៣៥] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់នូវចក្ខុន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីកើតនៃចក្ខុន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីរលត់នៃចក្ខុន្ទ្រិយ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃចក្ខុន្ទ្រិយ មិនដឹងច្បាស់នូវសោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ មនិន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីកើតនៃមនិន្ទ្រិយ មិនដឹងច្បាស់នូវសេចក្តីរលត់នៃមនិន្ទ្រិយ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនុ៎ះ ។ បេ ។ មិនធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ។

[២៣៦] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់នូវចក្ខុន្ទ្រិយ ដឹងច្បាស់នូវសេចក្តីកើតនៃចក្ខុន្ទ្រិយ ដឹងច្បាស់នូវសេចក្តីរលត់នៃចក្ខុន្ទ្រិយ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃចក្ខុន្ទ្រិយ ដឹងច្បាស់នូវសោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ មនិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីកើតនៃមនិន្ទ្រិយ ដឹងច្បាស់នូវសេចក្តីរលត់នៃមនិន្ទ្រិយ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ

ឆឡិន្ទ្រិយវគ្គោ

វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនា- យស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

ឆឡិន្ទ្រិយវគ្គោ តតិយោ ។

## តស្សុទ្ទានំ

ឃដ្ដិតេ ជីវិតញ្ញាយ
ឯកាភិញ្ញញ្ច សុទ្ធកំ
សោតោ ទ្វេ អរហា[១] ទ្វេ
សមណព្រាហ្មណេន ចាតិ ។

១ ឱ. អរហតា ។

ឬព្រាហ្មណ៍ទាំងនោះ ទើបសន្មតថាជាសមណៈក្នុងពួកសមណៈផង សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ដ្បិតថាអ្នកដ៏មានអាយុទាំងនោះ បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវប្រយោជន៍ជារបស់សមណៈ និងប្រយោជន៍ជារបស់ព្រាហ្មណ៍ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

ចប់ ឆឡិន្ទ្រិយវគ្គ ទី ៣ ។

# ឧទ្ទាននៃឆឡិន្ទ្រិយវគ្គនោះគឺ

និយាយអំពីព្រះដ៏មានព្រះភាគមិនវិលមកកាន់ភពថ្មីទៀត ១ អំពីឥន្ទ្រិយ ៣ មានជីវិតិន្ទ្រិយជាទីបំផុត ១ អំពីឥន្ទ្រិយ ៣ មានអញ្ញាតាវិន្ទ្រិយជាទីបំផុត ១ អំពីការត្រាស់ដឹងតែម្យ៉ាង ១ អំពីឥន្ទ្រិយ ៦ សុទ្ធ ១ អំពីព្រះសោតា ១ អំពីព្រះអរហន្តមាន ២ លើក អំពីសមណព្រាហ្មណ៍មាន ២ លើក ។

# សុខិន្ទ្រិយវគ្គោ

[២៣៧] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោ-មនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

[២៣៨] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោ-មនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[២៣៩] យតោ ខោ ភិក្ខវេ អរិយសាវកោ ឥមេ-សំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សា-ទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។

# សុខិន្ទ្រិយវគ្គ

[២៣៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ[១]នេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាងតើអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ យ៉ាងនេះឯង ។

[២៣៨] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[២៣៩] ម្នាលភិក្ខុទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់តាមពិត នូវហេតុកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវឥន្ទ្រិយ ៥ យ៉ាងនេះឯង ។

១ ប្រែថា ជាអធិបតី (ជាធំ) គឺធម្មជាតទាំងនេះមាននាទីផ្សេងៗគ្នាដូចអារម្មណ៍ជាសុខមានមុខងារទទួលយកខាងសុខ អារម្មណ៍ជាទុក្ខ មានមុខងារខាងទុក្ខ ។ អដ្ឋកថា ។

១៦៧

សុខិន្ទ្រិយវគ្គោ

អយំ វុច្ចតិ ភិក្ខវេ អរិយសាវកោ សោតាបន្នោ អវិនិ-ចាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។

[២៤០] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោ-មនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[២៤១] យតោ ខោ ភិក្ខវេ ភិក្ខុ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អា-ទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោតិ ។

[២៤២] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោ-មនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

សុខិន្ទ្រិយវគ្គ

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កនេះហៅថា សោតាបន្នបុគ្គល មានកិរិយាមិនធ្លាប់ចុះក្នុងអបាយជាធម្មតា ជាបុគ្គលទៀង ជាអ្នកមានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ ។

[២៤០] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[២៤១] ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុដឹងច្បាស់តាមពិតនូវហេតុកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវឥន្ទ្រិយទាំង ៥ នេះហើយ ជាអ្នករួចស្រឡះ (ចាកអាសវៈ) ព្រោះមិនប្រកាន់មាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់ហើយ ជាអ្នករួចស្រឡះ ព្រោះដឹងដោយប្រពៃ ។

[២៤២] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[២៤៣] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ។ នមេតេ[១] ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[២៤៤] យេហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ ។ តេ ខោមេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

---
១ ឱ. ន ច បនេតេ ។

[២៤៣] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមពិត នូវហេតុកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវឥន្ទ្រិយ ៥ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនុ៎ះ មិនសន្មតថាជាសមណៈក្នុងពួកសមណៈ ឬសន្មតថាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ ដ្បិតពួកអ្នកដ៏មានអាយុទាំងនុ៎ះ មិនបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផលឬព្រហ្មញ្ញផល ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[២៤៤] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមពិត នូវហេតុកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញផង នូវឥន្ទ្រិយ ៥ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ ទើបសន្មតថាសមណៈក្នុងពួកសមណៈផង សន្មតថាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ដ្បិតពួកអ្នកដ៏មានអាយុទាំងនោះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផលផង ព្រហ្មញ្ញផលផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

## សុខិន្ទ្រិយវគ្គោ

[២៤៥] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[១៤៦] យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា សុខិន្ទ្រិយំ នប្បជានន្តិ សុខិន្ទ្រិយសមុទយំ នប្បជានន្តិ សុខិន្ទ្រិយនិរោធំ នប្បជានន្តិ សុខិន្ទ្រិយនិរោធគាមិនីបដិបទំ នប្បជានន្តិ ទុក្ខិន្ទ្រិយំ នប្បជានន្តិ ។ សោមនស្សិន្ទ្រិយំ នប្បជានន្តិ ។ ទោមនស្សិន្ទ្រិយំ នប្បជានន្តិ ។ ឧបេក្ខិន្ទ្រិយំ នប្បជានន្តិ ឧបេក្ខិន្ទ្រិយសមុទយំ នប្បជានន្តិ ឧបេក្ខិន្ទ្រិយនិរោធំ នប្បជានន្តិ ឧបេក្ខិន្ទ្រិយនិរោធគាមិនីបដិបទំ នប្បជានន្តិ ។ នមេតេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បនេតេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

## សុខិន្ទ្រិយវគ្គ

[២៤៥] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[២៤៦] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយមិនដឹងច្បាស់នូវសុខិន្ទ្រិយ មិនដឹងច្បាស់នូវហេតុកើតឡើងនៃសុខិន្ទ្រិយ មិនដឹងច្បាស់នូវការរលត់នៃសុខិន្ទ្រិយ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសុខិន្ទ្រិយ មិនដឹងច្បាស់នូវទុក្ខិន្ទ្រិយ ។ មិនដឹងច្បាស់នូវសោមនស្សិន្ទ្រិយ ។ មិនដឹងច្បាស់នូវទោមនស្សិន្ទ្រិយ ។ មិនដឹងច្បាស់នូវឧបេក្ខិន្ទ្រិយ មិនដឹងច្បាស់នូវហេតុកើតឡើងនៃឧបេក្ខិន្ទ្រិយ មិនដឹងច្បាស់នូវការរលត់នៃឧបេក្ខិន្ទ្រិយ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃឧបេក្ខិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនុ៎ះ មិនសន្មតថាសមណៈក្នុងពួកសមណៈ ឬសន្មតថាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ ដ្បិតអ្នកដ៏មានអាយុទាំងនុ៎ះ មិនបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[២៤៧] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា សុខិន្ទ្រិយំ បជានន្តិ សុខិន្ទ្រិយសមុទយំ បជានន្តិ សុខិន្ទ្រិយនិរោធំ បជានន្តិ សុខិន្ទ្រិយនិរោធគាមិនីបដិបទំ បជានន្តិ ទុក្ខិន្ទ្រិយំ បជានន្តិ ។ សោមនស្សិន្ទ្រិយំ បជានន្តិ ។ ទោមនស្សិន្ទ្រិយំ បជានន្តិ ។ ឧបេក្ខិន្ទ្រិយំ បជានន្តិ ឧបេក្ខិន្ទ្រិយសមុទយំ បជានន្តិ ឧបេក្ខិន្ទ្រិយនិរោធំ បជានន្តិ ឧបេក្ខិន្ទ្រិយនិរោធគាមិនីបដិបទំ បជានន្តិ ។ តេ ច ខោមេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[២៤៨] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[២៤៧] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់នូវសុខិន្ទ្រិយ ដឹងច្បាស់នូវហេតុកើតឡើងនៃសុខិន្ទ្រិយ ដឹងច្បាស់នូវការរលត់នៃសុខិន្ទ្រិយ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃសុខិន្ទ្រិយ ដឹងច្បាស់នូវទុក្ខិន្ទ្រិយ ។ ដឹងច្បាស់នូវសោមនស្សិន្ទ្រិយ ។ ដឹងច្បាស់នូវទោមនស្សិន្ទ្រិយ ។ ដឹងច្បាស់នូវឧបេក្ខិន្ទ្រិយ ដឹងច្បាស់នូវហេតុកើតឡើងនៃឧបេក្ខិន្ទ្រិយ ដឹងច្បាស់នូវការរលត់នៃឧបេក្ខិន្ទ្រិយ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់នៃឧបេក្ខិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ ទើបសន្មតថាសមណៈក្នុងពួកសមណៈផង សន្មតថាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង ដ្បិតអ្នកដ៏មានអាយុទាំងនោះ បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវសាមញ្ញផលផង ព្រហ្មញ្ញផលផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។

[២៤៨] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ឥន្ទ្រិយ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

សុខិន្ទ្រិយវគ្គោ

[២៤៩] កតមញ្ច ភិក្ខវេ សុខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ សុខំ កាយិកំ សាតំ កាយសម្ផស្សជំ សុខំ សាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សុខិន្ទ្រិយំ ។

[២៥០] កតមញ្ច ភិក្ខវេ ទុក្ខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខិន្ទ្រិយំ ។

[២៥១] កតមញ្ច ភិក្ខវេ សោមនស្សិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចេតសិកំ សុខំ ចេតសិកំ សាតំ មនោសម្ផស្សជំ សុខំ សាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សោមនស្សិន្ទ្រិយំ ។

## សុខិន្ទ្រិយវគ្គ

[២៤៩] ម្នាលភិក្ខុទាំងឡាយ ចុះសុខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សេចក្តីត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្តីសុខនិងសេចក្តីត្រេកអរនោះ ដែលកើតអំពីកាយសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខិន្ទ្រិយ ។

[២៥០] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីមិនត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្តីទុក្ខ និងសេចក្តីមិនត្រេកអរនោះ ដែលកើតអំពីកាយសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខិន្ទ្រិយ ។

[២៥១] ម្នាលភិក្ខុទាំងឡាយ ចុះសោមនស្សិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សេចក្តីត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងចិត្ត បុគ្គលក៏បានសោយនូវសេចក្តីសុខនិងសេចក្តីត្រេកអរនោះ ដែលកើតអំពីមនោសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សោមនស្សិន្ទ្រិយ ។

[២៤២] កតមញ្ច ភិក្ខវេ ទោមនស្សិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សិន្ទ្រិយំ ។

[២៤៣] កតមញ្ច ភិក្ខវេ ឧបេក្ខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ វា ចេតសិកំ វា នេវសាតំនាសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ឧបេក្ខិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

[២៤៤] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សុខិន្ទ្រិយំ ។ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[២៥២] ម្នាលភិក្ខុទាំងឡាយ ចុះទោមនស្សិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីមិនត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងចិត្ត បុគ្គលក៏បានសោយនូវសេចក្តីទុក្ខនិងសេចក្តីមិនត្រេកអរនោះ ដែលកើតអំពីមនោសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទោមនស្សិន្ទ្រិយ ។

[២៥៣] ម្នាលភិក្ខុទាំងឡាយ ចុះឧបេក្ខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបានសោយនូវអារម្មណ៍ជាទីត្រេកអរក៏មិនមែន មិនជាទីត្រេកអរក៏មិនមែនឯណា ដែលប្រព្រឹត្តទៅក្នុងកាយក្តី ប្រព្រឹត្តទៅក្នុងចិត្តក្តី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបេក្ខិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ យ៉ាងនេះឯង ។

[២៥៤] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ៥ យ៉ាងតើអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

១៧៣

សុខិន្ទ្រិយវគ្គោ

[២៩៥] កតមញ្ច ភិក្ខវេ សុខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ សុខំ កាយិកំ សាតំ កាយ-សម្ផស្សជំ សុខំ សាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សុខិន្ទ្រិយំ ។

[២៩៦] កតមញ្ច ភិក្ខវេ ទុក្ខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយ-សម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខិន្ទ្រិយំ ។

[២៩៧] កតមញ្ច ភិក្ខវេ សោមនស្សិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចេតសិកំ សុខំ ចេតសិកំ សាតំ មនោសម្ផស្សជំ សុខំ សាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សោមនស្សិន្ទ្រិយំ ។

## សុខិន្ទ្រិយវគ្គ

[២៥៥] ម្នាលភិក្ខុទាំងឡាយ ចុះសុខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សេចក្តីត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្តីសុខនិងសេចក្តីត្រេកអរនោះ ដែលកើតអំពីកាយសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខិន្ទ្រិយ ។

[២៥៦] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីមិនត្រេកអរឯណា ដែលប្រ-ព្រឹត្តទៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្តីទុក្ខនិងសេចក្តីត្រេកអរនោះ ដែលកើតអំពីកាយសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខិន្ទ្រិយ ។

[២៥៧] ម្នាលភិក្ខុទាំងឡាយ ចុះសោមនស្សិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សេចក្តីត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងចិត្ត បុគ្គលក៏បានសោយនូវសេចក្តីសុខនិងសេចក្តីត្រេកអរនោះ ដែលកើតអំពីមនោសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សោមនស្សិន្ទ្រិយ ។

[២៤៨] កាតមញ្ច ភិក្ខវេ ទោមនស្សិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សិន្ទ្រិយំ ។

[២៤៩] កាតមញ្ច ភិក្ខវេ ឧបេក្ខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ វា ចេតសិកំ វា នេវសាតំនាសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ឧបេក្ខិន្ទ្រិយំ ។

[២៦០] តត្រ ភិក្ខវេ យញ្ច សុខិន្ទ្រិយំ យញ្ច សោមនស្សិន្ទ្រិយំ សុខា សា វេទនា ទដ្ឋព្វា ។

[២៦១] តត្រ ភិក្ខវេ យញ្ច ទុក្ខិន្ទ្រិយំ យញ្ច ទោមនស្សិន្ទ្រិយំ ទុក្ខា សា វេទនា ទដ្ឋព្វា ។

[២៦២] តត្រ ភិក្ខវេ យទិទំ ឧបេក្ខិន្ទ្រិយំ អ-ទុក្ខមសុខា សា វេទនា ទដ្ឋព្វា ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានីតិ ។

[២៥៨] ម្នាលភិក្ខុទាំងឡាយ ចុះទោមនស្សិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីមិនត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងចិត្ត បុគ្គលក៏បានសោយនូវសេចក្តីទុក្ខនិងសេចក្តីមិនត្រេកអរនោះ ដែលកើតអំពីមនោសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា ទោមនស្សិន្ទ្រិយ ។

[២៥៩] ម្នាលភិក្ខុទាំងឡាយ ចុះឧបេក្ខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបានសោយនូវអារម្មណ៍ជាទីត្រេកអរក៏មិនមែន មិនជាទីត្រេកអរក៏មិនមែនឯណា ដែលប្រព្រឹត្តទៅក្នុងកាយក្តីប្រព្រឹត្តទៅក្នុងចិត្តក្តី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបេក្ខិន្ទ្រិយ ។

[២៦០] ម្នាលភិក្ខុទាំងឡាយ បណ្តាឥន្ទ្រិយទាំងនោះ សុខិន្ទ្រិយនិងសោមនស្សិន្ទ្រិយ បណ្ឌិតគប្បីឃើញថា ជាសុខវេទនា ។

[២៦១] ម្នាលភិក្ខុទាំងឡាយ បណ្តាឥន្ទ្រិយទាំងនោះ ទុក្ខិន្ទ្រិយនិងទោមនស្សិន្ទ្រិយ បណ្ឌិតគប្បីឃើញថាជាទុក្ខវេទនា ។

[២៦២] ម្នាលភិក្ខុទាំងឡាយ បណ្តាឥន្ទ្រិយទាំងនោះ ឧបេក្ខិន្ទ្រិយនេះ បណ្ឌិតគប្បីឃើញថា ជាអទុក្ខសុខវេទនា ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ យ៉ាងនេះឯង ។

១៧៤

សុខិន្ទ្រិយវគ្គោ

[២៦៣] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោ-មនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[២៦៤] កតមញ្ច ភិក្ខវេ សុខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ សុខំ កាយិកំ សាតំ កាយសម្ផ-ស្សជំ សុខំ សាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សុខិន្ទ្រិយំ ។

[២៦៥] កតមញ្ច ភិក្ខវេ ទុក្ខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយ-សម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខិន្ទ្រិយំ ។

[២៦៦] កតមញ្ច ភិក្ខវេ សោមនស្សិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចេតសិកំ សុខំ ចេតសិកំ សាតំ មនោសម្ផស្សជំ សុខំ សាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ សោមនស្សិន្ទ្រិយំ ។

## សុខិន្ទ្រិយវគ្គ

[២៦៣] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ៥ យ៉ាងតើអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[២៦៤] ម្នាលភិក្ខុទាំងឡាយ ចុះសុខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សេចក្តីត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្តីសុខនិងសេចក្តីត្រេកអរនោះ ដែលកើតអំពីកាយសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុខិន្ទ្រិយ ។

[២៦៥] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីមិនត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងកាយ បុគ្គលក៏បានសោយនូវសេចក្តីទុក្ខនិងសេចក្តីមិនត្រេកអរនោះ ដែលកើតអំពីកាយសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខិន្ទ្រិយ ។

[២៦៦] ម្នាលភិក្ខុទាំងឡាយ ចុះសោមនស្សិន្ទ្រិយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សេចក្តីត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងចិត្ត បុគ្គលបានសោយនូវសេចក្តីសុខនិងសេចក្តីត្រេកអរនោះ ដែលកើតអំពីមនោសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សោមនស្សិន្ទ្រិយ ។

[២៦៧] កតមញ្ច ភិក្ខវេ ទោមនស្សិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សិន្ទ្រិយំ ។

[២៦៨] កតមញ្ច ភិក្ខវេ ឧបេក្ខិន្ទ្រិយំ ។ យំ ខោ ភិក្ខវេ កាយិកំ វា ចេតសិកំ វា នេវសាតំនាសាតំ វេទយិតំ ។ ឥទំ វុច្ចតិ ភិក្ខវេ ឧបេក្ខិន្ទ្រិយំ ។

[២៦៩] តត្រ ភិក្ខវេ យញ្ច សុខិន្ទ្រិយំ យញ្ច សោមនស្សិន្ទ្រិយំ សុខា សា វេទនា ទដ្ឋព្វា ។

[២៧០] តត្រ ភិក្ខវេ យញ្ច ទុក្ខិន្ទ្រិយំ យញ្ច ទោមនស្សិន្ទ្រិយំ ទុក្ខា សា វេទនា ទដ្ឋព្វា ។

[២៧១] តត្រ ភិក្ខវេ យទិទំ ឧបេក្ខិន្ទ្រិយំ អទុក្ខមសុខា សា វេទនា ទដ្ឋព្វា ។ ឥតិ ខោ ភិក្ខវេ ឥមានិ បញ្ចិន្ទ្រិយានិ បញ្ច ហុត្វា តីណិ ហោន្តិ តីណិ ហុត្វា បញ្ច ហោន្តិ បរិយាយេនាតិ ។

[២៦៧] ម្នាលភិក្ខុទាំងឡាយ ចុះទោមនស្សិន្ទ្រិយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីទុក្ខ សេចក្ដីមិនត្រេកអរឯណា ដែលប្រព្រឹត្តទៅក្នុងចិត្ត បុគ្គលបានសោយនូវសេចក្ដីទុក្ខនិងសេចក្ដីមិនត្រេកអរនោះ ដែលកើតអំពីមនោសម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទោមនស្សិន្ទ្រិយ ។

[២៦៨] ម្នាលភិក្ខុទាំងឡាយ ចុះឧបេក្ខិន្ទ្រិយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបានសោយនូវអារម្មណ៍ជាទីត្រេកអរក៏មិនមែន មិនជាទីត្រេកអរក៏មិនមែនឯណា ដែលប្រព្រឹត្តទៅក្នុងកាយក្ដី ប្រព្រឹត្តទៅក្នុងចិត្តក្ដី ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧបេក្ខិន្ទ្រិយ ។

[២៦៩] ម្នាលភិក្ខុទាំងឡាយ បណ្ដាឥន្ទ្រិយទាំងនោះ សុខិន្ទ្រិយ និងសោមនស្សិន្ទ្រិយ បណ្ឌិតគប្បីឃើញថាជាសុខវេទនា ។

[២៧០] ម្នាលភិក្ខុទាំងឡាយ បណ្ដាឥន្ទ្រិយទាំងនោះ ទុក្ខិន្ទ្រិយ និងទោមនស្សិន្ទ្រិយ បណ្ឌិតគប្បីឃើញថាជាទុក្ខវេទនា ។

[២៧១] ម្នាលភិក្ខុទាំងឡាយ បណ្ដាឥន្ទ្រិយទាំងនោះ ឧបេក្ខិន្ទ្រិយនេះ បណ្ឌិតគប្បីឃើញថាជាអទុក្ខមសុខវេទនា ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ យ៉ាងនេះ ចែកជា ៥ ឬបំប្រួញមកជា ៣ ក៏បាន ឬ ៣ ចែកជា ៥ ក៏បាន ដោយបរិយាយដូច្នេះឯង ។

១៧៧

សុខិន្ទ្រិយវគ្គោ

[២៧២] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោ-មនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

[២៧៣] សុខវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្ប-ជ្ជតិ សុខិន្ទ្រិយំ ។ សោ សុខិតោវ សមានោ សុខិ-តោស្មីតិ បជានាតិ តស្សេវ សុខវេទនិយស្ស ផស្សស្ស និរោធា យន្តជ្ជំ វេទយិតំ សុខវេទនិយំ ផស្សំ បដិច្ច ឧប្បន្នំ សុខិន្ទ្រិយំ តំ និរុជ្ឈតិ តំ វូបសមតីតិ បជា-ជាតិ ។

[២៧៤] ទុក្ខវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្ប-ជ្ជតិ ទុក្ខិន្ទ្រិយំ ។ សោ ទុក្ខិតោវ សមានោ ទុក្ខិតោ-ស្មីតិ បជានាតិ តស្សេវ ទុក្ខវេទនិយស្ស ផស្សស្ស និរោធា យន្តជ្ជំ វេទយិតំ ទុក្ខវេទនិយំ ផស្សំ បដិច្ច ឧប្បន្នំ ទុក្ខិន្ទ្រិយំ តំ និរុជ្ឈតិ តំ វូបសមតីតិ បជា-ជាតិ ។

## សុខិន្ទ្រិយវគ្គ

[២៧២] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[២៧៣] ម្នាលភិក្ខុទាំងឡាយ សុខិន្ទ្រិយកើតឡើង ព្រោះអាស្រ័យនូវផស្សៈ ដែលជាបច្ច័យនៃសុខវេទនា ។ បុគ្គលនោះកាលបើដល់នូវសេចក្តីសុខ ក៏រមែងដឹងច្បាស់ថា អាត្មាអញជាអ្នកដល់នូវសេចក្តីសុខ រមែងដឹងច្បាស់ថា សុខិន្ទ្រិយឯណា កើតឡើងហើយព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃសុខវេទនាកើតអំពីផស្សៈនោះ ដែលបុគ្គលបានសោយហើយ សុខិន្ទ្រិយនោះក៏រលត់ទៅ សុខិន្ទ្រិយនោះក៏ស្ងប់រម្ងាប់ទៅ ព្រោះរលត់ផស្សៈជាបច្ច័យនៃសុខវេទនានោះឯង ។

[២៧៤] ម្នាលភិក្ខុទាំងឡាយ ទុក្ខិន្ទ្រិយកើតឡើង ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃទុក្ខវេទនា ។ បុគ្គលនោះកាលបើដល់នូវសេចក្តីទុក្ខ ក៏រមែងដឹងច្បាស់ថា អាត្មាអញជាអ្នកដល់នូវសេចក្តីទុក្ខ រមែងដឹងច្បាស់ថា ទុក្ខិន្ទ្រិយឯណា កើតឡើងហើយ ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃទុក្ខវេទនាកើតអំពីផស្សៈនោះ ដែលបុគ្គលបានសោយហើយ ទុក្ខិន្ទ្រិយនោះក៏រលត់ទៅ ទុក្ខិន្ទ្រិយនោះក៏ស្ងប់រម្ងាប់ទៅ ព្រោះរលត់ផស្សៈជាបច្ច័យនៃទុក្ខវេទនានោះឯង ។

[២៧៥] សោមនស្សវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ សោមនស្សិន្ទ្រិយំ ។ សោ សុមនោ វ សមានោ សុមនោស្មីតិ បជានាតិ តស្សេវ សោមនស្សវេទនិយស្ស ផស្សស្ស និរោធា យន្តជ្ជំ វេទយិតំ សោមនស្សវេទនិយំ ផស្សំ បដិច្ច ឧប្បន្នំ សោមនស្សិន្ទ្រិយំ តំ និរុជ្ឈតិ តំ វូបសមតីតិ បជានាតិ ។

[២៧៦] ទោមនស្សវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ ទោមនស្សិន្ទ្រិយំ ។ សោ ទុម្មនោ វ សមានោ ទុម្មនោស្មីតិ បជានាតិ តស្សេវ ទោមនស្សវេទនិយស្ស ផស្សស្ស និរោធា យន្តជ្ជំ វេទយិតំ ទោមនស្សវេទនិយំ ផស្សំ បដិច្ច ឧប្បន្នំ ទោមនស្សិន្ទ្រិយំ តំ និរុជ្ឈតិ តំ វូបសមតីតិ បជានាតិ ។

[២៧៥] ម្នាលភិក្ខុទាំងឡាយ សោមនស្សិន្ទ្រិយកើតឡើង ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃសោមនស្សវេទនា ។ បុគ្គលនោះ កាលបើមានចិត្តរីករាយ ក៏រមែងដឹងច្បាស់ថា អាត្មាអញជាអ្នកមានចិត្ត រីករាយ រមែងដឹងច្បាស់ថា សោមនស្សិន្ទ្រិយឯណាកើតឡើងហើយ ព្រោះអាស្រ័យនូវផស្សៈ ជាបច្ច័យនៃសោមនស្សវេទនាកើតអំពីផស្សៈ នោះ ដែលបុគ្គលបានសោយហើយ សោមនស្សិន្ទ្រិយនោះក៏រលត់ទៅ សោមនស្សិន្ទ្រិយនោះក៏ស្ងប់រម្ងាប់ទៅ ព្រោះរលត់ផស្សៈជាបច្ច័យនៃ សោមនស្សវេទនានោះឯង ។

[២៧៦] ម្នាលភិក្ខុទាំងឡាយ ទោមនស្សិន្ទ្រិយរមែងកើតឡើង ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃទោមនស្សវេទនា ។ បុគ្គលនោះ កាលបើតូចចិត្តក៏រមែងដឹងច្បាស់ថា អាត្មាអញជាអ្នកតូចចិត្ត រមែងដឹង ច្បាស់ថា ទោមនស្សិន្ទ្រិយឯណា កើតឡើងហើយ ព្រោះអាស្រ័យ នូវផស្សៈជាបច្ច័យនៃទោមនស្សវេទនាកើតអំពីផស្សៈនោះ ដែលបុគ្គល បានសោយហើយ ទោមនស្សិន្ទ្រិយនោះក៏រលត់ទៅ ទោមនស្សិន្ទ្រិយ នោះក៏ស្ងប់រម្ងាប់ទៅ ព្រោះរលត់ផស្សៈជាបច្ច័យនៃទោមនស្សវេទនា នោះឯង ។

## សុខិន្ទ្រិយវគ្គោ

[២៧៧] ឧបេក្ខាវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ ឧបេក្ខិន្ទ្រិយំ ។ សោ ឧបេក្ខកោ វ សមានោ ឧបេក្ខកោស្មីតិ បជានាតិ តស្សេវ ឧបេក្ខាវេទនិយស្ស ផស្សស្ស និរោធាយន្តជ្ជំ វេទយិតំ ឧបេក្ខាវេទនិយំ ផស្សំ បដិច្ច ឧប្បន្នំ ឧបេក្ខិន្ទ្រិយំ តំ និរុជ្ឈតិ តំ វូបសមតីតិ បជានាតិ ។

[២៧៨] សេយ្យថាបិ ភិក្ខវេ ទ្វិន្នំ កដ្ឋានំ សង្ឃដ្ដនសមោធានា ឧស្មា ជាយតិ តេជោ អភិនិព្វត្តតិ តេសំ យេវ កដ្ឋានំ នានាភាវនិក្ខេចាយា តជ្ជា ឧស្មា សា និរុជ្ឈតិ[១] វូបសមតិ ។ ឯវមេវ ខោ ភិក្ខវេ សុខវេទនិយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខិន្ទ្រិយំ ។ សោ សុខិតោវ សមានោ សុខិតោស្មីតិ បជានាតិ តស្សេវ សុខវេទនិយស្ស ផស្សស្ស និរោធា យន្តជ្ជំ វេទយិ តំ សុខវេទនិយំ ផស្សំ បដិច្ច ឧប្បន្នំ[២]

---
១ឱ. ម. ឯត្ថន្តរេសោឥតិសទ្ទោអត្ថិ។២ម. ឧប្បជ្ជតិ។

## សុខិន្ទ្រិយវគ្គ

[២៧៧] ម្នាលភិក្ខុទាំងឡាយ ឧបេក្ខិន្ទ្រិយកើតឡើង ព្រោះអាស្រ័យនូវផស្សៈ ជាបច្ច័យនៃឧបេក្ខាវេទនា ។ បុគ្គលនោះ កាលបើមានចិត្តព្រងើយក៏រមែងដឹងច្បាស់ថា អាត្មាអញជាអ្នកមានចិត្តព្រងើយ រមែងដឹងច្បាស់ថា ឧបេក្ខិន្ទ្រិយឯណាកើតឡើងហើយ ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃឧបេក្ខាវេទនាកើតអំពីផស្សៈនោះ ដែលបុគ្គលបានសោយហើយ ឧបេក្ខិន្ទ្រិយនោះ ក៏រលត់ទៅឧបេក្ខិន្ទ្រិយនោះ ក៏ស្ងប់រម្ងាប់ទៅ ព្រោះរលត់ផស្សៈជាបច្ច័យនៃឧបេក្ខាវេទនានោះឯង ។

[២៧៨] ម្នាលភិក្ខុទាំងឡាយ ដូចចំហាយកើតឡើងភ្លើងរមែងកើតឡើង ព្រោះការពួតនិងប្រជុំចុះនៃឈើពំនួតពីរកំណាត់ ចំហាយឯណាដែលកើតឡើងអំពីឈើពំនួតនោះ ចំហាយនោះក៏រលត់ស្ងប់រម្ងាប់ទៅព្រោះដាក់ឈើពំនួតទាំងនោះទីទៃពីគ្នា យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សុខិន្ទ្រិយកើតឡើង ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃសុខវេទនា ។ បុគ្គលនោះ កាលបើដល់នូវសេចក្តីសុខ ក៏រមែងដឹងច្បាស់ថា អាត្មាអញជាអ្នកដល់នូវសេចក្តីសុខ រមែងដឹងច្បាស់ថា សុខិន្ទ្រិយឯណាកើតឡើងហើយ ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃសុខវេទនាកើតអំពីផស្សៈនោះ ដែលបុគ្គលបានសោយហើយ

សុខិន្ទ្រិយំ តំ និរុជ្ឈតិ តំ វូបសមតីតិ បជានាតិ ។ ទុក្ខវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ។ បេ ។ សោមនស្សវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ។ ទោមនស្សវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ។ ឧបេក្ខាវេទនិយំ ភិក្ខវេ ផស្សំ បដិច្ច ឧប្បជ្ជតិ ឧបេក្ខិន្ទ្រិយំ ។ សោ ឧបេក្ខកោ វ សមានោ ឧបេក្ខកោស្មីតិ បជានាតិ តស្សេវ ឧបេក្ខាវេទនិយស្ស ផស្សស្ស និរោធា យន្តជ្ជំ វេទនិយំ ឧបេក្ខាវេទនិយំ ផស្សំ បដិច្ច ឧប្បន្នំ ឧបេក្ខិន្ទ្រិយំ តំ និរុជ្ឈតិ តំ វូបសមតីតិ បជានាតីតិ ។

[២៧៩] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ បញ្ច ។ ទុក្ខិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ សុខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ ។

សុខិន្ទ្រិយនោះក៏រលត់ទៅ សុខិន្ទ្រិយនោះក៏ស្ងប់រម្ងាប់ទៅ ព្រោះរលត់ផស្សៈជាបច្ច័យនៃសុខវេទនានោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃទុក្ខវេទនា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃសោមនស្សវេទនា ។ ម្នាលភិក្ខុទាំង-ឡាយ ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃទោមនស្សវេទនា ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខិន្ទ្រិយកើតឡើងព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃឧបេក្ខាវេទនា ។ បុគ្គលនោះកាលបើមានចិត្តព្រងើយ ក៏រមែងដឹងច្បាស់ថា អាត្មាអញជាអ្នកមានចិត្តព្រងើយ រមែងដឹងច្បាស់ថា ឧបេក្ខិន្ទ្រិយឯណាកើតឡើងហើយ ព្រោះអាស្រ័យនូវផស្សៈជាបច្ច័យនៃឧបេក្ខាវេទនាកើតអំពីផស្សៈនោះ ដែលបុគ្គលបានសោយហើយ ឧបេ-ក្ខិន្ទ្រិយនោះក៏រលត់ទៅ ឧបេក្ខិន្ទ្រិយនោះក៏ស្ងប់រម្ងាប់ទៅ ព្រោះរលត់ផស្សៈជាបច្ច័យនៃឧបេក្ខាវេទនានោះឯង យ៉ាងនោះដែរ ។

[២៧៩] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ។ ៥ យ៉ាងគឺដូចម្តេច ។ គឺទុក្ខិន្ទ្រិយ១ ទោមនស្សិន្ទ្រិយ ១ សុខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

១៨១

## សុខិន្ទ្រិយវគ្គោ

[២៨០] ឥធ ភិក្ខវេ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ ទុក្ខិន្ទ្រិយំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ ទុក្ខិន្ទ្រិយំ តញ្ច ខោ សនិមិត្តំ សនិទានំ សសង្ខារំ សប្បច្ចយំ តញ្ច អនិមិត្តំ អនិទានំ អសង្ខារំ អប្បច្ចយំ ទុក្ខិន្ទ្រិយំ ឧប្បជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ សោ ទុក្ខិន្ទ្រិយញ្ច បជានាតិ ទុក្ខិន្ទ្រិយសមុទយញ្ច បជានាតិ ទុក្ខិន្ទ្រិយនិរោធញ្ច បជានាតិ យត្ថ ចុប្បន្នំ ទុក្ខិន្ទ្រិយំ អបរិសេសិ និរុជ្ឈតិ តញ្ច បជានាតិ ។ កត្ថ[១] ចុប្បន្នំ ទុក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯត្ថ ចុប្បន្នំ ទុក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អញ្ញាសិ ទុក្ខិន្ទ្រិយស្ស និរោធំ តទត្ថាយ ចិត្តំ ឧបសំហរតិ[២] ។

---

១ ម. តត្ថ ។ ២ ឱ. ឧបសំហាសិ ។

## សុខិន្ទ្រិយវគ្គ

[២៨០] ម្នាលភិក្ខុទាំងឡាយ ទុក្ខិន្ទ្រិយ រមែងកើតឡើងដល់ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ភិក្ខុនោះក៏ដឹងច្បាស់យ៉ាងនេះថា ទុក្ខិន្ទ្រិយនេះកើតឡើងហើយ ដល់អាត្មាអញ ទុក្ខិន្ទ្រិយនោះឯងប្រកបដោយនិមិត្ត ប្រកបដោយហេតុ ប្រកបដោយសង្ខារ ប្រកបដោយបច្ច័យ ឯទុក្ខិន្ទ្រិយនោះ មិនមាននិមិត្ត មិនមានហេតុ មិនមានសង្ខារ មិនមានបច្ច័យ នឹងកើតឡើង ហេតុនុ៎ះមិនមានទេ ។ ភិក្ខុនោះដឹងច្បាស់ នូវទុក្ខិន្ទ្រិយផង ដឹងច្បាស់នូវហេតុកើតឡើងនៃទុក្ខិន្ទ្រិយផង ដឹងច្បាស់នូវការរលត់ទៅនៃទុក្ខិន្ទ្រិយផង ទុក្ខិន្ទ្រិយកើតឡើងហើយក្នុងទីឯណា ក៏រលត់ទៅឥតមានសេសសល់ ក៏ដឹងច្បាស់នូវទីនោះផង ។ ចុះទុក្ខិន្ទ្រិយកើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ រមែងចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខ ដែលកើតអំពីវិវេក ។ ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ដឹងច្បាស់នូវការរលត់ទៅនៃទុក្ខិន្ទ្រិយ ប្រមូលមកនូវចិត្តដើម្បីសេចក្តីពិត ។

[២៩១] ឥធ បន ភិក្ខវេ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ ទោមនស្សិន្ទ្រិយំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ ទោមនស្សិន្ទ្រិយំ តញ្ច ខោ សនិមិត្តំ សនិទានំ សសង្ខារំ សប្បច្ចយំ តញ្ច[១] អនិមិត្តំ អនិទានំ អសង្ខារំ អប្បច្ចយំ ទោមនស្សិន្ទ្រិយំ ឧប្បជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ សោ ទោមនស្សិន្ទ្រិយញ្ច បជានាតិ ទោមនស្សិន្ទ្រិយសមុទយញ្ច បជានាតិ ទោមនស្សិន្ទ្រិយនិរោធញ្ច បជានាតិ យត្ថ ចុប្បន្នំ ទោមនស្សិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ តញ្ច បជានាតិ ។ កត្ថ ចុប្បន្នំ ទោមនស្សិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ ឥធ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯត្ថ ចុប្បន្នំ ទោមនស្សិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។

---

១ ឱ. តំ វត ។

[២៨១] ម្នាលភិក្ខុទាំងឡាយ ទោមនស្សិន្ទ្រិយ រមែងកើតឡើងដល់ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ភិក្ខុនោះក៏ដឹងច្បាស់យ៉ាងនេះថា ទោមនស្សិន្ទ្រិយនេះកើតឡើងហើយដល់អាត្មាអញ ទោ-មនស្សិន្ទ្រិយនោះឯង ប្រកបដោយនិមិត្ត ប្រកបដោយហេតុ ប្រកបដោយសង្ខារ ប្រកបដោយបច្ច័យ ឯទោមនស្សិន្ទ្រិយនោះ មិនមាននិមិត្ត មិនមានហេតុ មិនមានសង្ខារ មិនមានបច្ច័យ នឹងកើតឡើង ហេតុនុ៎ះមិនមានទេ ។ ភិក្ខុនោះរមែងដឹងច្បាស់នូវទោមនស្សិន្ទ្រិយផង ដឹងច្បាស់នូវហេតុកើតឡើងនៃទោមនស្សិន្ទ្រិយផង ដឹងច្បាស់នូវការរលត់ទៅនៃទោមនស្សិន្ទ្រិយផង មួយវិញទៀត ទោមនស្សិន្ទ្រិយកើតឡើងក្នុងទីឯណា រមែងរលត់ទៅឥតមានសេសសល់ ក៏ដឹងច្បាស់នូវទីនោះផង ។ ចុះទោមនស្សិន្ទ្រិយកើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះស្ងប់ស្ងាត់នៃវិតក្កៈនិងវិចារៈ រមែងចូលកាន់ទុតិយជ្ឈានមានសេចក្តីជ្រះថ្លាខាំងក្នុងសន្តាន មានភាពនៃចិត្តដ៏ខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ។ ទោមនស្សិន្ទ្រិយកើតឡើងក្នុងទុតិយជ្ឈាននេះតែងរលត់ទៅឥតមានសេសសល់ ។

សុខិន្ទ្រិយវគ្គោ

អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អញ្ញាសិ ទោមនស្សិន្ទ្រិយស្សនិរោធំ តថត្តាយ ចិត្តំ ឧបសំហរតិ ។

[២៨២] ឥធ បន ភិក្ខវេ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិសុខិន្ទ្រិយំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ សុខិន្ទ្រិយំ តញ្ច ខោ សនិមិត្តំ សនិទានំ សសង្ខារំ សប្បច្ចយំ តញ្ច អនិមិត្តំ អនិទានំ អសង្ខារំ អប្បច្ចយំ សុខិន្ទ្រិយំ ឧប្បជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ សោ សុខិន្ទ្រិយញ្ច បជានាតិ សុខិន្ទ្រិយសមុទយញ្ច បជានាតិ សុខិន្ទ្រិយនិរោធញ្ច បជានាតិ យត្ថ ចុប្បន្នំ សុខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ តញ្ច បជានាតិ ។ កត្ថ ចុប្បន្នំ សុខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ ឥធ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ដឹងច្បាស់នូវការរលត់ទៅនៃទោ-មនស្សិន្ទ្រិយ ប្រមូលមកនូវចិត្តដើម្បីសេចក្តីពិត ។

[២៨២] ម្នាលភិក្ខុទាំងឡាយ ចំណែកសុខិន្ទ្រិយ រមែងកើតឡើងដល់ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ភិក្ខុនោះក៏ដឹងច្បាស់យ៉ាងនេះថា សុខិន្ទ្រិយនេះកើតឡើងហើយ ដល់អាត្មាអញ សុខិន្ទ្រិយនោះឯង ប្រកបដោយនិមិត្ត ប្រកបដោយហេតុ ប្រកបដោយសង្ខារ ប្រកបដោយបច្ច័យ ឯសុខិន្ទ្រិយនោះមិនមាននិមិត្ត មិនមានហេតុ មិនមានសង្ខារ មិនមានបច្ច័យ នឹងកើតឡើង ហេតុនុ៎ះមិនមានឡើយ ។ ភិក្ខុនោះក៏ដឹងច្បាស់នូវសុខិន្ទ្រិយផង ដឹងច្បាស់នូវហេតុកើតឡើងនៃសុខិន្ទ្រិយផង ដឹងច្បាស់នូវការរលត់ទៅនៃសុខិន្ទ្រិយផង មួយវិញទៀត សុខិន្ទ្រិយកើតឡើងក្នុងទីឯណា រមែងរលត់ទៅឥតមានសេសសល់ ក៏ដឹងច្បាស់នូវទីនោះផង ។ ចុះសុខិន្ទ្រិយកើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសា-សនានេះ ព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង ទទួលនូវសុខដោយនាមកាយផង

យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហា-
រីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯត្ថ ចុប្បន្នំ
សុខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ អយំ វុច្ចតិ ភិក្ខវេ
ភិក្ខុ អញ្ញាសិ សុខិន្ទ្រិយស្ស និរោធំ តទត្ថាយ ចិត្តំ
ឧបសំហរតិ ។

[២៨៣] ឥធ បន ភិក្ខវេ ភិក្ខុនោ អប្បមត្តស្ស
អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ សោ-
មនស្សិន្ទ្រិយំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ
មេ ឥទំ សោមនស្សិន្ទ្រិយំ តញ្ច ខោ សនិមិត្តំ ស-
និទានំ សសង្ខារំ សប្បច្ចយំ តញ្ច អនិមិត្តំ អនិទានំ
អសង្ខារំ អប្បច្ចយំ សោមនស្សិន្ទ្រិយំ ឧប្បជ្ជិស្សតីតិ
នេតំ ឋានំ វិជ្ជតីតិ ។ សោ សោមនស្សិន្ទ្រិយញ្ច បជា-
នាតិ សោមនស្សិន្ទ្រិយសមុទយញ្ច បជានាតិ សោ-
មនស្សិន្ទ្រិយនិរោធញ្ច បជានាតិ យត្ថ ចុប្បន្នំ សោម-
នស្សិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ តញ្ច បជានាតិ ។

ព្រះអរិយទាំងឡាយ តែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ចូលកាន់តតិយជ្ឈាននោះហើយសម្រេចសម្រាន្តនៅ ។ សុខិន្ទ្រិយកើតឡើងក្នុងតតិយជ្ឈាននុ៎ះ រមែងរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ដឹងច្បាស់នូវការរលត់នៃសុខិន្ទ្រិយ ប្រមូលមកនូវចិត្តដើម្បីសេចក្តីពិត ។

[២៨៣] ម្នាលភិក្ខុទាំងឡាយ សោមនស្សិន្ទ្រិយតែងកើតឡើងដល់ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ភិក្ខុនោះ រមែងដឹងច្បាស់យ៉ាងនេះថា សោមនស្សិន្ទ្រិយនេះកើតឡើងហើយដល់អាត្មាអញ សោ-មនស្សិន្ទ្រិយនោះឯង ប្រកបដោយនិមិត្ត ប្រកបដោយហេតុ ប្រកបដោយសង្ខារ ប្រកបដោយបច្ច័យ ឯសោមនស្សិន្ទ្រិយនោះ មិនមាននិមិត្ត មិនមានហេតុ មិនមានសង្ខារ មិនមានបច្ច័យ នឹងកើតឡើងហេតុនុ៎ះមិនមានឡើយ ។ ភិក្ខុនោះដឹងច្បាស់នូវសោមនស្សិន្ទ្រិយផង ដឹងច្បាស់នូវហេតុកើតឡើងនៃសោមនស្សិន្ទ្រិយផង ដឹងច្បាស់នូវការរលត់នៃសោមនស្សិន្ទ្រិយផង មួយវិញទៀត សោមនស្សិន្ទ្រិយកើតឡើងក្នុងទីឯណា រមែងរលត់ទៅឥតមានសេសសល់ ក៏ដឹងច្បាស់នូវទីនោះផង ។

សុខិន្ទ្រិយវគ្គោ

កាត្ថ ចុប្បន្នំ សោមនស្សិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ ឥធ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧប-សម្បជ្ជ វិហរតិ ។ ឯត្ថ ចុប្បន្នំ សោមនស្សិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អញ្ញាសិ សោមនស្សិន្ទ្រិយស្ស និរោធំ តថត្តាយ ចិត្តំ ឧបសំហរតិ ។

[២៨៤] ឥធ បន ភិក្ខវេ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ឧប្បជ្ជតិ ឧបេ-ក្ខិន្ទ្រិយំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ ឧបេក្ខិន្ទ្រិយំ តញ្ច ខោ សនិមិត្តំ សនិទា-នំ សសង្ខារំ សប្បច្ចយំ តញ្ច ខោ អនិមិត្តំ អ-និទានំ អសង្ខារំ អប្បច្ចយំ ឧបេក្ខិន្ទ្រិយំ ឧប្បជ្ជិ-ស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ សោ ឧបេក្ខិន្ទ្រិ-យញ្ច បជានាតិ ឧបេក្ខិន្ទ្រិយសមុទយញ្ច បជានាតិ

ចុះសោមនស្សិន្ទ្រិយកើតឡើងក្នុងទីដូចម្តេច ទើបរលត់ឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង ចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខាហើយសម្រេចសម្រាន្តនៅ ។ សោមនស្សិន្ទ្រិយកើតឡើងហើយក្នុងចតុត្ថជ្ឈាននុ៎ះ ទើបរលត់ទៅ ឥតមានសេសសល់ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនេះហៅថា ដឹងច្បាស់នូវការរលត់ទៅនៃសោមនស្សិន្ទ្រិយប្រមូលមកនូវចិត្តដើម្បីសេចក្តីពិត ។

[២៨២] ម្នាលភិក្ខុទាំងឡាយ ឧបេក្ខិន្ទ្រិយរមែងកើតឡើងដល់ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅនូវកិលេសមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថាឧបេក្ខិន្ទ្រិយនេះកើតឡើងហើយដល់អាត្មាអញ ឧបេក្ខិន្ទ្រិយនោះឯង ប្រ-កបដោយនិមិត្ត ប្រកបដោយហេតុ ប្រកបដោយសង្ខារ ប្រកបដោយបច្ច័យ ឯឧបេក្ខិន្ទ្រិយនោះ មិនមាននិមិត្ត មិនមានហេតុ មិនមានសង្ខារ មិនមានបច្ច័យ នឹងកើតឡើង ហេតុនុ៎ះមិនមានឡើយ ។ ភិក្ខុនោះដឹងច្បាស់នូវឧបេក្ខិន្ទ្រិយផង ដឹងច្បាស់នូវហេតុកើតឡើងនៃឧបេក្ខិន្ទ្រិយផង

ឧបេក្ខិន្ទ្រិយនិរោធញ្ច បជានាតិ យត្ថ ចុប្បន្នំ ឧ-
បេក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ តញ្ច បជានាតិ ។
កត្ថ ចុប្បន្នំ ឧបេក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។ ឥធ
ភិក្ខវេ ភិក្ខុ សព្វសោ នេវសញ្ញានាសញ្ញាយតនំ ស-
មតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។
ឯត្ថ ចុប្បន្នំ ឧបេក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ ។
អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អញ្ញាសិ ឧបេក្ខិន្ទ្រិយស្ស
និរោធំ តថត្តាយ ចិត្តំ ឧបសំហរតីតិ ។

សុខិន្ទ្រិយវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

សុទ្ធកញ្ច[១] សោតោ អរហា[២]
ទ្វេ សមណព្រាហ្មណោ[៣] ច
វិភង្គេន តយោ វុត្តា
អរហាតោ[៤] ឧប្បដិកេន ចាតិ ។

១ ឱ. ម. សុទ្ធិកញ្ច ។ ២ អរហំ ។ ៣ សមណព្រាហ្មណា ។ ៤ អរណិ ។

ដឹងច្បាស់នូវការរលត់ទៅនៃឧបេក្ខិន្ទ្រិយផង មួយវិញទៀត ឧបេក្ខិន្ទ្រិយកើតឡើងក្នុងទីឯណា រមែងរលត់ទៅឥតមានសេសសល់ ក៏ដឹងច្បាស់នូវទីនោះផង ។ ចុះឧបេក្ខិន្ទ្រិយ កើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កន្លងនូវនេវសញ្ញានាសញ្ញាយតនៈដោយសព្វគ្រប់ ហើយចូលកាន់សញ្ញាវេទយិតនិរោធ ។ ឧបេក្ខិន្ទ្រិយកើតឡើងក្នុងសញ្ញាវេទយិតនិរោធនុ៎ះ ទើបរលត់ទៅឥតមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ដឹងច្បាស់នូវការរលត់ទៅនៃឧបេក្ខិន្ទ្រិយ ប្រមូលមកនូវចិត្តដើម្បីសេចក្តីពិត ។

ចប់ សុខិន្ទ្រិយវគ្គទី ៤ ។

## ឧទ្ទាននៃសុខិន្ទ្រិយវគ្គនោះគឺ

និយាយអំពីឥន្ទ្រិយសុទ្ធ ១ អំពីសោតាបន្នបុគ្គល ១ អំពីភិក្ខុជាអរហន្ត ១ អំពីសមណព្រាហ្មណ៍មានពីរលើក អំពីការចែកឥន្ទ្រិយមាន ៣ លើក អំពីសុខិន្ទ្រិយកើតឡើងព្រោះអាស្រ័យផស្សៈដូចព្រន្ទួតភ្លើង ១ អំពីភិក្ខុបានសម្រេចឈាន ១ ។

# ជរាវគ្គោ

[២៨៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បាសាទេ ។ តេន ខោ បន សមយេន ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ បច្ឆាតបកេ[១] និសិន្នោ ហោតិ បិដ្ឋឹ ឱតាបយមានោ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិ-វាទេត្វា ភគវតោ គត្តានិ បាណិនា អនោមជ្ជន្តោ ភគវន្តំ ឯតទវោច

[២៨៦] អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ ន ចេវទានិ ភន្តេ ភគវតោ តាវ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ សិថិលានិ ច គត្តានិ សព្ពានិ[២] វលិជាតានិ បុរតោ បព្ភារោ ច កាយោ ទិស្សតិ ច ឥន្ទ្រិយានំ អញ្ញថត្តំ ចក្ខុន្ទ្រិយស្ស សោតិន្ទ្រិយស្ស ឃានិន្ទ្រិយស្ស ជិវ្ហិន្ទ្រិ-យស្ស កាយិន្ទ្រិយស្សាតិ ។

---

១ ឱ. ម. បច្ឆាតបេ ។ ២ សព្វានិ ។

# ជរាវគ្គ

[២៨៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងប្រាសាទនៃមិគារមាតា ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះដ៏មានព្រះភាគចេញអំពីទីពួនសម្ងំ (ផលសមាបត្តិ) ក្នុងសាយណ្ហសម័យ ហើយទ្រង់គង់ហាលព្រះបិដ្ឋិ (ខ្នង) ក្នុងទីកម្តៅថ្ងៃខាងក្រោយ (ប្រាសាទ) ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយច្របាច់នូវព្រះកាយ នៃព្រះដ៏មានព្រះភាគដោយដៃ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

[២៨៦] អស្ចារ្យណាស់ ព្រះអង្គ ចម្លែកណាស់ ព្រះអង្គបពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះព្រះឆវិវណ្ណរបស់ព្រះអង្គមិនបរិសុទ្ធផូរផង់ដូចអំពីមុនឡើយ ទាំងព្រះអង្គាវយវៈក៏ធូរជ្រាយ មានព្រះចម្មៈជ្រួញជ្រីវ ព្រះកាយក៏ទន់ទោរ ការប្រែប្រួលនៃឥន្ទ្រិយទាំងឡាយ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ក៏ឃើញប្រាកដ ។

[២៨៧] ឯវញ្ចេតំ អានន្ទ ហោតិ ជរាធម្មោ យោព្វញ្ញេ ព្យាធិធម្មោ អារោគ្យេ មរណធម្មោ ជីវិតេ ។ ន ចេវ តាវ បរិសុទ្ធោ ហោតិ ឆវិវណ្ណោ បរិយោទាតោ សិថិលានិ ច ហោន្តិ គត្តានិ សព្ពានិ វលិជាតានិ បុរតោ បព្ភារោ ច ហោតិ កាយោ ទិស្សតិ ច ឥន្ទ្រិយានំ អញ្ញថត្តំ ចក្ខុន្ទ្រិយស្ស សោតិន្ទ្រិយស្ស ឃានិន្ទ្រិយស្ស ជិវ្ហិន្ទ្រិយស្ស កាយិន្ទ្រិយស្សាតិ ។ ឥទមវោច ភគវា ឥទំ វត្វា សុគតោ អថាបរំ ឯតទវោច សត្ថា

[២៨៨] ធិ តំ ជម្មីជរេ អត្ថុ
ទុព្វណ្ណករណីជរេ
តាវ មនោរមំ ពិម្ពំ
ជរាយ អភិមទ្ទិតំ ។
យោបិ វស្សសតំ ជីវេ
សព្វេ មច្ចុបរាយណា
ន កិញ្ចិ បរិវជ្ជេតិ
សព្វមេវាភិមទ្ទតីតិ ។

[២៨៧] អើ អានន្ទ ពាក្យនុ៎ះមែនហើយ ជរាធម៌រមែងមាននៅត្រង់អវយវៈដែលកំពុងចម្រើន ព្យាធិធម៌ មាននៅត្រង់ការដែលមិនមានរោគ មរណធម៌ក៏មាននៅត្រង់ជីវិត ។ ឆវិវណ្ណ (របស់តថាគត) មិនបរិសុទ្ធផូរផង់ដូចមុនទេ ទាំងអង្គាវយវៈក៏ធូរជ្រាយ មានស្បែកជ្រួញជ្រីវ កាយក៏ទន់ទោរ ការប្រែប្រួលនៃឥន្ទ្រិយទាំងឡាយ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ក៏ឃើញប្រាកដមែន ។ ព្រះដ៏មានព្រះភាគបានត្រាស់ភាសិតនេះហើយ លុះព្រះសុគតទ្រង់ត្រាស់ភាសិតនេះរួចហើយ ទើបព្រះសាស្តាត្រាស់គាថានេះតទៅទៀតដូច្នេះ

[២៨៨] ប្តីយសវីរៈនោះ រមែងមានក្នុងកាលដែលចាស់
អាក្រក់ក្នុងកាលដែលជរា ធ្វើឲ្យមានសម្បុរអាក្រក់ អត្ត-
ភាពជាទីត្រេកអរនៃចិត្ត ក៏ត្រូវជរាគ្របសង្កត់ដោយពិត ។
ពួកសត្វទាំងអស់មានមច្ចុប្រព្រឹត្តទៅខាងមុខ ទោះជនឯណា
រស់នៅអស់ ១០០ ឆ្នាំក្តី ជននោះចៀសវាងនូវមច្ចុតិចតួចក៏ពុំ
រួច មច្ចុតែងញាំញីនូវសត្វទាំងអស់ឥតសល់ឡើយ ។

ជរាវគ្គោ

[២៨៩] សាវត្ថីនិទានំ ។ អថខោ ឧណ្ណាភោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧណ្ណាភោ ព្រាហ្មណោ ភគវន្តំ ឯតទវោច

[២៩០] បញ្ចិមានិ ភោ គោតម ឥន្ទ្រិយានិ នានាវិសយានិ នានាគោចរានិ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ ។ កតមានិ បញ្ច ។ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ។ ឥមេសំ នុ ខោ ភោ គោតម បញ្ចន្នំ ឥន្ទ្រិយានំ នានាវិសយានំ នានាគោចរានំ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តានំ កឹ បដិសរណំ កោ ច នេសំ គោចរវិសយំ បច្ចនុភោតីតិ ។

ជរាវគ្គ

[២៨៩] សាវត្ថីនិទាន ។ គ្រានោះ ឯងឧណ្ណាភព្រាហ្មណ៍ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧណ្ណាភ-ព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

[២៩០] បពិត្រព្រះគោតមចម្រើន ឥន្ទ្រិយ៥យ៉ាងនេះ មានវិស័យផ្សេង ៗ គ្នាមានអារម្មណ៍ផ្សេង ៗ គ្នា រមែងមិនទទួលនូវអារម្មណ៍និងវិស័យនៃគ្នានិងគ្នាឡើយ ។ ឥន្ទ្រិយ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជីវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះអ្វីជាទីពឹងរបស់ឥន្ទ្រិយទាំង ៥ យ៉ាងនេះ ដែលមានវិស័យផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា មិនទទួលនូវអារម្មណ៍និងវិស័យនៃគ្នានិងគ្នា ចុះសភាវៈដូចម្តេច រមែងទទួលនូវអារម្មណ៍និងវិស័យនៃឥន្ទ្រិយទាំងនេះ ។

[២៩១] បញ្ចិមានិ ព្រាហ្មណ ឥន្ទ្រិយានិ នានាវិសយានិ នានាគោចរានិ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ ។ កតមានិ បញ្ច ។ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ។ ឥមេសំ ខោ ព្រាហ្មណ បញ្ចន្នំ ឥន្ទ្រិយានំ នានាវិសយានំ នានាគោចរានំ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តានំ មនោ បដិសរណំ មនោ ច នេសំ គោចរវិសយំ បច្ចនុភោតីតិ ។

[២៩២] មនស្ស បន ភោ គោតម កឹ បដិសរណន្តិ ។ មនស្ស ខោ ព្រាហ្មណ សតិ បដិសរណន្តិ ។

[២៩៣] សតិយា បន ភោ គោតម កឹ បដិសរណន្តិ ។ សតិយា បន ខោ ព្រាហ្មណ វិមុត្តិ បដិសរណន្តិ ។

[២៩០] ម្នាលព្រាហ្មណ៍ ឥន្ទ្រិយ ៥ យ៉ាងនេះមានវិស័យផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា រមែងមិនទទួលនូវអារម្មណ៍និងវិស័យនៃគ្នានិងគ្នា ។ ឥន្ទ្រិយ ៥ យ៉ាងគឺអ្វីខ្លះ ។ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ។ ម្នាលព្រាហ្មណ៍ កាលបើឥន្ទ្រិយទាំង ៥ យ៉ាងនេះ មានវិស័យផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា មិនទទួលនូវអារម្មណ៍និងវិស័យនៃគ្នានឹងគ្នាហើយ មានតែចិត្តជាទីពឹងទាំងចិត្តក៏រមែងទទួលនូវអារម្មណ៍និងវិស័យនៃឥន្ទ្រិយទាំងនោះ ។

[២៩២] បពិត្រព្រះគោតមដ៏ចម្រើន ចុះអ្វីជាទីពឹងរបស់ចិត្ត ។ ម្នាលព្រាហ្មណ៍ សតិជាទីពឹងរបស់ចិត្ត ។

[២៩៣] បពិត្រព្រះគោតមដ៏ចម្រើន ចុះអ្វីជាទីពឹងរបស់សតិ ។ ម្នាលព្រាហ្មណ៍ វិមុត្តិជាទីពឹងរបស់សតិ ។

ជរាវគ្គោ

[១៩៤] វិមុត្តិយា បន ភោ គោតម កឹ បដិសរណាន្តិ ។ វិមុត្តិយា ខោ ព្រាហ្មណ និព្វានំ បដិសរណាន្តិ ។ និព្វានស្ស បន ភោ គោតម កឹ បដិសរណាន្តិ ។ អច្ចសរា(១) ព្រាហ្មណ បញ្ហំ នាសក្ខិ បញ្ហស្ស បរិយន្តំ គហេតុំ ។ និព្វានោគធំ ហិ ព្រាហ្មណ ព្រហ្មចរិយំ វុស្សតិ និព្វានបរាយនំ និព្វានបរិយោសានន្តិ ។

[២៩៥] អថខោ ឧណ្ណាភោ ព្រាហ្មណោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[២៩៦] អថខោ ភគវា អចិរបក្កន្តេ ឧណ្ណាភេ ព្រាហ្មណេ ភិក្ខូ អាមន្តេសិ

---

១ ឱ. ម. អជ្ឈបរំ ។

[២៩៤] បពិត្រព្រះគោតមដ៏ចម្រើន ចុះអ្វីជាទីពឹងរបស់វិមុត្តិ ។ ម្នាលព្រាហ្មណ៍ និព្វានជាទីពឹងរបស់វិមុត្តិ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះអ្វីជាទីពឹងរបស់ព្រះនិព្វាន ។ ម្នាលព្រាហ្មណ៍ អ្នកកន្លងហួសប្រស្នាហើយ អ្នកមិនអាចកាន់យកនូវទីបំផុតនៃប្រស្នាបានឡើយ ។ ម្នាលព្រាហ្មណ៍ ព្រោះថាមគ្គព្រហ្មចរិយធម៌ ឈមទៅកាន់និព្វាន មាននិព្វានប្រព្រឹត្តទៅខាងមុខ មាននិព្វានជាទីបំផុត ។

[២៩៥] គ្រានោះឯង ឧណ្ណាភព្រាហ្មណ៍ ក៏ត្រេកអរអនុមោទនានូវភាសិតនៃព្រះដ៏មានព្រះភាគ រួចក្រោកចាកអាសនៈថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយ ដើរចេញទៅ ។

[២៩៦] គ្រានោះ កាលឧណ្ណាភព្រាហ្មណ៍ ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះដ៏មានព្រះភាគ ក៏ត្រាស់នឹងពួកភិក្ខុថា

[២៩៧] សេយ្យថាបិ ភិក្ខវេ កូដាគារំ វា កូដាគារសាលា វា[១] ឧត្តរាយ វា ទក្ខិណាយ វា វាតទានា សុរិយេ ឧគ្គច្ឆន្តេ វាតបានេន រស្មិយោ បវិសិត្វា កាយ បតិដ្ឋិតាតិ ។ បច្ឆិមាយំ ភន្តេ ភិត្តិយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ឧឡារកស្ស ព្រាហ្មណស្ស តថាគតេ សទ្ធា និវិដ្ឋា មូលជាតា បតិដ្ឋិតា ទឡ្ហា អសំហារិយា សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ ឥមម្ហិ ចេ ភិក្ខវេ សមយេ ឧឡារកោ ព្រាហ្មណោ កាលំ ករេយ្យ នត្ថិ តំ សញ្ញោជនំ យេន សញ្ញោជនេន សញ្ញុត្តោ ឧឡារកោ ព្រាហ្មណោ បុន ឥមំ លោកំ អាគច្ឆេយ្យាតិ ។

១ ឱ. ម. កូដាគារេ វា កូដាគារសាលាយំ វា ។

[២៩៧] ម្នាលភិក្ខុទាំងឡាយ ផ្ទះកំពូលឬសាលាដែលមានកំពូល មានបង្អួចក្នុងទិសខាងជើងឬទិសខាងកើត កាលបើព្រះអាទិត្យរះឡើង រស្មីចូលទៅតាមបង្អួចហើយស្ថិតនៅក្នុងទីណា មានឧបមាយ៉ាងណា ។ បពិត្រព្រះអង្គដ៏ចម្រើន រស្មីស្ថិតនៅត្រង់ជញ្ជាំងទិសខាងលិច ។ ម្នាលភិក្ខុទាំងឡាយ ឯឧណ្ណាភព្រាហ្មណ៍ មានសទ្ធាខ្ជាប់ខ្ជួនជាឫសស្ថិតនៅមាំមួនចំពោះតថាគត ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្នុងលោកក្តី មិនងាយបំបែរឲ្យងាកចេញបានឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនេះ បើឧណ្ណាភព្រាហ្មណ៍ ធ្វើមរណកាល ឧណ្ណាភព្រាហ្មណ៍ដែលប្រកបដោយសញ្ញោជនឯណាហើយ គប្បីមកកាន់លោកនេះម្តងទៀត សញ្ញោជននោះមិនមានទេ ។

១៩៣

ជរាវគ្គោ

[២៩៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាកេតេ វិហរតិ អញ្ជនវនេ មិគទាយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ អត្ថិ នុ ខោ ភិក្ខវេ បរិ-យាយោ យំ បរិយាយំ អាគម្ម យានិ បញ្ចិន្ទ្រិយានិ តានិ បញ្ច ពលានិ ហោន្តិ យានិ បញ្ច ពលានិ តានិ បញ្ចិន្ទ្រិយានិ ហោន្តីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ បេ ។

[២៩៩] អត្ថិ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម យានិ បញ្ចិន្ទ្រិយានិ តានិ បញ្ច ពលានិ ហោន្តិ យានិ បញ្ច ពលានិ តានិ បញ្ចិន្ទ្រិយានិ ហោន្តិ ។ កតមោ ច ភិក្ខវេ បរិយាយោ យំ បរិ-យាយំ អាគម្ម យានិ បញ្ចិន្ទ្រិយានិ តានិ បញ្ច ពលានិ ហោន្តិ យានិ បញ្ច ពលានិ តានិ បញ្ចិន្ទ្រិ-យានិ ហោន្តិ ។

ជរាវគ្គ

[២៩៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រៃអញ្ជ័នជាទីឲ្យអភ័យដល់ម្រឹក ទៀបនគរសាកេត ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ ឯណា ឥន្ទ្រិយ ៥ នោះ គឺពលៈ ៥ ពលៈ ៥ ឯណា ពលៈ ៥ នោះ គឺឥន្ទ្រិយ ៥ ព្រោះអាស្រ័យបរិយាយឯណា បរិយាយនោះមានដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំព្រះអង្គ មានព្រះដ៏មានព្រះភាគជាឫសគល់ មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គសូមអារាធនា សូមព្រះដ៏មានព្រះភាគ បំភ្លឺសេចក្តីនៃភាសិតនុ៎ះឲ្យទាន បើពួកភិក្ខុបានស្តាប់ព្រះវាចារបស់ព្រះដ៏មានព្រះភាគហើយនឹងចងចាំបាន ។ បេ ។

[២៩៩] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ ឯណា ឥន្ទ្រិយ ៥ នោះក៏គឺពលៈ ៥ ពលៈ ៥ ឯណា ពលៈ ៥ នោះក៏គឺឥន្ទ្រិយ ៥ ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះមានដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះឥន្ទ្រិយ ៥ ឯណា ឥន្ទ្រិយ ៥ នោះក៏គឺពលៈ ៥ ពលៈ ៥ ឯណា ពលៈ ៥ នោះក៏គឺឥន្ទ្រិយ ៥ ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះ តើដូចម្តេច ។

[៣០០] យំ ភិក្ខវេ សទ្ធិន្ទ្រិយំ តំ សទ្ធាពលំ យំ សទ្ធាពលំ តំ សទ្ធិន្ទ្រិយំ យំ វីរិយិន្ទ្រិយំ តំ វីរិយ-ពលំ យំ វីរិយពលំ តំ វីរិយិន្ទ្រិយំ យំ សតិន្ទ្រិយំ តំ សតិពលំ យំ សតិពលំ តំ សតិន្ទ្រិយំ យំ សមា-ធិន្ទ្រិយំ តំ សមាធិពលំ យំ សមាធិពលំ តំ សមា-ធិន្ទ្រិយំ យំ បញ្ញិន្ទ្រិយំ តំ បញ្ញាពលំ យំ បញ្ញាពលំ តំ បញ្ញិន្ទ្រិយំ ។

[៣០១] សេយ្យថាបិ ភិក្ខវេ នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា តស្សា មជ្ឈេ ទីបោ ។ អត្ថិ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម តស្សា នទិយា ឯកោ សោតោត្វេវ សង្ខំ គច្ឆតិ ។ អត្ថិ បន ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម តស្សា នទិយា ទ្វេ សោតានិត្វេវ សង្ខំ គច្ឆន្តិ ។

[៣០០] ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយឯណា សទ្ធិន្ទ្រិយនោះក៏គឺសទ្ធាពលៈ សទ្ធាពលៈឯណា សទ្ធាពលៈនោះក៏គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយឯណា វីរិយិន្ទ្រិយនោះក៏គឺវីរិយពលៈ វីរិយពលៈឯណា វីរិយពលៈនោះក៏គឺវីរិយិន្ទ្រិយ សតិន្ទ្រិយឯណា សតិន្ទ្រិយនោះ ក៏គឺសតិពលៈ សតិពលៈឯណា សតិពលៈនោះ ក៏គឺសតិន្ទ្រិយសមាធិន្ទ្រិយឯណា សមាធិន្ទ្រិយនោះក៏គឺសមាធិពលៈ សមាធិពលៈឯណា សមាធិពលៈនោះក៏គឺសមាធិន្ទ្រិយ បញ្ញិន្ទ្រិយឯណា បញ្ញិន្ទ្រិយនោះក៏គឺបញ្ញាពលៈ បញ្ញាពលៈឯណា បញ្ញាពលៈនោះក៏គឺបញ្ញិន្ទ្រិយ ។

[៣០១] ម្នាលភិក្ខុទាំងឡាយ ដូចទន្លេហូរទៅទិសខាងកើត ទេរទៅទិសខាងកើត ឈមទៅទិសខាងកើត កោះក៏មាននៅត្រង់កណ្តាលនៃទន្លេនោះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលដល់នូវការរាប់ថា ទន្លេនោះមានខ្សែទឹកតែមួយ ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះរមែងមាន ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ហេតុដែលដល់នូវការរាប់ថា ទន្លេនោះមានខ្សែទឹកពីរ ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយនោះក៏មានដែរ ។

ជរាវគ្គោ

[៣០២] កតមោ ច ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម តស្សា ទនិយា ឯកោ សោតោត្វេវ សង្ខំ គច្ឆតិ ។ យញ្ច ភិក្ខវេ តស្ស ទីបស្ស បុរត្ថិមន្តេ ឧទកំ យញ្ច បច្ឆិមន្តេ ឧទកំ ។ អយំ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម តស្សា ទនិយា ឯកោ សោតោត្វេវ សង្ខំ គច្ឆតិ ។

[៣០៣] កតមោ ច ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម តស្សា ទនិយា ទ្វេ សោតានិត្វេវ សង្ខំ គច្ឆន្តិ ។ យញ្ច ភិក្ខវេ តស្ស ទីបស្ស ឧត្តរន្តេ ឧទកំ យញ្ច ទក្ខិណន្តេ ឧទកំ ។ អយំ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម តស្សា ទនិយា ទ្វេ សោតានិត្វេវ សង្ខំ គច្ឆន្តិ ។

ជរាវគ្គ

[៣០២] ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលដល់នូវការរាប់ថា ទន្លេនោះមានខ្សែទឹកតែមួយ ព្រោះអាស្រ័យនូវបរិយាយឯណា បរិ-យាយនោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទឹកឯណាមាននៅចុង នៃទិសខាងកើតនៃកោះនោះ និងទឹកឯណាមាននៅចុងនៃទិសខាងលិច នៃកោះនោះ ។ ម្នាលភិក្ខុទាំងឡាយ ទឹកនោះ ៗ ដល់នូវការរាប់ថា ទន្លេ នោះមានខ្សែទឹកតែមួយ ព្រោះអាស្រ័យនូវបរិយាយឯណា នេះឯងជា បរិយាយ ។

[៣០៣] ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលដល់នូវការរាប់ថា ទន្លេនោះមានខ្សែទឹកពីរ ព្រោះអាស្រ័យនូវបរិយាយឯណា បរិយាយ នោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទឹកឯណាមាននៅចុងនៃទិស ខាងជើងនៃកោះនោះ និងទឹកឯណាមាននៅចុងនៃទិសខាងត្បូងនៃកោះ នោះ ។ ម្នាលភិក្ខុទាំងឡាយ ទឹកនោះ ៗ ដល់នូវការរាប់ថា ទន្លេនោះ មានខ្សែទឹកពីរ ព្រោះអាស្រ័យនូវបរិយាយឯណា នេះឯងជាបរិយាយ យ៉ាងណាមិញ ។

[៣០៤] ឯវមេវ ខោ ភិក្ខវេ យំ សទ្ធិន្ទ្រិយំ តំ សទ្ធាពលំ យំ សទ្ធាពលំ តំ សទ្ធិន្ទ្រិយំយំ វីរិយិន្ទ្រិ-យំ តំ វីរិយពលំ យំ វីរិយពលំ តំ វីរិយិន្ទ្រិយំ យំ សតិន្ទ្រិយំ តំ សតិពលំ យំ សតិពលំ តំ សតិន្ទ្រិយំ យំ សមាធិន្ទ្រិយំ តំ សមាធិពលំ យំ សមាធិពលំ តំ សមាធិន្ទ្រិយំ យំ បញ្ញិន្ទ្រិយំ តំ បញ្ញាពលំ យំ បញ្ញាពលំ តំ បញ្ញិន្ទ្រិយំ ។

[៣០៥] បញ្ចន្នំ ភិក្ខវេ ឥន្ទ្រិយានំ ភាវិតត្តា ពហុ-លីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិ-មុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៣០៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វកោដ្ឋកេ ។ តត្រ ខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ ។

[៣០៤] ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយឯណា សទ្ធិន្ទ្រិយនោះក៏គឺសទ្ធាពលៈ សទ្ធាពលៈឯណា សទ្ធាពលៈនោះក៏គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយឯណា វីរិយិន្ទ្រិយនោះក៏គឺវីរិយពលៈ វីរិយពលៈឯណា វីរិយ-ពលៈនោះក៏គឺវីរិយិន្ទ្រិយ សតិន្ទ្រិយឯណា សតិន្ទ្រិយនោះក៏គឺសតិពលៈ សតិពលៈឯណា សតិពលៈនោះក៏គឺសតិន្ទ្រិយ សមាធិន្ទ្រិយឯណា សមាធិន្ទ្រិយនោះក៏គឺសមាធិពលៈ សមាធិពលៈឯណា សមាធិពលៈនោះក៏គឺសមាធិន្ទ្រិយ បញ្ញិន្ទ្រិយឯណា បញ្ញិន្ទ្រិយនោះក៏គឺបញ្ញាពលៈ បញ្ញាពលៈឯណា បញ្ញាពលៈនោះក៏គឺបញ្ញិន្ទ្រិយ ក៏យ៉ាងនោះដែរ ។

[៣៩៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុរមែងធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ព្រោះបានចម្រើនបានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយទាំង ៥ ហើយសម្រាន្តនៅ ។

[៣០៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងបុព្វកោដ្ឋកនិគម ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់សួរបញ្ហាក់ព្រះសារីបុត្តដ៏មានអាយុថា

[៣០៧] សទ្ទហសិ ត្វំ សារីបុត្ត សទ្ធិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានន្តិ ។

[៣០៨] ន ខ្វាហំ ភន្តេ ឯត្ថ ភគវតោ សទ្ធាយ គច្ឆាមិ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានំ ។ យេសញ្ហិ តំ ភន្តេ អញ្ញាតំ[១] អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផស្សិតំ[២] បញ្ញាយ តេ តត្ថ បរេសំ សទ្ធាយ គច្ឆេយ្យុំ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានំ ។ យេសញ្ច ខោ ឯតំ ភន្តេ

១ ឱ. ម. អញ្ញាតមស្ស ។ ២ ឱ. អផុសិតំ ។

[៣០៧] ម្នាលសារីបុត្ត អ្នកជឿដែរឬ ថាសទ្ធិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ បេ ។ ថាបញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។

[៣០៨] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនលុះដោយការជឿព្រះដ៏មានព្រះភាគក្នុងដំណើរនុ៎ះទេ ថាសទ្ធិន្ទ្រិយ ។ បេ ។ បញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះលុះតែពួកជនដែលមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ប្រទះដោយប្រាជ្ញា ទើបលុះដោយការជឿជនដទៃក្នុងដំណើរនុ៎ះថាសទ្ធិន្ទ្រិយ ។ បេ ។ ថាបញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះ បើពួកជនឯណា

ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ បស្សិតំ បញ្ញាយ និក្កង្ខា តេ តត្ថ និព្វិចិកិច្ឆា សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានំ ។ មយ្ហញ្ច ខោ ឯតំ ភន្តេ ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ បស្សិតំ បញ្ញាយ និក្កង្ខាហំ តត្ថ[១] និព្វិចិកិច្ឆោ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានន្តិ ។

[៣០៩] សាធុ សាធុ សារីបុត្ត យេសញ្ហិ តំ សារីបុត្ត អញ្ញាតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អបស្សិតំ បញ្ញាយ តេ តត្ថ បរេសំ សទ្ធាយ គច្ឆេយ្យុំ សទ្ធិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ

---

១ ឱ. បរេសំ ។

ធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្វើឲ្យជាក់ច្បាស់ ប្រទះដោយប្រាជ្ញាហើយ ពួកជននោះឥតមានសង្ស័យ ឥតមានងឿងឆ្ងល់ក្នុងដំណើរនុ៎ះឡើយ ជាសទ្ធិន្ទ្រិយ ។ បេ ។ ជាបញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះ ឯខ្ញុំព្រះអង្គធ្លាប់ដឹង ឃើញ យល់ ធ្វើឲ្យជាក់ច្បាស់ ប្រទះដោយប្រាជ្ញាហើយ ខ្ញុំព្រះអង្គឥតមានសង្ស័យ ឥតមានងឿងឆ្ងល់ក្នុងដំណើរនុ៎ះទេ ជាសទ្ធិន្ទ្រិយ ។ បេ ។ បញ្ញិន្ទ្រិយដែលបុគ្គលចម្រើន ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅអមតៈ បានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។

[៣០៩] ម្នាលសារីបុត្ត ប្រពៃហើយ ៗ ម្នាលសារីបុត្ត ព្រោះថាដំណើរនោះ ពួកជនដែលមិនធ្លាប់ដឹង មិនឃើញ មិនយល់ មិនទាន់ធ្វើឲ្យជាក់ច្បាស់ មិនទាន់ប្រទះដោយប្រាជ្ញា ទើបលុះដោយការជឿជនដទៃក្នុងដំណើរនុ៎ះ សទ្ធិន្ទ្រិយដែលបុគ្គលចម្រើន ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ

អមតបរិយោសានំ ។ បេ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលី-
កតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោ-
សានំ ។ យេសញ្ច ខោ ឯតំ សារីបុត្ត ញាតំ ទិដ្ឋំ
វិទិតំ សច្ឆិកតំ ផស្សិតំ បញ្ញាយ និក្កង្ខា តេ តត្ថ
និព្វិចិកិច្ឆា សទ្ធិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោ-
គធំ ហោតិ អមតបរាយនំ អមតបរិយោសានំ ។ បេ។
បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ
អមតបរាយនំ អមតបរិយោសានន្តិ ។

[៣១០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា
សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ ។ តត្រ
ខោ ភគវា ភិក្ខូ អាមន្តេសិ កតីនំ នុ ខោ ភិក្ខវេ
ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ

មានអមតៈជាទីបំផុត ។ បេ ។ ថា បញ្ញិន្ទ្រិយ ដែលបុគ្គលចម្រើន ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ ម្នាលសារីបុត្ត ដំណើរនុ៎ះ បើពួកជនឯណា ធ្លាប់ដឹង ឃើញ យល់ ធ្វើឲ្យជាក់ច្បាស់ ប្រទះដោយប្រាជ្ញា ពួកជននោះមិនមានសង្ស័យ មិនមានងឿងឆ្ងល់ក្នុងដំណើរនោះឡើយ ថាសទ្ធិន្ទ្រិយដែលបុគ្គលចម្រើន ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ បេ ។ ថា បញ្ញិន្ទ្រិយ ដែលបុគ្គលចម្រើន ធ្វើឲ្យក្រាស់ក្រែលហើយ ជាធម្មជាតឈមទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។

[៣១០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងប្រាសាទរបស់មិគារមាតា ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែខ្លួនបានចម្រើន ធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយប៉ុន្មានយ៉ាង ទើបភិក្ខុជាខីណាស្រព

អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។

[៣១១] ឯកស្ស ខោ ភិក្ខវេ ឥន្ទ្រិយស្ស ភាវិ-តត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាក-រោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណី-យំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ កតមស្ស ឯ-កស្ស ។ បញ្ញិន្ទ្រិយស្ស ។

[៣១២] បញ្ញវតោ ភិក្ខវេ អរិយសាវកស្ស តទន្វ-យា សទ្ធា សណ្ឋាតិ តទន្វយំ វីរិយំ សណ្ឋាតិ តទន្វ-យា សតិ សណ្ឋាតិ តទន្វយោ សមាធិ សណ្ឋាតិ ។

ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយនៃយើងខ្ញុំព្រះអង្គ ។ មានព្រះដ៏មានព្រះភាគជាឫសគល់ ។បេ។

[៣១១] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែខ្លួនបានចម្រើនធ្វើឲ្យក្រាស់ក្រែលនូវឥន្ទ្រិយមួយ ទើបភិក្ខុជាខីណាស្រពប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយ-ធម៌ អាត្មាអញប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ឥន្ទ្រិយតែមួយគឺអ្វី ។ គឺបញ្ញិន្ទ្រិយ ។

[៣១២] ម្នាលភិក្ខុទាំងឡាយ សទ្ធាដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះ ក៏តាំងនៅស៊ប់ វីរិយៈដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះក៏តាំងនៅស៊ប់ សតិដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះ ក៏តាំងនៅស៊ប់ សមាធិដែលសម្រេចទៅតាមបញ្ញិន្ទ្រិយនោះ ក៏តាំងនៅស៊ប់ចំពោះអរិយសាវកដែលមានបញ្ញា ។

ជរាវគ្គោ

[៣១៣] ឥមស្ស ខោ ភិក្ខវេ ឯកស្ស ឥន្ទ្រិ-
យស្ស ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ
អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ
កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣១៤] តំយេវ និទានំ ។ កតីនំ នុ ខោ ភិក្ខវេ
ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ
អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ
កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។
ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។

[៣១៣] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយមួយនេះឯង ទើបភិក្ខុជាខីណាស្រពប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣១៤] និទានដដែលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយប៉ុន្មានយ៉ាង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយនៃយើងខ្ញុំព្រះអង្គ មានព្រះដ៏មានព្រះភាគជាឫសគល់ ។ បេ ។

[៣១៥] ទ្វិន្នំ ខោ ភិក្ខវេ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណាជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣១៦] កតមេសំ ទ្វិន្នំ ។ អរិយាយ ច បញ្ញាយ អរិយាយ ច វិមុត្តិយា ។ យា ហិស្ស ភិក្ខវេ អរិយា បញ្ញា តទស្ស បញ្ញិន្ទ្រិយំ ។ យា ហិស្ស ភិក្ខវេ អរិយាវិមុត្តិ តទស្ស សមាធិន្ទ្រិយំ ។

[៣១៧] ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណាជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣១៥] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យច្រាស់ក្រៃល នូវឥន្ទ្រិយពីរ ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣១៦] ឥន្ទ្រិយពីរយ៉ាងតើអ្វីខ្លះ ។ គឺបញ្ញាដ៏ប្រសើរ ១ វិមុត្តិដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបញ្ញាដ៏ប្រសើរឯណារបស់ភិក្ខុនោះ បញ្ញានោះឈ្មោះថាបញ្ញិន្ទ្រិយរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាវិមុត្តិដ៏ប្រសើរឯណារបស់ភិក្ខុនោះ វិមុត្តិនោះឈ្មោះថាសមាធិន្ទ្រិយរបស់ភិក្ខុនោះ ។

[៣១៧] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យច្រាស់ក្រៃល នូវឥន្ទ្រិយពីរយ៉ាងនេះឯង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

២០៣

ជរាវគ្គោ

[៣១៨] តំយេវ និទានំ ។ កតីនំ នុ ខោ ភិក្ខវេ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។

[៣១៩] ចតុន្នំ ខោ ភិក្ខវេ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នា-បរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣២០] កតមេសំ ចតុន្នំ ។ វីរិយិន្ទ្រិយស្ស ស-តិន្ទ្រិយស្ស សមាធិន្ទ្រិយស្ស បញ្ញិន្ទ្រិយស្ស ។

[៣១៨] និទានដដែលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយប៉ុន្មានយ៉ាង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយនៃយើងខ្ញុំព្រះអង្គ មានព្រះដ៏មានព្រះភាគជាឫសគល់ ។ បេ ។

[៣១៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយ ៤ យ៉ាង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣២០] ឥន្ទ្រិយ ៤ យ៉ាងតើអ្វីខ្លះ ។ គឺវីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។

[៣២១] ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣២២] តំយេវ និទានំ ។ កតីនំ នុ ខោ ភិក្ខវេ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។

[៣២១] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយ ៤ យ៉ាងនេះឯង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣២២] និទានដដែលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយប៉ុន្មានយ៉ាង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោ-ឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយនៃយើងខ្ញុំព្រះអង្គ មានព្រះដ៏មានព្រះភាគជាឫសគល់ ។ បេ ។

ជរាវគ្គោ

[៣២៣] បញ្ចិមានិ ខោ ភិក្ខវេ ឥន្ទ្រិយានិ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣២៤] កតមេសំ បញ្ចន្នំ ។ សទ្ធិន្ទ្រិយស្ស វីរិយិ-ន្ទ្រិយស្ស សតិន្ទ្រិយស្ស សមាធិន្ទ្រិយស្ស បញ្ញិន្ទ្រិ-យស្ស ។

[២៣៥] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ខីណាសវោ ភិក្ខុ អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣២៣] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយ ៥ យ៉ាង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហន្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣២៤] ឥន្ទ្រិយ ៥ យ៉ាងតើអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។

[៣២៥] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយ ៥ យ៉ាងនេះឯង ទើបភិក្ខុជាខីណាស្រព ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣៦៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មតា បិណ្ឌោលភារទ្វាជេន អញ្ញា ព្យាកតា ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣៦៧] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អាយស្មតា ភន្តេ បិណ្ឌោលភារទ្វាជេន អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣៤២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ សម័យនោះឯង ព្រះបិណ្ឌោលភារទ្វាជៈដ៏មានអាយុ ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣៤៧] គ្រានោះ ពួកភិក្ខុច្រើនរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិណ្ឌោលភារទ្វាជៈដ៏មានអាយុ ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

ជរាវគ្គោ

[៣២៨] កឹ នុ ខោ ភន្តេ អត្ថវសំ សម្បស្សមា-
នេន អាយស្មតា បិណ្ឌោលភារទ្វាជេន អញ្ញា ព្យាក-
តា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ
នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣២៩] តិណ្ណំ ខោ ភិក្ខវេ ឥន្ទ្រិយានំ ភាវិ-
តត្តា ពហុលីកតត្តា បិណ្ឌោលភារទ្វាជេន ភិក្ខុនា
អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ
កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣៣០] កតមេសំ តិណ្ណំ ។ សតិន្ទ្រិយស្ស
សមាធិន្ទ្រិយស្ស បញ្ញិន្ទ្រិយស្ស ។

[៣៣១] ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ឥន្ទ្រិយានំ
ភាវិតត្តា ពហុលីកតត្តា បិណ្ឌោលភារទ្វាជេន ភិក្ខុនា

[៣២៨] បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិណ្ឌោលភារទ្វាជៈ ដ៏មានអាយុ ឃើញអំណាចប្រយោជន៍ដូចម្ដេច ទើបប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣២៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយ ៣ យ៉ាង ទើបបិណ្ឌោលភារទ្វាជភិក្ខុ ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣៣០] ឥន្ទ្រិយ ៣ យ៉ាង តើអ្វីខ្លះ ។ គឺសតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។

[៣៣១] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែល នូវឥន្ទ្រិយ ៣ យ៉ាងនេះឯង ទើបបិណ្ឌោលភារទ្វាជភិក្ខុ

អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

[៣៣២] ឥមានិ ច ភិក្ខវេ តីណិ ឥន្ទ្រិយានិ កតមានិ ។ ខយន្តានិ ។ កិស្ស ខយន្តានិ ។ ជាតិ-ជរាមរណស្ស ។ ជាតិជរាមរណក្ខយន្តិ ខោ ភិក្ខវេ សម្បស្សមានេន បិណ្ឌោលភារទ្វាជេន ភិក្ខុនា អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។

ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[៣៣២] ម្នាលភិក្ខុទាំងឡាយ ចុះឥន្ទ្រិយទាំង ៣ យ៉ាងនេះ មានអ្វីជាទីបំផុត ។ មានការអស់ទៅជាទីបំផុត ។ មានការអស់ទៅជាទីបំផុតនៃអ្វី ។ នៃជាតិ ជរា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ បិណ្ឌោលភារទ្វាជភិក្ខុ ឃើញច្បាស់ថា ការអស់ទៅនៃជាតិ ជរា មរណៈ ដូច្នេះឯង ទើបប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

២០៩

ជរាវគ្គោ

[៣៣៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អង្គេសុ វិហរតិ អាបណន្នាម អង្គានំ និគមោ ។ តត្រ ខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ យោ សោ សារីបុត្ត អរិយស្សាវកោ តថាគតេ ឯកន្តគតោ អភិប្បសន្នោ[១] ន សោ តថាគតេ វា តថាគតសាសនេ វា កង្ខេយ្យ វា វិចិកិច្ឆេយ្យាវាតិ ។

[៣៣៤] យោ សោ ភនេ អរិយស្សាវកោ តថាគតេ ឯកន្តគតោ អភិប្បសន្នោ ន សោ តថាគតេ វា តថាគតសាសនេ វា កង្ខេយ្យ វា វិចិកិច្ឆេយ្យ វា ។ សទ្ធស្ស ហិ ភន្តេ អរិយស្សាវកស្ស ឯតំ បាដិកង្ខំ យំ អារទ្ធវីរិយោ វិហរិស្សតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។

[៣៣៥] យញ្ហិស្ស ភន្តេ វីរិយំ តទស្ស វីរិយិន្ទ្រិយំ ។ សទ្ធស្ស ហិ ភន្តេ អរិយស្សាវកស្ស អារទ្ធវីរិយស្ស

១ ឱ. អបិ នុ សោ ។

ជរាវគ្គ

[៣៣៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងនិគមឈ្មោះអាបណៈ របស់ពួកអ្នកស្រុកអង្គៈ ក្នុងដែនអង្គៈ ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគបានត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត អរិយសាវកឯណាជ្រះថ្លាតាំងនៅមាំមួន ចំពោះព្រះតថាគត អរិយសាវកនោះ មិនគប្បីងឿងឆ្ងល់ឬសង្ស័យចំពោះព្រះតថាគត នឹងចំពោះសាសនានៃព្រះតថាគត ទេឬ។

[៣៣៤] បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកឯណាជ្រះថ្លាតាំងនៅមាំមួន ចំពោះព្រះតថាគតហើយ អរិយសាវកនោះមិនគប្បីងឿងឆ្ងល់ ឬសង្ស័យចំពោះព្រះតថាគត និងចំពោះសាសនានៃព្រះតថាគតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាអរិយសាវកអ្នកមានសទ្ធាគប្បីនឹកសង្ឃឹមនូវហេតុនុ៎ះជាប្រាកដ គឺអរិយសាវកនោះនឹងប្រារព្ធនូវសេចក្តីព្យាយាមដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។

[៣៣៥] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាវីរិយៈឯណារបស់អរិយសាវកនោះ វីរិយៈនោះឈ្មោះថាវីរិយិន្ទ្រិយរបស់លោក ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតអរិយសាវកអ្នកមានសទ្ធា ប្រារព្ធសេចក្តីព្យាយាម

ឯតំ ចាដិកង្ខំ យំ សតិមា ភវិស្សតិ បរមេន សតិ-នេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ។

[៣៣៦] យា ហិស្ស ភន្តេ សតិ តទស្ស សតិន្ទ្រិយំ ។ សទ្ធស្ស ហិ ភន្តេ អរិយសាវកស្ស អារទ្ធវិរិយស្ស ឧបដ្ឋិតស្សតិនោ ឯតំ ចាដិកង្ខំ យំ វោស្សគ្គារម្មណំ ករិត្វា លភិស្សតិ សមាធឹ លភិស្សតិ ចិត្តស្ស ឯកគ្គតំ ។

[៣៣៧] យោ ហិស្ស ភន្តេ សមាធិ តទស្ស សមាធិន្ទ្រិយំ ។ សទ្ធស្ស ហិ ភន្តេ អរិយសាវកស្ស អារទ្ធវិរិយស្ស ឧបដ្ឋិតស្សតិនោ សមាហិតចិត្តស្ស ឯតំ ចាដិកង្ខំ យំ ឯវំ បជានិស្សតិ អនមតគ្គោ ខោ សំសារោ បុព្វា កោដិ នប្បញ្ញាយតិ អវិជ្ជា-នីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ

នឹងនឹកសង្ស័យមនូវហេតុនុ៎ះជាប្រាកដ គឺជាអ្នកមានស្មារតីប្រកបដោយប្រាជ្ញាចាស់ក្លាដ៏ប្រសើរ តែងនឹកបានចាំបាន នូវអំពើដែលធ្លាប់ធ្វើមកជាយូរហើយផង នូវពាក្យសម្តីដែលធ្លាប់និយាយមកជាយូរហើយផង ។

[៣៣៦] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាសតិឯណារបស់អរិយសាវកនោះ សតិនោះឈ្មោះថាសតិន្ទ្រិយរបស់លោក ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតអរិយសាវកអ្នកមានសទ្ធា ប្រារព្ធសេចក្តីព្យាយាម មានសតិតម្កល់ខ្ជាប់ នឹងនឹកសង្ស័យមនូវហេតុនុ៎ះជាប្រាជក គឺធ្វើនូវព្រះនិព្វានឲ្យជាអារម្មណ៍ ហើយនឹងបាននូវសមាធិ និងបាននូវភាវៈនៃចិត្តមានអារម្មណ៍តែមួយ ។

[៣៣៧] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាសមាធិឯណារបស់អរិយសាវកនោះ សមាធិនោះឈ្មោះថាសមាធិន្ទ្រិយរបស់លោក ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតអរិយសាវកអ្នកមានសទ្ធា ប្រារព្ធសេចក្តីព្យាយាម មានសតិតម្កល់ខ្ជាប់ មានចិត្តតាំងមាំដោយប្រពៃ នឹងនឹកសង្ស័យមនូវហេតុនុ៎ះជាប្រាជក គឺនឹងដឹងច្បាស់យ៉ាងនេះថា សង្សារមានទីបំផុតកំណត់មិនបាន ទីបំផុតខាងដើមមិនប្រាកដដល់សត្វទាំងឡាយដែលមានអវិជ្ជាជាគ្រឿងរាំង មានតណ្ហាជាគ្រឿងប្រកប ដែលអន្ទោលទៅ

សំសារតំ អវិជ្ជាយត្វេវ តមោកាយស្ស អសេសវិរាគនិរោធោ សន្តមេតំ បទំ បណីតមេតំ បទំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។

[៣៣៨] យា ហិស្ស ភន្តេ បញ្ញា តទស្ស បញ្ញិន្ទ្រិយំ ។ សទ្ធោ សោ ភន្តេ អរិយសាវកោ ឯវំ បទហិត្វា បទហិត្វា ឯវំ សរិត្វា សរិត្វា ឯវំ សមាទហិត្វា សមាទហិត្វា ឯវំ បជានិត្វា បជានិត្វា ឯវំ អភិសទ្ទហាតិ ឥមេ ខោ តេ ធម្មា យេ មេ បុព្វេ សុតា វ អហេសុំ តេនាហំ ឯតរហិ កាយេន ច ផុសិត្វា វិហរាមិ បញ្ញាយ ច អតិវិជ្ឈ[១] បស្សាមីតិ ។

[៣៣៩] យាហិស្ស ភន្តេ សទ្ធា តទស្ស សទ្ធិន្ទ្រិយន្តិ ។

---

១ ឱ. បដិវិជ្ឈ ។

ត្រាច់រង្គាត់ទៅ ការប្រាសចាកតម្រេក និងការរលត់ឥតមានសេសសល់នៃគំនរងងឹតគឺអវិជ្ជានុ៎ះឯង ជាផ្លូវដ៏ស្ងប់ ជាផ្លូវដ៏ប្រសើរ គឺការស្ងប់រម្ងាប់ទៅនៃសង្ខារទាំងពួង លះបង់នូវឧបក្កិលេសទាំងពួង ក្ស័យទៅនៃតណ្ហាប្រាសចាកតម្រេក រលត់ទៅ (នៃកិលេស) ឈ្មោះថានិព្វាន ។

[៣៣៨] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាបញ្ញាឯណារបស់អរិយសាវកនោះ បញ្ញានោះឈ្មោះថា បញ្ញិន្ទ្រិយរបស់លោក ។ បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកអ្នកមានសទ្ធានោះ បានផ្គូផ្គងស្រេចយ៉ាងនេះ នឹករឭកឃើញស្រេចយ៉ាងនេះ តម្កល់ទុកស្រេចយ៉ាងនេះ ដឹងច្បាស់ស្រេចយ៉ាងនេះ រមែងជឿស៊ប់យ៉ាងនេះថា ធម៌ទាំងឡាយនេះឯងជាធម៌ដែលអាត្មាអញធ្លាប់ស្តាប់មកក្នុងកាលមុន ព្រោះហេតុនោះអាត្មាអញរមែងបានប៉ះពាល់ដោយនាមកាយក្នុងកាលឥឡូវនេះផង ចាក់ធ្លុះធ្លាយឃើញដោយប្រាជ្ញាផង ។

[៣៣៩] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាសទ្ធាឯណារបស់អរិយសាវកនោះ សទ្ធានោះ ឈ្មោះថាសទ្ធិន្ទ្រិយរបស់លោក ។

[៣៤០] សាធុ សាធុ សារីបុត្ត យោ សោ សារីបុត្ត អរិយសាវកោ តថាគតេ ឯកន្តគតោ អភិប្បសន្នោ ន សោ តថាគតេ វា តថាគតសាសនេ វា កង្ខេយ្យ វា វិចិកិច្ឆេយ្យ វា ។ សទ្ធស្ស ហិ សារីបុត្ត អរិយសាវកស្ស ឯតំ បាដិកង្ខំ យំ អារទ្ធវីរិយោ វិហរិស្សតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។

[៣៤១] យំ ហិស្ស សារីបុត្ត វីរិយំ តទស្ស វីរិយិន្ទ្រិយំ ។ សទ្ធស្ស ហិ សារីបុត្ត អរិយសាវកស្ស អារទ្ធវីរិយស្ស ឯតំ បាដិកង្ខំ យំ សតិមា ភវិស្សតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ។

[៣៤០] ម្នាលសារីបុត្ត ប្រពៃហើយ ៗ ម្នាលសារីបុត្ត អរិយសាវកឯណាជ្រះថ្លាតាំងនៅមាំមួន ចំពោះព្រះតថាគត អរិយសាវកនោះ មិនគប្បីងឿងឆ្ងល់ឬសង្ស័យចំពោះព្រះតថាគត និងចំពោះសាសនានៃព្រះតថាគតឡើយ ។ ម្នាលសារីបុត្ត ព្រោះថាអរិយសាវកអ្នកមានសទ្ធា នឹងនឹកសង្ឃឹមនូវហេតុនុ៎ះជាប្រាកដ គឺនឹងប្រារព្ធសេចក្តីព្យាយាមដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នការមានកម្លាំងចិត្ត មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។

[៣៤១] ម្នាលសារីបុត្ត ព្រោះថាវីរិយឯណារបស់អរិយសាវកនោះ វីរិយនោះឈ្មោះថាវីរិយិន្ទ្រិយរបស់លោក ។ ម្នាលសារីបុត្ត ដ្បិតអរិយសាវក អ្នកមានសទ្ធាប្រារព្ធសេចក្តីព្យាយាម នឹងនឹកសង្ឃឹមនូវហេតុនុ៎ះជាប្រាកដ គឺជាអ្នកមានស្មារតីប្រកបដោយប្រាជ្ញាចាស់ក្លាដ៏ប្រសើរ តែងនឹកបាន ចាំបាន នូវអំពើដែលធ្លាប់ធ្វើមកជាយូរហើយផង នូវពាក្យសម្តីដែលធ្លាប់និយាយមកជាយូរហើយផង ។

ជរាវគ្គោ

[៣៤២] យា ហិស្ស សារីបុត្ត សតិ តទស្ស សតិន្ទ្រិយំ ។ សទ្ធស្ស ហិ សារីបុត្ត អរិយស្សាវកស្ស អារទ្ធវីរិយស្ស ឧបដ្ឋិតស្សតិនោ ឯតំ បាដិកង្ខំ យំ វោស្សគ្គារម្មណំ ករិត្វា លភិស្សតិ សមាធឹ លភិស្សតិ ចិត្តស្ស ឯកគ្គតំ ។

[៣៤៣] យោ ហិស្ស សារីបុត្ត សមាធិ តទ-ស្ស សមាធិន្ទ្រិយំ ។ សទ្ធស្ស ហិ សារីបុត្ត អរិ-យស្សាវកស្ស អារទ្ធវីរិយស្ស ឧបដ្ឋិតស្សតិនោ សម្មា-សមាហិតចិត្តស្ស ឯតំ បាដិកង្ខំ យំ ឯវំ បជានិស្សតិ អនមតគ្គោ ខោ សំសារោ បុព្វា កោដិ នប្បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ អវិជ្ជាយត្វេវ តមោកាយស្ស អសេសវិរាគ-និរោធោ សន្តមេតំ បទំ បណីតមេតំ បទំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។

[៣៤២] ម្នាលសារីបុត្ត ព្រោះថាសតិឯណារបស់អរិយសាវក នោះ សតិនោះឈ្មោះថាសតិន្ទ្រិយរបស់លោក ។ ម្នាលសារីបុត្ត ដ្បិតអរិយសាវក អ្នកមានសទ្ធា ប្រារព្ធសេចក្ដីព្យាយាម មានសតិតម្កល់ខ្ជាប់ នឹងនឹកសង្ស័មនូវហេតុនុ៎ះជាប្រាកដ គឺធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ហើយ នឹងបាននូវសមាធិ នឹងបាននូវភាវៈនៃចិត្តមានអារម្មណ៍តែមួយ ។

[៣៤៣] ម្នាលសារីបុត្ត ព្រោះថាសមាធិឯណារបស់អរិយ-សាវកនោះ សមាធិនោះឈ្មោះថាសមាធិន្ទ្រិយរបស់លោក ។ ម្នាលសារីបុត្ត ដ្បិតអរិយសាវកអ្នកមានសទ្ធា ប្រារព្ធសេចក្ដីព្យាយាម មានសតិតម្កល់ខ្ជាប់ មានចិត្តតាំងមាំដោយប្រពៃ នឹងនឹកសង្ស័មនូវហេតុនុ៎ះជាប្រាកដ គឺនឹងដឹងច្បាស់យ៉ាងនេះថា សង្សារមានទីបំផុតកំណត់មិនបាន ទីបំផុតខាងដើមមិនប្រាកដដល់សត្វទាំងឡាយ ដែលមានអវិជ្ជាជាគ្រឿងរារាំង មានតណ្ហាជាគ្រឿងប្រកប ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ ការប្រាសចាកតម្រេក និងការរលត់ទៅឥតមានសេសសល់នៃគំនរងងឹតគឺអវិជ្ជានុ៎ះឯង ជាផ្លូវដ៏ស្ងប់ ជាផ្លូវដ៏ប្រសើរ គឺការស្ងប់រម្ងាប់ទៅនៃសង្ខារទាំងពួង លះបង់នូវឧបធិក្កិលេសទាំងពួង ក្ស័យទៅនៃតណ្ហា ប្រាសចាកតម្រេក រលត់ទៅ (នៃកិលេស) ឈ្មោះថានិព្វាន ។

[៣៤៤] យា ហិស្ស សារីបុត្ត បញ្ញា តទស្ស បញ្ញិន្ទ្រិយំ ។ សទ្ធោ សោ សារីបុត្ត អរិយសាវកោ ឯវំ បទហិត្វា បទហិត្វា ឯវំ សរិត្វា សរិត្វា ឯវំ សមាទហិត្វា សមាទហិត្វា ឯវំ បជានិត្វា បជានិត្វា ឯវំ អភិសទ្ទហាតិ ឥមេ ខោ តេ ធម្មា យេ មេ បុព្វេ សុតា វ អហេសុំ តេនាហំ ឯតរហិ កាយេន ច ផុសិត្វា វិហរាមិ បញ្ញាយ ច អតិវិជ្ឈ បស្សាមីតិ ។

[៣៤៥] យា ហិស្ស សារីបុត្ត សទ្ធា តទស្ស សទ្ធិន្ទ្រិយន្តិ ។

ជរាវគ្គោ បញ្ចមោ ។

[៣៤៤] ម្នាលសារីបុត្ត ព្រោះថាបញ្ញាឯណារបស់អរិយសាវកនោះ បញ្ញានោះឈ្មោះថាបញ្ញិន្ទ្រិយរបស់លោក ។ ម្នាលសារីបុត្ត អរិយសាវកអ្នកមានសទ្ធានោះ បានផ្គួផ្គងស្រេចយ៉ាងនេះ នឹករឭកឃើញស្រេចយ៉ាងនេះ តម្កល់ទុកស្រេចយ៉ាងនេះ ដឹងច្បាស់ស្រេចយ៉ាងនេះ រមែងជឿស៊ប់យ៉ាងនេះថា ធម៌ទាំងឡាយនេះឯង ជាធម៌ដែលអាត្មាអញធ្លាប់បានស្តាប់មកក្នុងកាលមុន ព្រោះហេតុនោះ អាត្មាអញរមែងបានប៉ះពាល់ដោយនាមកាយក្នុងកាលឥឡូវនេះផង ចាក់ធ្លុះធ្លាយឃើញដោយប្រាជ្ញាផង ។

[៣៤៥] ម្នាលសារីបុត្ត ព្រោះថាសទ្ធាឯណា របស់អរិយសាវកនោះ សទ្ធានោះឈ្មោះថា សទ្ធិន្ទ្រិយរបស់លោក ។

ចប់ ជរាវគ្គ ទី ៥ ។

ជរាវគ្គោ

# តស្សុទ្ទានំ

ជរា ឧណ្ណាភោ ព្រាហ្មណោ
សាកេតោ បុព្វកោដ្ឋកោ
បុព្វារាមេ ច ចត្តារិ
បិណ្ឌោលោ សត្វេន តេ ឧសាតិ ។

ជរាវគ្គ

# ឧទ្ទាននៃជរាវគ្គនោះគឺ

*និយាយអំពីព្រះដ៏មានព្រះភាគទ្រង់ព្រះជរា ១ អំពីឧណ្ណាភព្រាហ្មណ៍ ១ អំពីព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងសាកេត ១ អំពីព្រះដ៏មានព្រះភាគគង់នៅក្នុងបុព្វកោដ្ឋកនិគម ១ អំពីព្រះដ៏មានព្រះភាគគង់នៅក្នុងបុព្វារាមមាន ៤ លើក អំពីព្រះបិណ្ឌោលភារទ្វាជៈ ១ អំពីអរិយសាវកអ្នកមានសទ្ធា ១ រួមទាំងអស់ត្រូវជា ១០ ។*

# សូករខាតវគ្គោ

[៣៤៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ វិហរតិ កោសលាយំ ព្រាហ្មណគ្គាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ

[៣៤៧] សេយ្យថាបិ ភិក្ខវេ យេ កេចិ តិរច្ឆានគតា បាណា សីហោ មិគរាជា តេសំ អគ្គមក្ខាយតិ យទិទំ ថាមេន ជវេន សូរិយេន(១) ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយ ។

[៣៤៨] កតមេ ច ភិក្ខវេ ពោធិបក្ខិយា ធម្មា ។ សទ្ធិន្ទ្រិយំ ភិក្ខវេ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។ វីរិយិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។ សតិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ

១ ឱ. ម. សូរេន ។

# សូករខាតវគ្គ

[៣៤៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រាហ្មណគ្រាមឈ្មោះកោសល ក្នុងដែនកោសល ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា

[៣៤៧] ម្នាលភិក្ខុទាំងឡាយ ស្រេចលើសីហៈជាស្តេចនៃម្រឹគប្រសើរជាងពួកសត្វតិរច្ឆានទាំងអស់ដោយកម្លាំង ដោយសន្ទុះ ដោយសេចក្តីក្លៀវក្លា ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយស្រេចលើបញ្ញិន្ទ្រិយប្រសើរជាងពួកធម៌ចំណែកខាងការត្រាស់ដឹងទាំងអស់ ដោយការត្រាស់ដឹងដូច្នោះឯង ។

[៣៤៨] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ចំណែកខាងការត្រាស់ដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយជាធម៌ចំណែកខាងការត្រាស់ដឹង សទ្ធិន្ទ្រិយនោះប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ វីរិយិន្ទ្រិយជាធម៌ចំណែកខាងការត្រាស់ដឹង វីរិយិន្ទ្រិយនោះប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ សតិន្ទ្រិយជាធម៌ចំណែកខាងការត្រាស់ដឹងសតិន្ទ្រិយនោះ

ពោធាយ សំវត្តតិ ។ សមាធិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។ បញ្ញិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។

[៣៨៩] សេយ្យថាបិ ភិក្ខវេ យេ កេចិ តិរច្ឆានគតា បាណា សីហោ មិគរាជា តេសំ អគ្គមក្ខាយតិ យទិទំ ថាមេន ជវេន សូរិយេន ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយាតិ ។

[៣៩០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មល្លកេសុ[១] វិហរតិ ឧរុវេលកប្បំ នាម មល្លកានំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ

[៣៩១] យាវកីវញ្ច ភិក្ខវេ អរិយសាវកស្ស អរិយញាណំ ន ឧប្បន្នំ ហោតិ នេវ តាវ ចតុន្នំ ឥន្ទ្រិយានំ សណ្ឋិតិ ហោតិ នេវ តាវ ចតុន្នំ ឥន្ទ្រិយានំ អវដ្ឋិតិ ហោតិ ។ យតោ ច ខោ ភិក្ខវេ អរិយសាវកស្ស អរិយញាណំ ឧប្បន្នំ ហោតិ អថ ចតុន្នម ឥន្ទ្រិយានំ សណ្ឋិតំ ហោតិ អថ ចតុន្នំ ឥន្ទ្រិយានំ អវដ្ឋិតិ ហោតិ ។

១ ឱ. ម. មល្លិកេសុ ។

ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ សមាធិន្ទ្រិយជាធម៌ចំណែកខាងការត្រាស់ដឹង សមាធិន្ទ្រិយនោះប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ បញ្ញិន្ទ្រិយជាធម៌ចំណែកខាងការត្រាស់ដឹង បញ្ញិន្ទ្រិយនោះប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។

[៣៨៩] ម្នាលភិក្ខុទាំងឡាយ ស្រេចលើសីហៈជាស្តេចនៃម្រឹគ ប្រសើរជាងពួកសត្វតិរច្ឆានទាំងអស់ ដោយកម្លាំង ដោយសន្ទុះ ដោយសេចក្តីក្លៀវក្លា ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ស្រេចលើបញ្ញិន្ទ្រិយ ប្រសើរជាងពួកធម៌ចំណែកខាងការត្រាស់ដឹងទាំងអស់ ដោយការត្រាស់ដឹងដូច្នោះឯង ។

[៣៩០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងនិគមឈ្មោះឧរុវេលកប្បរបស់ពួកអ្នកស្រុកមល្លកក្នុងមល្លកជនបទ ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា

[៣៩១] ម្នាលភិក្ខុទាំងឡាយ អរិយញ្ញាណមិនបានកើតឡើងដល់អរិយសាវកត្រឹមណា ឥន្ទ្រិយទាំង ៤ ក៏មិនទាន់ស្ថិតនៅត្រឹមនោះ ឥន្ទ្រិយទាំង ៤ មិនបានស្ថិតនៅស៊ប់ត្រឹមនោះ ។ ម្នាលភិក្ខុទាំងឡាយ អរិយញ្ញាណកើតឡើងដល់អរិយសាវកកាលណា ឥន្ទ្រិយទាំង ៤ ក៏ស្ថិតនៅកាលនោះ ឥន្ទ្រិយទាំង ៤ ក៏ស្ថិតនៅស៊ប់កាលនោះ ។

[៣៨២] សេយ្យថាបិ ភិក្ខវេ យាវកីវញ្ច កូដាគារស្ស កូដំ ន ឧស្សិតំ ហោតិ នេវ តាវ គោបានសីនំ សណ្ឋិតំ ហោតិ នេវ តាវ គោបានសីនំ អវដ្ឋិតំ ហោតិ ។ យតោ ច ខោ ភិក្ខវេ កូដាគារស្ស កូដំ ឧស្សិតំ ហោតិ អថខោ គោបានសីនំ សណ្ឋិតំ ហោតិ អថខោ គោបានសីនំ អវដ្ឋិតំ ហោតិ ។ ឯវមេវ ខោ ភិក្ខវេ យាវកីវញ្ច អរិយសាវកស្ស អរិយញាណំ ន ឧប្បន្នំ ហោតិ នេវ តាវ ចតុន្នំ ឥន្ទ្រិយានំ សណ្ឋិតិ ហោតិ នេវ តាវ ចតុន្នំ ឥន្ទ្រិយានំ អវដ្ឋិតំ ហោតិ ។ យតោ ច ខោ ភិក្ខវេ អរិយសាវកស្ស អរិយញាណំ ឧប្បន្នំ ហោតិ អថ ចតុន្នំ ឥន្ទ្រិយានំ ។ បេ ។ អវដ្ឋិតិ ហោតិ ។ កាតមេសំ ចតុន្នំ ។ សទ្ធិន្ទ្រិយស្ស វីរិយិន្ទ្រិយស្ស សតិន្ទ្រិយស្ស សមាធិន្ទ្រិយស្ស ។

[៣៨៣] បញ្ញវតោ ភិក្ខវេ អរិយសាវកស្ស តទន្វយា សទ្ធា សណ្ឋាតិ តទន្វយំ វីរិយំ សណ្ឋាតិ តទន្វយា សតិ សណ្ឋាតិ តទន្វយោ សមាធិ សណ្ឋាតីតិ ។

[៣៥២] ម្នាលភិក្ខុទាំងឡាយ ផ្ទះមានកំពូលដែលគេមិនទាន់លើកកំពូលត្រឹមណា បង្កង់ទាំងឡាយក៏មិនទាន់ស្ថិតនៅត្រឹមនោះ បង្កង់ទាំងឡាយមិនទាន់ស្ថិតនៅស៊ប់ត្រឹមនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែផ្ទះមានកំពូលដែលគេលើកកំពូលឡើងកាលណា ទើបបង្កង់ទាំង-ឡាយស្ថិតនៅកាលនោះ បង្កង់ទាំងឡាយស្ថិតនៅស៊ប់កាលនោះឯង ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយញ្ញាណ មិនទាន់កើតឡើងដល់អរិយសាវកត្រឹមណា ឥន្ទ្រិយទាំង ៤ ក៏មិនទាន់ស្ថិតនៅត្រឹមនោះ ឥន្ទ្រិយទាំង ៤ មិនទាន់ស្ថិតនៅស៊ប់ត្រឹមនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែអរិយញ្ញាណកើតឡើងដល់អរិយសាវកកាលណា ទើបឥន្ទ្រិយទាំង ៤ ។ បេ ។ ស្ថិតនៅស៊ប់កាលនោះ ។ ឥន្ទ្រិយទាំង ៤ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ ក៏ដូច្នោះឯង ។

[៣៥៣] ម្នាលភិក្ខុទាំងឡាយ សទ្ធារបស់អរិយសាវកអ្នកមានប្រាជ្ញាដ៏សមគួរដល់ប្រាជ្ញានោះ ទើបស្ថិតនៅបាន វីរិយៈដ៏សមគួរដល់សទ្ធានោះ ទើបស្ថិតនៅបាន សតិដ៏សមគួរដល់វីរិយៈនោះ ទើបស្ថិតនៅបាន សមាធិដ៏សមគួរដល់សតិនោះ ទើបស្ថិតនៅបាន ។

២១៩

## សូករខាតវគ្គោ

[៣៩៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា គោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ អត្ថិ នុ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម សេក្ខោ ភិក្ខុ សេក្ខភូមិយំ សណ្ឋិតោ សេក្ខោស្មីតិ បជានេយ្យ អសេក្ខោ ភិក្ខុ អសេក្ខភូមិយំ សណ្ឋិតោ អសេក្ខោស្មីតិ បជា-នេយ្យាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។

[៣៩៥] អត្ថិ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម សេក្ខោ ភិក្ខុ សេក្ខភូមិយំ សណ្ឋិតោ សេ-ក្ខោស្មីតិ បជានេយ្យ អសេក្ខោ ភិក្ខុ អសេក្ខភូ-មិយំ សណ្ឋិតោ អសេក្ខោស្មីតិ បជានេយ្យ ។

[៣៩៦] កតមោ ច ភិក្ខវេ បរិយាយោ យំ បរិ-យាយំ អាគម្ម សេក្ខោ ភិក្ខុ សេក្ខភូមិយំ សណ្ឋិតោ សេក្ខោស្មីតិ បជានាតិ ។ ឥធ ភិក្ខវេ សេក្ខោ ភិក្ខុ

សូករខាតវគ្គ

[៣៩៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសេក្ខបុគ្គលស្ថិតនៅក្នុងសេក្ខភូមិ គប្បីដឹងច្បាស់ថា អាត្មាអញជាសេក្ខបុគ្គល ភិក្ខុជាអសេក្ខបុគ្គលស្ថិតនៅក្នុងអសេក្ខភូមិ គប្បីដឹងច្បាស់ថា អាត្មាអញជាអសេក្ខបុគ្គល ព្រោះអាស្រ័យបរិយាយឯណា បរិយាយនោះមានដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះដ៏មានព្រះភាគជាឫសគល់ ។ បេ ។

[៣៩៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសេក្ខបុគ្គលស្ថិតនៅក្នុងសេក្ខភូមិ គប្បីដឹងច្បាស់ថា អាត្មាអញជាសេក្ខបុគ្គល ភិក្ខុជាអសេក្ខ-បុគ្គលស្ថិតនៅក្នុងអសេក្ខភូមិ គប្បីដឹងច្បាស់ថា អាត្មាអញជាអសេក្ខ-បុគ្គល ព្រោះអាស្រ័យបរិយាយឯណា បរិយាយនោះមាន ។

[៣៩៦] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាសេក្ខបុគ្គលស្ថិតនៅក្នុងសេក្ខភូមិ អាស្រ័យបរិយាយដូចម្តេច ទើបដឹងច្បាស់ថា អាត្មាអញជាសេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសេក្ខបុគ្គលក្នុងសាសនានេះ

ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទ-យោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិប-ទាតិ យថាភូតំ បជានាតិ ។ អយំបិ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម សេក្ខោ ភិក្ខុ សេក្ខភូមិយំ សណ្ឋិតោ សេក្ខោម្ហីតិ បជានាត ។

[៣៨៧] បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អត្ថិ នុ ខោ ឥតោ ពហិទ្ធា អញ្ញោ សមណោ វា ព្រាហ្មណោ វា យោ ឯវំ ភូតំ តច្ឆំ តថំ ធម្មំ ទេសេតិ យថា ភគវាតិ ។ សោ ឯវំ បជានាតិ នត្ថិ នុ ខោ ឥតោ ពហិទ្ធា អញ្ញោ សមណោ វា ព្រាហ្មណោ វា យោ ឯវំ ភូតំ តច្ឆំ តថំ ធម្មំ ទេសេតិ យថា ភគវាតិ ។ អយំបិ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម សេក្ខោ ភិក្ខុ សេក្ខភូមិយំ សណ្ឋិតោ សេក្ខោម្ហីតិ បជានាតិ ។

រមែងដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសភាវៈរំលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសេក្ខបុគ្គលស្ថិតនៅក្នុងសេក្ខភូមិ អាស្រ័យបរិយាយនេះឯង ទើបដឹងច្បាស់ថា អាត្មាអញជាសេក្ខបុគ្គល ។

[៣៥៧] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខបុគ្គលរមែងពិចារណាឃើញថា សមណៈឬព្រាហ្មណ៍ដទៃក្រៅអំពីសាសនានេះ មាននរណាសម្ដែងធម៌ពិត មែន ប្រាកដ ដូចព្រះដ៏មានព្រះភាគយ៉ាងនេះដែរឬ ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា សមណៈឬព្រាហ្មណ៍ដទៃក្រៅអំពីសាសនានេះ មិនមាននរណាសម្ដែងធម៌ពិត មែន ប្រាកដដូចព្រះដ៏មានព្រះភាគយ៉ាងនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសេក្ខបុគ្គលស្ថិតនៅក្នុងសេក្ខភូមិ អាស្រ័យបរិយាយនេះឯង ទើបដឹងច្បាស់ថា អាត្មាអញជាសេក្ខបុគ្គល ។

២២១

សូករខាតវគ្គោ

[៣៩៨] បុន ចបរំ ភិក្ខវេ សេក្ខោ ភិក្ខុ បញ្ចិន្ទ្រិយានិ បជានាតិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ យំគតិកានិ យំបរមានិ យំផលានិ យំបរិយោសានានិ ន ហេវ ខោ កាយេន ផុសិត្វា វិហរតិ បញ្ញាយ ច អតិវិជ្ឈ បស្សតិ ។ អយំបិ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម សេក្ខោ ភិក្ខុ សេក្ខភូមិយំ សណ្ឋិតោ សេក្ខោស្មីតិ បជានាតិ ។

[៣៩៩] កតមោ ច ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម អសេក្ខោ ភិក្ខុ អសេក្ខភូមិយំ សណ្ឋិតោ អសេក្ខោស្មីតិ បជានាតិ ។ ឥធ ភិក្ខវេ អសេក្ខោ ភិក្ខុ បញ្ចិន្ទ្រិយានិ បជានាតិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ យំគតិកានិ យំបរមានិ យំផលានិ យំបរិយោសានានិ កាយេន ច ផុសិត្វា វិហរតិ បញ្ញាយ ច អតិវិជ្ឈ បស្សតិ ។ អយំបិ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម អសេក្ខោ ភិក្ខុ អសេក្ខភូមិយំ សណ្ឋិតោ អសេក្ខោស្មីតិ បជានាតិ ។

[៣៥៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាសេក្ខបុគ្គល រមែងដឹងច្បាស់នូវឥន្ទ្រិយទាំង ៥ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិ-ន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ភិក្ខុជាសេក្ខបុគ្គលមិនទាន់បានប៉ះពាល់នូវគតិដ៏ប្រសើរ និងផលដែលជាទីបំផុត ដោយកាយនៅឡើយទេ គ្រាន់តែពិចារណាឃើញធ្លុះធ្លាយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសេក្ខបុគ្គលស្ថិតនៅក្នុងសេក្ខភូមិ អាស្រ័យបរិយាយនេះឯង ទើបដឹងច្បាស់ថា អាត្មាអញជាសេក្ខបុគ្គល ។

[៣៥៩] ចុះភិក្ខុជាអសេក្ខបុគ្គលស្ថិតនៅក្នុងអសេក្ខភូមិ អាស្រ័យបរិយាយដូចម្ដេច ទើបដឹងច្បាស់ថា អាត្មាអញជាអសេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអសេក្ខបុគ្គលក្នុងសាសនានេះ រមែងដឹងច្បាស់នូវឥន្ទ្រិយទាំង ៥ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ភិក្ខុជាអសេក្ខបុគ្គល រមែងបានប៉ះពាល់នូវគតិដ៏ប្រសើរ និងផលដែលជាទីបំផុតដោយកាយផង ពិចារណាឃើញធ្លុះធ្លាយដោយប្រាជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអសេក្ខបុគ្គលស្ថិតនៅក្នុងអសេក្ខភូមិ អាស្រ័យបរិយាយនេះឯង ទើបដឹងច្បាស់ថាអាត្មាអញជាអសេក្ខបុគ្គល ។

[៣៦០] ឆុន ចេមរំ ភិក្ខវេ អសេក្ខោ ភិក្ខុ ឆ ឥន្ទ្រិយានិ បជានាតិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ។ ឥមានិ ខោ ឆ ឥន្ទ្រិយានិ សព្វេន សព្វំ សព្វថា សព្វំ អបរិសេសា និរុជ្ឈិស្សន្តិ អញ្ញានិ ច ឆ ឥន្ទ្រិយានិ ន កុហិញ្ចិ កិស្មិញ្ចិ ឧប្បជ្ជិស្សន្តីតិ បជានាតិ ។ អយំបិ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម អសេក្ខោ ភិក្ខុ អសេក្ខភូមិយំ សណ្ឋិតោ អសេក្ខោស្មីតិ បជានាតីតិ ។

[៣៦១] សេយ្យថាបិ ភិក្ខវេ យានិ កានិចិ ជង្គលានំ បាណានំ បទជាតានិ សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ ហត្ថិបទំ តេសំ អគ្គមក្ខាយតិ យទិទំ មហន្តត្តេន ។ ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ បទានិ ពោធាយ សំវត្តន្តិ បញ្ញិន្ទ្រិយំ បទំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយ ។

[៣៦០] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអសេក្ខបុគ្គល រមែងដឹងច្បាស់នូវឥន្ទ្រិយទាំង ៦ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ។ រមែងដឹងច្បាស់ថា ឥន្ទ្រិយទាំង ៦ នេះឯង គង់នឹងរលត់ទៅអស់ទាំងអស់គ្រប់អន្លើ ឥតមានសល់ផង ឥន្ទ្រិយទាំង ៦ ដទៃទៀត គង់នឹងមិនកើតឡើងក្នុងកាលខ្លះ ៗ ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអសេក្ខបុគ្គលស្ថិតនៅក្នុងអសេក្ខភូមិ អាស្រ័យបរិយាយនេះឯង ទើបដឹងច្បាស់ថា អាត្មាអញជាអសេក្ខបុគ្គល ។

[៣៦១] ម្នាលភិក្ខុទាំងឡាយ ស្នាមជើងរបស់ពួកសត្វដែលនៅលើផែនដី តែងប្រជុំក្នុងស្នាមជើងដំរី ស្រេចលើស្នាមជើងដំរី ប្រសើរជាងស្នាមជើងសត្វទាំងអស់ ព្រោះស្នាមជើងវាធំ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ បទគឺចំណែកធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ស្រេចលើបទគឺបញ្ញិន្ទ្រិយ ប្រសើរជាងឥន្ទ្រិយទាំងអស់ ដោយការត្រាស់ដឹង ក៏ដូច្នោះឯង ។

២២៣

សូករខាតវគ្គោ

[៣៦២] កាតមានិ ច ភិក្ខវេ បទានិ ពោធាយ សំវត្តន្តិ សទ្ធិន្ទ្រិយំ ភិក្ខវេ បទំ តំ ពោធាយ សំវត្តតិ ។ វិរិយិន្ទ្រិយំ បទំ តំ ពោធាយ សំវត្តតិ ។ សតិន្ទ្រិយំ បទំ តំ ពោធាយ សំវត្តតិ ។ សមាធិន្ទ្រិយំ បទំ តំ ពោធាយ សំវត្តតិ ។ បញ្ញិន្ទ្រិយំ បទំ តំ ពោធាយ សំវត្តតិ ។

[៣៦៣] សេយ្យថាបិ ភិក្ខវេ យានិ កានិចិ ជង្គលានំ បាណានំ បទជាតានិ សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ ហត្ថិបទំ តេសំ អគ្គមក្ខាយតិ យទិទំ មហន្តត្តេន ។ ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ បទានិ ពោធាយ សំវត្តន្តិ បញ្ញិន្ទ្រិយំ បទំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយាតិ ។

[៣៦៤] សេយ្យថាបិ ភិក្ខវេ យេ កេចិ សារគន្ធា លោហិតចន្ទនំ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយ ។

សូករខាតវគ្គ

[៣៦២] ម្នាលភិក្ខុទាំងឡាយ ចុះបទដូចម្តេចដែលប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ម្នាលភិក្ខុទាំងឡាយ បទគឺសទ្ធិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ បទគឺវីរិយិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ បទគឺសតិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ បទគឺសមាធិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ បទគឺបញ្ញិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។

[៣៦៣] ម្នាលភិក្ខុទាំងឡាយ ស្នាមជើងរបស់ពួកសត្វដែលនៅលើផែនដី តែងប្រជុំចុះក្នុងស្នាមជើងដំរី ស្រេចលើស្នាមជើងដំរី ប្រសើរជាងស្នាមជើងសត្វទាំងអស់ ព្រោះស្នាមជើងវាធំ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ បទទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ស្រេចលើបទគឺបញ្ញិន្ទ្រិយ ប្រសើរជាងបទទាំងអស់ ដោយការត្រាស់ដឹង ក៏ដូច្នោះឯង ។

[៣៦៤] ម្នាលភិក្ខុទាំងឡាយ ពួកក្លិនខ្លឹមឈើ ស្រេចលើក្លិនខ្លឹមចន្ទន៍ក្រហម ប្រសើរជាងក្លិនខ្លឹមឈើទាំងអស់ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ជាចំណែកខាងការត្រាស់ដឹង ស្រេចលើបញ្ញិន្ទ្រិយ ប្រសើរជាងធម៌ទាំងអស់ដោយការត្រាស់ដឹង ក៏ដូច្នោះឯង ។

[៣៦៥] កតមេ ច ភិក្ខវេ ពោជ្ឈបក្ខិយា ធម្មា ។ សទ្ធិន្ទ្រិយំ ភិក្ខវេ ពោជ្ឈបក្ខិយោ ធម្មោ តំ ពោ-ជាយ សំវត្តតិ ។ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ពោជ្ឈបក្ខិយោ ធម្មោ តំ ពោជាយ សំវត្តតិ ។

[៣៦៦] សេយ្យថាបិ ភិក្ខវេ យេ កេចិ សារគន្ធា លោហិតចន្ទនំ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោជ្ឈបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោជាយាតិ ។

[៣៦៧] ឯកធម្មេ បតិដ្ឋិតស្ស ភិក្ខវេ ភិក្ខុនោ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតានិ ។ កត-មស្មឹ ឯកធម្មេ ។ អប្បមាទេ ។

[៣៦៥] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ជាចំណែកខាងការត្រាស់ដឹងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយ ជាធម៌ជាចំណែកខាងការត្រាស់ដឹង សទ្ធិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជាធម៌ជាចំណែកខាងការត្រាស់ដឹង បញ្ញិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។

[៣៦៦] ម្នាលភិក្ខុទាំងឡាយ ពួកក្លិនខ្លឹមឈើ ស្រេចលើក្លិនខ្លឹមចន្ទន៍ក្រហម ប្រសើរជាងក្លិនខ្លឹមឈើទាំងអស់ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ជាចំណែកខាងការត្រាស់ដឹង ស្រេចលើបញ្ញិន្ទ្រិយ ប្រសើរជាងធម៌ទាំងអស់ដោយការត្រាស់ដឹង ក៏ដូច្នោះឯង ។

[៣៦៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយទាំង ៥ ជាឥន្ទ្រិយដែលភិក្ខុស្ថិតនៅក្នុងធម៌មួយ ទើបចម្រើនដោយប្រពៃបាន ។ ធម៌ ១ គឺអ្វី ។ គឺអប្បមាទ ។

សូករខាតវគ្គោ

[៣៦៨] កតមោ ច ភិក្ខវេ អប្បមាទោ ។ ឥធ ភិក្ខវេ ភិក្ខុ ចិត្តំ រក្ខតិ អាសវេសុ ច សាសវេសុ ច ធម្មេសុ ។ តស្ស ចិត្តំ រក្ខតោ អាសវេសុ ច សាសវេសុ ច ធម្មេសុ សទ្ធិន្ទ្រិយំបិ ភាវនាបារិបូរឹ គច្ឆតិ វីរិយិន្ទ្រិយំបិ ភាវនាបារិបូរឹ គច្ឆតិ សតិន្ទ្រិយំបិ ភាវនាបារិបូរឹ គច្ឆតិ សមាធិន្ទ្រិយំបិ ភាវនាបារិបូរឹ គច្ឆតិ បញ្ញិន្ទ្រិយំបិ ភាវនាបារិបូរឹ គច្ឆតិ ។

[៣៦៩] ឯវំបិ ខោ ភិក្ខវេ ឯកធម្មេ បតិដ្ឋិតស្ស ភិក្ខុនោ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតា-និតិ ។

[៣៧០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបា-លនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ អថខោ ភគវតោ

[៣៦៨] ម្នាលភិក្ខុទាំងឡាយ ចុះអប្បមាទតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះរក្សាចិត្តក្នុងអាសវៈទាំងឡាយ និងក្នុងធម៌ទាំងឡាយដែលប្រកបដោយអាសវៈ ។ កាលភិក្ខុនោះរក្សាចិត្តក្នុងអាសវៈទាំងឡាយ និងក្នុងធម៌ដែលប្រកបដោយអាសវៈទាំងឡាយ[១] សទ្ធិន្ទ្រិយ ក៏ដល់នូវការពេញលេញដោយភាវនា វីរិយិន្ទ្រិយ ក៏ដល់នូវការពេញលេញដោយភាវនា សតិន្ទ្រិយក៏ដល់នូវការពេញលេញដោយភាវនា សមាធិន្ទ្រិយក៏ដល់នូវការពេញលេញដោយភាវនា បញ្ញិន្ទ្រិយក៏ដល់នូវការពេញលេញដោយភាវនា ។

[៣៦៩] ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហើយ ឥន្ទ្រិយទាំង ៥ ជាឥន្ទ្រិយដែលភិក្ខុស្ថិតនៅក្នុងធម៌មួយ ទើបចម្រើនដោយប្រពៃបាន ។

[៣៧០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ បានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅនាអជបាលនិគ្រោធទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះ ព្រះដ៏មានព្រះភាគ

---

១ ប្រារព្ធចំពោះចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឃាត់នូវអាសវៈមិនឲ្យកើតឡើងបាន ឈ្មោះថារក្សាចិត្តក្នុងអាសវៈ និងក្នុងធម៌ដែលប្រកបដោយអាសវៈ ។ អដ្ឋកថា ។

វេហាកតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អ-មតោគធានិ ហោន្តិ អមតបរាយណានិ អមតបរិយោ-សានានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយណំ អម-តបរិយោសានំ ។ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយណំ អមតបរិយោសានំ ។ ឥមានិ បញ្ចិន្ទ្រិ-យានិ ភាវិតានិ ពហុលីកតានិ អមតោគធានិ ហោន្តិ អមតបរាយណានិ អមតបរិយោសានានីតិ ។

[៣៧១] អថខោ ព្រហ្មា សហម្បតិ ភគវតោ ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្ត-រហិតោ ភគវតោ បុរតោ បាតុរហោសិ ។

នៅក្នុងទីស្ងាត់ទ្រង់សម្ងំនៅក្នុងផលសមាបត្តិ កើតព្រះហឫទ័យបរិវិតក្កយ៉ាងនេះថា ឥន្ទ្រិយទាំង ៥ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។ ឥន្ទ្រិយទាំង ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។ ឥន្ទ្រិយទាំង ៥ នេះ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។

[៣៧១] គ្រានោះឯង សហម្បតិព្រហ្មដឹងនូវចេតោបរិវិតក្កនៃព្រះដ៏មានព្រះភាគដោយចិត្ត (របស់ខ្លួន) ក៏បាត់អំពីព្រហ្មលោកមកប្រាកដក្នុងទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ដូចជាបុរសមានកម្លាំងលាដៃដែលបត់ ឬបត់ដៃដែលលា ។

២២៧

## សូករខាតវគ្គោ

[៣៧២] អថខោ ព្រហ្មា សហម្បតិ ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច ឯវមេតំ ភគវា ឯវមេតំ សុគត បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អមតោគធានិ ហោន្តិ អមតបរាយណានិ អមតបរិយោសានានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយណំ អមតបរិយោសានំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយណំ អមតបរិយោសានំ ។ ឥមានិ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អមតោគធានិ ហោន្តិ អមតបរាយណានិ អមតបរិយោសានានិ ។

សូករខាតវគ្គ

[៣៧២] គ្រានោះឯង សហម្បតិព្រហ្មធ្វើសំពត់បង់កឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត សេចក្តីនុ៎ះយ៉ាងហ្នឹងហើយ ឥន្ទ្រិយទាំង ៥ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។ ចុះឥន្ទ្រិយទាំង ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយដែលបុគ្គលចម្រើនហើយ បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។ បេ ។ បញ្ញិន្ទ្រិយដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។ ឥន្ទ្រិយទាំង ៥ នេះឯង ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។

[៣៧៣] ភូតបុព្វាហំ ភន្តេ កស្សបេ សម្មាសម្ពុទ្ធេ ព្រហ្មចរិយំ អចរឹ តត្របិ មំ ឯវំ ជានន្តិ សហកោ ភិក្ខុ សហកោ ភិក្ខូតិ ។ សោ ខ្វាហំ ភន្តេ ឥមេសំយេវ បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា កាមេសុ កាមច្ឆន្ទំ វិរាជេត្វា កាយស្ស ភេទា បរំ មរណា សុគតឹ ព្រហ្មលោកំ ឧបបន្នោ តត្របិ មំ ឯវំ ជានន្តិ ព្រហ្មា សហម្បតិ ព្រហ្មា សហម្បតីតិ ។

[៣៧៤] ឯវមេតំ ភគវា ឯវមេតំ សុគត អហមេតំ ជានាមិ អហមេតំ បស្សាមិ យថា ឥមានិ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អមតោគធានិ ហោន្តិ អមតបរាយណានិ អមតបរិយោសានានីតិ ។

[៣៧៣] បពិត្រព្រះអង្គដ៏ចម្រើន កាលពីព្រេងនាយ ខ្ញុំព្រះអង្គបានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះកស្សបសម្មាសម្ពុទ្ធ ក្នុងកាលណោះអ្នកផងតែងស្គាល់ខ្ញុំព្រះអង្គយ៉ាងនេះថា សហកភិក្ខុ សហកភិក្ខុដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះនឿយណាយ ចាកកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ ព្រោះបានចម្រើន បានធ្វើឲ្យច្រើននូវឥន្ទ្រិយទាំង ៥ នេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិព្រហ្មលោក ពួកទេវតាទាំងនោះ ក៏ស្គាល់ខ្ញុំព្រះអង្គក្នុងទីនោះយ៉ាងនេះថា សហម្បតិព្រហ្ម សហម្បតិព្រហ្ម ដូច្នេះ ។

[៣៧៤] បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត សេចក្តីនុ៎ះយ៉ាងហ្នឹងហើយ ខ្ញុំព្រះអង្គដឹងហេតុនុ៎ះ ខ្ញុំព្រះអង្គឃើញហេតុនុ៎ះ ដូចជាឥន្ទ្រិយទាំង ៥ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ រមែងជាឥន្ទ្រិយចុះស៊ប់កាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត ។

២២៩

### សូករខាតវគ្គោ

[៣៨៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ សូករខាតាយំ ។ តត្រ ខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ កឹ នុ ខោ សារីបុត្ត អត្ថវសំ សម្បស្សមានោ ខីណាសវោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតិ ។

[៣៧៦] អនុត្តរំ ហិ ភន្តេ យោគក្ខេមំ សម្បស្សមានោ ខីណាសវោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតីតិ ។

[៣៧៧] សាធុ សាធុ សារីបុត្ត អនុត្តរញ្ហិ សារីបុត្ត យោគក្ខេមំ សម្បស្សមានោ ខីណាសវោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតីតិ ។

សូករខាតវគ្គ

[៣៧៥] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងគុហាឈ្មោះសូករខាតៈ នាភ្នំគិជ្ឈកូដទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រព ពិចារណាឃើញនូវអំណាចប្រយោជន៍ដូចម្តេចទើបប្រព្រឹត្តធ្វើសេចក្តីកោតក្រែង ដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសា-សនារបស់ព្រះតថាគតផង ។

[៣៧៦] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះតែភិក្ខុជាខីណាស្រព ពិចារណាឃើញ ព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាកយោគៈដោយពិត ទើបប្រព្រឹត្តធ្វើសេចក្តីកោតក្រែង ក៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ។

[៣៧៧] ម្នាលសារីបុត្ត ប្រពៃហើយ ៗ ម្នាលសារីបុត្ត ព្រោះតែភិក្ខុជាខីណាស្រពពិចារណាឃើញ ព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាកយោគៈដោយពិត ទើបប្រព្រឹត្តធ្វើសេចក្តីកោតក្រែង ដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ។

[៣៧៨] កតមោ ច សារីបុត្ត អនុត្តរោ យោគ-ក្ខេមោ យំ សម្បស្សមានោ ខីណាសវោ ភិក្ខុ តថា-គតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវ-ត្តមានោ បវត្តតីតិ ។

[៣៧៩] ឥធ ភន្តេ ខីណាសវោ ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ ។ វីរិយិន្ទ្រិយំ ភា-វេតិ ។ សតិន្ទ្រិយំ ភាវេតិ ។ សមាធិន្ទ្រិយំ ភាវេតិ ។ បញ្ញិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ ។ អយំ ខោ ភន្តេ អនុត្តរោ យោគក្ខេមោ យំ សម្បស្សមានោ ខីណាសវោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតីតិ ។

[៣៨០] សាធុ សាធុ សារីបុត្ត ឯសោ ហិ សារីបុត្ត អនុត្តរោ យោគក្ខេមោ យំ សម្បស្សមានោ ខីណាសវោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតិ ។

[៣៧៨] ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រព ពិចារណាឃើញព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាកយោគៈ រមែងប្រព្រឹត្តធ្វើសេចក្តីកោតក្រែង ដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ដូចម្តេចខ្លះ ។

[៣៧៩] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពក្នុងសាសនានេះ ចម្រើននូវសទ្ធិន្ទ្រិយ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ។ ចម្រើនវីរិយិន្ទ្រិយ ។ ចម្រើនសតិន្ទ្រិយ ។ ចម្រើនសមាធិន្ទ្រិយ ។ ចម្រើនបញ្ញិន្ទ្រិយជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពពិចារណាឃើញ ព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាកយោគៈនេះឯង ទើបប្រព្រឹត្តធ្វើសេចក្តីកោតក្រែង ដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ។

[៣៨០] ម្នាលសារីបុត្ត ប្រពៃហើយ ៗ ម្នាលសារីបុត្ត ព្រោះតែភិក្ខុជាខីណាស្សវព ពិចារណាឃើញ ព្រះអរហត្តដ៏ប្រសើរ ដែលក្សេមចាកយោគៈនុ៎ះឯង ទើបប្រព្រឹត្តធ្វើសេចក្តីកោតក្រែង ដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ។

២៣១

## សូករខាតវគ្គោ

[៣៨១] កតមោ ច សារីបុត្ត បរមនិបច្ចការោ យំ ខីណាសវោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតីតិ ។

[៣៨២] ឥធ ភន្តេ ខីណាសវោ ភិក្ខុ សត្ថរិ សគារវោ វិហរតិ សប្បដិស្សោ ធម្មេ សគារវោ វិហរតិ សប្បដិស្សោ សង្ឃេ សគារវោ វិហរតិ សប្បដិស្សោ សិក្ខាយ សគារវោ វិហរតិ សប្បដិស្សោ សមាធិស្មឹ សគារវោ វិហរតិ សប្បដិស្សោ ។ អយំ ខោ ភន្តេ បរមនិបច្ចការោ យំ ខីណាសវោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតីតិ ។

សូករខាតវគ្គ

[៣៨១] ម្នាលសារីបុត្ត ចុះភិក្ខុជាខីណាស្រព ដែលមានសេចក្តីកោតក្រែងដ៏ប្រសើរ រមែងប្រព្រឹត្តធ្វើសេចក្តីកោតក្រែងដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង ដូចម្តេចខ្លះ ។

[៣៨២] បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ក្នុងសាសនានេះ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងព្រះសាស្តា ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងព្រះធម៌ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងព្រះសង្ឃ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងសិក្ខា ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងសមាធិ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ដែលមានសេចក្តីកោតក្រែងដ៏ប្រសើរ រមែងប្រព្រឹត្តធ្វើសេចក្តីកោតក្រែងដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសាសនារបស់ព្រះតថាគតផង យ៉ាងនេះឯង ។

[៣៨៣] សាធុ សាធុ សារីបុត្ត ឯសោ ហិ សារី-បុត្ត បរមនិបច្ចការោ យំ ទីឃាសរោ ភិក្ខុ តថាគតេ វា តថាគតសាសនេ វា បរមនិបច្ចការំ បវត្តមានោ បវត្តតីតិ ។

[៣៨៤] សាវត្ថីនិទានំ ។ បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិ-យានិ ភាវិតានិ ពហុលីកតានិ អនុប្បន្នានិ ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស ចាតុភាវា អរហតោ សម្មាសម្ពុ-ទ្ធស្ស ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វិរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អនុ-ប្បន្នានិ ឧប្បជ្ជន្តិ នាញ្ញត្រ តថាគតស្ស ចាតុភាវា អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

[៣៨៣] ម្នាលសារីបុត្ត ប្រពៃហើយ ៗ ម្នាលសារីបុត្ត មែនហើយ ភិក្ខុជាខីណាស្រព ដែលមានសេចក្តីកោតក្រែងដ៏ប្រសើរ រមែងប្រព្រឹត្តធ្វើសេចក្តីកោតក្រែងដ៏ក្រៃលែង ក្នុងព្រះតថាគតផង ក្នុងសា-សនារបស់ព្រះតថាគតផង យ៉ាងនុ៎ះឯង ។

[៣៨៤] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ ប្រការនេះ ដែលមិនទាន់កើត បើបុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងកើតឡើង តែមិនមែនកើតឡើង ក្នុងកាលដទៃអំពីកាលជាទីកើតនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទេ ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយទាំង ៥ នេះឯង ដែលមិនទាន់កើត បើបុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងកើតឡើង តែមិនមែនកើតឡើង ក្នុងកាលដទៃអំពីកាលជាទីកើតនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទេ ។

២៣៣



[៣៨៤] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អនុប្បន្នានិ ឧប្បជ្ជន្តិ ជាញត្រ សុគតវិនយា ។ កាតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អនុប្បន្នានិ ឧប្បជ្ជន្តិ ជាញត្រ សុគតវិនយាតិ ។

សូករខាតវគ្គោ ឆដ្ឋោ ។

# តស្សុទ្ទានំ

សាលំ មល្លិកំ សេក្ខោ ច បទេ សារេ បតិដ្ឋិតោ ព្រហ្មសូករខាតាយោ ឧប្បាទេ អបរេ ទុវេតិ ។

[៣៨៥] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ ដែលមិនទាន់កើត បើបុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងកើតឡើង តែមិនមែនកើតឡើងក្នុងកាលដទៃអំពីវិន័យរបស់ព្រះសុគតទេ ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយទាំង ៥ នេះឯង ដែលមិនទាន់កើត បើបុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងកើតឡើង តែមិនមែនកើតឡើងក្នុងកាលដទៃអំពីវិន័យរបស់ព្រះសុគតទេ ។

ចប់ សូករខាតវគ្គទី ៦ ។

## ឧទ្ទាននៃសូករខាតវគ្គនោះគឺ

និយាយអំពីព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដែនកោសល ១ ក្នុងមល្លកជនបទ ១ អំពីភិក្ខុជាសេក្ខបុគ្គល ១ អំពីស្នាមជើងដំរី ១ អំពីក្លិនខ្លឹមចន្ទន៍ ១ អំពីភិក្ខុស្ថិតនៅក្នុងធម៌រមែងញុំាងឥន្ទ្រិយទាំង ៥ ឲ្យចម្រើន ១ អំពីសហម្បតិព្រហ្ម ១ អំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងសូករខាតគុហា ១ អំពីការកើតឡើងនៃឥន្ទ្រិយ ២ លើកដទៃទៀត ។

# ពោធិបក្ខិយវគ្គោ

[៣៨៦] សាវត្ថីនិទានំ ។ បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ សញ្ញោជនានំ បហានាយ សំវត្តន្តិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ សញ្ញោជនានំ បហានាយ សំវត្តន្តីតិ ។

[៣៨៧] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អនុសយសមុគ្ឃាតាយ សំវត្តន្តិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អនុសយសមុគ្ឃាតាយ សំវត្តន្តីតិ ។

# ពោធិបក្ខិយវគ្គ

[៣៨៦] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវសញ្ញោជនៈទាំងឡាយ ។ ចុះឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះឯង បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីលះបង់សញ្ញោជនៈទាំងឡាយ ។

[៣៨៧] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកិរិយាដកចោលនូវអនុសយកិលេស ។ ចុះឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះឯង បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកិរិយាដកចោលនូវអនុសយកិលេស ។

## ពោធិបក្ខិយវគ្គោ

[៣៣៨] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អទ្ធានបរិញ្ញាយ សំវត្តន្តិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អទ្ធាន-បរិញ្ញាយ សំវត្តន្តីតិ ។

[៣៨៩] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អាសវានំ ខយាយ សំវត្តន្តិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ អាសវានំ ខយាយ សំវត្តន្តីតិ ។

ពោធិបក្ខិយវគ្គ

[៣៨៨] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកំណាត់ដឹងនូវកាលយូរ ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះឯង បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកំណាត់ដឹងនូវកាលយូរ ។

[៣៨៩] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកិរិយាអស់ទៅនៃអាសវៈទាំង-ឡាយ ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះឯង បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយ ។

[៣៩០] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ សញ្ញោជនានំ បហានាយ សំវត្តន្តិ អនុសយសមុគ្ឃាតាយ សំវត្តន្តិ អទ្ធានបរិញ្ញាយ សំ-វត្តន្តិ អាសវានំ ខយាយ សំវត្តន្តិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ភាវិតានិ ពហុលីកតានិ សញ្ញោជនានំ បហានាយ សំវត្តន្តិ អនុសយសមុគ្ឃាតាយ សំវត្តន្តិ អទ្ធានបរិញ្ញាយ សំវត្តន្តិ អាសវានំ ខយាយ សំ-វត្តន្តីតិ ។

[៣៩១] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

[៣៩០] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកិរិយាលះបង់នូវសញ្ញោជនៈ ទាំង-ឡាយ ប្រព្រឹត្តទៅដើម្បីកិរិយាដកចោលនូវអនុសយកិលេស ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវកាលយូរ ប្រព្រឹត្តទៅដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយ ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះឯង បុគ្គលបានចម្រើន បានធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីកិរិយាលះបង់នូវសញ្ញោជនៈទាំងឡាយ ប្រព្រឹត្តទៅដើម្បីដកចោលនូវអនុសយក្កិលេស ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវកាលយូរ ប្រព្រឹត្តទៅដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយ ។

[៣៩១] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ នេះ មាន ៥ ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាផលទាំង ២ ផលណាមួយរមែងកើតប្រាកដ គឺបានអរហត្តផលក្នុងបច្ចុប្បន្ន ពុំនោះសោត បើឧបាទានក្ខន្ធនៅសេសសល់នៅឡើយ ក៏គង់បានអនាគាមិ-ផលដែរ ព្រោះបានចម្រើន បានធ្វើឲ្យច្រើន នូវឥន្ទ្រិយ ៥ នេះឯង ។

## ពោធិបក្ខិយវគ្គោ

[៣៩២] បញ្ចិមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កតមានិ បញ្ច ។ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចិន្ទ្រិយានិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា សត្ត ផលា សត្តានិសំសា បាដិកង្ខា ។ កតមេ សត្ត ផលា សត្តានិសំសា ។ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ អថ មរណកាលេ អញ្ញំ អារាធេតិ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ មរណកាលេ អញ្ញំ អារាធេតិ អថ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយាយ អន្តរាបរិនិព្វាយី ហោតិ ឧបហច្ចបរិនិព្វាយី ហោតិ អសង្ខារបរិនិព្វាយី ហោតិ សសង្ខារបរិនិព្វាយី ហោតិ ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឥន្ទ្រិយានំ ភាវិតត្តា ពហុលីកតត្តា ឥមេ សត្ត ផលា សត្តានិសំសា បដិកង្ខាតិ ។

## ពោធិបក្ខិយវគ្គ

[៣៩២] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ ។ បេ ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ផល ៧ អានិសង្ស ៧ រមែងកើតប្រាកដ ព្រោះបានចម្រើន បានធ្វើឲ្យច្រើន នូវឥន្ទ្រិយ ៥ នេះឯង ។ ផល ៧ អានិសង្ស ៧ គឺអ្វីខ្លះ ។ គឺបុគ្គលនោះរមែងបានអរហត្តផលយ៉ាងឆាប់ក្នុងបច្ចុប្បន្ន បើមិនបានអរហត្តផលយ៉ាងឆាប់ក្នុងបច្ចុប្បន្នទេ ក៏គង់បានអរហត្តផលក្នុងកាលទៀបស្លាប់ បើមិនបានអរហត្តផលយ៉ាងឆាប់ក្នុងបច្ចុប្បន្នទេ បើមិនបានអរហត្តផលក្នុងកាលទៀបស្លាប់ទេ បុគ្គលនោះក៏គង់បានជាអន្តរាបរិនិព្វាយិបុគ្គល បានជាឧបហច្ចបរិនិព្វាយិបុគ្គល បានជាអសង្ខារបរិនិព្វាយិបុគ្គល បានជាសសង្ខារបរិនិព្វាយិបុគ្គល បានជាឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ព្រោះអស់ទៅនៃសញ្ញោជនៈ ៥ ជាចំណែកខាងក្រោម ។ ម្នាលភិក្ខុទាំងឡាយ ផល ៧ អានិសង្ស ៧ រមែងកើតប្រាកដ ព្រោះតែបានចម្រើន បានធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ នេះឯង ។

[៣៩៣] សេយ្យថាបិ ភិក្ខវេ យេ កេចិ ជម្ពុ-
ទីបកា រុក្ខា ជម្ពូ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ
ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ
តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយ ។

[៣៩៤] កតមេ ច ភិក្ខវេ ពោធិបក្ខិយា ធម្មា ។
សទ្ធិន្ទ្រិយំ ភិក្ខវេ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ
សំវត្តតិ ។ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិ-
ន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។

[៣៩៥] សេយ្យថាបិ ភិក្ខវេ យេ កេចិ ជម្ពុ-
ទីបកា រុក្ខា ជម្ពូ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ
ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិ-
ន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយាតិ ។

[៣៩៣] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយដែលនៅក្នុងជម្ពូទ្វីប មានតែដើមព្រីង ប្រាកដជាប្រសើរជាងដើមឈើទាំងនោះ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយ ប្រាកដជាប្រសើរជាងធម៌ទាំងនោះដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

[៣៩៤] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ជាចំណែកខាងការត្រាស់ដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយ ជាធម៌ជាចំ-ណែកខាងការត្រាស់ដឹង សទ្ធិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជាធម៌ជាចំណែកខាងការត្រាស់ដឹង បញ្ញិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។

[៣៩៥] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយដែលនៅក្នុងជម្ពូទ្វីប មានតែដើមព្រីង ប្រាកដជាប្រសើរជាងដើមឈើទាំងនោះ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

២៣៩

ពោធិបក្ខិយវគ្គោ

[៣៩៦] សេយ្យថាបិ ភិក្ខវេ យេ កេចិ នេវាធំ តាវត្តឹសានំ រុក្ខា ចារិច្ឆត្តកោ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយ ។

[៣៩៧] កតមេ ច ភិក្ខវេ ពោធិបក្ខិយា ធម្មា ។ សទ្ធិន្ទ្រិយំ ភិក្ខវេ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។ វីរិយិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។ សតិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ ។ សមាធិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ ។ បញ្ញិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។

ពោធិបក្ខិយវគ្គ

[៣៩៦] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយរបស់ពួកទេវតាជាន់តាវត្តិង្ស មានតែដើមបារិច្ឆត្តកព្រឹក្ស ប្រាកដជាប្រសើរជាងដើមឈើទាំងនោះ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយ ដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយប្រាកដជាប្រសើរជាងធម៌ទាំងនោះដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

[៣៩៧] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ជាចំណែកខាងការត្រាស់ដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយជាធម៌ជាចំណែកខាងការត្រាស់ដឹង សទ្ធិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ វីរិយិន្ទ្រិយ ជាធម៌ជាចំណែកខាងការត្រាស់ដឹង វីរិយិន្ទ្រិយនោះប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ សតិន្ទ្រិយ ជាធម៌ជាចំណែកខាងការត្រាស់ដឹង ។ សមាធិន្ទ្រិយ ជាធម៌ជាចំណែកខាងការត្រាស់ដឹង ។ បញ្ញិន្ទ្រិយជាធម៌ជាចំណែកខាងការត្រាស់ដឹង បញ្ញិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។

[៣៩៨] សេយ្យថាបិ ភិក្ខវេ យេ កេចិ ទេវានំ តាវត្តឹសានំ រុក្ខា ចារិច្ឆត្តកោ តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយាតិ ។

[៣៩៩] សេយ្យថាបិ ភិក្ខវេ យេ កេចិ អសុ-រានំ រុក្ខា ចិត្តបាដលី តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយ ។

[៤០០] កតមេ ច ភិក្ខវេ ពោធិបក្ខិយា ធម្មា ។ សទ្ធិន្ទ្រិយំ ភិក្ខវេ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។ បេ ។ បញ្ញិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។

[៣៩៨] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយរបស់ពួកទេវតាជាន់តាវត្តិង្ស មានតែដើមបារិច្ឆត្តកព្រឹក្ស ប្រាកដជាប្រសើរជាងដើមឈើទាំងនោះ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយ ដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយ ប្រាកដជាប្រសើរជាងធម៌ទាំងនោះដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

[៣៩៩] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយ របស់ពួកអសុរ មានតែដើមច្រនៀង ប្រាកដជាប្រសើរជាងដើមឈើទាំងនោះ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

[៤០០] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ជាចំណែកខាងការត្រាស់ដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយជាធម៌ជាចំណែកខាងការត្រាស់ដឹង សទ្ធិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ បេ ។ បញ្ញិន្ទ្រិយ ជាធម៌ជាចំណែកខាងការត្រាស់ដឹង បញ្ញិន្ទ្រិយនោះប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។

២៤១

ពោធិបក្ខិយវគ្គោ

[៤០១] សេយ្យថាបិ ភិក្ខវេ យេ កេចិ អសុរានំ វុក្ខា ចិត្តបាដលី តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយាតិ ។

[៤០២] សេយ្យថាបិ ភិក្ខវេ យេ កេចិ សុបណ្ណានំ វុក្ខា កោដសិម្ពលី តេសំ អគ្គមក្ខាយតិ ។ ឯវមេវ ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយ ។

[៤០៣] កតមេ ច ភិក្ខវេ ពោធិបក្ខិយា ធម្មា ។ សទ្ធិន្ទ្រិយំ ភិក្ខវេ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។ បេ ។ បញ្ញិន្ទ្រិយំ ពោធិបក្ខិយោ ធម្មោ តំ ពោធាយ សំវត្តតិ ។

ពោធិបក្ខិយវគ្គ

[៤០១] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយ របស់ពួកអសុរ មានតែដើមប្រទៀង ប្រសើរជាងដើមឈើទាំងនោះ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយ ប្រសើរជាងពួកធម៌ទាំងនោះ ដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

[៤០២] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយ របស់ពួកគ្រុឌ មានតែដើមរកា ប្រសើរជាងដើមឈើទាំងនោះ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយ ប្រសើរជាងពួកធម៌ទាំងនោះ ដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

[៤០៣] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ជាចំណែកខាងការត្រាស់ដឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយជាធម៌ជាចំណែកខាងការត្រាស់ដឹង សទ្ធិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ បេ ។ បញ្ញិន្ទ្រិយជាធម៌ជាចំណែកខាងការត្រាស់ដឹង បញ្ញិន្ទ្រិយនោះ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។

[៤០៤] សេយ្យថាបិ ភិក្ខវេ យេ កេចិ សុបណ្ណា-
នំ រុក្ខា កោដសិម្ពលី តេសំ អគ្គមក្ខាយតិ ។ ឯវមេវ
ខោ ភិក្ខវេ យេ កេចិ ពោធិបក្ខិយា ធម្មា បញ្ញិន្ទ្រិយំ
តេសំ អគ្គមក្ខាយតិ យទិទំ ពោធាយាតិ ។

ពោធិបក្ខិយវគ្គោ  សត្តមោ  ។

## តស្សុទ្ទានំ

សញ្ញោជនា  អនុសយា
បរិញ្ញា  អាសវក្ខយា
ទ្វេ  ផលា  ចតុរោ  រុក្ខា
វគ្គោ  តេន  បវុច្ចតីតិ  ។

[៤០៤] ម្នាលភិក្ខុទាំងឡាយ ពួកដើមឈើឯណានីមួយ របស់ពួកគ្រុឌ មានតែដើមរកា ប្រសើរជាងដើមឈើទាំងនោះ ដូចម្ដេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកធម៌ឯណានីមួយដែលជាចំណែកខាងការត្រាស់ដឹង មានតែបញ្ញិន្ទ្រិយ ប្រសើរជាងពួកធម៌ទាំងនោះ ដោយការត្រាស់ដឹង ក៏ដូច្នោះដែរ ។

ចប់ ពោធិបក្ខិយវគ្គ ទី ៧ ។

# ឧទ្ទាននៃពោធិបក្ខិយវគ្គនោះគឺ

និយាយអំពីចម្រើនឥន្ទ្រិយ ដើម្បីលះបង់សញ្ញោជនៈ ១ ដើម្បីដកចោលនូវអនុស័យ ១ ដើម្បីកំណត់ដឹងកាលយូរ ១ ដើម្បីកិរិយាអស់ទៅនៃអាសវៈ ១ អំពីផល ២ លើក អំពីដើមឈើ ៤ លើក ហេតុនោះបានជាហៅថាវគ្គ ។

# ឥន្ទ្រិយសំយុត្តស្ស គង្គាទិបេយ្យាលោ

[៤០៥] សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចី-
ននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ
ភិក្ខវេ ភិក្ខុ បញ្ចិន្ទ្រិយានិ ភាវេន្តោ បញ្ចិន្ទ្រិយានិ
ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ
និព្វានបព្ភារោ ។

[៤០៦] កថញ្ច ភិក្ខវេ ភិក្ខុ បញ្ចិន្ទ្រិយានិ
ភាវេន្តោ បញ្ចិន្ទ្រិយានិ ពហុលីករោន្តោ និព្វាននិន្នោ
ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ
ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ
និរោធនិស្សិតំ វោស្សគ្គបរិណាមឹ វីរិយិន្ទ្រិយំ សតិ-
ន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ភាវេតិ វិវេកនិស្សិតំ
វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ
ខោ ភិក្ខវេ ភិក្ខុ បញ្ចិន្ទ្រិយានិ ភាវេន្តោ បញ្ចិន្ទ្រិយានិ
ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ
និព្វានបព្ភារោតិ ។

# ឥន្ទ្រិយសំយុត្ត គង្គាទិបេយ្យាល

[៤០៥] ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គាមានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើត ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ក៏ដូច្នោះដែរ ។

[៤០៦] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធិន្ទ្រិយ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ ចម្រើននូវវីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។

[៤០៧] បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។

[៤០៨] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ បញ្ចិន្ទ្រិយានិ ភាវេតព្វានិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមានិ បញ្ចិន្ទ្រិយានិ ភាវេតព្វានីតិ ។ (យថា មគ្គសំយុត្តំ វិត្ថារិតំ តថា វិត្ថារេតព្វំ វិវេកនិស្សិតំ) ។

[៤០៧] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះមាន ៥ ។ ចុះសញ្ញោជនៈជាចំណែកខាងលើមាន ៥ គឺអ្វីខ្លះ ។ គឺរូបរាគ ១ អរូបរាគ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ នេះឯង ។

[៤០៨] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ ភិក្ខុគួរចម្រើន ដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីកិរិយាលះបង់នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។ ឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធិន្ទ្រិយដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ ។ បេ ។ ចម្រើននូវបញ្ញិន្ទ្រិយ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ ភិក្ខុគួរចម្រើនដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីកិរិយាលះបង់នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។ (មគ្គសំយុត្ត ដែលឲ្យពិស្តារហើយយ៉ាងណា ពាក្យថា អាស្រ័យនូវវិវេក (ជាដើម) បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ) ។

## គង្គាទិបេយ្យាលោ

[៤០៩] សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ បញ្ចិន្ទ្រិយានិ ភាវេន្តោ បញ្ចិន្ទ្រិយានិ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។

[៤១០] កថញ្ច ភិក្ខវេ ភិក្ខុ បញ្ចិន្ទ្រិយានិ ភាវេន្តោ បញ្ចិន្ទ្រិយានិ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បញ្ចិន្ទ្រិយានិ ភាវេន្តោ បញ្ចិន្ទ្រិយានិ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោតិ ។

គង្គាទិបេយ្យាល

[៤០៩] ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គាមានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើត ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ក៏ដូច្នោះដែរ ។

[៤១០] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធិន្ទ្រិយ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ។ បេ ។ ចម្រើននូវបញ្ញិន្ទ្រិយ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។

[៤១១] បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កាតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ច ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។

[៤១២] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ បញ្ចិន្ទ្រិយានិ ភាវេតព្វានិ ។ កាតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមានិ បញ្ចិន្ទ្រិយានិ ភាវេតព្វានីតិ ។

(យថា មគ្គសំយុត្តេ ឯវំ ភវតិ ឥន្ទ្រិយសំយុត្តំ) ។

គង្គាទិបេយ្យាលោ អដ្ឋមោ ។

[៤១១] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះមាន ៥ ។ ចុះសញ្ញោជនៈជាចំណែកខាងលើមាន ៥ គឺអ្វីខ្លះ ។ គឺរូបរាគ ១ អរូបរាគ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ នេះឯង ។

[៤១២] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ ភិក្ខុគួរចម្រើន ដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។ ចុះឥន្ទ្រិយ ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធិន្ទ្រិយ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ចម្រើននូវវីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយ ៥ នេះ ភិក្ខុគួរចម្រើន ដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។ (ក្នុងមគ្គសំយុត្តយ៉ាងណា ឥន្ទ្រិយសំយុត្តក៏យ៉ាងនោះដែរ) ។

ចប់ គង្គាទិបេយ្យាល ទី ៨ ។

គង្គាទិបេយ្យាលោ

# តស្សុទ្ទានំ

សញ្ញោជនា   អនុសយា
អទ្ធានំ   អាសវក្ខយា
ទ្វេ   ផលា   សត្តានិសំសា
ចតុរុក្ខា   វគ្គោ   តេន   បវុច្ចតីតិ ។

ឥន្ទ្រិយសំយុត្តំ   និដ្ឋិតំ ។

គង្គាទិបេយ្យាល

# ឧទ្ទាននៃឥន្ទ្រិយសំយុត្តនោះគឺ

*និយាយអំពីចម្រើនឥន្ទ្រិយ ដើម្បីលះបង់សញ្ញោជនៈ ១ ដើម្បីដកអនុស័យ ១ ដើម្បីកំណត់ដឹងកាលយូរ ១ ដើម្បីកិរិយាអស់ទៅនៃអាសវៈ ១ អំពីផលពីរយ៉ាង ១ អំពីអានិសង្ស ប្រាំពីរយ៉ាង ១ អំពីដើមឈើ ៤ លើក ហេតុនោះបានជាហៅថាវគ្គ ។*

ចប់ ឥន្ទ្រិយសំយុត្ត ។

# សម្មប្បធានសំយុត្តំ

[៤១៣] សាវត្ថី ។ តត្រ ខោ ភគវា ។ បេ ។ ឯតទវោច ចត្តារោមេ ភិក្ខវេ សម្មប្បធានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតំ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សម្មប្បធានាតិ ។

# សម្មប្បធានសំយុត្ត

[៤១៣] សាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ។ បេ ។ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សម្មប្បធាននេះមាន ៤ ។ សម្មប្បធាន ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់ធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ១ ។ ញុំាងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ១ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យចម្រើនធំទូលាយ ឲ្យបរិបូណ៌ជាភិយ្យោភាព ១ ។ ម្នាលភិក្ខុទាំងឡាយ សម្មប្បធានមាន ៤ នេះឯង ។

២៤៩

សម្មប្បធានសំយុត្តំ

[៤១៤] សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ចត្តារោ សម្មប្បធានេ ភាវេន្តោ ចត្តារោ សម្មប្ប-ធានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោ-ណោ និព្វានបព្ភារោ ។

[៤១៥] កថញ្ច ភិក្ខវេ ភិក្ខុ ចត្តារោ សម្មប្បធា-នេ ភាវេន្តោ ចត្តារោ សម្មប្បធានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ បាប-កានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

សម្មប្បធានសំយុត្ត

[៤១៤] ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គា មានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើត យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុចម្រើននូវសម្មប្បធាន ៤ ធ្វើឲ្យច្រើននូវសម្មប្បធាន ៤ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនោះដែរ ។

[៤១៥] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចម្រើននូវសម្មប្បធាន ៤ ធ្វើឲ្យច្រើននូវសម្មប្បធាន ៤ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមកដែលមិនទាន់កើតឲ្យកើតឡើង ១ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមកដែលកើតឡើងហើយ ។

អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ចត្តារោ សម្មប្បធានេ ភាវេន្តោ ចត្តារោ សម្មប្បធានេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោតិ ។

ឆ បាចីនតោ និន្នា
ឆ និន្នា ច សមុទ្ទតោ
ឯតេ ទ្វេ ឆ ទ្វាទស ហោន្តិ
វគ្គោ តេន បវុច្ចតីតិ ។

(សម្មប្បធានសំយុត្តស្ស គង្គាបេយ្យាលិ សម្មប្បធានវសេន វិត្ថារេតព្វា) ។ វគ្គោ ។

ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើតឲ្យកើតឡើងបាន ១ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យចម្រើនដំទូលាយ ឲ្យបរិបូណ៌ជាតិយោភាព ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើននូវសម្មប្បធាន ៤ ធ្វើឲ្យច្រើននូវសម្មប្បធាន ៤ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។

និយាយអំពីទន្លេគង្គាមានទំនាបទៅខាងកើត ៦ លើក អំពីទន្លេគង្គាមានទំនាបទៅរកសមុទ្រ ៦ លើកទាំង ៦ លើក ២ ដង ទុំះរួមជា ១២ លើក ហេតុនោះទើបហៅថាវគ្គ ។

(គង្គាបេយ្យាលរបស់សម្មប្បធានសំយុត្ត បណ្ឌិតគប្បីឲ្យពិស្តារតាមទំនងនៃសម្មប្បធានចុះ) ។ ចប់ ១ វគ្គ ។

២៤១

## សម្មប្បធានសំយុត្តំ

តថាគតំ បទំ កូដំ
មូលំ សារេន វស្សិកំ
រាជា ចន្ទិមសុរិយា
វត្ថេន ទសមំ បទំ ។

(អប្បមាទវគ្គោ សម្មប្បធានវសេន វិត្ថារេតព្វោ) ។ វគ្គោ ។

[៤១៦] សេយ្យថាបិ ភិក្ខវេ យេ កេចិ ពលករណីយា កម្មន្តា ករិយន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា កម្មន្តា ករិយន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សម្មប្បធានេ ភាវេតិ ចត្តារោ សម្មប្បធានេ ពហុលីករោតិ ។

សម្មប្បធានសំយុត្ត

និយាយអំពីព្រះតថាគត ១ អំពីស្នាមជើង ១ អំពីមេដំបូល ផ្ទះ ១ អំពីក្លិនឫស ១ អំពីក្លិនខ្លឹម ១ អំពីក្លិនផ្កាម្លិះ ១ អំពីស្ដេចចក្រពត្តិ ១ អំពីព្រះចន្ទ្រ ១ អំពីព្រះអាទិត្យ ១ អំពីសំពត់ ១ រួមជា ១០ ។

(អប្បមាទវគ្គ បណ្ឌិតគប្បីឲ្យពិស្ដារ តាមទំនងនៃសម្មប្បធានចុះ) ។ ចប់ ១ វគ្គ ។

[៤១៦] ម្នាលភិក្ខុទាំងឡាយ ការងារណាមួយដែលបុគ្គលត្រូវធ្វើដោយកម្លាំង លុះតែអាស្រ័យនឹងផែនដី ស្ថិតលើផែនដី ទើបធ្វើការងារដែលត្រូវធ្វើដោយកម្លាំងទាំងអស់នោះបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលុះតែអាស្រ័យនូវសីល ស្ថិតនៅក្នុងសីល ទើបចម្រើននូវសម្មប្បធាន ៤ ធ្វើឲ្យច្រើន នូវសម្មប្បធាន ៤ បាន យ៉ាងនោះដែរ ។

[៤១៧] កាថញ្ច ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សម្មប្បធានេ ភាវេតិ ចត្តារោ សម្មប្បធានេ ពហុលីករោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បា-ទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេ-បុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សម្មប្បធានេ ភាវេតិ ចត្តារោ សម្មប្បធានេ ពហុលីករោតីតិ ។ (ឯវំពលករណីយវគ្គោសម្មប្ប-ធានវសេន វិត្ថារេតព្វោ) ។

[៤១៨] តិស្សោ ឥមា ភិក្ខវេ ឯសនា ។ កាតមា តិស្សោ ។ កាមេសនា ភវេសនា ព្រហ្មចរិយេសនា ។ ឥមា ខោ ភិក្ខវេ តិស្សោ ឯសនា ។

[៤១៧] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអាស្រ័យនូវសីល ស្ថិតនៅក្នុងសីល ចម្រើននូវសម្មប្បធាន ៤ ធ្វើឲ្យច្រើននូវសម្មប្បធាន ៤ បានតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាអកុសលធម៌លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ១ ។ បេ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យចម្រើនធំទូលាយ បរិបូណ៌ជាភិយ្យោភាព ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ស្ថិតនៅក្នុងសីល ចម្រើននូវសម្មប្បធាន ៤ ធ្វើឲ្យច្រើននូវសម្មប្បធាន ៤ យ៉ាងនេះឯង ។ (ពលករណីយវគ្គ បណ្ឌិតគប្បីឲ្យពិស្តារ តាមទំនងនៃសម្មប្បធានយ៉ាងនេះចុះ) ។

[៤១៨] ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះមាន ៣ យ៉ាង ។ ការស្វែងរក ៣ យ៉ាង គឺអ្វីខ្លះ ។ គឺការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ យ៉ាងនេះឯង ។

២៨៣

សម្មប្បធានសំយុត្តំ

[៤១៩] ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ចត្តារោ សម្មប្បធានា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមាសំ ខោ ភិក្ខវេ តិស្សន្នំ ឯសនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមេ ចត្តារោ សម្មប្បធានា ភាវេតព្វាតិ ។

[៤២០] បញ្ចិមានិ ភិក្ខវេ ឱរម្ភាគិយានិ សញ្ញោ-ជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុ-ទ្ធម្ភាគិយានិ សញ្ញោជនានិ ។

## សម្មប្បធានសំយុត្ត

[៤១៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរចម្រើននូវសម្មប្បធាន ៤ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់នូវការស្វែងរកទាំង ៣ ប្រការនេះឯង ។ សម្មប្បធាន៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ។ បេ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសលដែលកើតឡើងហើយឲ្យស្ថិតស្ថេរ ដើម្បីឲ្យវិនាស ឲ្យចម្រើន ធំទូលាយ បរិបូណ៌ជាភិយ្យោភាព ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរចម្រើនសម្មប្បធាន ៤ នេះ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវការស្វែងរកទាំង ៣ យ៉ាងនេះឯង ។

[៤២០] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះមាន ៥ ។ សញ្ញោជនៈជាចំណែកខាងលើ ៥ គឺអ្វីខ្លះ ។ គឺរូបរាគ ១ អរូបរាគ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ នេះឯង ។

[៤២១] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិ-
យានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ
បហានាយ ចត្តារោ សម្មប្បធានា ភាវេតព្វា ។ កតមេ
ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ ។ បេ ។
ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ
ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ
ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហាតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ
សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ
បហានាយ ឥមេ ចត្តារោ សម្មប្បធានា ភាវេតព្វាតិ ។
(ឯវំ ឯសនា ចាលិ វិត្ថារេតព្វា ។

សម្មប្បធានសំយុត្តំ និដ្ឋិតំ ។

[៤២១] ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរចម្រើនសម្មប្បធាន ៤ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។ សម្មប្បធាន ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ។ បេ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យចម្រើនធំទូលាយ បរិបូណ៌ជាភិយ្យោភាព ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរចម្រើនសម្មប្បធាន ៤ នេះ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈ ជាចំណែកខាងលើ ៥ នេះឯង ។ (បាលីសម្តែងអំពីការស្វែងរកបណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះ) ។

ចប់ សម្មប្បធានសំយុត្ត ។

# ពលសំយុត្តំ

[៤២២] បញ្ចិមានិ ភិក្ខវេ ពលានិ ។ កតមានិ បញ្ច ។ សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ។ ឥមានិ ខោ ភិក្ខវេ បញ្ចពលានីតិ ។

[៤២៣] សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីន-និន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ បញ្ចពលានិ ភាវេន្តោ បញ្ចពលានិ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។

[៤២៤] កថញ្ច ភិក្ខវេ ភិក្ខុ បញ្ចពលានិ ភាវេន្តោ បញ្ច ពលានិ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធាពលំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។

# ពលសំយុត្ត

[៤២២] ម្នាលភិក្ខុទាំងឡាយ ពលៈទាំងឡាយ នេះ មាន ៥ ។ ពលៈ ៥ គឺអ្វីខ្លះ ។ គឺសទ្ធាពលៈ ១ វីរិយពលៈ ១ សតិពលៈ ១ សមាធិពលៈ ១ បញ្ញាពលៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពលៈ មាន ៥ នេះឯង ។

[៤២៣] ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គា មានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើត ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ក៏ដូច្នោះដែរ ។

[៤២៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធាពលៈ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រដ័យនូវនិរោធ បង្អោនទៅរកការលះបង់ ចម្រើននូវវីរិយពលៈ សតិពលៈ សមាធិពលៈ បញ្ញាពលៈ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅរកការលះបង់ ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ បញ្ច ពលានិ ភាវេន្តោ បញ្ច ពលានិ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វាន-ចោណោ និព្វានបព្ភារោតិ ។

[៤២៥] បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោ-ជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។

[៤២៦] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហា-នាយ បញ្ច ពលានិ ភាវេតព្វានិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធាពលំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ ភាវេតិ វិវេកនិស្សិ-តំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជ-នានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមានិ បញ្ច ពលានិ ភាវេតព្វានីតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើននូវ ពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។

[៤២៥] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះមាន ៥ ។ ចុះសញ្ញោជនៈជាចំណែកខាងលើ ៥ គឺអ្វីខ្លះ ។ គឺរូបរាគ ១ អរូបរាគ ១ មានៈ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ នេះឯង ។

[៤២៦] ម្នាលភិក្ខុទាំងឡាយ ពលៈ ៥ បុគ្គលគួរចម្រើន ដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។ ពលៈ ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ចម្រើននូវសទ្ធាពលៈ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីកិរិយាលះបង់ ចម្រើននូវវីរិយពលៈ សតិពលៈ សមាធិពលៈ បញ្ញាពលៈ ដែលអាស្រ័យនូវវិវេក អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីកិរិយាលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ពលៈ ៥ នេះ បុគ្គលគួរចម្រើនដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។

២៤៧

ពលសំយុត្តំ

[៤២៧] សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចី-
ននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ
ភិក្ខវេ ភិក្ខុ បញ្ច ពលានិ ភាវេន្តោ បញ្ច ពលានិ
ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ
និព្វានបព្ភារោ ។

[៤២៨] កថញ្ច ភិក្ខវេ ភិក្ខុ បញ្ច ពលានិ
ភាវេន្តោ បញ្ច ពលានិ ពហុលីករោន្តោ និព្វាននិន្នោ
ហោតិ និព្វានបោណោ និព្វានបព្ភារោ ។ ឥធ ភិក្ខវេ
ភិក្ខុ សទ្ធាពលំ ភាវេតិ រាគវិនយបរិយោសានំ ទោ-
សវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ ឯវំ ខោ
ភិក្ខវេ ភិក្ខុ បញ្ច ពលានិ ភាវេន្តោ បញ្ច ពលានិ
ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វានបោណោ
និព្វានបព្ភារោតិ ។ (ឯវំ ឯសនា បាលិ វិត្ថារេតព្វា
រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោ-
ហវិនយបរិយោសានំ) ។

ពលសំយុត្ត

[៤២៧] ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គាមានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើត ដូចម្ដេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ក៏ដូច្នោះដែរ ។

[៤២៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធាពលៈ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត មានកិរិយាកម្ចាត់បង់នូវទោសៈជាទីបំផុត មានកិរិយាកម្ចាត់បង់នូវមោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។ (បាលីសម្ដែងអំពីការស្វែងរក មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត កម្ចាត់បង់នូវទោសៈជាទីបំផុត កម្ចាត់បង់នូវមោហៈជាទីបំផុត បណ្ឌិតគប្បីឲ្យពិស្ដារយ៉ាងនេះចុះ) ។

[៤២៩] បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។

[៤៣០] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ បញ្ច ពលានិ ភាវេតព្វានិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធាពលំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ បេ ។ បញ្ញាពលំ ភាវេតិ រាគវិនយបរិយោសានំ ទោសវិនយបរិយោសានំ មោហវិនយបរិយោសានំ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមានិ បញ្ច ពលានិ ភាវេតព្វានីតិ ។

ពលសំយុត្តំ និដ្ឋិតំ ។

[៤២៩] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះមាន ៥ ។ សញ្ញោជនៈជាចំណែកខាងលើ ៥ គឺអ្វីខ្លះ ។ គឺរូបរាគ ១ អរូបរាគ ១ មាន ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ នេះឯង ។

[៤៣០] ម្នាលភិក្ខុទាំងឡាយ ពលៈ ៥ ប្រការ បុគ្គលគួរចម្រើន ដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។ ពលៈ ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធាពលៈ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត មានកិរិយាកម្ចាត់បង់នូវទោសៈជាទីបំផុត មានកិរិយាកម្ចាត់បង់នូវមោហៈជាទីបំផុត ។ បេ ។ ចម្រើននូវបញ្ញាពលៈ មានកិរិយាកម្ចាត់បង់នូវរាគៈជាទីបំផុត មានកិរិយាកម្ចាត់បង់នូវទោសៈជាទីបំផុត មានកិរិយាកម្ចាត់បង់នូវមោហៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ពលៈ ៥ នេះ បុគ្គលគួរចម្រើន ដើម្បីដឹង ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈជាចំណែកខាងលើ ៥ នេះឯង ។

ចប់ ពលសំយុត្ត ។

# ឥទ្ធិបាទសំយុត្តំ

## បាវាលវគ្គោ

[៤៣១] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ភាវិតា ពហុលីកតា អបារា បារំ គមនាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា អបារា បារំ គមនាយ សំវត្តន្តីតិ ។

# ឥទ្ធិបាទសំយុត្ត

## បាវាលវគ្គ

[៨៣១] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីចេញចាកវដ្តៈ ហើយបានដល់ព្រះនិព្វាន ។ ឥទ្ធិបាទ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទៈ-សមាធិនិងបធានសង្ខារ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវិរិយសមាធិនិងបធានសង្ខារ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវិមំសាសមាធិនិងបធាន-សង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះឯង ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងប្រព្រឹត្តទៅដើម្បីចេញចាកវដ្តៈ ហើយបានដល់ព្រះនិព្វាន ។

[៤៣២] យេសំ កេសញ្ចិ ភិក្ខវេ ចត្តារោ ឥទ្ធិ-
បាទា វិរទ្ធា វិរទ្ធោ តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខ-
យគាមី ។ យេសំ កេសញ្ចិ ភិក្ខវេ ចត្តារោ ឥទ្ធិបា-
ទា អារទ្ធា អារទ្ធោ តេសំ អរិយោ មគ្គោ សម្មាទុក្ខ-
ក្ខយគាមី ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ
ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។
វិរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធាន-
សង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ យេសំ កេសញ្ចិ
ភិក្ខវេ ឥមេ ចត្តារោ ឥទ្ធិបាទា វិរទ្ធា វិរទ្ធោ តេសំ
អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមី ។ យេសំ កេសញ្ចិ
ភិក្ខវេ ឥមេ ចត្តារោ ឥទ្ធិបាទា អារទ្ធា អារទ្ធោ តេសំ
អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមីតិ ។

[៤៣៣] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ភាវិតា ពហុ-
លីកតា អរិយា និយ្យានិកា និយ្យន្តិ តក្ករស្ស សម្មា-
ទុក្ខក្ខយាយ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ

[៨៣២] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ពួកបុគ្គលណាមួយ លះបង់ហើយ អរិយមគ្គដែលប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ក៏ឈ្មោះថាបុគ្គលទាំងនោះលះបង់ដែរ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ពួកបុគ្គលណាមួយបានប្រារព្ធហើយ អរិយមគ្គដែលប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ក៏ឈ្មោះថាបុគ្គលទាំងនោះប្រារព្ធដែរ ។ ឥទ្ធិបាទ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះ ពួកបុគ្គលណាមួយលះបង់ហើយ អរិយមគ្គដែលប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ក៏ឈ្មោះថាបុគ្គលទាំងនោះលះបង់ដែរ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះ ពួកបុគ្គលណាមួយប្រារព្ធហើយ អរិយមគ្គដែលប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃក៏ឈ្មោះថាបុគ្គលទាំងនោះប្រារព្ធដែរ ។

[៨៣៣] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ជានិយ្យានិកធម៌ដ៏ប្រសើរ រមែងប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ដល់អ្នកចម្រើនឥទ្ធិបាទនោះ ។ ឥទ្ធិបាទ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា អរិយា និយ្យានិកា និយ្យន្តិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ ។

[៤៣៤] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តីតិ ។

ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វិរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះឯង ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ជានិយ្យានិកធម៌ដ៏ប្រសើរ រមែងប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ដល់បុគ្គលអ្នកចម្រើនឥទ្ធិបាទនោះ ។

[៤៣៤] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយៗហើយ រមែងប្រព្រឹត្តទៅដើម្បីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វិរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះឯង ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ប្រព្រឹត្តទៅដើម្បីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។

[៤៣៩] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ ស-
មណា វា ព្រាហ្មណា វា ឥទ្ធិប្បភេទំ អភិនិប្ផាទេសុំ
សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។
យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា
ព្រាហ្មណា វា ឥទ្ធិប្បភេទំ អភិនិប្ផាទេស្សន្តិ សព្វេ តេ
ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ
ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា
ឥទ្ធិប្បភេទំ អភិនិប្ផាទេន្តិ សព្វេ តេ ចតុន្នំ ឥទ្ធិបា-
ទានំ ភាវិតត្តា ពហុលីកតត្តា ។ កតមេសំ ចតុន្នំ ។
ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ
ឥទ្ធិបាទំ ភាវេតិ ។ វិរិយសមាធិ ។ ចិត្តសមាធិ ។ វីមំ-
សាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[៤៣៩] ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលកន្លងទៅហើយបានញ៉ាំងឥទ្ធិប្បទេស គឺឫទ្ធិ ជាចំណែកដោយអន្ទើ[១] ឲ្យសម្រេចហើយ សមណព្រាហ្មណ៍ទាំងអស់នោះ ក៏បានសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលមិនទាន់មកដល់ នឹងញ៉ាំងឥទ្ធិប្បទេស ឲ្យសម្រេចបាន សមណព្រាហ្មណ៍ទាំងអស់នោះ នឹងបានសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ កំពុងញ៉ាំងឥទ្ធិប្បទេស ឲ្យសម្រេច សមណៈឬព្រាហ្មណ៍ទាំងអស់នោះ បានសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។

១ សំដៅយកមគ្គ ៣ ផល ៣ ។ សារត្ថប្បកាសិនី ។

បារាលវគ្គោ

[៤៣៦] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សម-
ណា វា ព្រាហ្មណា វា ឥទ្ធិប្បទេសំ អភិនិប្ផាទេសុំ សព្វេ
តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលី-
កតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ ស-
មណា វា ព្រាហ្មណា វា ឥទ្ធិប្បទេសំ អភិនិប្ផាទេស្សន្តិ
សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា
ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ ស-
មណា វា ព្រាហ្មណា វា ឥទ្ធិប្បទេសំ អភិនិប្ផាទេន្តិ
សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា
ពហុលីកតត្តាតិ ។

[៤៣៧] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ ស-
មណា វា ព្រាហ្មណា វា សមត្តំ ឥទ្ធឹ អភិនិប្ផាទេសុំ
សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីក-
តត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សម-
ណា វា ព្រាហ្មណា វា សមត្តំ ឥទ្ធឹ អភិនិប្ផាទេស្សន្តិ
សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។

[៤៣៦] ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល បានញ៉ាំងឥទ្ធិប្បទេសឲ្យសម្រេច សមណព្រាហ្មណ៍ទាំងអស់នោះ បានសម្រេចហើយ ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងញ៉ាំងឥទ្ធិប្បទេសឲ្យសម្រេច សមណ-ព្រាហ្មណ៍ទាំងអស់នោះ នឹងសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ កំពុងញ៉ាំងឥទ្ធិប្បទេសឲ្យសម្រេច សមណព្រាហ្មណ៍ទាំងអស់នោះ ក៏សម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។

[៤៣៧] ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល បានញ៉ាំងសមត្តឫទ្ធិ[១] ឲ្យសម្រេច សមណព្រាហ្មណ៍ទាំងអស់នោះ បានសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិ-បាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងញ៉ាំងសមត្តឫទ្ធិឲ្យសម្រេច សមណព្រាហ្មណ៍ទាំងអស់នោះនឹងសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។

---
១ ឫទ្ធិដ៏ចប់គ្រប់គ្រាន់ គឺផុតកិច្ចនឹងធ្វើទៀត សំដៅយកអរហត្តផល ។ សារត្ថប្បកាសិនី ។

យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា សមត្តំ ឥទ្ធឹ អភិនិប្ផាទេន្តិ សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[៤៣៨] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា សមត្តំ ឥទ្ធឹ អភិនិប្ផាទេសុំ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា សមត្តំ ឥទ្ធឹ អភិនិប្ផាទេស្សន្តិ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា សមត្តំ ឥទ្ធឹ អភិនិប្ផាទេន្តិ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តាតិ ។

ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ កំពុងញុំាងសមត្ថឫទ្ធិឲ្យសម្រេច សមណៈឬព្រាហ្មណ៍ទាំងអស់នោះសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។

[៤៣៨] ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល បានញុំាងសមត្ថឫទ្ធិឲ្យសម្រេច សមណព្រាហ្មណ៍ទាំងអស់នោះ បានសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងញុំាងសមត្ថឫទ្ធិឲ្យសម្រេច សមណ-ព្រាហ្មណ៍ទាំងអស់នោះ នឹងសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ កំពុងញុំាងសមត្ថឫទ្ធិឲ្យសម្រេច សមណ-ព្រាហ្មណ៍ទាំងអស់នោះ សម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។

២៦៨



[៤៣៩] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ ភិក្ខូ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរឹសុ សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ ភិក្ខូ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សន្តិ សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ ភិក្ខូ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វិរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

បាវាលវគ្គ

[៨៣៩] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ក្នុងអតីតកាល បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ភិក្ខុទាំងអស់នោះ ក៏បានសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ក្នុងអនាគតកាល នឹងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ភិក្ខុទាំងអស់នោះនឹងសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ក្នុងកាលឥឡូវនេះ កំពុងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ភិក្ខុទាំងអស់នោះសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ ។ ឥទ្ធិបាទ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធាន-សង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។

[៤៤០] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ ភិក្ខូ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរឹសុ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ ភិក្ខូ អាសវានំ ខយា អនាសវំ ចេ-តោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិ-កត្វា ឧបសម្បជ្ជ វិហរិស្សន្តិ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ ភិក្ខូ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីក-តត្តាតិ ។

[៤៤០] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ក្នុងអតីតកាល បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ភិក្ខុទាំងអស់នោះ បានសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ក្នុងអនាគតកាល នឹងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ភិក្ខុទាំងអស់នោះ នឹងសម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ក្នុងកាលឥឡូវនេះ កំពុងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ភិក្ខុទាំងអស់នោះ សម្រេច ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយៗ នូវឥទ្ធិបាទ ៤ នេះឯង ។

ចាបាលវគ្គោ

[៤៤១] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធាន-សង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបា-ទា ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា តថាគតោ អរហំ សម្មាសម្ពុទ្ធោតិ វុច្ចតីតិ ។

[៤៤២] អយំ ឆន្ទសមាធិប្បធានសង្ខារសមន្នា-គតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សោ ខោ បនាយំ ឆន្ទសមាធិប្បធានសង្ខារស-មន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ មេ ភិក្ខវេ ។

បាវាលវគ្គ

[៤៤១] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទនេះមាន ៤ ។ ឥទ្ធិ-
បាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិ-
បាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។
ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធាន-
សង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុ
ទាំងឡាយ ព្រះតថាគត ដែលហៅថា អរហន្តសម្មាសម្ពុទ្ធ ព្រោះ
ចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។

[៤៤២] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើត
ឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើង
ហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮបាន
ស្តាប់ ក្នុងកាលពីដើមថា នេះជាឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិង
បធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ (ចក្ខុជាដើមកើតឡើងហើយ ក្នុងធម៌
ដែលតថាគតមិនធ្លាប់បានឮបានស្តាប់ក្នុងកាលពីដើម) ថា ឥទ្ធិបាទ ប្រ-
កបដោយឆន្ទសមាធិនិងបធានសង្ខារនេះឯង ដែលតថាគតត្រូវចម្រើន ។

ភាវិតោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

[៤៤៣] អយំ វីរិយសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សោ ខោ បនាយំ វីរិយសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ មេ ភិក្ខវេ ។ ភាវិតោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮបានស្តាប់មកពីដើមថា (នេះឯងជាឥទ្ធិបាទ) ដែលតថាគតចម្រើនហើយ ។

[៤៤៣] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮបានស្តាប់ក្នុងកាលពីដើមថា នេះជាឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនឹងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ តថាគត (មិនធ្លាប់បានឮបានស្តាប់) ថា ឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារនោះឯងដែលតថាគតត្រូវចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮបានស្តាប់ ក្នុងកាលពីដើមថា (នេះជាឥទ្ធិបាទ) ដែលតថាគតបានចម្រើនហើយ ។

២៦៩

បាវាលវគ្គោ

[៤៤៤] អយំ ចិត្តសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សោ ខោ បនាយំ ចិត្តសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ មេ ភិក្ខវេ ។ ភាវិតោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។

បាវាលវគ្គ

[៤៤៤] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮបានស្តាប់ ក្នុងកាលពីដើមថា នេះជាឥទ្ធិបាទ ប្រកបដោយចិត្ត-សមាធិនិងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ តថាគត (មិនធ្លាប់បានឮបានស្តាប់) ថា ឥទ្ធិបាទប្រកបដោយចិត្តសមាធិនិងបធានសង្ខារនេះឯងដែលតថាគតត្រូវចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮបានស្តាប់ ក្នុងកាលពីដើមថា (នេះជាឥទ្ធិបាទ) ដែលតថាគតបានចម្រើនហើយ ។

[៤៤៥] អយំ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ។ សោ ខោ បនាយំ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ភាវេតព្វោតិ មេ ភិក្ខវេ ។ ភាវិតោតិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ ។

[៤៤៥] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮបានស្តាប់ ក្នុងកាលពីដើមថា នេះជាឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ តថាគត (មិនធ្លាប់បានឮបានស្តាប់) ថា ឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារនេះឯង ដែលតថាគតត្រូវចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮបានស្តាប់ ក្នុងកាលពីដើមថា (នេះជាឥទ្ធិបាទ) ដែលតថាគតបានចម្រើនហើយ ។

## ចាវាលវគ្គោ

[៤៤៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ គណ្ហាហិ អានន្ទ និសីទនំ យេន ចាវាលចេតិយំ (១)តេនុបសង្កមិស្សាមិ ទិវា វិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា និសីទនំ អាទាយ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។

[៤៤៧] អថខោ ភគវា យេន ចាវាលចេតិយំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អាយស្មាបិ ខោ អានន្ទោ ភគវន្តំ អភិវាទេត្វា

---
១ ឱ. ម. ចាបាលចេតិយំ ។

[៤៤៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងកូដាគារសាលា នាមហាវន ជិតក្រុងវេសាលី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ទ្រង់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ហើយត្រឡប់អំពីបិណ្ឌបាតក្នុងបច្ឆាភត្ត ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរកាន់យកនូវសំពត់និសីទនៈ តថាគតនឹងចូលទៅឯបាវាលចេតិយ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយក៏កាន់នូវសំពត់និសីទនៈដើរតាមក្រោយ ៗ ព្រះដ៏មានព្រះភាគទៅ ។

[៤៤៧] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចូលទៅបាវាល-ចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលបុគ្គលតាក់តែងថ្វាយ ។ ព្រះអានន្ទដ៏មានអាយុ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនចេតិយំ រមណីយំ គោតមកចេតិយំ រមណីយំ សត្តម្ពចេតិយំ រមណីយំ ពហុបុត្តកចេតិយំ រមណីយំ សារន្ទទចេតិយំ[១] រមណីយំ ចាបាលចេតិយំ ។ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា ។ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។

៨៤៨ ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ[២]

---

១ ម. សានន្ទរំ ចេតិយំ ។ ឱ. សារន្ទទមចេតិយំ ។ ២ ឱ. ម. កប្បាវសេសំ ។

ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ក្រុងវេសាលី គួរជាទីរីករាយ ឧទេនចេតិយ គួរជាទីរីករាយ គោតមកចេតិយ គួរជាទីរីករាយ សត្តម្ពចេតិយ គួរជាទីរីករាយ ពហុបុត្តកចេតិយ គួរជាទីរីករាយ សារន្ទទចេតិយ គួរជាទីរីករាយ បាវាលចេតិយ គួរជាទីរីករាយ ។ ម្នាលអានន្ទ បុគ្គលណាមួយបានចម្រើនឥទ្ធិបាទ ៤ បានធ្វើឱ្យរឿយៗ ធ្វើឱ្យដូចជាយាន ធ្វើឱ្យជាទីនៅ តាំងទុករឿយ ៗ សន្សំទុក ផ្ដើមល្អហើយ កាលបើបុគ្គលនោះប្រាថ្នា អាចស្ថិតនៅអស់មួយអាយុកប្ប ឬជាង់មួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ ឥទ្ធិបាទ ៤ តថាគតបានចម្រើនហើយ ធ្វើឱ្យរឿយៗហើយ ធ្វើឱ្យដូចជាយាន ធ្វើឱ្យជាទីនៅ តាំងទុករឿយ ៗ សន្សំទុក ផ្ដើមល្អហើយ ។ ម្នាលអានន្ទ បើតថាគតប្រាថ្នា អាចស្ថិតនៅអស់មួយអាយុកប្ប ឬជាង់មួយអាយុកប្បក៏បាន ។

[៤៤៨] កាលបើព្រះដ៏មានព្រះភាគទ្រង់ធ្វើនិមិត្ត ជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិកយ៉ាងនេះក៏ដោយ ព្រះអានន្ទដ៏មានអាយុ នៅតែមិនអាចនឹងយល់សេចក្ដីច្បាស់លាស់បានឡើយ មិនបានអារាធនាព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់គង់នៅអស់ ១ អាយុកប្ប សូមព្រះសុគតទ្រង់គង់នៅអស់ ១ អាយុកប្ប

ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថា តំ មារេន បរិយុដ្ឋិតចិត្តោ ។

[៤៤៩] ទុតិយំបិ ខោ ភគវា ។ តតិយំបិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនចេតិយំ រមណីយំ គោតមកចេតិយំ រមណីយំ សត្តម្ពចេតិយំ រមណីយំ ពហុបុត្តកចេតិយំ រមណីយំ សារន្ទទចេតិយំ រមណីយំ ចាវាលចេតិយំ ។ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិចាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិចាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា ឥទ្ធិចាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។

ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយដូច្នេះឡើយ ព្រោះមារចូលមកជ្រែកចិត្ត ។

[៤៤៩] ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកា (នឹងព្រះអានន្ទ) ជាគម្រប់ពីរដង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុជាគម្រប់ ៣ ដងថា ម្នាលអានន្ទ ក្រុងវេសាលី គួរជាទីរីករាយ ឧទេនចេតិយ គួរជាទីរីករាយ គោតមកចេតិយ គួរជាទីរីករាយ សត្តម្ពចេតិយ គួរជាទីរីករាយ ពហុបុត្តកចេតិយ គួរជាទីរីករាយ សារន្ទទចេតិយ គួរជាទីរីករាយ បាវាលចេតិយ គួរជាទីរីករាយ ។ ម្នាលអានន្ទ បុគ្គលណាមួយបានចម្រើន ឥទ្ធិបាទ ៤ ធ្វើឲ្យច្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីតាំងនៅ តាំងទុករឿយ ៗ សន្សំទុក ផ្តើមទុកល្អហើយ បើបុគ្គលនោះប្រាថ្នា អាចនៅអស់ ១ អាយុកប្ប ឬជាងមួយអាយុ-កប្បក៏បាន ។ ម្នាលអានន្ទ តថាគតបានចម្រើនឥទ្ធិបាទ ៤ បានធ្វើឲ្យរឿយ ៗ បានធ្វើឲ្យដូចជាយាន បានធ្វើឲ្យជាទីតាំងនៅ បានតាំងទុករឿយ ៗ បានសន្សំទុក បានផ្តើមទុកល្អហើយ ។ ម្នាលអានន្ទ បើតថាគតប្រាថ្នា អាចនៅអស់មួយអាយុកប្ប ឬជាងមួយអាយុកប្បក៏បាន ។

[៤៨០] ឯវំបិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជ-នហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថា-យ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថា តំ មា-រេន បរិយុដ្ឋិតចិត្តោ ។

[៤៨១] អថខោ ភគវា អាយស្មន្តំ អានន្ទំ អា-មន្តេសិ គច្ឆ ខោ ត្វំ អានន្ទ យស្សទានិ កាលំ មញ្ញសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វាឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។

[៤៩០] កាលព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិកយ៉ាងនេះក៏ដោយ ព្រះអានន្ទដ៏មានអាយុ នៅតែមិនយល់សេចក្តីច្បាស់លាស់ឡើយ មិនបានអារាធនា ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់គង់នៅអស់មួយអាយុកប្ប សូមព្រះសុគត ទ្រង់គង់នៅអស់មួយអាយុកប្ប ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះឡើយ ព្រោះមារចូលមកជ្រែកចិត្ត ។

[៤៩១] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះ ចូរសម្គាល់នូវកាលគួរក្នុងកាលឥឡូវនេះចុះ ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ករុណា ព្រះអង្គ រួចក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយអង្គុយជិតគល់ឈើមួយដើម ដ៏មិនឆ្ងាយប៉ុន្មាន ។

[៤៩២] អថខោ មារោ បាបិមា (អចិរបក្កន្តេ អាយស្មន្តេ អានន្ទេ[១]) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ (ឯកមន្តំ ឋិតោ ខោ មារោ បាបិមា[២]) ភគវន្តំ ឯតទវោច បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ។ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា[៣] ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីការិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ។ សន្តិ ខោ បន ភន្តេ ឯតរហិ ភិក្ខូ ភគវតោ សាវកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា

១-២ មរម្មបោត្ថកេយេវ ឥមស្មឹ សុត្តេ ឥមេ បាឋា ទិស្សន្តិ ។ ៣ ឱ. ឯត្ថន្តរេ បត្តយោគក្ខេមាតិ បាឋោ ភវតិ ។

បាវាលវគ្គ

[៤៩២] (កាលដែលព្រះអានន្ទដ៏មានអាយុចេញទៅមិនយូរប៉ុន្មាន) មារមានចិត្តបាបចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរក្នុងទីសមគួរ ។ (លុះមារមានចិត្តបាបឈរក្នុងទីសមគួរហើយ) ក៏ក្រាបទូលអារាធនា ព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះទៅ សូមព្រះសុគតនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះដ៏មានព្រះភាគល្មមបរិនិព្វានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគបានត្រាស់វាចានេះថា នែមារមានចិត្តបាប (បើ) ពួកភិក្ខុជាសាវករបស់តថាគតដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយកោតក្រែង ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀនវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនល្អ តាមពាក្យដែលសមហេតុ ហើយនឹងសម្តែងធម៌ប្រកបដោយបាដិហារ្យដរាបណាទេ តថាគត នឹងមិនទាន់បរិនិព្វានដរាបនោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុជាសាវករបស់ព្រះដ៏មានព្រះភាគបានឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូតទ្រទ្រង់ធម៌

ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ។

[៤៨៣] ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា ធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ

ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយកោតក្រែង ប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាម ពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបាន ហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគបរិនិព្វានក្នុង កាលឥឡូវនេះទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរព្រះដ៏មានព្រះភាគបរិនិព្វានហើយ ។

[៤៥៣] បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះដ៏មានព្រះភាគបាន ត្រាស់វាចានេះថា ម្នាលមារមានចិត្តបាប តថាគតនឹងមិនទាន់បរិនិព្វាន ទេ ព្រោះពួកភិក្ខុនីជាសាវិការបស់តថាគត ឈ្លាសវាង វៃឆ្លៀវឆ្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយ កោតក្រែង ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់រៀននូវ វាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សម្តែង បញ្ញត្ត តាំងទុក

## ២៧៧



វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ។ សន្តិ ខោ បន ភន្តេ ឯតរហិ ភិក្ខុនិយោ ភគវតោ សាវិកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ។

បើក បែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយនឹងសម្តែងធម៌ប្រកបដោយបាដិហារ្យទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងកាលឥឡូវនេះ ពួកភិក្ខុនីជាសាវិការបស់ព្រះដ៏មានព្រះភាគ បានឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយកោតក្រែង ប្រព្រឹត្តតាមធម៌ហើយ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះឥឡូវនេះ ជាកាលគួរល្មមព្រះដ៏មានព្រះភាគបរិនិព្វានហើយ ។

[៤៩៤] ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ច តាវាហំ ចាបិម បរិនិព្ពាយិស្សាមិ យាវ មេ ឧបាសកា ។ បេ ។ យាវ មេ ឧបាសិកា ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសេស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានី ករិស្សន្តិ ឧប្បន្នំបរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ ។ សន្តិ ខោ បន ភន្តេ ឯតរហិ ឧបាសិកា ភគវតោ សាវិកា វិយត្តា វិនីតា វិសារទា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោសកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ

[៤៥២] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគបានត្រាស់វាចានេះថា ម្នាលមារមានចិត្តបាប តថាគតនឹងមិនទាន់បរិនិព្វានទេ ព្រោះពួកឧបាសក (ជាសាវក) របស់តថាគត ។ បេ ។ ព្រោះពួកឧបាសិកាជាសាវិការបស់តថាគត ដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយកោតក្រែង ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិន នូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយនឹងសម្តែងធម៌ប្រកបដោយបាដិហារ្យទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ មានពួកឧបាសិកាជាសាវិការបស់ព្រះដ៏មានព្រះភាគ បានឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយកោតក្រែង ប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត

បាវាលវគ្គោ

បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ។

[៤៨៨] ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិតំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ ។ តយិទំ ភន្តេ ភគវតោ ព្រហ្មចរិយំ ឥទ្ធញ្ចេវ ផីតញ្ច វិត្ថារិតំ ពាហុជញ្ញំ បុថុភូតំ

តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះឥឡូវនេះ ជាកាលគួរល្មមព្រះដ៏មានព្រះភាគបរិនិព្វានហើយ ។

[៤៥៥] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគបានត្រាស់វាចានេះថា ម្នាលមារមានចិត្តបាប តថាគតនឹងមិនទាន់បរិនិព្វានទេ ព្រោះព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួនមិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នាមិនទាន់ពេញបរិបូណ៌ ពួកទេវតានិងមនុស្ស មិនទាន់ចេះសម្តែងបានដោយប្រពៃទេ ។ បពិត្រព្រះអង្គដ៏ចម្រើនព្រហ្មចារ្យរបស់ព្រះដ៏មានព្រះភាគនោះបានខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ

យាវ ទេវមនុស្សេហិ សុប្បកាសិតំ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោ-ទានិ ភន្តេ ភគវតោតិ ។

[៤៩៦] ឯវំ វុត្តេ ភគវា មារំ បាបិមន្តំ ឯតទវោច អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ[១] តថា-គតស្ស បរិនិព្វានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ ។

[៤៩៧] អថខោ ភគវា ចាបាលេ ចេតិយេ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ ។ ឱស្សជ្ជេ ច[២] ភគវតា អាយុសង្ខារេ មហាភូមិចាលោ អហោសិ ភឹស-នកោ លោមហំសោ ទេវទុន្ទុភិយោ[៣] ច ផលឹសុ ។

១ ម. នចិរស្សេវ ។ ២ ម. ឱស្សជ បន ។ ៣ ម. ទេវទុន្ទ្រភិយោ ។

ពួកទេវតានិងមនុស្សបេះសម្ដែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះឥឡូវនេះជាកាលគួរល្មមព្រះដ៏មានព្រះភាគបរិនិព្វានហើយ ។

[៤៥៦] កាលបើក្រុងមារក្រាបទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ក៏បានត្រាស់ទៅនឹងក្រុងមារមានចិត្តបាបដូច្នេះថា ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្ដីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគតមិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីកាលនេះទៅ តថាគតនឹងបរិនិព្វាន ។

[៤៥៧] លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់មានព្រះសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារឰដ៏បាវាលចេតិយ ។ លុះព្រះដ៏មានព្រះភាគដាក់អាយុសង្ខារហើយ ក៏កើតកក្រើកផែនដីយ៉ាងធំ គួរឲ្យភ្លូកភ្លឹកព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។

២៨១

បាវាលវគ្គោ

[៤៩៨] អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

តុលមតុលញ្ច សម្ភវំ

ភវសង្ខារមវស្សជ្ជិ មុនិ

អជ្ឈត្តរតោ សមាហិតោ

អភិន្ទិ កវចមិវត្តសម្ភវន្តិ ។

បាវាលវគ្គោ បឋមោ ។

តស្សុទ្ទានំ

អចាភបិ វិរេឡ្ហោ ច

អរិយា និព្វុតេ យថា

បទេសំ សម្មត្តា ភិក្ខុ

ពុទ្ធញ្ញាណេន ចេតិយាតិ ។

១ ឱ. និព្វិទា ។

បាវាលវគ្គ

[៤៥៨] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវដំណើរនោះហើយ ក៏បន្លឺនូវឧទាននេះក្នុងវេលានោះថា

ព្រះពុទ្ធជាអ្នកប្រាជ្ញ ពិចារណាឃើញនូវព្រះនិព្វានដែល
មានគុណថ្លឹងមិនបានផង នូវភពផង លះបង់នូវសង្ខារដែល
នាំសត្វទៅកាន់ភពហើយ ត្រេកអរចំពោះអារម្មណ៍ខាងក្នុង
(ដោយអំណាចវិបស្សនា) មានចិត្តតាំងមាំ (ដោយអំណាច
សមថៈ) បានទំលាយហើយនូវបណ្តាញ គឺកិលេសដែល
កើតមាននៅក្នុងខ្លួនដូចជាក្រោះ ។

ចប់ បាវាលវគ្គ ទី ១ ។

ឧទ្ទាននៃបាវាលវគ្គនោះគឺ

ឥទ្ធិបាទប្រព្រឹត្តទៅដើម្បីចេញចាកវដ្ដ ១ ឥទ្ធិបាទដែលបុគ្គល
លះបង់ ១ ឥទ្ធិបាទជាធម៌ដ៏ប្រសើរ ១ ប្រព្រឹត្តទៅដើម្បី
រំលត់នូវទុក្ខ ១ ឲ្យសម្រេចឥទ្ធិប្បទេស ១ សមត្តឫទ្ធិ ១
ពួកភិក្ខុ ១ និងភិក្ខុចម្រើនឥទ្ធិបាទ ១ ពុទ្ធញាណកើតឡើង
ហើយ ១ បាវាលចេតិយ ។

# បាសាទកម្បនវគ្គោ

[៤៥៩] សាវត្ថិយំ ។ បុព្វេ មេ ភិក្ខវេ សម្ពោធាយ អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ ឥទ្ធិបាទភាវនាយាតិ ។

[៤៦០] តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ ឆន្ទោ ន ច អតិលីនោ ភវិស្សតិ ន ច អតិប្បគ្គហិតោ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តោ ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តោ ភវិស្សតិ បច្ឆាបុរេ សញ្ញីច វិហរតិ យថាបុរេ តថាបច្ឆា យថាបច្ឆា តថាបុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោយថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

# បាសាទកម្បនវគ្គ

[៤៥៩] ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ កាលពីមុនដែលតថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងសម្ពោធិនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ដើម្បីញុាំងឥទ្ធិបាទឲ្យចម្រើន ។

[៤៦០] ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារថា ឆន្ទៈរបស់អញ នឹងមិនបានធូរថយណាស់ផង មិនបានផ្គងឡើងពេកផង មិនបានរួញខាងក្នុងផង មិនបានរាយមាយទៅខាងក្រៅផងដូច្នេះ ទាំងជាបុគ្គលមានសញ្ញាក្នុងខាងក្រោយ និងខាងមុខ គឺខាងមុខយ៉ាងណា ខាងក្រោយក៏យ៉ាងនោះ ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ ខាងលើយ៉ាងណា ខាងក្រោមក៏យ៉ាងនោះ វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តបើកហើយ មានកិលេសមិនបានរួបរឹត ចម្រើននូវចិត្ត ប្រកបដោយពន្លឺដូច្នេះ ។

បាសាទកម្បនវគ្គោ

[៤៦១] វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-បាទំ ភាវេតិ ឥតិ មេ វីរិយំ ន ច អតិលីនំ ភវិស្សតិ ន ច អតិប្បគ្គហិតំ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តំ ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តំ ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

[៤៦២] ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-បាទំ ភាវេតិ ឥតិ មេ ចិត្តំ ន ច អតិលីនំ ភវិស្សតិ ន ច អតិប្បគ្គហិតំ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តំ ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តំ ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ

បាសាទកម្បនវគ្គ

[៨៦១] ភិក្ខុចម្រើនឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារថា សេចក្តីព្យាយាមរបស់អញ នឹងមិនបានធូរថយពេកផង មិនផ្គងឡើងពេកផង មិនរួញខាងក្នុងផង មិនរាយមាយទៅខាងក្រៅផងដូច្នេះ ទាំងជាបុគ្គលមានសញ្ញាក្នុងខាងក្រោយនិងខាងមុខ គឺខាងមុខយ៉ាងណា ខាងក្រោយក៏យ៉ាងនោះ ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ ខាងលើយ៉ាងណា ខាងក្រោមក៏យ៉ាងនោះ វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តបើកហើយ មានកិលេសមិនបានរួបរឹតហើយ រមែងចម្រើននូវចិត្ត ប្រកបដោយពន្លឺដូច្នេះ ។

[៨៦២] ភិក្ខុចម្រើនឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារថា ចិត្តរបស់អញ នឹងមិនបានធូរថយពេកផង មិនផ្គងឡើងពេកផង មិនរួញខាងក្នុងផង មិនបានរាយមាយទៅខាងក្រៅផងដូច្នេះ ទាំងជាបុគ្គលមានសញ្ញាក្នុងខាងក្រោយនិងខាងមុខ គឺខាងមុខយ៉ាងណា ខាងក្រោយក៏យ៉ាងនោះ ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ

យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

[៤៦៣] វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ វីមំសា ន ច អតិលីនា ភវិ-ស្សតិ ន ច អតិប្បគ្គហិតា ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តា ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តា ភវិស្សតិ បច្ឆា-បុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ ខាងលើយ៉ាងណា ខាងក្រោមក៏យ៉ាងនោះ វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តបើកហើយ មានកិលេសមិនបានរួបរឹត រមែងចម្រើននូវចិត្ត ប្រកបដោយពន្លឺដូច្នេះ ។

[៤៦៣] ភិក្ខុរមែងចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារថា ប្រាជ្ញាជាគ្រឿងពិចារណារបស់អញ នឹងមិនធូរថយពេកផង មិនផ្គងឡើងពេកផង មិនរួញខាងក្នុងផង មិនរាយមាយទៅខាងក្រៅផងដូច្នេះ ទាំងជាបុគ្គលមានសញ្ញាក្នុងខាងក្រោយនិងខាងមុខ គឺខាងមុខយ៉ាងណា ខាងក្រោយក៏យ៉ាងនោះ ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ ខាងលើយ៉ាងណា ខាងក្រោមក៏យ៉ាងនោះ វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តបើកហើយ មានកិលេសមិនបានរួបរឹត រមែងចម្រើននូវចិត្ត ប្រកបដោយពន្លឺដូច្នេះ ។

[៤៦៤] ឯវំ ភាវិតេសុ ខោ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមតិ[១] សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំ មហិទ្ធិកេ ឯវំ មហានុភាវេ បាណិនា បរាមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៤៦៥] ឯវំ ភាវិតេសុ ខោ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ ។

១ ឱ. ចង្កមតិ ។

[៤៦៤] កាលភិក្ខុបានចម្រើនឥទ្ធិបាទទាំង ៤ យ៉ាងនេះ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ ភិក្ខុ (នោះ) រមែងបានសម្រេចឫទ្ធិច្រើនប្រការ គឺតែម្នាក់ ប្លែងទៅជាច្រើននាក់ក៏បាន ឬច្រើននាក់ ប្លែងឲ្យមកតែម្នាក់វិញក៏បាន នៅក្នុងទីកំបាំង ដើរទៅក្នុងទីវាលក៏បាន នៅខាងក្នុង ដើរទៅខាងក្រៅក៏បាន នៅខាងក្នុងជញ្ជាំង ដើរទៅខាងក្រៅជញ្ជាំង(ដោយឥតទ្វារឥតផ្លូវ) ក៏បាន នៅខាងក្នុងកំពែង ដើរទៅខាងក្រៅកំពែងក៏បាន នៅខាងក្នុងភ្នំ ដើរទៅខាងក្រៅភ្នំវិញក៏បាន ឥតមានទើស ដូចគេដើរក្នុងទីវាល មុជងើបក្នុងផែនដី ដូចគេមុជងើបក្នុងទឹកក៏បាន ដើរលើទឹកឥតមានបែកធ្លាយ ដូចគេដើរលើផែនដីក៏បាន ហោះទៅឰដ៏អាកាសទាំងភ្នែន ដូចជាបក្សីសកុណជាតិក៏បាន យកដៃទៅស្ទាបអង្អែលព្រះចន្ទ្រ ព្រះអាទិត្យទាំងនេះដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះក៏បាន ហោះទៅទាំងអំណាចខ្លួន រហូតដល់ព្រហ្មលោកក៏បាន ។

[៤៦៥] កាលបើភិក្ខុចម្រើនឥទ្ធិបាទទាំង ៤ យ៉ាងនេះ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ ភិក្ខុ (នោះ) មានត្រចៀកដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសត្រចៀករបស់មនុស្សធម្មតា រមែងឮសំឡេងពីរប្រការ គឺសំឡេងទិព្វនិងសំឡេងជារបស់មនុស្ស ទាំងឆ្ងាយទាំងជិតបាន ។

[៨៦៦] ឯវំ ភាវិតេសុ ខោ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច ជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។

[៤៦៦] *កាលបើភិក្ខុចម្រើនឥទ្ធិបាទទាំង ៤ យ៉ាងនេះ ធ្វើឲ្យច្រើន ៗ យ៉ាងនេះហើយ ភិក្ខុ (នោះ) ក៏អាចកំណត់ដឹងនូវចិត្តរបស់សត្វដទៃ បុគ្គលដទៃដោយចិត្ត (របស់ខ្លួន) បាន គឺចិត្ត (របស់សត្វដទៃ) ដែលប្រកបដោយរាគៈក្តី ក៏កំណត់ដឹងថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាកមោហៈ ចិត្តដែលរួញក្តី ក៏ស្គាល់ថា ចិត្តរួញ ចិត្តដែលរាយមាយក្តី ក៏ស្គាល់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ គឺរូបាវចរៈនិងអរូបាវចរៈក្តី ក៏ស្គាល់ថា ចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈក្តី ក៏ស្គាល់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈ គឺលោកិយចិត្តក្តី ក៏ស្គាល់ថា ចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈ គឺលោកុត្តរចិត្តក្តី ក៏ស្គាល់ថា ចិត្តជាអនុត្តរៈ ចិត្តដែលតាំងមាំក្តី ក៏ស្គាល់ថា ចិត្តតាំងមាំ ចិត្តដែលមិនតាំងមាំក្តី ក៏ស្គាល់ថា ចិត្តមិនតាំងមាំ ចិត្តដែលរួចស្រឡះ (ចាកកិលេសាសវៈ) ក្តី ក៏ស្គាល់ថា ចិត្តរួចស្រឡះ ចិត្តដែលមិនរួចស្រឡះក្តី ក៏ស្គាល់ថា ចិត្តមិនរួចស្រឡះ ។*

២៨៧

បាសាទកម្បនវគ្គោ

[៤៦៧] ឯវំ ភាវិតេសុ ខោ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សេយ្យថីទំ ។ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ ជាតិសតំបិ ជាតិសហស្សំបិ ជាតិសតសហស្សំបិ អនេកេបិ សំវដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្របាសឹ[1] ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

---

១ ម. តត្រាបាសឹ ។

បាសាទកម្បនវគ្គ

[៤៦៧] កាលបើភិក្ខុចម្រើនឥទ្ធិបាទទាំង ៤ យ៉ាងនេះ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ ភិក្ខុ (នោះ) រមែងរលឹកឃើញ បុព្វេនិវាស មានប្រការច្រើន ។ បុព្វេនិវាស ដូចម្តេច ។ គឺរលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ (រហូតដល់) ច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំ-វដ្តវិវដ្តកប្បខ្លះថា អញបានកើតក្នុងទីឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុយ៉ាងនេះ លុះអាត្មាអញនោះច្យុតអំពីទីនោះហើយ ក៏ទៅកើតក្នុងទីឯនោះ ក្នុងទីនោះឯង អាត្មាអញក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុយ៉ាងនេះ លុះអាត្មាអញនោះច្យុតអំពីទីនោះហើយ ទើបមកកើតក្នុងទីនេះទៀត រលឹកឃើញនូវបុព្វេនិវាស មានប្រការច្រើន ព្រមទាំងអាការ គឺរូប និងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រកូល ដោយប្រការដូច្នេះ ។

[៤៦៨] ឯវំ ភាវិតេសុ ខោ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ

[៤៦៨] កាលបើភិក្ខុចម្រើនឥទ្ធិបាទទាំង ៤ យ៉ាងនេះ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ ភិក្ខុ (នោះ) មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា រមែងឃើញសត្វទាំងឡាយ គឺកំណត់ដឹងពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ សម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ ពួកសត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលព្រះអរិយៈទាំងឡាយ ជាអ្នកយល់ខុស ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស ពួកសត្វទាំងនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកខាងសត្វពួកនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោ-សុចរិត មិនតិះដៀលព្រះអរិយៈទាំងឡាយ មានគំនិតយល់ត្រូវ ប្រកាន់នូវអំពើតាមសេចក្តីយល់ត្រូវ ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងសុគតិសួគ៌ទេវលោក ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា ក៏បានឃើញនូវពួកសត្វ

ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។

[៤៦៩] ឯវំ ភាវិតេសុ ខោ ភិក្ខុ ចតូសុ ឥទ្ធិ-បាទេសុ ឯវំ ពហុលីកតេសុ អាសវានំ ខយា អនា-សវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អ-ភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៤៧០] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា ។ កថំ ភាវិតា ច ភិក្ខវេ ចត្តារោ ឥទ្ធិបាទា កថំ ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ ឆន្ទោ ន ច អតិលីនោ ភវិស្សតិ ន ច អតិប្បគ្គហិតោ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តោ ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តោ ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ

គឺកំណត់ដឹងនូវពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានសម្បុរល្អខ្លះ សម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ ដែលទៅកើតតាមកម្មរបស់ខ្លួន ។

[៤៦៩] កាលបើភិក្ខុចម្រើនឥទ្ធិបាទទាំង ៤ យ៉ាងនេះ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ ភិក្ខុ (នោះ) បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ។

[៤៧០] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទទាំង ៤ យ៉ាងនេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ដែលបុគ្គលចម្រើនហើយដូចម្តេច ធ្វើឲ្យរឿយ ៗ ហើយដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារថា ឆន្ទៈរបស់អញ នឹងមិនធូរថយពេកផង មិនផ្គងឡើងពេកផង មិនរួញខាងក្នុងផង មិនរាយមាយទៅខាងក្រៅផង ដូច្នេះ ទាំងជាបុគ្គលមានសញ្ញាក្នុងខាងក្រោយនិងខាងមុខ គឺខាងមុខយ៉ាងណា ខាងក្រោយក៏យ៉ាងនោះ ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ ខាងលើយ៉ាងណា

តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ វីមំសា ន ច អតិលីនា ភវិស្សតិ ន ច អតិប្បគ្គហិតា ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តា ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តា ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ ឯវំ ភាវិតា ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ឯវំ ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា ។

ខាងក្រោមក៏យ៉ាងនោះ វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តបើកហើយ មានកិលេសមិនរួបរឹត រមែងចម្រើននូវចិត្ត ប្រកបដោយពន្លឺដូច្នេះ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ នឹងបធានសង្ខារថា វីមំសា (ការពិចារណា) របស់អញ នឹងមិនធូរថយពេកផង មិនផ្គងឡើងពេកផង មិនរួញខាងក្នុងផង មិនរាយមាយទៅខាងក្រៅផង ដូច្នេះ ទាំងជាបុគ្គលមានសញ្ញាក្នុងខាងក្រោយនិងខាងមុខ គឺខាងមុខយ៉ាងណា ខាងក្រោយក៏យ៉ាងនោះ ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ ខាងលើយ៉ាងណា ខាងក្រោមក៏យ៉ាងនោះ វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តបើកហើយ មានកិលេសមិនបានរួបរឹត ចម្រើននូវចិត្ត ប្រកបដោយពន្លឺដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ដែលបុគ្គលចម្រើនយ៉ាងនេះ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

២៩១

បាសាទកម្បនវគ្គោ

[៤៧១] ឯវំ ភាវិតេសុ ខោ ភិក្ខវេ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៤៧២] ឯវំ ភាវិតេសុ ខោ ភិក្ខវេ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៤៧៣] ឆន្ទំ ចេ ភិក្ខវេ ភិក្ខុ និស្សាយ លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ។ អយំ វុច្ចតិ ឆន្ទសមាធិ ។ សោ អនុប្បន្នានំ បាបកានំ អកុ-សលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយ-មតិ វីរយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[៤៧១] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ដែលភិក្ខុចម្រើនយ៉ាងនេះហើយ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ រមែងបាននូវឥទ្ធិវិធៈមានប្រការច្រើន គឺភិក្ខុតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ។ បេ ។ ហោះទៅទាំងអំណាចខ្លួន រហូតដល់ព្រហ្មលោកក៏បាន ។

[៤៧២] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ដែលភិក្ខុចម្រើនយ៉ាងនេះហើយ ធ្វើឲ្យរឿយ ៗ យ៉ាងនេះហើយ ភិក្ខុ (នោះ) បានធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងអត្តភាពដ៏ជាក់ស្តែង ។

[៤៧៣] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យឆន្ទៈហើយ បាននូវសមាធិ បាននូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ។ នេះហៅថាឆន្ទសមាធិ ។ ភិក្ខុនោះញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធ ព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមកដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ។

ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមេ វុច្ចន្តិ បធានសង្ខារាតិ ។ ឥតិ អយំ ច ឆន្ទោ អយំ ច ឆន្ទសមាធិ ឥមេ ច បធានសង្ខារា ។ អយំ វុច្ចតិ ភិក្ខវេ ឆន្ទសមាធិប្ប-ធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ។

[៨៧៤]វីរិយំ ចេ ភិក្ខវេ ភិក្ខុ និស្សាយ លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ។ អយំ វុច្ចតិ វីរិយ-សមាធិ ។ សោ អនុប្បន្នានំ ។ បេ ។ ឧប្បន្នានំ កុស-លានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមេ វុច្ចន្តិ

ញុាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធ ព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ។ ញុាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធ ព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុាំងធម៌ទាំងឡាយ ជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ។ ញុាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធ ព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុាំងធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើតធំទូលាយ ចម្រើនបរិបូណ៌ ។ នេះហៅថាបធានសង្ខារ ។ នេះហៅថា ឆន្ទៈផង នេះហៅថាឆន្ទសមាធិផង នេះហៅថាបធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ។

[៤៧៤] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យវីរិយៈ ហើយបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ។ នេះហៅថា វីរិយសមាធិ ។ ភិក្ខុនោះ ។ បេ ។ ញុាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធ ព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុាំងធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើតធំទូលាយ ចម្រើន ពេញបរិបូណ៌ ។ នេះហៅថា

បធានសង្ខារាតិ ។ ឥតិ ឥទំ ច វីរិយំ អយំ ច វីរិយ-
សមាធិ ឥមេ ច បធានសង្ខារា ។ អយំ វុច្ចតិ ភិក្ខវេ
វីរិយសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ។

[៤៧៥] ចិត្តំ ចេ ភិក្ខវេ ភិក្ខុ និស្សាយ លភតិ
សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ។ អយំ វុច្ចតិ ចិត្ត-
សមាធិ ។ សោ អនុប្បន្នានំ ។ បេ ។ ឧប្បន្នានំ កុ-
សលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ
វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ
វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥមេ វុច្ចន្តិ
បធានសង្ខារាតិ ។ ឥតិ ឥទញ្ច ចិត្តំ អយំ ច ចិត្តស-
មាធិ ឥមេ ច បធានសង្ខារា ។ អយំ វុច្ចតិ ភិក្ខវេ
ចិត្តសមាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោ ។

[៤៧៦] វីមំសំ ចេ ភិក្ខវេ ភិក្ខុ និស្សាយ លភតិ
សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ ។ អយំ វុច្ចតិ
វីមំសាសមាធិ ។ សោ អនុប្បន្នានំ បាបកានំ អកុស-
លានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ
វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ បេ ។

បធានសង្ខារ ។ នេះហៅថាវីរិយៈផង នេះហៅថាវីរិយសមាធិផង នេះហៅថាបធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ។

[៤៧៥] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យនូវចិត្តហើយ បាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ។ នេះហៅថា ចិត្តសមាធិ ។ ភិក្ខុនោះ ។ បេ ។ ញុាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុាំងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើតធំទូលាយ ចម្រើន ពេញបរិបូណ៌ ។ នេះហៅថា បធាន-សង្ខារ ។ នេះហៅថាចិត្តផង នេះហៅថាចិត្តសមាធិផង នេះហៅថាបធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ។

[៤៧៦] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យនូវវីមំសាហើយ បាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ។ នេះហៅថា វីមំសាសមាធិ ។ ភិក្ខុនោះ ញុាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុាំងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ។ បេ ។

ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហាតិ ។ ឥមេ វុច្ចន្តិ បធានសង្ខារាតិ ។ ឥតិ អយំ ច វីមំសា អយញ្ច វីមំសាសមាធិ ឥមេ ច បធានសង្ខារា ។ អយំ វុច្ចតិ ភិក្ខវេ វីមំសាស-មាធិប្បធានសង្ខារសមន្នាគតោ ឥទ្ធិបាទោតិ ។

[៤៧៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បសាទេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ហេដ្ឋា មិគារមាតុប្បាសាទេ វិហរន្តិ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា មុដ្ឋស្សតិនោ អសម្បជានា អ-សមាហិតា វិព្ភន្តចិត្តា បាកតិន្ទ្រិយា ។

ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើតជំទូលាយ ចម្រើន ពេញបរិបូណ៌ ។ នេះហៅថា បធានសង្ខារ ។ នេះហៅថាវីមំសាផង នេះហៅថាវីមំសាសមាធិផង នេះហៅថាបធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។

[៤៧៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងមិគារមាតុប្រាសាទ នាបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុច្រើនរូបនៅក្នុងមិគារមាតុប្រាសាទជាន់ក្រោម ជាអ្នករវើរវាយ មានមានៈដូចជាបបុស ងើបឡើងហើយ រដើបរដោរ មានមាត់រឹង មានវាចាពោយពាយ មានស្មារតីវង្វេង ប្រាសចាកបញ្ញា មានចិត្តមិនតម្កល់មាំ មានចិត្តអណ្តែតអណ្តូង មានឥន្ទ្រិយមិនសង្រួម ។

បាសាទកម្បនវគ្គោ

[៤៧៨] អថខោ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ អាមន្តេសិ ឯតេ ខោ មោគ្គល្លាន សព្រហ្មចារិនោ ហេដ្ឋា មិគារមាតុប្បាសាទេ វិហរន្តិ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា មុដ្ឋស្សតិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា បាកតិន្ទ្រិយា គច្ឆ មោគ្គល្លាន តេ ភិក្ខូ សំវេជេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា មហាមោគ្គល្លានោ ភគវតោ បដិស្សុត្វា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ យថា បាទង្គុដ្ឋកេន មិគារមាតុប្បាសាទំ សង្កម្បេសិ សម្បកម្បេសិ សម្បចាលេសិ ។

[៤៧៩] អថខោ តេ ភិក្ខូ សំវិគ្គា លោមហដ្ឋជាតា ឯកមន្តំ អដ្ឋំសុ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ និវាតញ្ច វត អយញ្ច មិគារមាតុប្បាសាទោ គម្ភីរនេមោ សុនិខាតោ អចលោ អសម្បកម្បិ អថ ច បន សង្កម្បិតោ សម្បកម្បិតោ សម្បចាលិតោតិ ។

[៤៧៨] លំដាប់នោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅព្រះមហាមោគ្គល្លានដ៏មានអាយុថា ម្នាលមោគ្គល្លាន សព្រហ្មចារីភិក្ខុទាំងនោះឯង នៅក្នុងមិគារមាតុប្រាសាទជាន់ក្រោម ជាអ្នកមានចិត្តរវើរវាយ មានមានៈដូចជាបបុស ងើបឡើងហើយ រជើបរជោរ មានមាត់រឹង មានសម្តីរោយរាយ វង្វេង ភ្លេចស្មារតី ប្រាសចាកបញ្ញា មានចិត្តមិនតម្កល់មាំ មានចិត្តអណ្តែតអណ្តូង មានឥន្ទ្រិយមិនសង្រួម ម្នាលមោគ្គល្លាន អ្នកចូរទៅញុំាងភិក្ខុទាំងនោះឲ្យសង្វេគ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ទទួលព្រះបន្ទូល ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយញុំាងមិគារមាតុប្រាសាទឲ្យកម្រើក ឲ្យរង្គើ ឲ្យញាប់ញ័រដោយម្រាមមេជើងយ៉ាងណា ក៏សម្តែងតាក់តែងនូវឫទ្ធិមានសភាពយ៉ាងនោះ ។

[៤៧៩] លំដាប់នោះឯង ភិក្ខុទាំងនោះតក់ស្លុតកើតព្រឺព្រួចរោម ឈរក្នុងទីសមគួរប្រាប់គ្នាថា យីអើ អស្ចារ្យណាស់តើ យីអើចម្លែកណាស់តើ គ្មានខ្យល់សោះ មិគារមាតុប្រាសាទនេះ មានរណ្តៅដ៏ជ្រៅ កប់ក៏ជ្រៅ ឥតកម្រើក ឥតញាប់ញ័រ ស្រាប់តែកម្រើក រង្គើញាប់ញ័រ ។

[៤៨០] អថខោ ភគវា យេន តេ ភិក្ខូ តេនុ-
បសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កិន្នុ
តុម្ហេ ភិក្ខវេ សំវិក្កា លោមហដ្ឋជាតា ឯកមន្តំ ឋិតា-
តិ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ និវាតញ្ចវត អយញ្ច
មិគារមាតុប្បាសាទោ គម្ភីរនេមោ សុនិខាតោ អចលោ
អសម្បកម្បិ អថ ច បន សង្កម្បិតោ សម្បកម្បិតោ
សម្បចាលិតោតិ ។

[៤៨១] តុម្ហេ ច ខោ ភិក្ខវេ សំវេជេតុកាមេន
មោគ្គល្លានេន ភិក្ខុនា ចាទង្គុដ្ឋកេន មិគារមាតុប្បា-
សាទោ សង្កម្បិតោ សម្បកម្បិតោ សម្បចាលិតោ ។
តំ កឹ មញ្ញថ ភិក្ខវេ កតមេសំ ធម្មានំ ភាវិតត្តា
ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ ឯវំមហិទ្ធិកោ
ឯវំមហានុភាវោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា
ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ

[៤៨០] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងនោះដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហ្ន៎ ក៏អ្នកទាំងឡាយ តក់ស្លុត កើតព្រឺព្រួចរោម ឈរក្នុងទីសមគួរ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ ស្ងប់ខ្យល់សោះ មិគារមាតុប្រាសាទនេះសោត មានរណ្តៅដ៏ជ្រៅ កប់ក៏ជ្រៅ ជារបស់ឥតកម្រើក ឥតញាប់ញ័រ ក៏ស្រាប់តែកម្រើក រង្គើ ញាប់ញ័រ ។

[៤៨១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះមោគ្គល្លាន ប្រាថ្នានឹងឲ្យអ្នកទាំងឡាយសង្វេគ ទើបធ្វើមិគារមាតុប្រាសាទឲ្យកម្រើក រង្គើញាប់ញ័រដោយមេជើងទេតើ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ហេតុនោះដូចម្តេច ភិក្ខុឈ្មោះមោគ្គល្លានមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវធម៌ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់យើងខ្ញុំ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់មេត្តាប្រោស

ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគ-វតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។

[៤៨២] តេនហិ ភិក្ខវេ សុណាថ ។ ចតុន្នំ ខោ ភិក្ខវេ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា មោគ្គល្លា-នោ ភិក្ខុ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ មោគ្គល្លានោ ភិក្ខុ ឆន្ទសមាធិ-ប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ ឆន្ទោ ន ច អតិលីនោ ភវិស្សតិ ។ បេ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ វីមំសា ន ច អតិលីនា ភវិស្សតិ ន ច អតិប្បគ្គហិតា ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តា ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តា ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ

សូមព្រះដ៏មានព្រះភាគសម្ដែងសេចក្ដីនៃភាសិតនុ៎ះ ឲ្យទាន ភិក្ខុទាំង-ឡាយ ស្ដាប់នូវភាសិតរបស់ព្រះដ៏មានព្រះភាគហើយនឹងចាំទុក ។

[៤៨២] ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្ដាប់ចុះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះមោគ្គល្លាន មានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ ឥទ្ធិបាទ ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះមោគ្គល្លាន ក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទ-សមាធិនិងបធានសង្ខារថា ឆន្ទៈរបស់អញនឹងមិនធូរថយពេកផង ។ បេ ។ វិរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារថា វីមំសារបស់អញ នឹងមិនធូរថយពេកផង មិនផ្គងឡើងពេកផង មិនរួញខាងក្នុងផង មិនមានចិត្តរាយមាយទៅខាងក្រៅផង ទាំងជាបុគ្គលមានសញ្ញាក្នុងខាងក្រោយនិងខាងមុខ គឺខាងមុខយ៉ាងណា

តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ ។

[៤៨៣] ឥមេសំ ច បន ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៤៨៤] ឥមេសំ ច បន ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ (ឯវំ ច អភិញ្ញាយោ វិត្ថារេតព្វា) ។

ខាងក្រោយក៏យ៉ាងនោះ ខាងក្រោយយ៉ាងណា ខាងមុខក៏យ៉ាងនោះ ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ ខាងលើយ៉ាងណា ខាងក្រោមក៏យ៉ាងនោះ វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តបើកមានកិលេសមិនរួបរឹត ចម្រើនចិត្តដែលប្រកបដោយពន្លឺដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះមោគ្គល្លាន មានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយៗ នូវឥទ្ធិបាទ ៤ នេះឯង ។

[៤៨៣] ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានភិក្ខុបានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះឯង ។ បេ។ ទៅទាំងអំណាចខ្លួនរហូតដល់ព្រហ្មលោកនាយបាន ។

[៤៨៤] ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានភិក្ខុបានធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងអត្តភាពដែលឃើញជាក់ស្តែង ព្រោះចម្រើន ព្រោះធ្វើឲ្យរឿយ ៗ នូវឥទ្ធិបាទ ៤ នេះ ។ (បណ្ឌិតត្រូវញ៉ាំងអភិញ្ញាទាំងឡាយឲ្យពិស្តារយ៉ាងនេះចុះ) ។

បាសាទកម្បនវគ្គោ

[៤៨៥] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថ-ខោ ឧណ្ណាកោ ព្រាហ្មណោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិ-សារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧណ្ណាភោ ព្រាហ្មណោ អាយស្មន្តំ អានន្ទំ ឯតទវោច

[៤៨៦] កិមត្ថិយំ នុ ខោ ភោ អានន្ទ សមណេ គោតមេ ព្រហ្មចរិយំ វុស្សតីតិ ។ ឆន្ទប្បហានត្ថំ ខោ ព្រាហ្មណ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។

[៤៨៧] អត្ថិ បន ភោ អានន្ទ មគ្គោ អត្ថិ បដិ-បទា ឯតស្ស ឆន្ទស្ស បហានាយាតិ ។ អត្ថិ ខោ ព្រាហ្មណ មគ្គោ អត្ថិ បដិបទា ឯតស្ស ឆន្ទស្ស បហានាយាតិ ។

[៤៨៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងឃោសិតារាមជិតក្រុងកោសម្ពី ។ លំដាប់នោះឯង ព្រាហ្មណ៍ឈ្មោះឧណ្ណាភៈ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍ឈ្មោះឧណ្ណាភៈ អង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា

[៤៨៦] បពិត្រព្រះអានន្ទដ៏ចម្រើន គេប្រព្រឹត្តព្រហ្មចារ្យ ក្នុងសំណាក់ព្រះសមណគោតម មានអ្វីជាប្រយោជន៍ ។ ម្នាលព្រាហ្មណ៍ គេប្រព្រឹត្តព្រហ្មចារ្យ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ មានការលះបង់ឆន្ទៈជាប្រយោជន៍ ។

[៤៨៧] បពិត្រព្រះអានន្ទដ៏ចម្រើន ចុះមានផ្លូវ មានបដិបទាដើម្បីលះបង់នូវឆន្ទៈនុ៎ះដែរឬ ។ ម្នាលព្រាហ្មណ៍ មានផ្លូវ មានបដិបទាដើម្បីលះបង់នូវឆន្ទៈនុ៎ះដែរ ។

[៤៨៨] កតមោ ចន ភោ អានន្ទ មគ្គោ កតមា បដិបទា ឯតស្ស ឆន្ទស្ស បហានាយាតិ ។ ឥធ ព្រាហ្មណ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំ-សាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ ខោ ព្រាហ្មណ មគ្គោ អយំ បដិបទា ឯតស្ស ឆន្ទស្ស បហានាយាតិ ។

[៤៨៩] ឯវំ សន្តេ ភោ[១] អានន្ទ សន្តកំ ហោតិ នោ អសន្តកំ ឆន្ទេនេវ[២] ឆន្ទំ បជហិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ តេនហិ ព្រាហ្មណ តញ្ញេវេត្ថ បដិបុច្ឆិ-ស្សាមិ យថា តេ ខមេយ្យ តថា តំ ព្យាករេយ្យាសិ ។

១ ឱ. ម. សន្តេ ខោ ។ ២ ម. ឆន្ទេ ច ។ ឱ. ឆន្ទេន ច

[៤៨៨] បពិត្រព្រះអានន្ទដ៏ចម្រើន ចុះផ្លូវដូចម្តេច បដិបទាដូចម្តេច ដើម្បីលះបង់នូវឆន្ទៈនុ៎ះ ។ ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលព្រាហ្មណ៍ នេះឯងជាផ្លូវ នេះជាបដិបទាដើម្បីលះបង់ឆន្ទៈនុ៎ះ ។

[៤៨៩] បពិត្រព្រះអានន្ទដ៏ចម្រើន កាលបើយ៉ាងនេះ វត្ថុដែលមាន នៅតែមាន វត្ថុដែលគ្មាន នៅតែគ្មាន ឯពាក្យដែលថា បុគ្គលនឹងលះបង់នូវឆន្ទៈដោយឆន្ទៈនុ៎ះ មិនសមហេតុទេ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ អាត្មានឹងសួរអ្នកក្នុងដំណើរនុ៎ះវិញ គួរដល់អ្នកយ៉ាងណា អ្នកត្រូវព្យាករប្រស្នានោះយ៉ាងនោះចុះ ។

៣០១

បាសាទកម្បនវគ្គោ

[៤៩០] តំ កឹ មញ្ញសិ ព្រាហ្មណា អហោសិ តេ បុព្វេ ឆន្ទោ អាគមំ គមិស្សាមីតិ ។ តស្ស តេ អាគមំ គតស្ស យោ តជ្ជោ ឆន្ទោ សោ បដិប្បស្សទ្ធោតិ ។ ឯវំ ភោ ។ អហោសិ តេ បុព្វេ វិរិយំ អាគមំ គមិស្សាមីតិ ។ តស្ស តេ អាគមំ គតស្ស យំ តជ្ជំ វិរិយំ តំ បដិប្បស្សទ្ធន្តិ ។ ឯវំ ភោ ។ អហោសិ តេ បុព្វេ ចិត្តំ អាគមំ គមិស្សាមីតិ ។ តស្ស តេ អាគមំ គតស្ស យំ តជ្ជំ ចិត្តំ តំ បដិប្បស្សទ្ធន្តិ ។ ឯវំ ភោ ។ អហោសិ តេ បុព្វេ វីមំសា អាគមំ គមិស្សាមីតិ ។ តស្ស តេ អាគមំ គតស្ស យា តជ្ជា វីមំសា សា បដិប្បស្សទ្ធាតិ ។ ឯវំ ភោ ។

បាសាទកម្បនវគ្គ

[៤៩០] ម្នាលព្រាហ្មណ៍ អ្នកយល់នូវដំណើរនោះដូចម្តេច អ្នកមានឆន្ទៈក្នុងកាលមុនថា អញនឹងទៅកាន់អារាម ។ កាលអ្នកនោះទៅដល់អារាមហើយ ឆន្ទៈដែលកើតមុននោះ ក៏ស្ងប់រម្ងាប់ឬទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ សេចក្តីព្យាយាមរបស់អ្នកក្នុងកាលមុនថា អញនឹងទៅកាន់អារាម ។ កាលអ្នកនោះទៅដល់អារាមហើយ ព្យាយាមដែលកើតមុននោះ ស្ងប់រម្ងាប់ឬទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ អ្នកបានមានចិត្តក្នុងកាលមុនថា អញនឹងទៅកាន់អារាម ។ កាលបើអ្នកនោះទៅដល់អារាមហើយ ចិត្តដែលកើតមុននោះស្ងប់រម្ងាប់ឬទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ បញ្ញារបស់អ្នកបានកើតឡើងក្នុងកាលមុនថា អញនឹងទៅកាន់អារាម ។ កាលអ្នកនោះទៅដល់អារាមហើយ បញ្ញាដែលកើតមុននោះស្ងប់រម្ងាប់ដែរឬទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន យ៉ាងហ្នឹងហើយ ។

[៤៩១] ឯវមេវ ខោ ព្រាហ្មណ យោ សោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិត-ភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ តស្ស យោ បុព្វេ ឆន្ទោ អហោសិ អរហត្តប្បត្តិយា អរហត្តេ បត្តេ យោ តជ្ជោ ឆន្ទោ សោ បដិប្បស្សទ្ធោ យំ បុព្វេ វិរិយំ អហោសិ អរហត្តប្បត្តិ-យា អរហត្តេ បត្តេ យំ តជ្ជំ វិរិយំ តំ បដិប្បស្សទ្ធំ យំ បុព្វេ ចិត្តំ អហោសិ អរហត្តប្បត្តិយា អរហត្តេ បត្តេ យំ តជ្ជំ ចិត្តំ តំ បដិប្បស្សទ្ធំ យា បុព្វេ វីមំសា អហោសិ អរហត្តប្បត្តិយា អរហត្តេ បត្តេ យា តជ្ជា វីមំសា សា បដិប្បស្សទ្ធា ។

[៤៩០] ម្នាលព្រាហ្មណ៍ ការនុ៎ះក៏ដូច្នោះដែរ ភិក្ខុជាព្រះអរហន្ត ខីណាស្រព មានព្រហ្មចារ្យប្រព្រឹត្តរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ផ្ទាល់ខ្លួនដល់ហើយ មានសំយោជនៈក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះការដឹងដោយប្រពៃ ភិក្ខុនោះមានឆន្ទៈក្នុងកាលមុន ដើម្បីឲ្យដល់អរហត្ត លុះសម្រេចអរហត្តហើយ ឆន្ទៈដែលកើតមុននោះក៏ស្ងប់រម្ងាប់ទៅ ភិក្ខុនោះមានព្យាយាមក្នុងកាលមុន ដើម្បីឲ្យដល់អរហត្ត លុះបានដល់អរហត្តហើយ ព្យាយាមដែលកើតអំពីមុននោះ ក៏ស្ងប់រម្ងាប់ទៅ ភិក្ខុនោះមានចិត្តក្នុងកាលមុន ដើម្បីឲ្យដល់អរហត្ត លុះដល់អរហត្តហើយ ចិត្តដែលកើតអំពីមុននោះ ក៏ស្ងប់រម្ងាប់ទៅ ភិក្ខុនោះមានបញ្ញាក្នុងកាលមុន ដើម្បីឲ្យដល់អរហត្ត លុះបានដល់អរហត្តហើយ បញ្ញាដែលកើតអំពីមុននោះ ក៏ស្ងប់រម្ងាប់ទៅ ។

## បាសាទកម្បនវគ្គោ

[៤៩២] តំ កឹ មញ្ញសិ ព្រាហ្មណ ឥតិ ឯវំ សន្តេ សន្តកំ វា ហោតិ នោ អសន្តកំ វាតិ ។ អទ្ធា ភោ អានន្ទ ឯវំ សន្តេ សន្តកំ ហោតិ នោ អសន្តកំ អ-ភិក្កន្តំ ភោ អានន្ទ អភិក្កន្តំ ភោ អានន្ទ សេយ្យថាបិ ភោ អានន្ទ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ។ ឯវមេវ តយា ភោ អានន្ទ(១) អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភោ អានន្ទ តំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបា-សកំ មំ ភវំ អានន្ទោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

---

១ ម. ឯវមេវំ ភោតា អានន្ទេន ។

បាសាទកម្បនវគ្គ

[៤៩២] ម្នាលព្រាហ្មណ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច កាលបើហេតុយ៉ាងនេះ វត្ថុដែលមាន នៅតែមាន វត្ថុដែលគ្មាន នៅតែគ្មានឬទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ពិតមែនហើយ បើយ៉ាងនេះ វត្ថុដែលមាន នៅតែមាន វត្ថុដែលគ្មាន នៅតែគ្មាន បពិត្រព្រះអានន្ទដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើករបស់ដែលកំបាំងពុំនោះដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេង ឬដូចគេទ្រោលប្រទីបក្នុងទីងងឹត ឲ្យអ្នកមានចក្ខុមើលឃើញរូបបាន ។ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលលោកសម្តែងហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះឯង ។ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់ព្រះគោតមដ៏ចម្រើននោះផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ សូមព្រះអានន្ទដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះករុណាថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ ។

[៤៩៣] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា មហិទ្ធិកា អហេសុំ មហានុភាវា សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា មហិទ្ធិកា ភវិស្សន្តិ មហានុភាវា សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា មហិទ្ធិកា មហានុភាវា សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[៤៩៣] ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល មានពួកសមណៈ ឬព្រាហ្មណ៍មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអនាគតកាលគង់មានពួកសមណៈឬព្រាហ្មណ៍មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ក៏មានពួកសមណៈឬព្រាហ្មណ៍មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។

[៤៩៤] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា មហិទ្ធិកា អហេសុំ មហានុភាវា សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា មហិទ្ធិកា ភវិស្សន្តិ មហានុភាវា សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា មហិទ្ធិកា មហានុភាវា សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តាតិ ។

[៤៩៥] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោសុំ ឯកោបិ ហុត្វា ពហុធា អហេសុំ ពហុធាបិ ហុត្វា ឯកោ អហេសុំ អាវិភាវំ តិរោភាវំ តិរោកុដ្ដំ តិរោបាការំ តិរោបព្វតំ អសជ្ជមានា អគមំសុ សេយ្យថាបិ

[៤៩៤] ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល មានពួកសមណៈឬព្រាហ្មណ៍ មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអនាគតកាលគង់មានពួកសមណៈឬព្រាហ្មណ៍មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ក៏មានពួកសមណៈឬព្រាហ្មណ៍ មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។

[៤៩៥] ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល មានពួកសមណៈឬព្រាហ្មណ៍ បានសម្រេច នូវឥទ្ធិវិធៈ (ការសម្តែងឫទ្ធិ) ច្រើនប្រការ គឺធ្វើមនុស្សម្នាក់ឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ធ្វើមនុស្សច្រើននាក់ឲ្យទៅជាមនុស្សម្នាក់ក៏បាន នៅក្នុងទីកំបាំងដើរទៅកាន់ទីវាល នៅខាងក្នុងដើរចេញទៅខាងក្រៅ នៅខាងក្នុងជញ្ជាំងដើរចេញទៅខាងក្រៅជញ្ជាំង នៅខាងក្នុងកំពែងដើរចេញទៅខាងក្រៅកំពែង នៅខាងក្នុងភ្នំដើរចេញទៅខាងក្រៅភ្នំ (ដោយឥតទ្វារឥតផ្លូវ) ឥតទើសទាល់ដូចដើរ

អាកាសេ បឋវិយំបិ ឧម្មុជ្ជនិម្មុជ្ជំ អកំសុ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ អគមំសុ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមឹសុ[១] សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរាមសឹសុ បរិមជ្ជឹសុ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេសុំ ។ សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោស្សន្តិ ឯកោបិ ហុត្វា ពហុធា ភវិស្សន្តិ ពហុធាបិ ហុត្វា ឯកោ ភវិស្សន្តិ អាវិភាវំ តិរោភាវំ តិរោកុដ្ដំ តិរោបាការំ តិរោបព្វតំ អសជ្ជមានា គមិស្សន្តិ សេយ្យថាបិ អាកាសេ បឋវិយំបិ ឧម្មុជ្ជនិម្មុជ្ជំ ករិស្សន្តិ

---

១ ឱ. អគមំសុ ។

លើអាកាសក៏បាន ងើបឡើងមុជចុះក្នុងផែនដី ដូចជាងើបឡើងមុជចុះក្នុងទឹកក៏បាន ដើរលើទឹកមិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែន ដូចជាសត្វស្លាបក៏បាន យកដៃស្ទាបអង្អែល (មណ្ឌល) ព្រះចន្ទព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ ព្រោះតែសមណព្រាហ្មណ៍ទាំងអស់នោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងអនាគតកាល គង់មានសមណៈឬព្រាហ្មណ៍បានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺនឹងធ្វើមនុស្សម្នាក់ ឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ធ្វើមនុស្សច្រើននាក់ឲ្យទៅជាមនុស្សម្នាក់ក៏បាន នៅក្នុងទីកំបាំងនឹងដើរទៅកាន់ទីវាល នៅខាងក្នុងដើរចេញទៅខាងក្រៅ នៅខាងក្នុងជញ្ជាំង ដើរចេញទៅខាងក្រៅជញ្ជាំង នៅខាងក្នុងកំពែង ដើរចេញទៅខាងក្រៅកំពែង នៅខាងក្នុងភ្នំដើរចេញទៅក្រៅភ្នំ (ដោយឥតទ្វារឥតផ្លូវ) ឥតទើសទាល់ ដូចជាដើរលើអាកាសក៏បា ងើបឡើង មុជចុះក្នុងផែនដី

៣០៧

## បាសាទកម្បនវគ្គោ

សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ កមិស្សន្តិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមិស្សន្តិ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរាមសិស្សន្តិ បរិមជ្ជិស្សន្តិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេស្សន្តិ ។ សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោន្តិ ឯកោបិ ហុត្វា ពហុធា ហោន្តិ ពហុធាបិ ហុត្វា ឯកោ ហោន្តិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានា គច្ឆន្តិ សេយ្យថាបិ អាកាសេ បឋវិយំបិ ឧម្មុជ្ជនិម្មុជ្ជំ ករោន្តិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆន្តិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមន្តិ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរាមសន្តិ បរិមជ្ជន្តិ

ដូចជាងើបឡើងមុជចុះក្នុងទឹកក៏បាន ដើរលើទឹកមិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន នឹងទៅឯអាកាសទាំងភ្នែន ដូចជាសត្វស្លាបក៏បាន នឹងយកដៃស្ទាបអង្អែល (មណ្ឌល) ព្រះចន្ទ្រព្រះអាទិត្យទាំងនេះដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន នឹងធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ព្រោះតែសមណព្រាហ្មណ៍ទាំងអស់នោះ បានចម្រើនធ្វើឲ្យច្រើននូវឥទ្ធិ-បាទ ៤ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ក៏មានសមណៈឬព្រាហ្មណ៍បានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺធ្វើមនុស្សម្នាក់ឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ធ្វើមនុស្សច្រើននាក់ឲ្យទៅជាមនុស្សម្នាក់ក៏បាន នៅក្នុងទីកំបាំងដើរទៅកាន់ទីវាល នៅខាងក្នុងដើរចេញទៅខាងក្រៅ នៅខាងក្នុងជញ្ជាំងដើរចេញទៅខាងក្រៅជញ្ជាំង នៅខាងក្នុងកំពែងដើរចេញទៅខាងក្រៅកំពែង នៅក្នុងភ្នំដើរចេញទៅខាងក្រៅភ្នំ (ដោយឥតទ្វារឥតផ្លូវ) ឥតទើសទាល់ ដូចជាដើរលើអាកាសក៏បាន ងើបឡើងមុជចុះក្នុងផែនដី ដូចជាងើបឡើងមុជចុះក្នុងទឹកក៏បាន ដើរលើទឹកមិនបែកធ្លាយទឹក ដូចជាដើរលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែនដូចជាសត្វស្លាបក៏បាន យកដៃស្ទាបអង្អែល (មណ្ឌល) ព្រះចន្ទ្រព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន

យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេន្តិ ។ សព្វេ តេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមា-ធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិ-យសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធា-នសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[៤៩៦] យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោសុំ ឯកោបិ ហុត្វា ពហុធា អហេសុំ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេសុំ ។ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ អនាគ-តមទ្ធានំ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោស្សន្តិ ឯកោបិ ហុត្វា ពហុធា

ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ព្រោះតែសមណព្រាហ្មណ៍ទាំងអស់នោះ បានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វិរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។

[៤៩៦] ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល មានពួកសមណៈឬព្រាហ្មណ៍ បានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺធ្វើមនុស្សម្នាក់ឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ។ បេ ។ ធ្វើអំណាចឱ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ព្រោះតែសមណព្រាហ្មណ៍ទាំងអស់នោះ បានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអនាគតកាល គង់មានពួកសមណៈឬព្រាហ្មណ៍បានសម្រេចនូវឥទ្ធិវិធៈ ច្រើនប្រការ គឺនឹងធ្វើមនុស្សម្នាក់ឲ្យទៅជាមនុស្សច្រើននាក់

ភវិស្សន្តិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេស្សន្តិ ។ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោន្តិ ឯកោបិ ហុត្វា ពហុធា ហោន្តិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេ-ន្តិ ។ សព្វេ តេ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តាតិ ។

[៤៩៧] ចតុន្នំ ភិក្ខវេ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសា-សមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

*ក៏បាន ។ បេ ។ នឹងធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្ម-លោកក៏បាន ។ ព្រោះតែសមណព្រាហ្មណ៍ទាំងអស់នោះ បានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ក៏មានពួកសមណៈឬព្រាហ្មណ៍ បានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺធ្វើមនុស្សម្នាក់ ឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ព្រោះតែសមណព្រាហ្មណ៍ទាំងអស់នោះ បានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។*

*[៤៩៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្ន ក៏ព្រោះតែបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។*

ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៤៩៨] ឥទ្ធិញ្ច វោ ភិក្ខវេ ទេសេស្សាមិ ឥទ្ធិ-បាទញ្ច ឥទ្ធិបាទភាវនញ្ច ឥទ្ធិបាទភាវនាគាមិនិញ្ច បដិបទំ តំ សុណាថ ។ កតមា ច ភិក្ខវេ ឥទ្ធិ ។ ឥធ ភិក្ខវេ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិ ។

[៤៩៩] កតមោ ច ភិក្ខវេ ឥទ្ធិបាទោ ។ យោ[១] ភិក្ខវេ មគ្គោ យា បដិបទា ឥទ្ធិលាភាយ ឥទ្ធិប្បដិ-លាភាយ សំវត្តេតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទោ ។

---

១ ម. យោ សោ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិនិង បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្ន ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវឥទ្ធិបាទ ៤ នេះដែរ ។

[៤៩៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវឫទ្ធិផង នូវឥទ្ធិបាទផង នូវការចម្រើនឥទ្ធិបាទផង នូវបដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់សេចក្តីនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះឫទ្ធិដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺធ្វើមនុស្សម្នាក់ឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ធ្វើមនុស្សច្រើននាក់ឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាឫទ្ធិ ។

[៤៩៩] ម្នាលភិក្ខុទាំងឡាយ ចុះឥទ្ធិបាទ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មគ្គឯណា បដិបទាឯណា ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ បានស៊ប់នូវឫទ្ធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាឥទ្ធិបាទ ។

បាសាទកម្បនវគ្គោ

[៤០០] កតមា ច ភិក្ខវេ ឥទ្ធិបាទភាវនា ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទភាវនា ។

[៤០១] កតមា ច ភិក្ខវេ ឥទ្ធិបាទភាវនាគាមិនី បដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទភាវនាគាមិនី បដិបទាតិ ។

[៤០២] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ភាវិតា ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា ។ កថំ ភាវិតា ច ភិក្ខវេ ចត្តារោ ឥទ្ធិបាទា កថំ ពហុលីកតា

បាសាទកម្បនវគ្គ

[៩០០] ម្នាលភិក្ខុទាំងឡាយ ចុះការចម្រើននូវឥទ្ធិបាទដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ។ វិរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការចម្រើននូវឥទ្ធិបាទ ។

[៩០១] ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់ការចម្រើននូវឥទ្ធិបាទ ដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ អ្វីខ្លះ ។គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើននូវឥទ្ធិបាទ ។

[៩០២] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ នេះ ដែលភិក្ខុចម្រើនធ្វើឲ្យច្រើនហើយ ជាធម៌មានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ចុះឥទ្ធិបាទ ៤ តើភិក្ខុចម្រើនដូចម្តេច ធ្វើឲ្យច្រើនដូចម្តេច

មហប្ផលា ហោន្តិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិចាទំ ភាវេតិ ឥតិ បេ ឆន្ទោ ន ច អតិសីនោ ភវិស្សតិ ន ច អតិប្បគ្គហិតោ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តោ ភវិស្សតិ ច ន ពហិទ្ធា វិក្ខិត្តោ ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តស-មាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-ចាទំ ភាវេតិ ឥតិ មេ វីមំសា ន ច អតិលីនា ភវិស្សតិ ន ច អតិប្បគ្គហិតា ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តា ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តា ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ

ទើបជាធម៌មានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធាន-សង្ខារដូច្នេះថា ឆន្ទៈរបស់អាត្មាអញនឹងមិនធូរថយខ្លាំងពេកផង នឹងមិនផ្គងកំហុសខ្លាំងពេកផង នឹងមិនរួញលីបនៅខាងក្នុងផង នឹងមិនរាយមាយទៅខាងក្រៅផង មានសញ្ញាក្នុងកាលជាខាងក្រោយនិងកាលមុន គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ ក្រោមយ៉ាងណា លើក៏យ៉ាងនោះ លើយ៉ាងណា ក្រោមក៏យ៉ាងនោះ ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ មានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺដោយប្រការដូច្នេះ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារដូច្នេះថា វីមំសារបស់អាត្មាអញនឹងមិនធូរថយខ្លាំងពេកផង នឹងមិនផ្គងកំហុសខ្លាំងពេកផង នឹងមិនរួញលីបនៅខាងក្នុងផង មិនរាយមាយទៅខាងក្រៅផង មានសញ្ញាក្នុងកាលជាខាងក្រោយនិងកាលមុន គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ ក្រោយយ៉ាងណា លើក៏យ៉ាងនោះ

យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

[៨០៣] កាតមោ ច ភិក្ខវេ អតិលីនោ ឆន្ទោ ។ យោ ភិក្ខវេ ឆន្ទោ កោសជ្ជសហាគតោ កោសជ្ជ-សម្បយុត្តោ ។ អយំ វុច្ចតិ ភិក្ខវេ អតិលីនោ ឆន្ទោ ។

៨០៤ កាតមោ ច ភិក្ខវេ អតិប្បគ្គហិតោ ឆន្ទោ ។ យោ ភិក្ខវេ ឆន្ទោ ឧទ្ធច្ចសហាគតោ ឧទ្ធច្ច-សម្បយុត្តោ ។ អយំ វុច្ចតិ ភិក្ខវេ អតិប្បគ្គហិតោ ឆន្ទោ ។

[៨០៥] កាតមោ ច ភិក្ខវេ អជ្ឈត្តំ សង្ខិត្តោ ឆន្ទោ ។ យោ ភិក្ខវេ ឆន្ទោ ថីនមិទ្ធសហាគតោ ថីនមិទ្ធសម្បយុត្តោ ។ អយំ វុច្ចតិ ភិក្ខវេ អជ្ឈត្តំ សង្ខិត្តោ ឆន្ទោ ។

*លើយ៉ាងណា ក្រោមក៏យ៉ាងនោះ ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ មានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ ដោយប្រការដូច្នេះ ។*

*[៥០៣] ម្នាលភិក្ខុទាំងឡាយ ចុះឆន្ទៈដែលនូវធូរថយខ្លាំងពេក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទៈឯណាប្រកបដោយកោសជ្ជៈ (សេចក្តីខ្ជិលច្រអូស) សម្បយុត្តដោយកោសជ្ជៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឆន្ទៈដែលធូរថយខ្លាំងពេក ។*

*[៥០៤] ម្នាលភិក្ខុទាំងឡាយ ចុះឆន្ទៈដែលផ្គងកំហុសខ្លាំងពេក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទៈឯណាប្រកបដោយឧទ្ធច្ចៈ (សេចក្តីរវើរវាយ) សម្បយុត្តដោយឧទ្ធច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឆន្ទៈដែលផ្គងកំហុសខ្លាំងពេក ។*

*[៥០៥] ម្នាលភិក្ខុទាំងឡាយ ចុះឆន្ទៈដែលរួញលឹបនៅខាងក្នុង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទៈឯណាប្រកបដោយថីនមិទ្ធៈ (សេចក្តីងងុយងោកងក់) សម្បយុត្តដោយថីនមិទ្ធៈ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា ឆន្ទៈដែលរួញលឹបនៅខាងក្នុង ។*

[៤០៦] កតមោ ច ភិក្ខវេ ពហិទ្ធា វិក្ខិត្តោ ឆន្ទោ ។ យោ ភិក្ខវេ ឆន្ទោ ពហិទ្ធា បញ្ច កាមគុ-ណេ អារព្ភ អនុវិក្ខិត្តោ អនុវិសដោ ។ អយំ វុច្ចតិ ភិក្ខវេ ពហិទ្ធា វិក្ខិត្តោ ឆន្ទោ ។

[៤០៧] កថញ្ច ភិក្ខវេ ភិក្ខុ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ ។ ឥធ ភិក្ខវេ ភិក្ខុនោ បច្ឆាបុរេ សញ្ញា សុគ្គ-ហិតា ហោតិ សុមនសិកតា សូបធារិតា សុប្បដិវិទ្ធា បញ្ញាយ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ ។

[៤០៨] កថញ្ច ភិក្ខវេ ភិក្ខុ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ វិហរតិ ។

[៥០៦] ម្នាលភិក្ខុទាំងឡាយ ចុះឆន្ទៈដែលរាយមាយទៅខាងក្រៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទៈឯណារាយមាយទៅតាមជាប់ទៅតាម ប្រារព្ធនូវបញ្ចកាមគុណខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា ឆន្ទៈដែលរាយមាយទៅខាងក្រៅ ។

[៥០៧] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានសញ្ញាក្នុងកាលជាខាងក្រោយនិងកាលមុន គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាបុគ្គលមានសញ្ញាកាន់យកល្អ ធ្វើទុកក្នុងចិត្តល្អ ទ្រទ្រង់ទុកល្អ ចាក់ធ្លុះល្អ ដោយប្រាជ្ញាក្នុងកាលជាខាងក្រោយនិងកាលមុន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសញ្ញាក្នុងកាលជាខាងក្រោយនិងកាលមុន គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មិនក៏យ៉ាងនោះ យ៉ាងនេះឯង ។

[៥០៨] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ (មានសញ្ញា) ក្រោមយ៉ាងណា លើក៏យ៉ាងនោះ លើយ៉ាងណា ក្រោមក៏យ៉ាងនោះ តើដូចម្តេច ។

៣១៩



ឥធ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរំ នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ វិហរតិ ។

បាសាទកម្បនវគ្គ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយនេះឯង ខាងលើតាំងអំពីបាទាដើងឡើងមក ខាងក្រោមតាំងអំពីចុងសក់ចុះទៅ មានស្បែករុំព័ទ្ធជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗថា ក្នុងកាយនេះមានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ[១]សួតពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ (មានសញ្ញា) ក្រោមយ៉ាងណា លើក៏យ៉ាងនោះ លើយ៉ាងណា ក្រោមក៏យ៉ាងនោះ យ៉ាងនោះឯង ។

---

១ក្រពៈនេះ គឺជាសាច់ដូចជាអណ្តាត បិតនៅក្នុងពោះ មានសណ្ឋានដូចជាអណ្តាតកូនគោខ្មៅ ប្រវែង៧ធ្នាក់ ផ្តាប់នឹងទីបំផុតដំបារពោះខាងឆ្វេងបេះដូង ។ (មិនមែនជាអាមាសយៈ ដែលអ្នកខ្លះធ្លាប់ហៅថា ក្រពះបាយនោះទេ ។ ឬនឹងប្រែថាលំពែងអារឹសដូច្នេះវិញក៏បាន ) ។

[៨០៩] កថញ្ច ភិក្ខវេ ភិក្ខុ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេហិ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ ទិវា ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ សោ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ រត្តឹ ឆន្ទសមាធិប្បធាន-សង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ យេហិ វា បន អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ រត្តឹ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ សោ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ ទិវា ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា វិហរតិ ។

[៩០៩] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ (មានសញ្ញា) ក្នុងពេលថ្ងៃយ៉ាងណា ពេលយប់ក៏យ៉ាងនោះ ពេលយប់យ៉ាងណា ពេលថ្ងៃក៏យ៉ាងនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ក្នុងវេលាថ្ងៃ ដោយអាការទាំងឡាយឯណា ដោយសណ្ឋានទាំងឡាយឯណា ដោយនិមិត្តទាំងឡាយឯណា ភិក្ខុនោះក៏ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ក្នុងវេលាយប់ ដោយអាការទាំងឡាយនោះ ដោយសណ្ឋានទាំងឡាយនោះ ដោយនិមិត្តទាំងឡាយនោះដែរ ឬថាភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ក្នុងវេលាយប់ ដោយអាការទាំងឡាយឯណា ដោយសណ្ឋានទាំងឡាយឯណា ដោយនិមិត្តទាំងឡាយឯណា ភិក្ខុនោះ ក៏ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទ-សមាធិនិងបធានសង្ខារ ក្នុងវេលាថ្ងៃ ដោយអាការទាំងឡាយនោះ ដោយសណ្ឋានទាំងឡាយនោះ ដោយនិមិត្តទាំងឡាយនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសញ្ញា ក្នុងពេលថ្ងៃយ៉ាងណា ពេលយប់ក៏យ៉ាងនោះ ពេលយប់យ៉ាងណា ពេលថ្ងៃក៏យ៉ាងនោះ យ៉ាងនេះឯង ។

៣១៧

បាសាទកម្បនវគ្គោ

[៥១០] កាថញ្ច ភិក្ខវេ ភិក្ខុ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អាលោកសញ្ញា សុគ្គហិតា ហោតិ ទិវាសញ្ញា ស្វាធិដ្ឋិតា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

[៥១១] កាតមញ្ច ភិក្ខវេ អតិលីនំ វីរិយំ ។ យំ ភិក្ខវេ វីរិយំ កោសជ្ជសហគតំ កោសជ្ជសម្បយុត្តំ ។ ឥទំ វុច្ចតិ ភិក្ខវេ អតិលីនំ វីរិយំ ។

[៥១២] កាតមញ្ច ភិក្ខវេ អតិប្បគ្គហិតំ វីរិយំ ។ យំ ភិក្ខវេ វីរិយំ ឧទ្ធច្ចសហគតំ ឧទ្ធច្ចសម្បយុត្តំ ។ ឥទំ វុច្ចតិ ភិក្ខវេ អតិប្បគ្គហិតំ វីរិយំ ។

[៥១៣] កាតមញ្ច ភិក្ខវេ អជ្ឈត្តំ សង្ខិត្តំ វីរិយំ ។ យំ ភិក្ខវេ វីរិយំ ថីនមិទ្ធសហគតំ ថីនមិទ្ធសម្បយុត្តំ ។ ឥទំ វុច្ចតិ ភិក្ខវេ អជ្ឈត្តំ សង្ខិត្តំ វីរិយំ ។

បាសាទកម្បនវគ្គ

[៥១០] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាបុគ្គលមានអាលោកសញ្ញាកាន់យកល្អ មានទិវាសញ្ញាអធិដ្ឋានដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺយ៉ាងនេះឯង ។

[៥១១] ម្នាលភិក្ខុទាំងឡាយ ចុះព្យាយាមដែលធូរថយខ្លាំងពេក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្យាយាមឯណា ប្រកបដោយកោសជ្ជៈ សម្បយុត្តដោយកោសជ្ជៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ព្យាយាមដែលធូរថយខ្លាំងពេក ។

[៥១២] ម្នាលភិក្ខុទាំងឡាយ ចុះព្យាយាមដែលផ្គងគំហុសខ្លាំងពេក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្យាយាមឯណា ប្រកបដោយឧទ្ធច្ចៈ សម្បយុត្តដោយឧទ្ធច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ព្យាយាមដែលផ្គងគំហុសខ្លាំងពេក ។

[៥១៣] ម្នាលភិក្ខុទាំងឡាយ ចុះព្យាយាមដែលរួញលឺបនៅខាងក្នុង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្យាយាមឯណាប្រកបដោយថីនមិទ្ធៈ សម្បយុត្តដោយថីនមិទ្ធៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ព្យាយាមដែលរួញលឺបនៅខាងក្នុង ។

[៩១៤] កាតមញ្ច ភិក្ខវេ ពហិទ្ធា វិក្ខិត្តំ វីរិយំ យំ ភិក្ខវេ វីរិយំ ពហិទ្ធា បញ្ច កាមគុណេ អារព្ភ អនុវិក្ខិត្តំ អនុវិសដំ ។ ឥទំ វុច្ចតិ ភិក្ខវេ ពហិទ្ធា វិក្ខិត្តំ វីរិយំ ។ បេ ។

[៩០៥] កាថញ្ច ភិក្ខវេ ភិក្ខុ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អាលោកសញ្ញា សុគ្គហិតា ហោតិ ទិវាសញ្ញា ស្វាធិដ្ឋិតា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

[៩១៦] កាតមញ្ច ភិក្ខវេ អតិលីនំ ចិត្តំ ។ យំ ភិក្ខវេ ចិត្តំ កោសជ្ជសហាគតំ កោសជ្ជសម្បយុត្តំ ។ ឥទំ វុច្ចតិ ភិក្ខវេ អតិលីនំ ចិត្តំ ។

[៥១៤] ម្នាលភិក្ខុទាំងឡាយ ចុះព្យាយាមដែលរាយមាយទៅខាងក្រៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្យាយាមឯណា រាយមាយទៅតាម ជាប់ទៅតាម ប្រារព្ធនូវបញ្ចកាមគុណខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ព្យាយាមដែលរាយមាយទៅខាងក្រៅ ។ បេ ។

[៥១៥] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាន់យកអាលោកសញ្ញាដោយល្អ អធិដ្ឋានទិវាសញ្ញាដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តស្វាង ឥតមានកិលេសរួបរឹតចម្រើនចិត្តប្រកបដោយពន្លឺ យ៉ាងនេះឯង ។

[៥០៦] ម្នាលភិក្ខុទាំងឡាយ ចុះចិត្តដែលធូរថយខ្លាំងពេក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចិត្តឯណាប្រកបដោយកោសជ្ជៈ សម្បយុត្តដោយកោសជ្ជៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តដែលធូរថយខ្លាំងពេក ។

៣១៩

បាសាទកម្បនវគ្គោ

[៤១៧] កាតមញ្ច ភិក្ខវេ អតិប្បគ្គហិតំ ចិត្តំ ។ យំ ភិក្ខវេ ចិត្តំ ឧទ្ធច្ចសហគតំ ឧទ្ធច្ចសម្បយុត្តំ ។ ឥទំ វុច្ចតិ ភិក្ខវេ អតិប្បគ្គហិតំ ចិត្តំ ។

[៤១៨] កាតមញ្ច ភិក្ខវេ អជ្ឈត្តំ សង្ខិត្តំ ចិត្តំ ។ យំ ភិក្ខវេ ចិត្តំ ថីនមិទ្ធសហគតំ ថីនមិទ្ធសម្ប-យុត្តំ ។ ឥទំ វុច្ចតិ ភិក្ខវេ អជ្ឈត្តំ សង្ខិត្តំ ចិត្តំ ។

[៤១៩] កាតមញ្ច ភិក្ខវេ ពហិទ្ធា វិក្ខិត្តំ ចិត្តំ ។ យំ ភិក្ខវេ ចិត្តំ ពហិទ្ធា បញ្ច កាមគុណេ អារព្ភ អនុវិក្ខិត្តំ អនុវិសដំ ។ ឥទំ វុច្ចតិ ភិក្ខវេ ពហិទ្ធា វិក្ខិត្តំ ចិត្តំ ។ បេ ។

[៤២០] ឯវំ ខោ ភិក្ខវេ ភិក្ខុ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។

[៥១៧] ម្នាលភិក្ខុទាំងឡាយ ចុះចិត្តដែលផ្គងគំហុកខ្លាំងពេក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចិត្តឯណាប្រកបដោយឧទ្ធច្ចៈ សម្បយុត្តដោយឧទ្ធច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តដែលផ្គងគំហុកខ្លាំងពេក ។

[៥១៨] ម្នាលភិក្ខុទាំងឡាយ ចុះចិត្តដែលរួញលីបនៅខាងក្នុង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចិត្តឯណាប្រកបដោយថីនមិទ្ធៈ សម្បយុត្តដោយថីនមិទ្ធៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តដែលរួញលីបនៅខាងក្នុង ។

[៥១៩] ម្នាលភិក្ខុទាំងឡាយ ចុះចិត្តដែលរាយមាយទៅខាងក្រៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចិត្តឯណារាយមាយទៅតាម ជាប់ទៅតាម ប្រារព្ធនូវបញ្ចកាមគុណខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តរាយមាយទៅខាងក្រៅ ។ បេ ។

[៥២០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តស្ងាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ យ៉ាងនេះឯង ។

[៤២១] កាតមា ច ភិក្ខវេ អតិលីនា វីមំសា ។ យា ភិក្ខវេ វីមំសា កោសជ្ជសហាគតា កោសជ្ជ-សម្បយុត្តា ។ អយំ វុច្ចតិ ភិក្ខវេ អតិលីនា វីមំសា ។

[៤២២] កាតមា ច ភិក្ខវេ អតិប្បគ្គហិតា វីមំ-សា ។ យា ភិក្ខវេ វីមំសា ឧទ្ធច្ចសហាគតា ឧទ្ធច្ចស-ម្បយុត្តា អយំ វុច្ចតិ ភិក្ខវេ អតិប្បគ្គហិតា វីមំសា ។

[៤២៣] កាតមា ច ភិក្ខវេ អជ្ឈត្តំ សង្ខិត្តា វីមំ-សា ។ យា ភិក្ខវេ វីមំសា ថីនមិទ្ធសហាគតា ថីនមិទ្ធ-សម្បយុត្តា។ អយំ វុច្ចតិ ភិក្ខវេ អជ្ឈត្តំ សង្ខិត្តា វីមំសា ។

[៤២៤] កាតមា ច ភិក្ខវេ ពហិទ្ធា វិក្ខិត្តា វីមំ-សា ។ យា ភិក្ខវេ វីមំសា ពហិទ្ធា បញ្ច កាមគុណេ អារព្ភ អនុវិក្ខិត្តា អនុវិសដា ។ អយំ វុច្ចតិ ភិក្ខវេ បហិទ្ធា វិក្ខិត្តា វីមំសា ។ បេ ។

[៥២១] ម្នាលភិក្ខុទាំងឡាយ ចុះវីមំសា ដែលធូរថយខ្លាំងពេក តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ វីមំសាឯណាប្រកបដោយកោសជ្ជៈ សម្បយុត្តដោយកោសជ្ជៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីមំសាដែលធូរថយខ្លាំងពេក ។

[៥២២] ម្នាលភិក្ខុទាំងឡាយ ចុះវីមំសាដែលផ្គងគំហុកខ្លាំងពេក តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ វីមំសាឯណា ប្រកបដោយឧទ្ធច្ចៈ សម្បយុត្តដោយឧទ្ធច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីមំសាដែលផ្គងគំហុកខ្លាំងពេក ។

[៥២៣] ម្នាលភិក្ខុទាំងឡាយ ចុះវីមំសាដែលរួញលឹបនៅខាងក្នុង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ វីមំសាឯណា ប្រកបដោយថីនមិទ្ធៈ សម្បយុត្តដោយថីនមិទ្ធៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីមំសាដែលរួញលឹបនៅខាងក្នុង ។

[៥២៤] ម្នាលភិក្ខុទាំងឡាយ ចុះវីមំសាដែលរាយមាយទៅខាងក្រៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ វីមំសាឯណារាយមាយទៅតាម ជាប់ទៅតាម ប្រារព្ធនូវបញ្ចកាមគុណខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វីមំសាដែលរាយមាយទៅខាងក្រៅ ។ បេ ។

៣២១

បាសាទកម្បនវគ្គោ

[៤២៥] ឯវំ ខោ ភិក្ខវេ ភិក្ខុ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ ឯវំ ភាវិតា ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ឯវំ ពហុលីកតា មហប្ផលា ហោន្តិ មហានិសំសា ។

[៤២៦] ឯវំ ភាវិតេសុ ខោ ភិក្ខវេ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៤២៧] ឯវំ ភាវិតេសុ ខោ ភិក្ខវេ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ (ឆបិ អភិញ្ញាយោ វិត្ថារេតព្វា) ។

បាសាទកម្បនវគ្គោ ទុតិយោ ។

បាសាទកម្បនវគ្គ

[៥២៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តស្ងាត់ ឥតមានកិលេសរួបរឹត ចំរើនចិត្តប្រកបដោយពន្លឺ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ដែលភិក្ខុចម្រើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះហើយ រមែងជាធម៌មានផលច្រើន មានអានិសង្សច្រើន ។

[៥២៦] ម្នាលភិក្ខុទាំងឡាយ កាលបើឥទ្ធិបាទ ៤ ដែលភិក្ខុចម្រើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះហើយ ភិក្ខុនោះរមែងបានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។

[៥២៧] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទ ៤ ដែលភិក្ខុបានចម្រើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ រមែងធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ។ (អភិញ្ញាទាំង ៦ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ) ។

ចប់ បាសាទកម្បនវគ្គ ទី ២ ។

## ឥមស្ស វគ្គស្ស ឧទ្ទានំ

បុព្វេ មហាបួលា ឆន្ទោ
មោគ្គល្លានោ ច ព្រាហ្មណោ
ទ្វេ សមណព្រាហ្មណា ភិក្ខុ[១]
ទេសនា វិភង្គេន ចាតិ ។

---

១ សមណព្រាហ្មណាបីតិបិ កត្ថចិ ទិស្សតិ ។ ម. សមណព្រាហ្មណាតិ ។

# ឧទ្ទាននៃវគ្គនោះគឺ

*និយាយអំពីបុព្វេនិវាសានុស្សតិញ្ញាណ ១ អំពីឥទ្ធិបាទមានផលច្រើន ១ អំពីឆន្ទៈ ១ អំពីព្រះមោគ្គល្លាន ១ អំពីព្រាហ្មណ៍ ១ អំពីសមណព្រាហ្មណ៍ ២ លើក អំពីភិក្ខុ ១ អំពីទេសនា ១ អំពីការចែកនូវឥទ្ធិបាទ ១ ។*

# អយោគុឡវគ្គោ

[៤២៨] សាវត្ថិយំ ។ បុព្វេ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កោ នុ ខោ មគ្គោ កា បដិបទា ឥទ្ធិបាទភាវនាយាតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ សោ ភិក្ខុ ឆន្ទស-មាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ ឆន្ទោ ន ច អតិលីនោ ភវិស្សតិ ន ច អតិប្បគ្គ-ហិតោ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តោ ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តោ ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា

# អយោគុឡវគ្គ

[៩២៨] ទៀបក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ មុនកាលត្រាស់ដឹង កាលដែលតថាគត នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា អ្វីហ្ន៎ជាមគ្គ អ្វីហ្ន៎ជាបដិបទា ដើម្បីចម្រើននូវឥទ្ធិបាទ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនោះតែងចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនឹងបធានសង្ខារដូច្នេះថា ឆន្ទៈរបស់អាត្មាអញនឹងមិនធូរថយខ្លាំងពេកផង នឹងមិនផ្គងគំហុកខ្លាំងពេកផង នឹងមិនរួញលឹបនៅខាងក្នុងផង នឹងមិនរាយមាយទៅខាងក្រៅផង មានសញ្ញាក្នុងកាលជាខាងក្រោយនិងកាលមុនផង គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ ក្រោមយ៉ាងណា លើក៏យ៉ាងនោះ លើយ៉ាងណា ក្រោមក៏យ៉ាងនោះ ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះដែរ លុះភិក្ខុនោះគិតដូច្នេះហើយ ក៏មានចិត្តស្វាង

អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។ វីរិយស-
មាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារ-
សមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ វីមំសា ន ច
អតិលីនា ភវិស្សតិ ន ច អតិប្បគ្គហិតា ភវិស្សតិ ន
ច អជ្ឈត្តំ សង្ខិត្តា ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តា
ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា
បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ
យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា
រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន
សប្បភាសំ ចិត្តំ ភាវេតិ ។

ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារដូច្នេះថា វីមំសារបស់អាត្មាអញ នឹងមិនធូរថយខ្លាំងពេកផង មិនផ្គងគំហុកខ្លាំងពេកផង មិនរួញលឹបនៅខាងក្នុងផង មិនរាយមាយទៅខាងក្រៅផង មានសញ្ញាក្នុងកាលជាខាងក្រោយនិងកាលមុនផង គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ ក្រោមយ៉ាងណា លើក៏យ៉ាងនោះ លើយ៉ាងណា ក្រោមក៏យ៉ាងនោះ ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះដែរ លុះភិក្ខុនោះគិតដូច្នេះហើយ ក៏មានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ ។

## អយោគុឡវគ្គោ

[៤២៩] ឯវំ ភាវិតេសុ ខោ ភិក្ខវេ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៤៣០] ឯវំ ភាវិតេសុ ខោ ភិក្ខវេ ភិក្ខុ ចតូសុ ឥទ្ធិបាទេសុ ឯវំ ពហុលីកតេសុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ (ឆបិ អភិញ្ញាយោ វិត្ថារេតព្វា) ។

អយោគុឡវគ្គ

[៥២៩] ម្នាលភិក្ខុទាំងឡាយ កាលបើឥទ្ធិបាទ ៤ ដែលភិក្ខុចម្រើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះហើយ ភិក្ខុរមែងបានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។

[៥៣០] ម្នាលភិក្ខុទាំងឡាយ កាលបើឥទ្ធិបាទ ៤ ដែលភិក្ខុចម្រើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះហើយ ភិក្ខុរមែងធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នហើយសម្រេចសម្រាន្តនៅ ។ (អភិញ្ញាទាំង ៦ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ) ។

[៥៣១] សាវត្ថិយំ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អភិជានាតិ នុ ខោ ភន្តេ ភគវា ឥទ្ធិយា មនោមយេន កាយេន ព្រហ្មលោកំ ឧបសង្កមិតាតិ ។ អភិជានាមិ ខ្វាហំ អានន្ទ ឥទ្ធិយា មនោមយេន កាយេន ព្រហ្មលោកំ ឧបសង្កមិតាតិ ។ អភិជានាតិ បន ភន្តេ ភគវា ឥមិនា ចាតុម្មហាភូតិកេន កាយេន ឥទ្ធិយា ព្រហ្មលោកំ ឧបសង្កមិតាតិ ។ អភិជានាមិ ខ្វាហំ អានន្ទ ឥមិនា ចាតុម្មហាភូតិកេន កាយេន ឥទ្ធិយា ព្រហ្មលោកំ ឧបសង្កមិតាតិ ។

[៥៣១] ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគធ្លាប់ចូលទៅកាន់ព្រហ្មលោក ដោយឫទ្ធិ ដោយព្រះកាលដែលសម្រេចតាមព្រះទ័យដែរឬ ទើបជ្រាបច្បាស់នូវព្រហ្មលោក ។ ម្នាលអានន្ទ តថាគតធ្លាប់ចូលទៅកាន់ព្រហ្មលោក ដោយឫទ្ធិ ដោយកាយដែលសម្រេចតាមចិត្តមែន ទើបដឹងច្បាស់នូវព្រហ្មលោក ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគ ធ្លាប់ចូលទៅកាន់ព្រហ្មលោកដោយឫទ្ធិ ដោយព្រះកាយដែលប្រកបដោយមហាភូតរូប ៤ នេះឬ ទើបជ្រាបច្បាស់នូវព្រហ្មលោក ។ ម្នាលអានន្ទ តថាគតធ្លាប់ចូលទៅកាន់ព្រហ្មលោក ដោយឫទ្ធិ ដោយកាយដែលប្រកបដោយមហាភូតរូប ៤ នេះឯង ទើបដឹងច្បាស់នូវព្រហ្មលោក ។

អយោគុឡវគ្គោ

[៥៣២] យំ ច ខោ ឥមាតិ[១] ភន្តេ ភគវា ឥទ្ធិយា មនោមយេន កាយេន ព្រហ្មលោកំ ឧបសង្កមិតា[២] យំ ច ខោ អភិជានាតិ ភន្តេ ភគវា ឥមិនា ចាតុម្មហាភូតិកេន កាយេន ឥទ្ធិយា ព្រហ្មលោកំ ឧបសង្កមិតា តយិទំ ភន្តេ ភគវតោ អច្ឆរិយញ្ចេវ អព្ភុតញ្ចាតិ ។ អច្ឆរិយា ចេវ អានន្ទ តថាគតា អច្ឆរិយធម្មសមន្នាគតា ច អព្ភុតា ចេវ អានន្ទ តថាគតា អព្ភុតធម្មសមន្នាគតា ច ។

[៥៣៣] យស្មឹ អានន្ទ សមយេ តថាគតោ កាយម្បិ ចិត្តេ សមាទហាតិ[៣] ចិត្តម្បិ កាយេ សមាទហាតិ សុខសញ្ញញ្ច លហុសញ្ញញ្ច កាយេ ឱក្កមិត្វា វិហរតិ តស្មឹ អានន្ទ សមយេ តថាគតស្ស កាយោ លហុតរោ ចេវ ហោតិ មុទុតរោ ច កម្មនិយតរោ ច បភស្សរតរោ ច ។

---

១ ឱ. ឱបបាតិ ។ ម. ឱក្កមាតិ ។ ២ ឱ. ម. ឧបសង្កមិតុំ ។ ៣ ម. សមោទហាតិ ។

## អយោគុឡវគ្គ

[៥៣២] បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ធ្លាប់ចូលទៅកាន់ព្រហ្មលោក ដោយឫទ្ធិ ដោយព្រះកាយដែលសម្រេចតាមព្រះទ័យដោយហេតុឯណា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគធ្លាប់ចូលទៅកាន់ព្រហ្មលោក ដោយឫទ្ធិ ដោយព្រះកាយ ប្រកបដោយមហាភូតរូប ៤ នេះ ជ្រាបច្បាស់នូវហេតុ ឯណា បពិត្រព្រះអង្គដ៏ចម្រើនហេតុនោះ ៗ ជាអស្ចារ្យចម្លែកណាស់របស់ព្រះដ៏មានព្រះភាគ ។ ម្នាលអានន្ទ ព្រះតថាគតទាំងឡាយ ជាអស្ចារ្យផង ប្រកបដោយធម៌ជាអស្ចារ្យផង ម្នាលអានន្ទ ព្រះតថាគតទាំងឡាយ ចម្លែកផង ប្រកបដោយធម៌ដ៏ចម្លែកផង ។

[៥៣៣] ម្នាលអានន្ទ សម័យណា តថាគត តម្កល់កាយក្នុងចិត្តផង តម្កល់ចិត្តក្នុងកាយផង ស្ងង់ចុះនូវសុខសញ្ញានឹងលហុសញ្ញាក្នុងកាយ ម្នាលអានន្ទ សម័យនោះ កាយរបស់តថាគតស្រាលដោយវិសេសផង ទន់ដោយវិសេសផង គួរដល់ការងារដោយវិសេសផង មានរស្មីដោយវិសេសផង ។

[៨៣៤] សេយ្យថាបិ អានន្ទ អយោគុឡោ ទិវសំ សន្តត្តោ លហុតរោ ចេវ ហោតិ មុទុតរោ ច កម្មនិយតរោ ច បភស្សរតរោ ច ។ ឯវមេវ ខោ អានន្ទ យស្មឹ សមយេ តថាគតោ កាយម្បិ ចិត្តេ សមាទហាតិ ចិត្តម្បិ កាយេ សមាទហាតិ សុខសញ្ញញ្ច លហុសញ្ញញ្ច កាយេ ឱក្កមិត្វា វិហរតិ តស្មឹ អានន្ទ សមយេ តថាគតស្ស កាយោ លហុតរោ ចេវ ហោតិ មុទុតរោ ច កម្មនិយតរោ ច បភស្សរតរោ ច ។

[៨៣៥] យស្មឹ អានន្ទ សមយេ តថាគតោ កាយម្បិ ចិត្តេ សមាទហាតិ ចិត្តម្បិ កាយេ សមាទហាតិ សុខសញ្ញញ្ច លហុសញ្ញញ្ច កាយេ ឱក្កមិត្វា វិហរតិ តស្មឹ អានន្ទ សមយេ តថាគតស្ស កាយោ អប្បកសិរេនេវ បថវិយា វេហាសំ អព្ភុគ្គច្ឆតិ ។ សោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៩៣៤] ម្នាលអានន្ទ ដុំដែកដែលក្តៅសព្វ អស់មួយថ្ងៃ ជាដុំដែកស្រាលដោយវិសេសផង ទន់ដោយវិសេសផង គួរដល់ការងារដោយវិសេសផង មានពន្លឺផ្លេក ៗ ដោយវិសេសផង ដូចម្តេចមិញ ។ ម្នាលអានន្ទ សម័យណា តថាគត តម្កល់កាយក្នុងចិត្តផង តម្កល់ចិត្តក្នុងកាយផង ស្ងង់ចុះនូវសុខសញ្ញានឹងលហុសញ្ញាក្នុងកាយ ម្នាលអានន្ទ សម័យនោះ កាយរបស់តថាគត ស្រាលដោយវិសេសផង ទន់ដោយវិសេសផង គួរដល់ការងារដោយវិសេសផង មានពន្លឺផ្លេក ៗ ដោយវិសេសផង ក៏ដូច្នោះឯង ។

[៩៣៥] ម្នាលអានន្ទ សម័យណា តថាគត តម្កល់កាយក្នុងចិត្តផង តម្កល់ចិត្តក្នុងកាយផង ស្ងង់ចុះនូវសុខសញ្ញានឹងលហុសញ្ញាក្នុងកាយ ម្នាលអានន្ទ សម័យនោះ កាយរបស់តថាគតអណ្តែតអំពីផែនដីទៅកាន់អាកាស ដោយឥតលំបាកសោះ ។ តថាគតនោះ តែងបានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។

៣២៩

អយោគុឡវគ្គោ

[៨៣៦] សេយ្យថាបិ អានន្ទ តូលបិចុ វា កប្បា-
សបិចុ វា លហុកោ ជាតុចាបាតោ អប្បកសិរេនេវ
បឋវិយា វេហាសំ អព្ភុគ្គច្ឆតិ ។ ឯវមេវ ខោ អានន្ទ
យស្មឹ សមយេ តថាគតោ កាយម្បិ ចិត្តេ សមា-
ទហតិ ចិត្តម្បិ កាយេ សមាទហតិ សុខសញ្ញញ្ច
លហុសញ្ញញ្ច កាយេ ឱក្កមិត្វា វិហរតិ ។ បេ ។

[៨៣៧] តស្មឹ អានន្ទ សមយេ តថាគតស្ស
កាយោ អប្បកសិរេនេវ បឋវិយា វេហាសំ អព្ភុគ្គច្ឆតិ ។
សោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា
ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។
យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតីតិ ។

[៨៣៨] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ។ កតមេ
ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារ-
សមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តស-
មាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-
បាទំ ភាវេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ។

អយោគុឡវគ្គ

[៩៣៦] ម្នាលអានន្ទ ប៉ុយគរឬប៉ុយកប្បាស ដ៏ស្រាលមានធាតុជាជើងទ្រ អណ្តែតអំពីផែនដីទៅកាន់អាកាស ដោយឥតលំបាកសោះ ដូចម្តេចមិញ ។ ម្នាលអានន្ទ សម័យណា តថាគតតម្កល់កាយក្នុងចិត្តផង តម្កល់ចិត្តក្នុងកាយផង ស្ទង់ចុះនូវសុខសញ្ញានឹងលហុសញ្ញាក្នុងកាយ ។ បេ ។ ក៏ដូច្នោះឯង ។

[៩៣៧] ម្នាលអានន្ទ សម័យនោះ កាយរបស់តថាគតអណ្តែតអំពីផែនដីទៅកាន់អាកាស ដោយឥតលំបាកនោះ ។ តថាគតនោះតែងបានសម្រេចនូវឥទ្ធិវិធៈច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។

[៩៣៨] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទនេះមាន ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទមាន ៤ នេះឯង ។

[៤៣៩] ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៤៤០] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ។

[៤៦១] ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។

[៥៣៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ក៏ព្រោះតែបានចម្រើន បានធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។

[៥៤០] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទនេះមាន ៤ ។ ឥទ្ធិបាទ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ១ ។ វិរិយសមាធិ១ ។ ចិត្តសមាធិ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទមាន ៤ នេះឯង ។

[៥៤១] ម្នាលភិក្ខុទាំងឡាយ បណ្ដាផលទាំង២ ផលណាមួយរមែងកើតឡើងប្រាកដ (ដល់ភិក្ខុ) គឺអរហត្តផលកើតប្រាកដក្នុងបច្ចុប្បន្ន ឬកាលបើឧបាទាននៅមានសេសសល់នៅឡើយ ក៏គង់អនាគាមិផលកើតឡើងប្រាកដដែរ ព្រោះតែបានចម្រើន បានធ្វើឲ្យច្រើននូវឥទ្ធិបាទ៤ នេះឯង ។

អយោគុឡវគ្គោ

[៤៤២] ចត្តារោមេ ភិក្ខវេ ឥទ្ធិបាទា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ឥទ្ធិបាទា ។

[៤៤៣] ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា សត្តផលា សត្តានិសំសា បាដិកង្ខា ។ កតមេ សត្តផលា សត្តានិសំសា ។ ទិដ្ឋេវ ធម្មេ បដិកច្ច(១) អញ្ញំ អារាធេតិ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ អថ មរណកាលេ អញ្ញំ អារាធេតិ នោ ចេ ទិដ្ឋេវ ធម្មេ បដិកច្ច អញ្ញំ អារាធេតិ នោ ចេ មរណកាលេ អញ្ញំ អារាធេតិ អថ

១ ឱ. បដិហច្ច ។

អយោគុឡវគ្គ

[៥៤២] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទនេះមាន ៤ ។ ឥទ្ធិបាទ ៤ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិ-បាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វិរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធាន-សង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥទ្ធិបាទមាន ៤ នេះឯង ។

[៥៤៣] ម្នាលភិក្ខុទាំងឡាយ ផល ៧ ប្រការ អានិសង្ស ៧ ប្រការ រមែងកើតប្រាកដ ព្រោះបានចម្រើន បានធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។ ផល ៧ ប្រការ អានិសង្ស ៧ ប្រការ ដូចម្ដេចខ្លះ ។ គឺបាន សម្រេច អរហត្តផលយ៉ាងឆាប់ ក្នុងបច្ចុប្បន្ន បើមិនបានសម្រេចអរហត្ត-ផលយ៉ាងឆាប់ក្នុងបច្ចុប្បន្នទេ គង់បានសម្រេចអរហត្តផលក្នុងមរណកាល ដែរ បើមិនបានសម្រេចអរហត្តផលយ៉ាងឆាប់ ក្នុងបច្ចុប្បន្នទេ បើមិន បានសម្រេចអរហត្តផល ក្នុងមរណកាលទេ ក៏គង់ក្នុងកាលជាខាងក្រោយ

បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្ត-
រាបរិនិព្វាយី ហោតិ ឧបហច្ចបរិនិព្វាយី ហោតិ អ-
សង្ខារបរិនិព្វាយី ហោតិ សសង្ខារបរិនិព្វាយី ហោតិ
ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។ ឥមេសំ ខោ
ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា
ឥមេ សត្ត ផលា សត្តានិសំសា បាដិកង្ខាតិ ។

[៨៤៤] សាវត្ថីនិទានំ ។ អថខោ អាយស្មា
អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច
កតមា នុ ខោ ភន្តេ ឥទ្ធិ កតមោ ឥទ្ធិបាទោ
កតមា ឥទ្ធិបាទភាវនា កតមា ឥទ្ធិបាទភាវនាគាមិនី
បដិបទាតិ ។

នឹងជាអន្តរាបរិនិព្វាយី ជាឧបហច្ចបរិនិព្វាយី ជាអសង្ខារបរិនិព្វាយី ជាសសង្ខារបរិនិព្វាយី ឬជាឧទ្ធំសោតអកនិដ្ឋគាមីមិនខាន ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ផល ៧ ប្រការ អានិសង្ស ៧ ប្រការនេះ រមែងកើតប្រាកដ ព្រោះបានចម្រើន បានធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។

[៥៤៤] សាវត្ថីនិទាន ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ដូចម្តេចហៅថា ឥទ្ធិ (ឫទ្ធិ) ដូចម្តេចហៅថា ឥទ្ធិបាទ ដូចម្តេចហៅថា ការចម្រើនឥទ្ធិបាទ ដូចម្តេចហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។

៣៣៣

អយោគុឡវគ្គោ

[៥៤៥] ឥធានន្ទ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ អយំ វុច្ចតានន្ទ ឥទ្ធិ ។

[៥៤៦] កតមោ ចានន្ទ ឥទ្ធិបាទោ ។ យោ អានន្ទ មគ្គោ យា បដិបទា ឥទ្ធិលាភាយ ឥទ្ធិប្បដិ-លាភាយ សំវត្តតិ ។ អយំ វុច្ចតានន្ទ ឥទ្ធិបាទោ ។

[៥៤៧] កតមា ចានន្ទ ឥទ្ធិបាទភាវនា ។ ឥធា-នន្ទ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-បាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសា-សមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតានន្ទ ឥទ្ធិបាទភាវនា ។

អយោគុឡវគ្គ

[៩៤៥] ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ បានសម្រេចនូវឥទ្ធិវិធៈ (ការសម្តែងឫទ្ធិ) ច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលអានន្ទ នេះហៅថា ឥទ្ធិ(ឫទ្ធិ) ។

[៩៤៦] ម្នាលអានន្ទ ចុះឥទ្ធិបាទ តើដូចម្តេច ។ ម្នាលអានន្ទ មគ្គឯណា បដិបទាឯណា ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ។ ម្នាលអានន្ទ នេះហៅថា ឥទ្ធិបាទ ។

[៩៤៧] ម្នាលអានន្ទ ចុះការចម្រើនឥទ្ធិបាទតើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនឹងបធានសង្ខារ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលអានន្ទ នេះហៅថា ការចម្រើនឥទ្ធិបាទ ។

[៤៤៨] កតមា ចានន្ទ ឥទ្ធិបាទភាវនាគាមិនី បដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ វុច្ចតានន្ទ ឥទ្ធិបាទភាវនាគាមិនី បដិបទាតិ ។

[៤៤៩] ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច កតមា នុ ខោ អានន្ទ ឥទ្ធិ កតមោ ឥទ្ធិបាទោ កតមា ឥទ្ធិបាទភាវនា កតមា ឥទ្ធិបាទភាវនាគាមិនី បដិបទាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ។ បេ ។

៤៥០ ឥធានន្ទ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ អយំ វុច្ចតានន្ទ ឥទ្ធិ ។

[៥៤៨] ម្នាលអានន្ទ ចុះបដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ។ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអានន្ទ នេះហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។

[៥៤៩] លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ដូចម្តេចហៅថា ឥទ្ធិ ដូចម្តេចហៅថា ឥទ្ធិបាទ ដូចម្តេចហៅថា ការចម្រើនឥទ្ធិបាទ ដូចម្តេចហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ ។ បេ ។

[៥៥០] ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ បានសម្រេចនូវឥទ្ធិវិធ: (ការសម្តែងឫទ្ធិ) ច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលអានន្ទ នេះហៅថា ឥទ្ធិ ។

៣៣៨

អយោគុឡវគ្គោ

[៨៨១] កតមោ ចានន្ទ ឥទ្ធិបាទោ ។ យោ អានន្ទ មគ្គោ យា បដិបទា ឥទ្ធិលាភាយ ឥទ្ធិប្បដិលាភាយ សំវត្តតិ ។ អយំ វុច្ចតានន្ទ ឥទ្ធិបាទោ ។

[៨៨២] កតមា ចានន្ទ ឥទ្ធិបាទភាវនា ។ ឥធានន្ទ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតានន្ទ ឥទ្ធិបាទភាវនា ។

[៨៨៣] កតមា ចានន្ទ ឥទ្ធិបាទភាវនាគាមិនី បដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ វុច្ចតានន្ទ ឥទ្ធិបាទភាវនាគាមិនី បដិបទាតិ ។

អយោគុឡវគ្គ

[៥៥១] ម្នាលអានន្ទ ចុះឥទ្ធិបាទ តើដូចម្តេច ។ ម្នាលអានន្ទ មគ្គឯណា បដិបទាឯណា ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ដើម្បីបាន ចំពោះនូវឫទ្ធិ ។ ម្នាលអានន្ទ នេះហៅថា ឥទ្ធិបាទ ។

[៥៥២] ម្នាលអានន្ទ ចុះការចម្រើនឥទ្ធិបាទ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទ-សមាធិនិងបធានសង្ខារ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើន ឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលអានន្ទ នេះហៅថា ការចម្រើនឥទ្ធិបាទ ។

[៥៥៣] ម្នាលអានន្ទ ចុះបដិបទាជាដំណើរទៅកាន់ការចម្រើន ឥទ្ធិបាទ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលអានន្ទ នេះហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។

[៨៨៤] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ កតមា នុ ខោ ភន្តេ ឥទ្ធិ កតមោ ឥទ្ធិបាទោ កតមា ឥទ្ធិបាទភាវនា កតមា ឥទ្ធិបាទភាវនាគាមិនី បដិបទាតិ ។

[៨៨៥] ឥធ ភិក្ខវេ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិ ។

[៨៨៦] កតមោ ច ភិក្ខវេ ឥទ្ធិបាទោ ។ យោ ភិក្ខវេ មគ្គោ បដិបទា ឥទ្ធិលាភាយ ឥទ្ធិប្បដិលាភាយ សំវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទោ ។

[៩៩៤] គ្រានោះឯង ភិក្ខុច្រើនរូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ដូចម្តេចហៅថា ឥទ្ធិ ដូចម្តេចហៅថា ឥទ្ធិបាទ ដូចម្តេចហៅថា ការចម្រើនឥទ្ធិបាទ ដូចម្តេចហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។

[៩៩៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានសម្រេចនូវឥទ្ធិវិធៈ (ការសម្តែងឫទ្ធិ) ច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិ ។

[៩៩៦] ម្នាលភិក្ខុទាំងឡាយ ចុះឥទ្ធិបាទ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មគ្គឯណា បដិបទាឯណា ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិដើម្បីបានចំពោះនូវឫទ្ធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទ ។

៣៣៧

អយោគុឡវគ្គោ

[៤៨៧] កតមា ច ភិក្ខវេ ឥទ្ធិបាទភាវនា ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទភាវនា ។

[៤៨៨] កតមា ច ភិក្ខវេ ឥទ្ធិបាទភាវនាគាមិនី បដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទភាវនាគាមិនី បដិបទាតិ ។

[៤៨៩] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា ។ បេ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច កតមា នុ ខោ ភិក្ខវេ ឥទ្ធិ កតមោ ឥទ្ធិបាទោ កតមា ឥទ្ធិបាទភាវនា កតមា ឥទ្ធិបាទភាវនាគាមិនី បដិបទាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ។ បេ ។

អយោគុឡវគ្គ

[៥៥៧] ម្នាលភិក្ខុទាំងឡាយ ចុះការចម្រើនឥទ្ធិបាទ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការចម្រើនឥទ្ធិបាទ ។

[៥៥៨] ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ តើដូចម្ដេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។

[៥៥៩] គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា ឥទ្ធិ ដូចម្ដេចហៅថា ឥទ្ធិបាទ ដូចម្ដេចហៅថា ការចម្រើនឥទ្ធិបាទ ដូចម្ដេចហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ ។ បេ ។

[៨៦០] កតមា ច ភិក្ខវេ ឥទ្ធិ ។ ឥធ ភិក្ខវេ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិ ។

[៨៦១] កតមោ ច ភិក្ខវេ ឥទ្ធិបាទោ ។ យោ ភិក្ខវេ មគ្គោ យា បដិបទា ឥទ្ធិលាភាយ ឥទ្ធិប្បដិលាភាយ សំវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទោ ។

[៨៦២] កតមា ច ភិក្ខវេ ឥទ្ធិបាទភាវនា ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វិរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទភាវនា ។

[៦៦០] ម្នាលភិក្ខុទាំងឡាយ ចុះឥទ្ធិតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានសម្រេចនូវឥទ្ធិវិធៈ (ការសម្តែងឫទ្ធិ) ច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលភិក្ខុទាំង-ឡាយនេះហៅថាឥទ្ធិ ។

[៦៦១] ម្នាលភិក្ខុទាំងឡាយ ចុះឥទ្ធិបាទតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មគ្គឯណា បដិបទាឯណា ដែលប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាឥទ្ធិបាទ ។

[៦៦២] ម្នាលភិក្ខុទាំងឡាយ ចុះការចម្រើននូវឥទ្ធិបាទ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទប្រកបដោយឆន្ទសមាធិនឹងបធានសង្ខារ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាការចម្រើនឥទ្ធិបាទ ។

អយោគុឡវគ្គោ

[៤៦៣] កតមា ច ភិក្ខវេ ឥទ្ធិបាទភាវនាគាមិនី-
បដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។
សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។
អយំ វុច្ចតិ ភិក្ខវេ ឥទ្ធិបាទភាវនាគាមិនីបដិបទាតិ ។

[៤៦៤] តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ តំ
កឹ មញ្ញថ ភិក្ខវេ កតមេសំ ធម្មានំ ភាវិតត្តា ពហុ-
លីកតត្តា មោគ្គល្លានោ ភិក្ខុ ឯវំមហិទ្ធិកោ ឯវំមហា-
នុភាវោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេ-
ត្តិកា ។ បេ ។

[៤៦៥] ចតុន្នំ ខោ ភិក្ខវេ ឥទ្ធិបាទានំ ភាវិតត្តា
ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ ឯវំមហិទ្ធិកោ ឯវំម-
ហានុភាវោ ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ មោគ្គល្លា-
នោ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-
បាទំ ភាវេតិ ឥតិ មេ ឆន្ទោ ន ច អតិលីនោ ភវិស្សតិ

អយោគុឡវគ្គ

[៩៦៣] ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ ។

[៩៦៤] ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់សេចក្តីនោះដូចម្តេច មោគ្គល្លានភិក្ខុមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវធម៌ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ ។ បេ ។

[៩៦៥] ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានភិក្ខុមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ព្រោះបានចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មោគ្គល្លានភិក្ខុចម្រើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនឹងបធានសង្ខារដូច្នេះថា ឆន្ទៈរបស់អាត្មាអញនឹងមិនធូរថយខ្លាំងពេកផង

ន ច អតិប្បគ្គហិតោ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តោ ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តោ ភវិស្សតិ បច្ឆាបុរេសញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភា-វេតិ ។ វិរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្ប-ធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ វីមំ-សា ន ច អតិលីនា ភវិស្សតិ ន ច អតិប្បគ្គហិតា ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តា ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តា ភវិស្សតិ ។ បេ ។ ឥតិ វិវដេន ចេតសា អបរិ-យោនទ្ធេន សប្បភាសំ ចិត្តំ ។ ភាវេតិ ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ ។

នឹងមិនផ្គងគហុកខ្លាំងពេកផង នឹងមិនរួញលីបនៅខាងក្នុងផង នឹងមិនរាយមាយទៅខាងក្រៅផង មានសញ្ញាក្នុងកាលក្រោយនិងមុនផង គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ ក្រោមយ៉ាងណា លើក៏យ៉ាងនោះ លើយ៉ាងណា ក្រោមក៏យ៉ាងនោះ ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ លុះមោគ្គល្លានភិក្ខុគិតដូច្នេះហើយ ក៏មានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ ។ វិរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារដូច្នេះថា វីមំសារបស់អាត្មាអញនឹងមិនធូរថយខ្លាំងពេកផង នឹងមិនផ្គងគំហុកខ្លាំងពេកផង នឹងមិនរួញលីបនៅខាងក្នុងផង នឹងមិនរាយមាយទៅខាងក្រៅផង ។ បេ ។ លុះមោគ្គល្លានភិក្ខុគិតដូច្នេះហើយ ក៏មានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានភិក្ខុមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ នេះឯង ។

អយោគុឡវគ្គោ

[៤៦៦] ឥមេសញ្ច បន ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ ឯវំ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៤៦៧] ឥមេសញ្ច បន ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា មោគ្គល្លានោ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៤៦៨] តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ កតមេសំ ធម្មានំ ភាវិតត្តា ពហុលីកតត្តា តថាគតោ ឯវំមហិទ្ធិកោ ឯវំមហានុភាវោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ បេ ។

អយោគុឡវគ្គ

[៥៦៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត មោគ្គល្លានភិក្ខុបាន សម្រេចនូវឥទ្ធិវិធៈ (ការសម្តែងឫទ្ធិ) ច្រើនប្រការយ៉ាងនេះ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជា មនុស្សម្នាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាប ដល់ព្រហ្មលោកក៏បាន ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវឥទ្ធិបាទ ៤ នេះឯង ។

[៥៦៧] ម្នាលភិក្ខុទាំងឡាយ មួយទៀត មោគ្គល្លានភិក្ខុបាន ធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុង បច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវ ឥទ្ធិបាទ ៤ នេះឯង ។

[៥៦៨] ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងពួក ភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់សេចក្តីនោះដូចម្តេចព្រះ តថាគតមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ព្រោះតែ ចម្រើន ធ្វើឲ្យច្រើន នូវធម៌ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំង-ឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល ។ បេ ។

[៤៦៩] ចតុន្នំ ខោ ភិក្ខវេ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា តថាគតោ ឯវំមហិទ្ធិកោ ឯវំមហានុ-ភាវោ ។ កតមេសំ ចតុន្នំ ។ ឥធ ភិក្ខវេ តថាគតោ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ ឆន្ទោ ន ច អតិលីនោ ភវិស្សតិ ន ច អតិប្ប-គ្គហិតោ ភវិស្សតិ ន ច អជ្ឈត្តំ សង្ខិត្តោ ភវិស្សតិ ន ច ពហិទ្ធា វិក្ខិត្តោ ភវិស្សតិ បច្ឆាបុរេ សញ្ញី ច វិហរតិ យថា បុរេ តថា បច្ឆា យថា បច្ឆា តថា បុរេ យថា អធោ តថា ឧទ្ធំ យថា ឧទ្ធំ តថា អធោ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធាន-សង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥតិ មេ វីមំសា ន ច អតិលីនា ភវិស្សតិ ន ច អតិប្បគ្គហិតា ភវិស្សតិ ។ បេ ។ ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន

[៩៦៩] ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនោះ ព្រោះតែចម្រើនធ្វើឲ្យច្រើន នូវឥទ្ធិបាទ៤ ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ព្រះតថាគត ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារដូច្នេះថា ឆន្ទៈរបស់អាត្មាអញនឹងមិនធូរថយខ្លាំងពេកផង នឹងមិនផ្គងគំហុកខ្លាំងពេកផង នឹងមិនរួញលីបនៅខាងក្នុងផង នឹងមិនរាយមាយទៅខាងក្រៅផង មានសញ្ញាក្នុងកាលក្រោយនិងមុនផង គឺកាលមុនយ៉ាងណា ក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ ក្រោមយ៉ាងណា លើក៏យ៉ាងនោះ លើយ៉ាងណា ក្រោមក៏យ៉ាងនោះ ថ្ងៃយ៉ាងណា យប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ លុះព្រះតថាគតទ្រង់គិតដូច្នេះហើយ ក៏មានចិត្តស្វាង ឥតមានកិលេសរួបរឹត ចម្រើនចិត្តប្រកបដោយពន្លឺ១ ។ វីរិយសមាធិ១ ។ ចិត្តសមាធិ១ ។ ចម្រើនឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារដូច្នេះថា វីមំសារបស់អាត្មាអញនឹងមិនធូរថយខ្លាំងពេកផងនឹងមិនផ្គង គំហុកខ្លាំងពេកផង ។ បេ ។ លុះព្រះតថាគតទ្រង់គិតដូច្នេះហើយ ក៏មានចិត្តស្វាង ឥតមានកិលេសរួបរឹត

សព្បកាសំ ចិត្តំ ភាវេតិ ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា តថា-គតោ ។ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ ។

[៤៧០] ឥមេសញ្ច បន ភិក្ខវេ ចតុន្នំ ឥទ្ធិបា-ទានំ ភាវិតត្តា ពហុលីកតត្តា តថាគតោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[៤៧១] ឥមេសញ្ច បន ភិក្ខវេ ចតុន្នំ ឥទ្ធិបា-ទានំ ភាវិតត្តា ពហុលីកតត្តា តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ (ឆបិ អភិញ្ញាយោ វិត្ថារេតព្វា) ។

អយោគុឡវគ្គោ តតិយោ ។

ចម្រើនចិត្តប្រកបដោយពន្លឺ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវឥទ្ធិបាទ ៤ នេះឯង ។

[៩៧០] ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតបានសម្រេចនូវឥទ្ធិវិធៈ (ការសម្តែងឫទ្ធិ) ច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវឥទ្ធិបាទ ៤ នេះឯង ។

[៩៧១] ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់សម្រេច នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវឥទ្ធិបាទ ៤ នេះឯង ។ (អភិញ្ញាទាំង ៦ បណ្ឌិតគប្បីឲ្យពិស្តារ) ។

ចប់ អយោគុឡវគ្គ ទី ៣ ។

# តស្សុទ្ទានំ

មគ្គោ អយោគុឡោ ភិក្ខុ

សុទ្ធកញ្ច ទ្វេ ផលា អានន្ទា[១]

ទ្វេ វុត្តា ភិក្ខូហិ អបរេ ទ្វេ

មោគ្គល្លានោ តថាគតោតិ ។

១ ឱ. ម. អានន្ទោ ។

សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ

# ឧទ្ទាននៃអយោគុឡវគ្គនោះគឺ

*និយាយអំពីមគ្គ ១ អំពីកាយប្រៀបដូចដុំដែក ១ អំពីភិក្ខុចម្រើនឥទ្ធិបាទ ១ អំពីផលសុទ្ធមាន ២ លើក អំពីព្រះអានន្ទមាន ២ លើក អំពីពួកភិក្ខុដទៃមាន ២ លើក អំពីព្រះមោគ្គល្លាន ១ អំពីព្រះតថាគត ១ ។*

# ឥទ្ធិបាទសំយុត្តស្ស គង្គាទិបេយ្យាលោ

[៤៧២] សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចី-
ននិន្នា បាចីនបោណា បាចីនបព្ភារា ។ ឯវមេវ ខោ
ភិក្ខវេ ភិក្ខុ ចត្តារោ ឥទ្ធិបាទេ ភាវេន្តោ ចត្តារោ
ឥទ្ធិបាទេ ពហុលីករោន្តោ និព្វាននិន្នោ ហោតិ និព្វាន-
បោណោ និព្វានបព្ភារោ ។

[៤៧៣] កថញ្ច ភិក្ខវេ ភិក្ខុ ចត្តារោ ឥទ្ធិ-
បាទេ ភាវេន្តោ ចត្តារោ ឥទ្ធិបាទេ ពហុលីករោន្តោ
និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភា-
រោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខា-
រសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។
ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ
ឥទ្ធិបាទំ ភាវេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ចត្តារោ
ឥទ្ធិបាទេ ភាវេន្តោ ចត្តារោ ឥទ្ធិបាទេ ពហុលីករោន្តោ
និព្វាននិន្នោ ហោតិ និព្វានបោណោ និព្វានបព្ភារោ-
តិ ។ (យាវ ឯសនា បាលិ ឥទ្ធិបាទេសុ វិត្ថារេតព្វា) ។

# ឥទ្ធិបាទសំយុត្ត គង្គាទិបេយ្យាល

[៥៧២] ម្នាលភិក្ខុទាំងឡាយ ទន្លេគង្គាមានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើត យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើននូវឥទ្ធិបាទ ៤ ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនោះដែរ ។

[៥៧៣] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលចម្រើននូវឥទ្ធិបាទ ៤ ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនឹងបធានសង្ខារ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ ចម្រើននូវឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលចម្រើននូវឥទ្ធិបាទ ៤ ធ្វើឲ្យច្រើននូវឥទ្ធិបាទ ៤ រមែងមានទំនាបទៅរកព្រះនិព្វាន មានជម្រាលទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន យ៉ាងនេះឯង ។ (បាលីសម្តែងអំពីការស្វែងរក បណ្ឌិតគប្បីឲ្យពិស្តារដូចក្នុងឥទ្ធិបាទចុះ) ។

[៩៧៤] បញ្ចិមានិ ភិក្ខវេ ឧទ្ធម្ភាគិយានិ សញ្ញោជនានិ ។ កតមានិ បញ្ច ។ រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា ។ ឥមានិ ខោ ភិក្ខវេ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ ។

[៩៧៥] ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ចត្តារោ ឥទ្ធិបាទា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយសមាធិ ។ ចិត្តសមាធិ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥមេសំ ខោ ភិក្ខវេ បញ្ចន្នំ ឧទ្ធម្ភាគិយានំ សញ្ញោជនានំ អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ឥមេ ចត្តារោ ឥទ្ធិបាទា ភាវេតព្វាតិ ។ (យថា មគ្គសំយុត្តំ វិត្ថារិតំ ឯវំ គង្គាបេយ្យាលោ យាវ ឯសនា បាលិ ឥទ្ធិបាទេសុ វិត្ថារេតព្វា) ។ គង្គានិបេយ្យាលោ ចតុត្ថោ ។

ឥទ្ធិបាទសំយុត្តំ និដ្ឋិតំ ។

[៩៧២] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើនេះមាន៥ ។ សញ្ញោជនៈ ៥ ដូចម្តេចខ្លះ ។ គឺរូបរាគៈ១ អរូបរាគៈ១ មានៈ១ ឧទ្ធច្ចៈ១ អវិជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈជាចំណែកខាងលើមាន ៥ នេះឯង ។

[៩៧៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចម្រើននូវឥទ្ធិបាទ ៤ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោ-ជនៈជាចំណែកខាងលើ ៥ នេះឯង ។ ឥទ្ធិបាទ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ។ វីរិយសមាធិ ១ ។ ចិត្តសមាធិ ១ ។ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីចម្រើននូវឥទ្ធិបាទ ៤ នេះ ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ នូវសញ្ញោជនៈ ជាចំណែកខាងលើ ៥ នេះឯង ។ (មគ្គសំយុត្ត ដែលឱ្យពិស្តារហើយយ៉ាងណា គង្គាបេយ្យាលៈក៏យ៉ាងនោះ បាលីសម្តែងអំពីការស្វែងរក បណ្ឌិតគប្បីឱ្យពិស្តារដូចក្នុងឥទ្ធិបាទចុះ)។ ចប់ គង្គាទិបេយ្យលៈទី ៤ ។

ចប់ ឥទ្ធិបាទសំយុត្ត ។

# អនុរុទ្ធសំយុត្តំ

## រហោគតវគ្គោ

[៨៧៦] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា អនុរុទ្ធោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មតោ អនុរុទ្ធស្ស រហោគ-តស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបា-ទិ យេសំ កេសញ្ចិ ចត្តារោ សតិប្បដ្ឋានា វិរទ្ធា វិរទ្ធោ តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមី យេសំ កេសញ្ចិ ចត្តារោ សតិប្បដ្ឋានា អារទ្ធា អារទ្ធោ តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមីតិ ។

[៨៧៧] អថខោ អាយស្មា មហាមោគ្គល្លានោ អា-យស្មតោ អនុរុទ្ធស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ អាយស្មតោ អនុរុទ្ធស្ស សម្មុខេ បាតុរហោសិ ។ អថ-ខោ អាយស្មា មហាមោគ្គល្លានោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច កិត្តាវតា នុ ខោ អាវុសោ អនុរុទ្ធ ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា អារទ្ធា ហោន្តីតិ ។

# អនុរុទ្ធសំយុត្ត

## រហោគតវគ្គ

[៩៧៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអនុរុទ្ធដ៏មានអាយុ សម្ងំនៅក្នុងទីស្ងាត់ កើតបរិវិតក្កក្នុងចិត្តយ៉ាងនេះថា ភិក្ខុទាំងឡាយឯណានីមួយ បោះបង់សតិប្បដ្ឋានទាំង ៤ ភិក្ខុទាំងនោះឈ្មោះថា បោះបង់មគ្គដ៏ប្រសើរ ជាដំណើរទៅកាន់ទីអស់ទុក្ខដោយប្រពៃ ភិក្ខុទាំងឡាយឯណានីមួយ ធ្វើនូវសតិប្បដ្ឋានទាំង៤ឱ្យបរិបូណ៌ ភិក្ខុទាំងនោះឈ្មោះថា ធ្វើនូវអរិយមគ្គជាដំណើរទៅកាន់ទីអស់ទុក្ខដោយប្រពៃឲ្យបរិបូណ៌ ។

[៩៧៧] គ្រានោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ ដឹងនូវបរិវិតក្កក្នុងចិត្តរបស់ព្រះអនុរុទ្ធដ៏មានអាយុ ដោយចិត្តហើយ ក៏មកប្រាកដក្នុងទីចំពោះមុខព្រះអនុរុទ្ធដ៏មានអាយុភ្លាម ដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ដៃដែលលាចេញ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ សួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ម្នាលអាវុសោអនុរុទ្ធ ចុះភិក្ខុធ្វើសតិប្បដ្ឋានទាំង ៤ ឲ្យបរិបូណ៌ដូចម្តេចទៅ ។

[៩៧៨] ឥធាវុសោ ភិក្ខុ អជ្ឈត្តំ កាយេ សមុទយធម្មានុបស្សី វិហរតិ ។ បេ ។ អជ្ឈត្តំ កាយេ វយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តំ កាយេ សមុទយវយធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ពហិទ្ធា កាយេ សមុទយធម្មានុបស្សី វិហរតិ ។ បេ ។ ពហិទ្ធា កាយេ វយធម្មានុបស្សី វិហរតិ ។ ពហិទ្ធា កាយេ សមុទយវយធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អជ្ឈត្តពហិទ្ធា កាយេ សមុទយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា កាយេ វយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា កាយេ សមុទយវយធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[៥៧៨] ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញធម៌ដែលកើតឡើងក្នុងកាខាងក្នុង ។ បេ ។ ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងកាយខាងក្នុង ។ ពិចារណាឃើញទាំងធម៌ដែលកើតឡើងនឹងសូន្យទៅក្នុងកាយខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញធម៌ដែលកើតឡើងក្នុងកាយខាងក្រៅ ។ បេ ។ ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងកាយខាងក្រៅ ។ ពិចារណាឃើញទាំងធម៌ដែលកើតឡើងនិងសូន្យទៅក្នុងកាយខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញធម៌ដែលកើតឡើងក្នុងកាយទាំងខាងក្នុងទាំងខាងក្រៅ ។ ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងកាយទាំងខាងក្នុងទាំងខាងក្រៅ ។ ពិចារណាឃើញទាំងធម៌ដែលកើតឡើងនិងសូន្យទៅក្នុងកាយ ទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ។

រហោគតវគ្គោ

[៤៧៩] សោ សចេ អាកង្ខតិ អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ បដិកូលេ អប្បដិកូលសញ្ញី វិហរេយ្យន្តិ អប្បដិកូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិកូលេ ច បដិកូលេ ច បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ បដិកូលេ ច អប្បដិកូលេ ច អប្បដិកូលសញ្ញី វិហរេយ្យន្តិ អប្បដិកូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិកូលញ្ច បដិកូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ ។

[៥៧៩] បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីមានដបិកូលសញ្ញាក្នុងកាយមិនគួរបដិកូល ដូច្នេះ ឈ្មោះថា មានបដិកូលសញ្ញាក្នុងកាយនោះ ។ បើប្រាថ្នាថា អាត្មាអញមិនគប្បីមានបដិកូលសញ្ញាក្នុងកាយដែលគួរបដិកូល ដូច្នេះ ឈ្មោះថា មិនមានបដិកូលសញ្ញាក្នុងកាយនោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីមានបដិកូលសញ្ញាក្នុងកាយមិនគួរបដិកូលផង ក្នុងកាយគួរបដិកូលផង ដូច្នេះ ឈ្មោះថា មានបដិកូល-សញ្ញាក្នុងកាយនោះ ។ បើប្រាថ្នាថា អាត្មាអញមិនគប្បីមានបដិកូល-សញ្ញាក្នុងកាយគួរបដិកូលផង មិនគួរបដិកូលផង ដូច្នេះ ឈ្មោះថា មិនមានបដិកូលសញ្ញាក្នុងកាយនោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីវៀរឲ្យផុតនូវកាយទាំងពីរ គឺទាំងកាយមិនគួរបដិកូល នឹងកាយគួរបដិកូលនោះចេញហើយ ជាអ្នកមានឧបេក្ខា មានសតិសម្បជញ្ញៈ ដូច្នេះ ឈ្មោះថា មានឧបេក្ខាមានសតិសម្បជញ្ញៈក្នុងកាយនោះ ។

[៥៨០] អជ្ឈត្តំ វេទនាសុ សមុទយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តំ វេទនាសុ វយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តំ វេទនាសុ សមុទយវយធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ពហិទ្ធា វេទនាសុ សមុទយធម្មានុបស្សី វិហរតិ ។ ពហិទ្ធា វេទនាសុ វយធម្មានុបស្សី វិហរតិ ។ ពហិទ្ធា វេទនាសុ សមុទយវយធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អជ្ឈត្តពហិទ្ធា វេទនាសុ សមុទយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា វេទនាសុ វយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា វេទនាសុ សមុទយវយធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[៥៨០] ពិចារណាឃើញធម៌ដែលកើតឡើង ក្នុងវេទនាទាំងឡាយខាងក្នុង ។ ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយខាងក្នុង ។ ពិចារណាឃើញទាំងធម៌ដែលកើតឡើងនិងសូន្យទៅក្នុងវេទនាទាំងឡាយខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញធម៌ដែលកើតឡើង ក្នុងវេទនាទាំងឡាយខាងក្រៅ ។ ពិចារណាឃើញធម៌ដែលសូន្យទៅ ក្នុងវេទនាទាំងឡាយខាងក្រៅ ។ ពិចារណាឃើញទាំងធម៌ដែលកើតឡើងនិងសូន្យទៅក្នុងវេទនាទាំងឡាយខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញធម៌ដែលកើតឡើងក្នុងវេទនាទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ ។ ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅ ។ ពិចារណាឃើញទាំងធម៌ដែលកើតឡើងនិងសូន្យទៅក្នុងវេទនាទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ។

វេហាគតវគ្គោ

[៥៨១] សោ សចេ អាកង្ខតិ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិក្កូលញ្ច បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ ។

[៥៨២] អជ្ឈត្តំ ចិត្តេ ។ បេ ។ ពហិទ្ធា ចិត្តេ ។ បេ ។ អជ្ឈត្តពហិទ្ធា ចិត្តេ សមុទយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា ចិត្តេ វយធម្មានុបស្សី វិហរតិ ។

រហោគតវគ្គ

[៥៨១] បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីមានបដិកូលសញ្ញាក្នុងវេទនាដែលមិនគួរបដិកូលដូច្នេះ ឈ្មោះថា មានបដិកូលសញ្ញាក្នុងវេទនានោះ ។ បើប្រាថ្នាថា អាត្មាអញមិនគប្បីមានបដិកូលសញ្ញាក្នុងវេទនាដែលគួរបដិកូលដូច្នេះ ឈ្មោះថា មិនមានបដិកូលសញ្ញាក្នុងវេទនានោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីមានបដិកូលសញ្ញាក្នុងវេទនាមិនគួរបដិកូលផង ក្នុងវេទនាគួរបដិកូលផងដូច្នេះ ឈ្មោះថា មានបដិកូលសញ្ញាក្នុងវេទនានោះ ។ បើប្រាថ្នាថា អាត្មាអញមិនគប្បីមានបដិកូលសញ្ញាក្នុងវេទនាគួរបដិកូលផង ក្នុងវេទនាមិនគួរបដិកូលផងដូច្នេះ ឈ្មោថា មិនមានបដិកូលសញ្ញាក្នុងវេទនានោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីវៀរផ្តាច់នូវវេទនាទាំងពីរ គឺទាំងវេទនាមិនគួរបដិកូលទាំងវេទនាគួរបដិកូលនោះចេញ ហើយជាអ្នកមានឧបេក្ខា មានសតិ-សម្បជញ្ញៈដូច្នេះ ឈ្មោះថា មានឧបេក្ខា មានសតិសម្បជញ្ញៈ ក្នុងវេទនានោះ ។

[៥៨២] ក្នុងចិត្តខាងក្នុង ។ បេ ។ ក្នុងចិត្តខាងក្រៅ ។ បេ ។ ពិចារណាឃើញធម៌ដែលកើតឡើងក្នុងចិត្តទាំងខាងក្នុងទាំងខាងក្រៅ ។ ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងចិត្តទាំងខាងក្នុងទាំងខាងក្រៅ ។

អជ្ឈត្តពហិទ្ធា ចិត្តេ សមុទយវយធម្មានុបស្សី វិហរតិ អាតាបី ។ បេ ។ អភិជ្ឈាទោមនស្សំ ។

[៥៨៣] សោ សចេ អាកង្ខតិ អប្បដិកូលេ បដិកូលសញ្ញី វិហរេយ្យន្តិ បដិកូលសញ្ញី តត្ថ វិហ-រតិ ។ បេ ។ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្ប-ជានោ ។

[៥៨៤] អជ្ឈត្តំ ធម្មេសុ ។ បេ ។ ពហិទ្ធា ធម្មេសុ ។ បេ ។ អជ្ឈត្តពហិទ្ធា ធម្មេសុ សមុទយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា ធម្មេសុ វយធម្មានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា ធម្មេសុ សមុទយវិយធម្មានុ-បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ពិចារណាឃើញនូវធម៌ដែលកើតឡើងនិងសូន្យទៅ  ក្នុងចិត្តទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ។ បេ ។ អភិជ្ឈានិងទោមនស្ស ។

[៥៨៣]  បើភិក្ខុនោះប្រាថ្នាថា  អាត្មាអញគប្បីមានបដិកូលសញ្ញាក្នុងចិត្តមិនគួរបដិកូលដូច្នេះ ឈ្មោះថា មានបដិកូលសញ្ញាក្នុងចិត្តនោះ ។ បេ ។ ជាអ្នកមានឧបេក្ខា មានសតិសម្បជញ្ញៈក្នុងចិត្តនោះ ។

[៥៨៤] ក្នុងធម៌ទាំងឡាយ ខាងក្នុង ។ បេ ។ ក្នុងធម៌ទាំងឡាយខាងក្រៅ ។ បេ ។ ពិចារណាឃើញធម៌ដែលកើតឡើងក្នុងធម៌ទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅ ។ ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ ។ ពិចារណាឃើញទាំងធម៌ដែលកើតឡើងនិងសូន្យទៅ ក្នុងធម៌ទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ។

## រហោគតវគ្គោ

[៥៨៥] សោ សចេ អាកង្ខតិ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ ។ បេ ។ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ ។ ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា អារទ្ធា ហោន្តីតិ ។

[៥៨៦] សាវត្ថីនិទានំ ។ អថខោ អាយស្មតោ អនុរុទ្ធស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យេសំ កេសញ្ចិ ចត្តារោ សតិប្បដ្ឋានា វិរទ្ធា វិរទ្ធោ តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមី យេសំ កេសញ្ចិ ចត្តារោ សតិប្បដ្ឋានា អារទ្ធា អារទ្ធោ តេសំ អរិយោ មគ្គោ សម្មាទុក្ខក្ខយគាមីតិ ។

[៥៨៧] អថខោ អាយស្មា មហាមោគ្គល្លានោ អាយស្មតោ អនុរុទ្ធស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ អាយស្មតោ អនុរុទ្ធស្ស សម្មុខេ បាតុរហោសិ ។

រហោគតវគ្គ

[៥៨៥] បើភិក្ខុនោះប្រាថ្នាថា អាត្មាអញ គប្បីមានបដិកូលសញ្ញាក្នុងធម៌មិនគួរបដិកូល ដូច្នេះ ឈ្មោះថា មានបដិកូលសញ្ញាក្នុងធម៌នោះ ។ បេ ។ ជាអ្នកមានឧបេក្ខាមានសតិសម្បជញ្ញៈក្នុងធម៌ទាំងនោះ ។ ម្នាលអាវុសោ ដោយហេតុប៉ុណ្ណេះឯង ទើបឈ្មោះថាភិក្ខុអ្នកធ្វើសតិប្បដ្ឋានទាំង ៤ ឲ្យបរិបូណ៌ ។

[៥៨៦] សាវត្ថីនិទាន ។ គ្រានោះឯង ព្រះអនុរុទ្ធដ៏មានអាយុសម្ងំនៅក្នុងទីស្ងាត់ កើតបរិវិតក្កក្នុងចិត្តយ៉ាងនេះថា ភិក្ខុទាំងឡាយ ឯណានីមួយបោះបង់សតិប្បដ្ឋានទាំង៤ ភិក្ខុទាំងនោះ ឈ្មោះថាបោះបង់មគ្គដ៏ប្រសើរជាដំណើរទៅកាន់ទីអស់ទុក្ខដោយប្រពៃ ភិក្ខុទាំងឡាយឯណានីមួយធ្វើសតិប្បដ្ឋានទាំង ៤ ឲ្យបរិបូណ៌ ភិក្ខុទាំងនោះ ឈ្មោះថាធ្វើមគ្គដ៏ប្រសើរជាដំណើរទៅកាន់ទីអស់ទុក្ខដោយប្រពៃ ឲ្យបរិបូណ៌ដែរ ។

[៥៨៧] គ្រានោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ ដឹងនូវបរិវិតក្កក្នុងចិត្តរបស់ព្រះអនុរុទ្ធដ៏មានអាយុ ដោយចិត្ត (ខ្លួន ) ហើយក៏មកប្រាកដ ក្នុងទីចំពោះមុខព្រះអនុរុទ្ធដ៏មានអាយុភ្លាម ដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ដៃដែលលាចេញដូច្នោះ ។

[៥៨៥] អថខោ អាយស្មា មហាមោគ្គល្លានោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច កតិន្នាវតា នុ ខោ អាវុសោ អនុរុទ្ធ ភិក្ខុនោ ចត្តារោ សតិបដ្ឋានា អារទ្ធា ហោន្តីតិ ។

[៥៨៦] ឥធាវុសោ ភិក្ខុ អជ្ឈត្តំ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ពហិទ្ធា កាយេ កាយានុបស្សី វិហរតិ អាតាបី ។ បេ ។ អជ្ឈត្តពហិទ្ធា កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[៥៨៨] លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានសួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ម្នាលអាវុសោអនុរុទ្ធ ដោយហេតុដូចម្តេចខ្លះ ទើបឈ្មោះថា ភិក្ខុធ្វើសតិប្បដ្ឋាន ៤ ឲ្យបរិបូណ៌ ។

[៥៨៩] ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញកាយក្នុងកាយខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ។ បេ ។ ពិចារណាឃើញកាយក្នុងកាយទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

រហោគតវគ្គោ

[៨៩០] អជ្ឈត្តំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អជ្ឈត្តពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[៨៩១] អជ្ឈត្តំ ចិត្តេ ។ ពហិទ្ធា ចិត្តេ ។ អជ្ឈត្តពហិទ្ធា ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

[៨៩២] អជ្ឈត្តំ ធម្មេសុ ។ ពហិទ្ធា ធម្មេសុ ។ អជ្ឈត្តពហិទ្ធា ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា អារទ្ធា ហោន្តីតិ ។

រហោគតវគ្គ

[៥៩០] ពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

[៥៩១] ក្នុងចិត្តខាងក្នុង ។ ក្នុងចិត្តខាងក្រៅ ។ ពិចារណាឃើញចិត្តក្នុងចិត្តទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

[៥៩២] ក្នុងធម៌ទាំងឡាយខាងក្នុង ។ ក្នុងធម៌ទាំងឡាយខាងក្រៅ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលអាវុសោ ដោយហេតុប៉ុណ្ណោះឯង ទើបឈ្មោះថាភិក្ខុធ្វើសតិប្បដ្ឋានទាំង ៤ ឲ្យបរិបូណ៌ ។

[៩៩៣] ឯកំ សមយំ អាយស្មា អនុរុទ្ធោ សាវត្ថិយំ វិហរតិ សុតនុតីរេ ។ អថខោ សម្ពហុលា ភិក្ខូ យេនាយស្មា អនុរុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អនុរុទ្ធេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ អនុរុទ្ធំ ឯតទវោចុំ កតមេសំ អាយស្មា អនុរុទ្ធោ ធម្មានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ[១] បត្តោតិ ។

[៩៩៤] ចតុន្នំ ខ្វាហំ អាវុសោ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ កតមេសំ ចតុន្នំ ។ ឥធាវុសោ[២] កាយេ កាយានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា

១ ឱ. មហាភិញ្ញាតំ ។ ២ ម. ឥធាហំ អាវុសោ ។ ឱ. ឥធាហមាវុសោ ។

[៥៩៣] សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុ គង់នៅក្បែរឆ្នេរស្ទឹង សុតនុ ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុច្រើនរូបចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះអនុរុទ្ធដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ព្រះអនុរុទ្ធដ៏មានអាយុ បានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះចម្រើន ធ្វើឲ្យច្រើននូវពួកធម៌ដូចម្តេចខ្លះ ។

[៥៩៤] ម្នាលអាវុសោ ខ្ញុំបានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះតែចម្រើនធ្វើឲ្យច្រើននូវសតិប្បដ្ឋានទាំង ៤ ។ សតិប្បដ្ឋានទាំង ៤ តើដូចម្តេចខ្លះ ។ ម្នាលអាវុសោ ក្នុងសាសនានេះ ខ្ញុំពិចារណាឃើញកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួនមានស្មារតី

វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខ្វាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា ហីនំ ធម្មំ ហីនតោ អព្ភញ្ញាសឹ មជ្ឈិមំ ធម្មំ បជ្ឈិមតោ អព្ភញ្ញាសឹ បណីតំ ធម្មំ បណីតតោ អព្ភញ្ញាសិន្តិ ។

[៨៩៨] ឯកំ សមយំ អាយស្មា ច អនុរុទ្ធោ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាមោគ្គល្លា-នោ សាកេតេ វិហរន្តិ កណ្ដកីវនេ ។ អថខោ អា-យស្មា ច សារីបុត្តោ អាយស្មា ច មហាមោគ្គល្លានោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតា យេនាយស្មា អនុរុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អនុរុទ្ធេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារា-ណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច សេក្ខេនាវុសោ អនុរុទ្ធ ភិក្ខុនា កតមេ ធម្មា ឧបសម្បជ្ជ វិហាតព្វាតិ ។

កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក១ ។ ម្នាលអាវុសោ ខ្ញុំបាន សម្រេចអភិញ្ញាដ៏ធំ ព្រោះតែចម្រើន ធ្វើឱ្យច្រើននូវសតិប្បដ្ឋានទាំង ៤ នេះឯង ។ ម្នាលអាវុសោ មួយទៀតខ្ញុំបានដឹងច្បាស់នូវធម៌ថោកទាប តាមសភាពថោកទាប ដឹងច្បាស់នូវធម៌យ៉ាងកណ្តាល តាមសភព យ៉ាងកណ្តាល ដឹងច្បាស់នូវធម៌ដ៏ឧត្តម តាមសភាពដ៏ឧត្តម ក៏ព្រោះតែ ចម្រើន ធ្វើឱ្យច្រើននូវសតិប្បដ្ឋានទាំង ៤ នេះដែរ ។

[៥៩៥] សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុផង ព្រះសារីបុត្ត ដ៏មានអាយុផង ព្រះមហាមោគ្គល្លានដ៏មានអាយុផង គង់នៅក្នុងកណ្ដ-កីវន (ព្រៃញាតស្បាតដោយបន្ទា) ទៀបក្រុងសាកេត ។ គ្រានោះឯង ព្រះសារីបុត្តដ៏មានអាយុនឹងព្រះមហាមោគ្គល្លានដ៏មានអាយុ ចេញអំពី ទីសម្ងំក្នុងសាយណ្ហសម័យ ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូល ទៅដល់ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះអនុរុទ្ធដ៏មានអាយុ លុះ បញ្ចប់ពាក្យដែលគួររាក់ទាក់ នឹងពាក្រដែលគួររលឹកហើយ ក៏អង្គុយក្នុង ទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយនៅក្នុងទីសមគួរហើយ បានសួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ម្នាលអាវុសោអនុរុទ្ធ ពួកធម៌ដូច ម្តេច ដែលភិក្ខុជាសេក្ខៈគួរសម្រេចសម្រាន្តនៅគ្រប់ឥរិយាបថទាំង ៤ ។

[៥៩៦] សេក្ខេនាវុសោ សារីបុត្ត ភិក្ខុនា ចត្តារោ សតិប្បដ្ឋានា ឧបសម្បជ្ជ វិហាតព្វា ។ កតមេ ចត្តារោ ។ ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ សេក្ខេនាវុសោ សារីបុត្ត ភិក្ខុនា ឥមេ ចត្តារោ សតិប្បដ្ឋានា ឧបសម្បជ្ជ វិហាតព្វាតិ ។

[៥៩៧] សាកេតនិទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច អសេក្ខេនាវុសោ អនុរុទ្ធ ភិក្ខុនា កតមេ ធម្មា ឧបសម្បជ្ជ វិហាតព្វាតិ ។

[៥៩៦] ម្នាលអាវុសោសារីបុត្ត សតិប្បដ្ឋានទាំង ៤ ភិក្ខុជាសេក្ខៈគួរសម្រេចសម្រាន្តនៅគ្រប់ឥរិយាបថទាំង ៤ ។ សតិប្បដ្ឋានទាំង ៤ ដូចម្តេចខ្លះ ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយ ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាលអាវុសោសារីបុត្ត សតិប្បដ្ឋានទាំង ៤ នេះ ដែលភិក្ខុជាសេក្ខៈគួរសម្រេចសម្រាន្តនៅគ្រប់ឥរិយាបថទាំង ៤ ។

[៥៩៧] សាកេតនិទាន ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ម្នាលអាវុសោអនុរុទ្ធ ពួកធម៌ដូចម្តេច ដែរលភិក្ខុជាអសេក្ខៈគួរសម្រេចសម្រាន្តនៅគ្រប់ឥរិយាបថទាំង ៤ ។

៣៤៩

## រហោគតវគ្គោ

[៤៩៨] អសេក្ខេនាវុសោ សារីបុត្ត ភិក្ខុនា ចត្តារោ សតិប្បដ្ឋានា ឧបសម្បជ្ជ វិហាតព្វា ។ កតមេ ចត្តារោ ។ ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អសេក្ខេនាវុសោ សារីបុត្ត ភិក្ខុនា ឥមេ ចត្តារោ សតិប្បដ្ឋានា ឧបសម្បជ្ជ វិហាតព្វាតិ ។

[៤៩៩] សាកេតនិទានំ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច កតមេសំ អាយស្មា អនុរុទ្ធោ ធម្មានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោតិ ។

រហោគតវគ្គ

[៥៩៨] ម្នាលអាវុសោសារីបុត្ត សតិប្បដ្ឋាន ៤ ភិក្ខុជាអសេក្ខៈគួរសម្រេចសម្រាន្តនៅគ្រប់ឥរិយាបថទាំង ៤ ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាលអាវុសោសារីបុត្ត សតិប្បដ្ឋាន ៤ នេះ ភិក្ខុជាអសេក្ខៈគួរសម្រេចសម្រាន្តនៅគ្របឥរិយាបថទាំង ៤ ។

[៥៩៩] សាកេតនិទាន ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ព្រះអនុរុទ្ធដ៏មានអាយុ បានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះចម្រើន ធ្វើឲ្យច្រើននូវធម៌ទាំងឡាយដូចម្តេចខ្លះ ។

[៦០០] ចតុន្នំ ខ្វាហំ អាវុសោ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ កតមេសំ ចតុន្នំ ។ ឥធាហំ អាវុសោ កាយេ កាយានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខ្វាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា សហស្សលោកំ អភិជានាមីតិ ។

[៦០១] សាវត្ថីនិទានំ ។ តត្រ ខោ អាយស្មា អនុរុទ្ធោ ភិក្ខូ អាមន្តេសិ ។ បេ ។ ឯតទវោច ចត្តារោមេ អាវុសោ សតិប្បដ្ឋានា ភាវិតា ពហុលីកតា តណ្ហាក្ខយាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ

[៦០០] ម្នាលអាវុសោ ខ្ញុំបានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ ដូចម្ដេចខ្លះ ។ ម្នាលអាវុសោ ក្នុងសាសនានេះ ខ្ញុំពិចារណាឃើញកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតីកម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាលអាវុសោខ្ញុំបានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវសតិប្បដ្ឋាន ៤ នេះឯង ។ ម្នាលអាវុសោ មួយទៀត ដែលខ្ញុំដឹងច្បាស់នូវលោកមួយពាន់ក៏ព្រោះតែចម្រើនធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦០១] សាវត្ថីនិទាន ។ ក្នុងទីនោះឯង ព្រះអនុរុទ្ធដ៏មានអាយុហៅភិក្ខុទាំងឡាយមក ។ បេ ។ ពោលដូច្នេះថា ម្នាលអាវុសោ សតិប្បដ្ឋាន ៤ នេះ ដែលភិក្ខុចម្រើន ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីអស់តណ្ហា ។ សតិប្បដ្ឋាន ៤ ដូចម្ដេចខ្លះ ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយក្នុងកាយ ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ

អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេ ខោ អាវុសោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ពហុលីកតត្តា តណ្ហាក្ខយាយ សំវត្តន្តីតិ ។

[៦០២] ឯកំ សមយំ អាយស្មា អនុរុទ្ធោ សាវត្ថិយំ វិហរតិ សលឡាគារេ ។ តត្រ ខោ អាយស្មា អនុរុទ្ធោ ភិក្ខូ អាមន្តេសិ ។ បេ ។ ឯតទវោច សេយ្យថាបិ អាវុសោ គង្គានទី ចាចីននិន្នា ចាចីនចោណា ចាចីនបព្ភារា អថ មហាជនកាយោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ មយំ ឥមំ គង្គានទឹ បច្ឆានិន្នំ ករិស្សាម បច្ឆាចោណំ បច្ឆាបព្ភារន្តិ ។ តំ កឹ មញ្ញថ អាវុសោ អបិ នុ សោ មហាជនកាយោ គង្គានទឹ បច្ឆានិន្នំ ករេយ្យ បច្ឆាចោណំ បច្ឆាបព្ភារន្តិ ។ នោ ហេតំ អាវុសោ ។ តំ កិស្ស ហេតុ ។ គង្គា អាវុសោ នទី ចាចីននិន្នា ចាចីនចោណា ចាចីនបព្ភារា

មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាលអាវុសោ សតិ-ប្បដ្ឋាន ៤ នេះឯង ដែលភិក្ខុចម្រើន ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្ត ទៅដើម្បីអស់តណ្ហា ។

[៦០២] សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុ នៅក្នុងផ្ទះធ្វើ ដោយឈើស្រស់ ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះអនុរុទ្ធដ៏មាន អាយុ ហៅភិក្ខុទាំងឡាយមក ។ បេ ។ ពោលដូច្នេះថា ម្នាលអាវុសោ ទន្លេគង្គា មានទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅ ខាងកើត តែពួកមហាជន កាន់យកចបនឹងកញ្ជើ មកដោយគិតថា យើងទាំងឡាយនឹងធ្វើទន្លេគង្គានេះ ឲ្យមានទំនាបទៅខាងលិច ឲ្យមាន ជម្រាលទៅខាងលិច ឲ្យឈមទៅខាងលិចវិញ ។ ម្នាលអាវុសោ អ្នកទាំងឡាយយល់សេចក្តីនោះដូចម្តេច ចុះពួកមហាជននោះ គប្បីធ្វើ ទន្លេគង្គា ឲ្យមានទំនាបទៅខាងលិច ឲ្យមានជម្រាលទៅខាងលិច ឲ្យ ឈមទៅខាងលិចបានដែរឬ ។ ម្នាលអាវុសោ ធ្វើដូច្នោះមិនបានទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោ ដ្បិតថាទន្លេគង្គានោះ មាន ទំនាបទៅខាងកើត មានជម្រាលទៅខាងកើត ឈមទៅខាងកើតហើយ

សា ន សុករា បច្ឆានិន្នំ កាតុំ បច្ឆាចោណំ បច្ឆា-
បព្ភារំ យាវ នេវ ច បន សោ មហាជនកាយោ តិ-
លមជស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ
អាវុសោ ភិក្ខុំ ចត្តារោ សតិប្បដ្ឋានេ ភាវេន្តំ ចត្តារោ
សតិប្បដ្ឋានេ ពហុលីករោន្តំ រាជា វា រាជមហាមត្តា
វា មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា
វា ភោគេហិ អភិហដ្ឋុំ បវារេយ្យុំ ឯហម្ភោ បុរិស
កិំ តេ ឥមេ កាសាវា អនុទហន្តិ កឹ មុណ្ឌោ កបា-
លមនុសំចរសិ ឯហិ ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជ-
ស្សុ បុញ្ញានិ ច ករោហីតិ ។ សោ វត អាវុសោ ភិក្ខុ
ចត្តារោ សតិប្បដ្ឋានេ ភាវេន្តោ ចត្តារោ សតិប្បដ្ឋានេ
ពហុលីករោន្តោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ
នេតំ ឋានំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ យំ ហិ
អាវុសោ[១] ចិត្តំ ទីឃរត្តំ វិវេកនិន្នំ វិវេកចោណំ វិវេក-
បព្ភារំតថា[២] ហីនាយាវត្តិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

១ ឱ. ម. យញ្ហិ តំ អាវុសោ ។ ២ តំ វត ។

គេមិនងាយធ្វើឲ្យមានទំនាបទៅខាងលិច ឲ្យមានជម្រាលទៅខាងលិច ឲ្យឈមទៅខាងលិចវិញបានទេ ឯពួកមហាជននោះ គ្រាន់តែបានចំណែកសេចក្តីលំបាកនឹងសេចក្តីចង្អៀតចង្អល់ប៉ុណ្ណោះ យ៉ាងណាមិញ ។ ម្នាលអាវុសោ ព្រះរាជាក្តី មហាមាត្យរបស់ព្រះរាជាក្តី មិត្តក្តី អមាត្យក្តី ញាតិក្តី សាលោហិតក្តី នាំភោគៈទាំងឡាយមកវារណាភិក្ខុដែលកំពុងចម្រើនសតិប្បដ្ឋានទាំង ៤ កំពុងធ្វើឲ្យច្រើន នូវសតិប្បដ្ឋានទាំង ៤ ថា ម្នាលបុរសដ៏ចម្រើន ចូរអ្នកមកអាយ សំពត់កាសាវៈទាំងនេះ សម្រេចប្រយោជន៍អ្វីដល់អ្នក អ្នកជាមនុស្សត្រងោលកាន់អំបែងត្រាច់សុំគេប្រយោជន៍អ្វី អ្នកចូរវិលត្រឡប់មករកភេទជោកទាប ចូរប្រើប្រាស់ភោគៈទាំងឡាយផង ចូរធ្វើបុណ្យទាំងឡាយផង ។ ម្នាលអាវុសោ ភិក្ខុដែលកំពុងចម្រើនសតិប្បដ្ឋាន ៤ កំពុងធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នោះនឹងពោលលាសិក្ខា ត្រឡប់មករកភេទជោកទាបវិញដូច្នោះ ហេតុនុ៎ះរមែងមិនមានឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលអាវុសោ ដ្បិតថាចិត្ត (របស់លោក) មានទំនាបទៅរកសេចក្តីស្ងប់ស្ងាត់ មានជម្រាលទៅរកសេចក្តីស្ងប់ស្ងាត ឈមទៅរកសេចក្តីស្ងប់ស្ងាត់ អស់កាលយូរអង្វែងមកហើយ នឹងឲ្យ (លោក) ត្រឡប់ទៅរកភេទជោកទាប ដូច្នោះ ហេតុនុ៎ះរមែងមិនមានឡើយ ក៏យ៉ាងនោះឯង ។

រហោគតវគ្គោ

[៦០៣] កថញ្ចាវុសោ ភិក្ខុ ចត្តារោ សតិប្បដ្ឋានេ ភាវេតិ ចត្តារោ សតិប្បដ្ឋានេ ពហុលីករោតិ ។ ឥធាវុ-សោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ វេទនា-សុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ អាវុសោ ភិក្ខុ ចត្តារោ សតិប្បដ្ឋានេ ភាវេតិ ចត្តារោ សតិប្បដ្ឋានេ ពហុលីករោតីតិ ។

[៦០៤] ឯកំ សមយំ អាយស្មា ច អនុរុទ្ធោ អាយស្មា ច សារីបុត្តោ វេសាលិយំ វិហរន្តិ អម្ពបាលី-វនេ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច វិប្បសន្នានិ ខោ តេ អាវុសោ អនុរុទ្ធ ឥន្ទ្រិយានិ បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ ។ កតមេនាយស្មា អនុរុទ្ធោ វិហារេន ឯតរហិ ពហុលំ វិហរតីតិ ។

[៦០៣] ម្នាលអាវុសោ ចុះភិក្ខុចម្រើនសតិប្បដ្ឋាន ៤ ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុ ក្នុងសាសនា-នេះ ពិចារណាឃើញកាយក្នុងកាយ ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាលអាវុសោ ភិក្ខុចម្រើនសតិ-ប្បដ្ឋាន ៤ ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ យ៉ាងនេះឯង ។

[៦០៤] សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុ និងព្រះសារីបុត្តដ៏មានអាយុ នៅក្នុងអម្ពបាលិវន ជិតក្រុងវេសាលី ។ គ្រានោះឯងព្រះសារីបុត្តដ៏មានអាយុ ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ។ បេ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ម្នាលអាវុសោអនុរុទ្ធ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លា សម្បុរមុខរបស់អ្នកបរិសុទ្ធផូរផង់ ។ ឥឡូវនេះ ព្រះអនុរុទ្ធដ៏មានអាយុ ច្រើននៅដោយវិហារធម៌ដូចម្តេច ។

[៦០៥] ចតូសុ ខ្វាហំ អាវុសោ សតិប្បដ្ឋានេសុ សូបដ្ឋិតចិត្តោ[១] ឯតរហិ ពហុលំ វិហរាមិ ។ កតមេសុ ចតូសុ ។ ឥធាហំ អាវុសោ កាយេ កាយានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសុ ខ្វាហំ អាវុសោ ចតូសុ សតិប្បដ្ឋានេសុ សូបដ្ឋិតចិត្តោ ឯតរហិ ពហុលំ វិហរាមិ ។ យោ សោ អាវុសោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ សោ ឥមេសុ ចតូសុ សតិប្បដ្ឋានេសុ សូបដ្ឋិតចិត្តោ ពហុលំ វិហរតីតិ ។ លាភា[២] នោ អាវុសោ សុលទ្ធំ[៣]នោ អាវុសោ យេ មយំ អាយស្មតោ អនុរុទ្ធស្ស សម្មុខាវ អស្សុម្ហ អាសភវាចំ ភាសមានស្សាតិ ។

១ ម. សុប្បតិដ្ឋិតចិត្តោ ។ ២ ឱ. ម. លាភាវត ។ ៣ សុលទ្ធំ វត ។

[៦០៥] ម្នាលអាវុសោ ឥឡូវនេះ ខ្ញុំច្រើននៅដោយមានចិត្តតម្កល់ស៊ប់ក្នុងសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ម្នាលអាវុសោក្នុងសាសនានេះ ខ្ញុំពិចារណាឃើញកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតីកម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតីកម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាលអាវុសោ ឥឡូវនេះ ខ្ញុំច្រើននៅដោយមានចិត្តតម្កល់ស៊ប់ក្នុងសតិប្បដ្ឋាន ៤ នេះឯង ។ ម្នាលអាវុសោ ភិក្ខុឯណា ជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយៈបាននៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសញ្ញោជនៈ (ធម៌ជាគ្រឿងប្រកបសត្វឲ្យជាប់នៅ) ក្នុងភពអស់ហើយរួចស្រឡះចាកកិលេស ព្រោះដឹងប្រពៃ ភិក្ខុនោះ ឈ្មោះថា ច្រើននៅដោយមានចិត្តដម្កល់ស៊ប់ក្នុងសតិប្បដ្ឋាន ៤ នេះ ។ ម្នាលអាវុសោ ជាលាភរបស់យើងហើយ ម្នាលអាវុសោ យើងបានល្អហើយ ព្រោះយើងបានស្តាប់អាសភិវាចាចំពោះមុខ ព្រះអនុរុទ្ធដ៏មានអាយុ កំពុងពោលដោយពិតនេះឯង ។

[៦០៦] ឯកំ សមយំ អាយស្មា អនុរុទ្ធោ សាវត្ថិ-
យំ វិហរតិ អន្ធវនស្មឹ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិ-
លានោ ។ អថខោ សម្ពហុលា ភិក្ខូ យេនាយស្មា
អនុរុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ
អនុរុទ្ធំ ឯតទវោចុំ កតមេនាយស្មតោ អនុរុទ្ធស្ស
វិហារេន វិហរតោ ឧប្បន្នា សារីរិកា ទុក្ខា វេទនា
ចិត្តំ ន បរិយាទាយ តិដ្ឋន្តីតិ ។

[៦០៧] ចតូសុ ខោ មេ អាវុសោ សតិប្បដ្ឋានេសុ
សុប្បតិដ្ឋិតចិត្តស្ស វិហរតោ ឧប្បន្នា សារីរិកា ទុក្ខា
វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋន្តិ ។ កតមេសុ ច-
តូសុ ។ ឥធាហំ អាវុសោ កាយេ កាយានុបស្សី
វិហរាមិ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី
វិហរាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោ-
កេ អភិជ្ឈាទោមនស្សំ ។ ឥមេសុ ខោ មេ អាវុសោ ច-
តូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តស្ស វិហរតោ ឧប្បន្នា
សារីរិកា ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋន្តីតិ ។

រហោគតវគ្គោ បឋមោ ។

រហោគតវគ្គ

[៦០៦] សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុ នៅក្នុងអន្ធវន ជិតក្រុងសាវត្ថី មានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជម្ងឺធ្ងន់ ។ គ្រានោះឯង ភិក្ខុច្រើនរូប ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ បានសួរព្រះអនុរុទ្ធដ៏មានអាយុដូច្នេះថា ព្រះអនុរុទ្ធដ៏មានអាយុនៅដោយវិហារធម៌ដូចម្ដេច បានជាទុក្ខវេទនាមានក្នុងសរីរៈកើតឡើងហើយគ្របសង្កត់ចិត្តមិនបាន ។

[៦០៧] ម្នាលអាវុសោ ខ្ញុំមានចិត្តតម្កល់ស៊ប់ក្នុងសតិប្បដ្ឋាន ៤ បានជាទុក្ខវេទនាមានក្នុងសរីរៈកើតឡើងហើយ គ្របសង្កត់ចិត្តមិនបាន ។ សតិប្បដ្ឋាន ៤ ដូចម្ដេចខ្លះ ។ ម្នាលអាវុសោ ក្នុងសាសនានេះ ខ្ញុំពិចារណាឃើញកាយក្នុងកាយ ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាលអាវុសោ ខ្ញុំមានចិត្តតម្កល់ស៊ប់ក្នុងសតិប្បដ្ឋាន ៤ នេះឯង បានជាទុក្ខវេទនាមានក្នុងសរីរៈកើតឡើងហើយ គ្របសង្កត់ចិត្តមិនបាន ។

ចប់ រហោគតវគ្គ ទី ១ ។

៣៦៦

សុត្តន្តបិដកេ សំយុត្តនិកាយស្ស មហាវារវគ្គោ

## តស្សុទ្ទានំ

រហោគតេន ទ្វេ វុត្តា
សុតនុកណ្ដកី តយោ
តណ្ហាក្ខយសលឡាគារំ
អម្ពបាលិគិលាយ[១] នន្ទិ

---
១ ឱ. សព្វំ ពាឡ្ហគិលាយនន្ទិ ។

# ឧទ្ទាននៃរហោគតវគ្គនោះគឺ

និយាយអំពីព្រះអនុរុទ្ធនៅក្នុងទីស្ងាត់ ត្រិះរិះសតិប្បដ្ឋាន ២ លើក អំពីព្រះអនុរុទ្ធនៅក្បែរ ឆ្នេរស្ទឹងសុតនុ ១ អំពីព្រះអនុរុទ្ធជាដើមនៅក្នុងកណ្ដកីវន ៣ លើក អំពីការចម្រើនសតិប្បដ្ឋាន ប្រព្រឹត្តទៅដើម្បីអស់តណ្ហា ១ អំពីព្រះអនុរុទ្ធនៅក្នុងផ្ទះធ្វើដោយឈើស្រស់ ១ អំពីព្រះអនុរុទ្ធនឹងព្រះសារីបុត្តនៅក្នុងអម្ពបាលិវន ១ អំពីព្រះអនុរុទ្ធមានអាពាធ ១ ។

# ទុតិយវគ្គោ

[៦០៨] ឯកំ សមយំ អាយស្មា អនុរុទ្ធោ សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
អថខោ សម្ពហុលា ភិក្ខូ យេនាយស្មា អនុរុទ្ធោ
តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អនុរុទ្ធេន
។ បេ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្ម-
ន្តំ អនុរុទ្ធំ ឯតទវោចុំ កតមេសំ អាយស្មា អនុរុ-
ទ្ធោ ធម្មានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ
បត្តោតិ ។

[៦០៩] ចតុន្នំ ខ្វាហំ អាវុសោ សតិប្បដ្ឋានានំ
ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ ក-
តមេសំ ចតុន្នំ ។ ឥធាហំ អាវុសោ កាយេ កា-
យានុបស្សី វិហរាមិ ។ វេទនាសុ ។ ចិត្តេ ។
ធម្មេសុ ធម្មានុបស្សី វិហរាមិ អាតាបី សម្បជានោ

# ទុតិយវគ្គ

[៦០៨] សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុ នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុច្រើនរូប ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះសំណាលនឹងព្រះអនុរុទ្ធដ៏មានអាយុ ។ បេ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអនុរុទ្ធដ៏មានអាយុ ដូច្នេះថា ព្រះអនុរុទ្ធដ៏មានអាយុ បានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះចម្រើន ធ្វើឲ្យច្រើននូវធម៌ដូចម្តេចខ្លះ ។

[៦០៩] ម្នាលអាវុសោ ខ្ញុំបានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ ដូចម្តេចខ្លះ ។ ម្នាលអាវុសោ ក្នុងសាសនានេះ ខ្ញុំពិចារណាឃើញកាយក្នុងកាយ ១ ។ ក្នុងវេទនាទាំងឡាយ ១ ។ ក្នុងចិត្ត ១ ។ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន

សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសំ ខ្វាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា មហាភិញ្ញតំ បត្តោ ។ ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា កប្បសហស្សំ[១] អនុស្សរាមីតិ ។

[៦១០] ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោមិ ឯកោបិ ហុត្វា ពហុធា ហោមិ ។ បេ ។ យាវ ព្រហ្មលោកា កាយេន វសំ វត្តេមីតិ ។

[៦១១] ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាមិ ទិព្វេ ច ហានុសេ ច យេ ទូរេ សន្តិកេ ចាតិ ។

---

១ ម. កប្បសតសហស្សំ ។

មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ១ ។ ម្នាល អាវុសោ ខ្ញុំបានសម្រេចនូវអភិញ្ញាដ៏ធំ ព្រោះចម្រើន ធ្វើឲ្យច្រើននូវសតិ-ប្បដ្ឋាន ៤ នេះឯង ។ ម្នាលអាវុសោ មួយវិញទៀត ខ្ញុំរលឹកបានមួយពាន់កប្ប ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១០] ម្នាលអាវុសោ មួយវិញទៀត ខ្ញុំបានសម្រេចឥទ្ធិវិធៈច្រើនប្រការ គឺថាខ្ញុំជាមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ។ បេ ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដ៏រាបដល់ព្រហ្មលោកក៏បាន ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១១] ម្នាលអាវុសោ មួយទៀត ខ្ញុំឮ សំឡេង ទាំងពីរយ៉ាងបាន គឺសំឡេងទិព្វនឹងសំឡេងជារបស់មនុស្ស ដែលនៅក្នុងទីឆ្ងាយក្ដីក្នុងទីជិតក្ដី ដោយសោតធាតុដូចជាទិព្វ ដ៏បរិសុទ្ធកន្លងសោតធាតុជារបស់មនុស្សជម្មតា ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវសតិប្បដ្ឋាន ៤ នេះដែរ ។

៣៦៩

## ទុតិយវគ្គោ

[៦១២] ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាមិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាមិ ។ បេ ។ វិមុត្តំ ចិត្តន្តិ បជានាមីតិ ។

[៦១៣] ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាមីតិ ។

[៦១៤] ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា អតីតានាគតប្បច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាមីតិ ។

[៦១៥] ឥមេសញ្ច បនាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា សព្វត្ថគាមិនីបដិបទំ យថាភូតំ បជានាមីតិ ។

## ទុតិយវគ្គ

[៦១២] ម្នាលអាវុសោ មួយទៀតខ្ញុំកំណត់ដឹងនូវចិត្តរបស់សត្វដទៃ បុគ្គលដទៃ ដោយចិត្ត (របស់ខ្លួន) ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ។ បេ ។ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១៣] ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់តាមពិតនូវហេតុដ៏គួរ តាមហេតុដ៏គួរផង នូវហេតុដ៏មិនគួរ តាមហេតុដ៏មិនគួរផង ក៏ព្រោះតែចម្រើនធ្វើឲ្យច្រើន នូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦០៤] ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់តាមពិត នូវវិបាករបស់បុគ្គលអ្នកសមាទាននូវកម្ម ដែលជាអតីតៈ អនាគតៈ បច្ចុប្បន្ន តាមឋានៈ តាមហេតុ ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើន នូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១៥] ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់នូវបដិបទាជាដំណើរប្រព្រឹត្តទៅដើម្បីប្រយោជន៍គ្រប់យ៉ាង ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១៦] ឥមេសញ្ច បជាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា អនេកធាតុនានាធាតុលោកំ យថាភូតំ បជានាមីតិ ។

[៦១៧] ឥមេសញ្ច បជាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា សត្តានំ នានាធិមុត្តិកតំ យថាភូតំ បជានាមីតិ ។

[៦១៨] ឥមេសញ្ច បជាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា បរសត្តានំ បរបុគ្គលានំ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ បជានាមីតិ ។

[៦១៩] ឥមេសញ្ច បជាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាមីតិ ។

[៦១៦] ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់តាមពិតនូវលោក ដែលមានធាតុច្រើនប្រការ មានធាតុផ្សេង ៗ ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១៧] ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់តាមពិតនូវអធ្យាស្រ័យផ្សេង ៗ របស់សត្វទាំងឡាយ ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១៨] ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់តាមពិតនូវសេចក្តីទន់ និងចាស់ក្លានៃឥន្ទ្រិយ របស់ពួកសត្វដទៃ ពួកបុគ្គលដទៃបាន ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦១៩] ម្នាលអាវុសោ មួយទៀត ខ្ញុំដឹងច្បាស់តាមពិតនូវទោស អានិសង្ស និងការចេញចាកឈាន វិមោក្ខ សមាធិ សមាបត្តិទាំងឡាយ ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

៣៧១

## ទុតិយវគ្គោ

[៦២០] ឥមេសញ្ច បជាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ សេយ្យថីទំ ។ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមីតិ ។

[៦២១] ឥមេសញ្ច បជាហំ អាវុសោ ចតុន្នំ ស-តិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ។ បេ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាមីតិ ។

[៦២២] ឥមេសញ្ច បជាហំ អាវុសោ ចតុន្នំ សតិប្បដ្ឋានានំ ភាវិតត្តា ពហុលីកតត្តា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។

វគ្គោ ទុតិយោ ។

## ទុតិយវគ្គ

[៦២០] ម្នាលអាវុសោ មួយទៀត ខ្ញុំរលឹកឃើញនូវបុព្វេនិវាស ច្រើនប្រការ ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។ រលឹកឃើញដូចម្ដេច ។ គឺ ១ ជាតិ ២ ជាតិ ។ បេ ។ រលឹកឃើញនូវ បុព្វេនិវាស ច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះ ។

[៦២១] ម្នាលអាវុសោ មួយទៀត ខ្ញុំមើលឃើញនូវពួកសត្វ កំពុងច្យុត កំពុងកើត ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់ មនុស្សធម្មតា ។ បេ ។ ខ្ញុំដឹងច្បាស់នូវពួកសត្វ ចូលទៅកើតតាមយថា-កម្ម ។ បេ ។ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ដូច្នេះ ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋាន ៤ នេះដែរ ។

[៦២២] ម្នាលអាវុសោ មួយទៀត ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ សម្រេច នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ក៏ព្រោះតែចម្រើន ធ្វើឲ្យច្រើននូវសតិប្បដ្ឋានទាំង ៤ នេះដែរ ។

ចប់ ទុតិយវគ្គ ។

# តស្សុទ្ទានំ

សហស្សំ ឥទ្ធិ អថ បន

ចេតោបរិច្ចជ្ឈានបេតីណិ[១]

បដិគោលិកោ ណាណាជិមុត្តិ

ឥន្ទ្រិយំ ជានន្តិ តិស្សោ វិជ្ជាតិ[២] ។

អនុរុទ្ធសំយុត្តំ និដ្ឋិតំ ។

---

១ ឱ. សហស្ស ច ឥទ្ធិ អថ ច បន ចេតោបរិច្ចជ្ឈានមេតីតិ ។ ២ ឱ. នានាវិមុត្តិ ឥន្ទ្រិយំ ជានន្តិស្សោ វិជ្ជាតិ ។ ម. ឈានំ តិស្សោ វិជ្ជាតិ ។

# ឧទ្ទាននៃទុតិយវគ្គនោះគឺ

*និយាយអំពីព្រះអនុរុទ្ធរលឹកបាន ១ ពាន់កប្ប ១ អំពីបាន ឫទ្ធិ ១ អំពីកំណត់ដឹងចិត្ត ១ អំពីហេតុគួរនឹងមិនគួរ ១ អំពីកម្មសមាទាន ៣ យ៉ាង អំពីដឹងបដិបទា ១ អំពីដឹងលោក ១ អំពីដឹងអធ្យាស្រ័យផ្សេងៗ ១ អំពីដឹងឥន្ទ្រិយ ១ អំពីដឹងត្រៃវិជ្ជា ។*

ចប់ អនុរុទ្ធសំយុត្ត ។

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស មហាវារវគ្គោ

# ទសមោ ភាគោ

---

## សតិប្បដ្ឋានសំយុត្តំ

## អម្ពបាលិវគ្គោ

## មាតិកា

អង្កេ


*ភគវតោ អម្ពបាលិវនេ វិហារកថា* ............................................ ១

*ចតុស្សតិប្បដ្ឋានកថា* ............................................ ២

*ភគវតោ កោសលេ ព្រាហ្មណគ្គាមេ វិហារកថា* ............................................ ១០

*កុសលាកុសលរាសិកថា* ............................................ ១៤

*សកុណគ្ឃិយា លាបស្ស សកុណស្ស អជ្ឈប្បត្តនកថា* ............................................ ១៥

*បញ្ចកាមគុណកថា* ............................................ ១៧

*មក្កដានំ មនុស្សានញ្ច ទុគ្គទេសកថា* ............................................ ១៩

*អកុសលសូទកថា* ............................................ ២៣

*ភគវតោ ខរអាពាធឧប្បជ្ជនកថា* ............................................ ៣០

*អានន្ទស្ស ភិក្ខុនូបស្សយស្ស ឧបសង្កមនកថា* ............................................ ៣៤


## នាឡន្ទវគ្គោ


*មហាបុរិសកថា* ............................................ ៤៤

# សុត្តន្តបិដក

# សំយុត្តនិកាយ  មហាវារវគ្គ

# ទសមភាគ

## *សតិប្បដ្ឋានសំយុត្ត*

### *អម្ពបាលិវគ្គ*

មាតិកា លេខទំព័រ


ពោលអំពីព្រះដ៏មានព្រះភាគគង់នៅក្នុងអម្ពបាលិវន ........................................ ១

ពោលអំពីសតិប្បដ្ឋាន ៤ ........................................................................... ២

ពោលអំពីព្រះដ៏មានព្រះភាគគង់នៅក្នុងព្រាហ្មណគ្រាមឈ្មោះកោសល ........... ១០

ពោលអំពីគំនរនៃកុសលនឹងអកុសល ............................................................ ១៤

ពោលអំពីសត្វខ្វែងឆាបសត្វប្រចៀច ............................................................ ១៥

ពោលអំពីកាមគុណ  ៥ ............................................................................. ១៧

ពោលអំពីប្រទេសដែលសត្វស្វានិងមនុស្សទៅបានដោយលំបាក...................... ១៩

ពោលអំពីអ្នកចម្អិនភត្តមិនឈ្លាសវៃ ............................................................ ២៣

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់ប្រឈួនជាទម្ងន់ ........................................... ៣០

ពោលអំពីព្រះអានន្ទចូលទៅកាន់លំនៅភិក្ខុនីមួយរូប ....................................... ៣៤


### *នាឡន្ទវគ្គ*


ពោលអំពីមហាបុរស ................................................................................... ៤៤

# មាតិកាបត្តានិ

## មាតិកា


| មាតិកា | អង្កេ |
| --- | --- |
| ភគវតោ បាវារិកម្ពវនេ នាឡន្ទាយំ វិហារកថា........................ | ៤៥ |
| ចុន្ទសមណុទ្ទេសកថា........................................................... | ៥១ |
| ភគវតោ ឧក្កចេលាយំ គង្គាតីរេ វិហារកថ............................. | ៥៧ |
| ពាហិយកថា.......................................................................... | ៦១ |
| ឧត្តិយកថា .......................................................................... | ៦៤ |
| សតិប្បដ្ឋានវិភង្គកថា .............................................................. | ៦៦ |
| សហម្បតិព្រហ្មកថា............................................................... | ៦៨ |
| ភគវតោ សេទកថានិគមេ វិហារកថា............................................ | ៧១ |


## សីលដ្ឋិតិវគ្គោ


| | |
| --- | --- |
| សីលកថា .............................................................................. | ៧៧ |
| សទ្ធម្មដ្ឋិតិកថា ...................................................................... | ៨០ |
| សទ្ធម្មបរិហានាបរិហានកថា ..................................................... | ៨២ |
| ចតុសតិប្បដ្ឋានកថា ................................................................. | ៨៤ |
| អញ្ញតរព្រាហ្មណុបសង្កមនកថា.................................................... | ៨៥ |
| ចតុសតិប្បដ្ឋានានំ បទេសភាវនាកថា.......................................... | ៨៨ |
| ចតុសតិប្បដ្ឋានានំ សមត្តភាវនាកថា .......................................... | ៨៩ |

# សង្ខឹកាចង្អុលច្រាប់មាតិកា


មាតិកា លេខទំព័រ

ពោលអំពីព្រះដ៏មានព្រះភាគគង់នៅក្នុងបាវារិកម្ពវនជិតក្រុងនាឡន្ទា............... ៥៥

ពោលអំពីចុន្ទសមណុទ្ទេស ........................................................................ ៥១

ពោលអំពីព្រះដ៏មានព្រះភាគគង់នៅទៀបឆ្នេរស្ទឹងគង្គា ជិតក្រុងឧក្កចេលា...... ៥៧

ពោលអំពីព្រះពាហិយៈ ........................................................................... ៦១

ពោលអំពីព្រះឧត្តិយៈ ............................................................................. ៦៤

ពោលអំពីសតិប្បដ្ឋានជារបស់ប្រសើរ ........................................................ ៦៦

ពោលអំពីសហម្បតិព្រហ្ម ......................................................................... ៦៨

ពោលអំពីព្រះដ៏មានព្រះភាគគង់នៅក្នុងសេទកនិគម ..................................... ៧១


## សីលដ្ឋិតិវគ្គ


ពោលអំពីសីល ....................................................................................... ៧៧

ពោលអំពីការស្ថិតនៅនៃព្រះសទ្ធម្ម ........................................................... ៨០

ពោលអំពីសេចក្តីសាបសូន្យនិងមិនសាបសូន្យនៃព្រះសទ្ធម្ម........................... ៨២

ពោលអំពីសតិប្បដ្ឋាន ៤............................................. .......................... ៨៤

ពោលអំពីព្រាហ្មណ៍ម្នាក់ចូលទៅទូលសួរព្រះដ៏មានព្រះភាគ ........................... ៨៥

ពោលអំពីបទេសភាវនា (ការចម្រើននូវចំណែកនៃសតិប្បដ្ឋាន ៤) ............... ៨៨

ពោលអំពីសមត្តភាវនា (ការចម្រើននូវសេចក្តីសម្រេចនៃសតិប្បដ្ឋាន ៤ )...... ៨៩

# មាតិកាបត្ថានិ

## មាតិកា

អង្កេ

អនុរុទ្ធស្ស លោកស្ស អភិជាននកថា ........ ៩០
សិរីវឌ្ឍគហបតិកថា ........ ៩១

## អនុរុទ្ធវគ្គោ

អននុស្សុតធម្មកថា ........ ៩៧
វិរាគកថា ........ ១០០
ចតុស្សតិប្បដ្ឋានវិរទ្ធកថា ........ ១០១
ចតុស្សតិប្បដ្ឋានភាវិតកថា ........ ១០២
សតិមភិក្ខុកថា ........ ១០៣
អរហត្តផលកថា ........ ១០៤
ឆន្ទប្បហានកថា ........ ១០៥
កាយាទិបរិញ្ញាកថា ........ ១០៧
សតិប្បដ្ឋានភាវនាកថា ........ ១០៨
សតិប្បដ្ឋានភាវនាគាមិនីបដិបទាកថា ........ ១១០

## អមតវគ្គោ

សតិប្បដ្ឋានសុប្បតិដ្ឋិតចិត្តកថា ........ ១១២
សតិប្បដ្ឋានសមុទយត្ថង្គមកថា ........ ១១៣

# សង្ខេបចង្អុលប្រាប់មាតិកា

មាតិកា | លេខទំព័រ

ពោលអំពីព្រះអនុរុទ្ធដឹងច្បាស់នូវលោក ........................................................ ៩០

ពោលអំពីសិរិវឌ្ឍគហបតី .................................................................................. ៩១

## អននុស្សុតវគ្គ

ពោលអំពីធម៌ដែលមិនធ្លាប់បានស្តាប់ .......................................................... ៩៧

ពោលអំពីការប្រាសចាកតម្រេក.................................................................... ១០០

ពោលអំពីសតិប្បដ្ឋាន ៤ ដែលបុគ្គលខ្វល់ខ្វាយហើយ................................. ១០១

ពោលអំពីសតិប្បដ្ឋាន ៤ ដែលបុគ្គលបានចម្រើនហើយ.............................. ១០២

ពោលអំពីភិក្ខុត្រូវមានស្មារតី........................................................................ ១០៣

ពោលអំពីការលះបង់ឆន្ទៈ ............................................................................. ១០៤

ពោលអំពីការកំណត់ដឹងនូវអារម្មណ៍មានកាយជាដើម .................................... ១០៧

ពោលអំពីសតិប្បដ្ឋានភាវនា.......................................................................... ១០៨

ពោលអំពីបដិបទាជាដំណើរទៅកាន់សតិប្បដ្ឋានភាវនា.................................. ១១០

## អមតវគ្គ

ពោលអំពីការតាំងចិត្តស៊ប់ក្នុងសតិប្បដ្ឋាន ...................................................... ១១២

ពោលអំពីសេចក្តីកើតឡើងនិងសូន្យទៅនៃសតិប្បដ្ឋាន.................................. ១១៣

# មាតិកាបត្តានិ

## មាតិកា

អង្កេ

សត្ថានំ វិសុទ្ធិកថា ............ ១១៤
សតីមភិក្ខុកថា ............ ១១៧
កុសលរាសិកថា ............ ១១៧
បាតិមោក្ខសំវរសំវុតកថា ............ ១១៩
ទុច្ចរិតប្បហានកថា ............ ១២១
មិត្តាមច្ចាទិកថា ............ ១២៣
តិវេទនាកថា ............ ១២៤
ត្យាសវកថា ............ ១២៥

### សតិប្បដ្ឋានសំយុត្តស្ស គង្គាទិបេយ្យាលោ

គង្គានទីបាចីននិន្នកថា ............ ១២៧

### ឥន្ទ្រិយសំយុត្តំ

### សុទ្ធិកវគ្គោ

បញ្ចិន្ទ្រិយកថា ............ ១៣០
អរិយសាវកសោតាបន្នកថា ............ ១៣០
អរហន្តក្ខីណាសវកថា ............ ១៣១
សមណព្រាហ្មណកថា ............ ១៣៣

# សង្ខេបបញ្ជីមាតិកា

មាតិកា លេខទំព័រ

ពោលអំពីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ........................................ ១១៤

ពោលអំពីភិក្ខុមានស្មារតី ........................................ ១១៧

ពោលអំពីកុសលរាស៍ ........................................ ១១៩

ពោលអំពីភិក្ខុសង្រួមក្នុងបាតិមោក្ខសំវរៈ ........................................ ១២០

ពោលអំពីការលះបង់ទុច្ចរិត ........................................ ១២៣

ពោលអំពីពួកជនមានមិត្តអាមាត្យជាដើម ........................................ ១២៤

ពោលអំពីវេទនា ៣ ........................................ ១២៥

ពោលអំពីអាសវៈ ៣ ........................................ ១២៥

## *សតិប្បដ្ឋានសំយុត្តគង្គាទិបេយ្យាល*

ពោលអំពីទន្លេគង្គាហូរទៅក្នុងទិសខាងកើត ........................................ ១២៧

## *ឥន្ទ្រិយសំយុត្ត*

### *សុទ្ធិកវគ្គ*

ពោលអំពីឥន្ទ្រិយ ៥ ........................................ ១៣០

ពោលអំពីអរិយសាវកបានដល់នូវសោតៈ........................................ ១៣០

ពោលអំពីអរហន្តខីណាស្រព........................................ ១៣១

ពោលអំពីសមណព្រាហ្មណ៍........................................ ១៣៣

# មាតិកាបត្តានិ

## មាតិកា

អង្គេ

សោតាបត្តិយង្គេសុ ទដ្ឋព្ពិន្ទ្រិយកថា ........................................ ១៣៦

បញ្ចិន្ទ្រិយកថា........................................................................ ១៣៧

មុទុតរវគ្គោ

បញ្ចិន្ទ្រិយកថា........................................................................ ១៤៤

បញ្ចិន្ទ្រិយានំ បរិបូរត្តា អរហន្តកថា ........................................ ១៤៦

បញ្ចិន្ទ្រិយបរសមគាមិកថា........................................................ ១៥៤

ឆឡិន្ទ្រិយវគ្គោ

ភគវតោ បុនព្ភវានិវត្តនកថា .... ................................................. ១៥៧

ឥន្ទ្រិយកថា ............................................................................ ១៥៧

បញ្ចន្នំ ឥន្ទ្រិយានំ បរិបូរត្តា ភិក្ខុនោ អរហន្តកថា ............... ១៥៨

ឆឡិន្ទ្រិយកថា ......................................................................... ១៥៩

ភិក្ខុអរហន្តក្ខីណាសវកថា .......................................................... ១៦០

សមណព្រាហ្មណកថា ................................................................ ១៦៣

សុខិន្ទ្រិយវគ្គោ

បញ្ចិន្ទ្រិយកថា........................................................................ ១៦៦

ភិក្ខុអរហន្តក្ខីណាសវកថា .......................................................... ១៦៧

# សង្ខេបបញ្ជីមាតិកា

មាតិកា លេខទំព័រ

ពោលអំពីឥន្ទ្រិយដែលបណ្ឌិតគប្បីឃើញក្នុងអង្គនៃសោតាបត្តិមគ្គ.................... ១៣៦

ពោលអំពីឥន្ទ្រិយ ៥ .................................................................................. ១៣៧

## មុទុតរវគ្គ

ពោលអំពីឥន្ទ្រិយ ៥ .................................................................................. ១៤៤

ពោលអំពីភិក្ខុបានជាអរហន្តព្រោះពេញលេញដោយឥន្ទ្រិយ ៥...................... ១៤៦

ពោលអំពីឥន្ទ្រិយ ៥ ជាដំណើរទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ........................... ១៥៤

## ឆឡិន្ទ្រិយវគ្គ

ពោលអំពីព្រះដ៏មានព្រះភាគមិនត្រឡប់មកកាន់ភពថ្មីទៀត ............................ ១៥៧

ពោលអំពីឥន្ទ្រិយ ៣.................................................................................. ១៥៧

ពោលអំពីភិក្ខុជាអរហន្តព្រោះពេញលេញដោយឥន្ទ្រិយ ៥ ........................... ១៥៨

ពោលអំពីឥន្ទ្រិយ ៦ .................................................................................. ១៥៩

ពោលអំពីភិក្ខុជាអរហន្តខីណាស្រព ............................................................ ១៦០

ពោលអំពីពួកសមណព្រាហ្មណ៍..................................................................... ១៦៣

## សុខិន្ទ្រិយវគ្គ

ពោលអំពីឥន្ទ្រិយ ៥ .................................................................................. ១៦៦

ពោលអំពីភិក្ខុជាអរហន្តខីណាស្រព ............................................................ ១៦៧

៣៧៩

# មាតិកាបត្តានិ

## មាតិកា

អង្កេ

*សមណព្រាហ្មណកថា* ............................................ ១៦៨

*ភិក្ខុត្តុំ ឥន្ទ្រិយវិភាគកថា* ............................................ ១៧១

*ផស្សំ បដិច្ច សុខិន្ទ្រិយាទិឧប្បជ្ជនកថា* ............................................ ១៧៧

*ភិក្ខុនោ អប្បមត្តស្ស ទុក្ខិន្ទ្រិយុប្បជ្ជនកថា* ............................................ ១៨១

### ជរាវគ្គោ

*ភគវតោ ជរាធម្មុប្បជ្ជនកថា* ............................................ ១៨៨

*ឧណ្ណាភព្រាហ្មណកថា* ............................................ ១៨៩

*ភគវតោ សាកេតេ អញ្ជនវនេ វិហារកថា* ............................................ ១៩៣

*ភគវតោ សាវត្ថិយំ បុព្វកោដ្ឋកេ វិហារកថា* ............................................ ១៩៦

*ភគវតោ បុព្វារាមេ វិហារកថា* ............................................ ១៩៩

*បិណ្ឌោលភារទ្វាជកថា* ............................................ ២០៦

*អភិប្បសន្នអរិយស្សាវកកថា* ............................................ ២០៩

### សូករខាតវគ្គោ

*ភគវតោ កោសលរដ្ឋេ ព្រាហ្មណគ្គាមេ វិហារកថា* ............................................ ២១៦

*ភគវតោ មល្លកជនបទេ ឧរុវេលកប្បនិគមេ វិហារកថា* ............................................ ២១៧

*ភិក្ខុអសេក្ខបុគ្គលកថា* ............................................ ២១៩

# សង្ខឹកាចង្អុលប្រាប់មាតិកា

មាតិកា

លេខទំព័រ

ពោលអំពីសមណព្រាហ្មណ៍ ........ ១៦៨

ពោលអំពីការចែកឥន្ទ្រិយមាន ៣ លើក ........ ១៧០

ពោលអំពីសុខិន្ទ្រិយជាដើមកើតឡើងព្រោះអាស្រ័យផស្សៈ ........ ១៧៧

ពោលអំពីទុក្ខិន្ទ្រិយជាដើមកើតឡើងដល់ភិក្ខុអ្នកមិនប្រមាទ ........ ១៨១

## *ជរាវគ្គ*

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់ព្រះរាជា ........ ១៨៨

ពោលអំពីឧណ្ណាភព្រាហ្មណ៍ ........ ១៨៩

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រៃអញ្ជនទៀតក្រុងសាកេត ........ ១៩៣

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងបុព្វកោដ្ឋកនិគមជិតក្រុងសាវត្ថី ..... ១៩៦

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងបុព្វារាម ........ ១៩៩

ពោលអំពីព្រះបិណ្ឌោលភារទ្វាជៈ ........ ២០៦

ពោលអំពីអរិយសាវកអ្នកមានសទ្ធា ........ ២០៩

## *សូករខាតវគ្គ*

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងព្រាហ្មណគ្រាមក្នុងដែនកោសល .. ២១៦

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងឧរុវេលកប្បនិគមក្នុងមល្លកជនបទ ...... ២១៧

ពោលអំពីភិក្ខុជាអសេក្ខបុគ្គល ........ ២១៩

# មាតិកាបត្តានិ

## មាតិកា

អង្កេ

ហត្ថិបទកថា........................................................................ ២២២
លោហិតចន្ទនកថា.................................................................. ២២៣
ឯកជម្មប្បតិដ្ឋិតភិក្ខុនា ភាវិតបញ្ចិន្ទ្រិយកថា............................ ២២៤
សហម្បតិព្រហ្មកថា.............................................................. ២២៦
ភគវតោ សូករខាតាយំ វិហារកថា....................................... ២២៩
ទ្វិក្ខត្តុំ ឥន្ទ្រិយុប្បជ្ជនកថា.......................................................... ២៣២

### ពោធិបក្ខិយវគ្គោ

សញ្ញោជនានំ បហានាយ ភាវិតិន្ទ្រិយបុគ្គលកថា................... ២៣៤
អទ្ធានបរិញ្ញាយ ភាវិតិន្ទ្រិយបុគ្គលកថាជ................................ ២៣៥
សត្តផលបត្តានិសំសកថា........................................................ ២៣៧
ចតុក្ខត្តុំ ជម្ពូទីបរុក្ខកថា......................................................... ២៣៨

### ឥន្ទ្រិយសំយុត្តស្ស គង្គានិបេយ្យាលោ

បាចីននិន្នគង្គានទី វិយ និព្វាននិន្នភាវិតិន្ទ្រិយភិក្ខុកថា.......... ២៤៣

### សម្មប្បធានសំយុត្តំ

ចតុស្សម្មប្បធានកថា.......................................................... ២៤៨
សីលំ និស្សាយ ភិក្ខុកថា...................................................... ២៥១

# សង្ខឹកាចង្អុលប្រាប់មាតិកា

មាតិកា

លេខទំព័រ

ពោលអំពីស្នាមជើងដំរី ........................................ ២២២

ពោលអំពីក្លិនខ្លឹមចន្ទន៍ក្រហម ........................................ ២២៣

ពោលអំពីភិក្ខុស្ថិតនៅក្នុងធម៌មួយរមែងញ៉ាំងឥន្ទ្រិយ ៥ ឲ្យចម្រើន ........................................ ២២៤

ពោលអំពីសហម្បតិព្រហ្ម ........................................ ២២៦

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងសូករខាតគូហា ........................................ ២២៩

ពោលអំពីការកើតឡើងនៃឥន្ទ្រិយមានពីរលើក ........................................ ២៣២

## ពោធិបក្ខិយវគ្គ

ពោលអំពីបុគ្គលចម្រើនឥន្ទ្រិយ ដើម្បីលះបង់សញ្ញោជនៈ ........................................ ២៣៤

ពោលអំពីបុគ្គលចម្រើនឥន្ទ្រិយ ដើម្បីកំណត់ដឹងនូវកាលយូរ ........................................ ២៣៥

ពោលអំពីផល ៧ អានិសង្ស ៧ ........................................ ២៣៧

ពោលអំពីដើមឈើក្នុងជម្ពូទ្វីបមាន ៤ លើក ........................................ ២៣៨

## ឥន្ទ្រិយសំយុត្ត គង្គាទិបេយ្យាល

ពោលអំពីភិក្ខុចម្រើនឥន្ទ្រិយ រមែងមានទំនាបរកព្រះនិព្វានដូចទន្លេគង្គាមានទំនាបកថាខាងកើត ........................................ ២៤៣

## សម្មប្បធានសំយុត្ត

ពោលអំពីសម្មប្បធាន ៤ ........................................ ២៤៨

ពោលអំពីភិក្ខុអាស្រ័យនូវសីល ........................................ ២៥១

# មាតិកាបត្ថានិ

## មាតិកា

អង្កេ

*តិឯសនាកថា* ........................................ ២៥២

*បញ្ចុទ្ទម្ភាតិយសញ្ញោជនកថា* ........................................ ២៥៣

### ពលសំយុត្តំ

*បញ្ចពលកថា* ........................................ ២៥៥

### ឥទ្ធិបាទសំយុត្តំ

### ចាបាលវគ្គោ

*ចតិទ្ធិបាទកថា* ........................................ ២៥៩

*ភគវតោ កូដាគារសាលាយំ វិហារកថា* ........................................ ២៧១

*រមណីយវេសាលីកថា* ........................................ ២៧២

*ភគវតោ អានន្ទាមន្តនកថា* ........................................ ២៧៤

*បាបិមមារស្ស ភគវន្តូបសង្កមនំ* ........................................ ២៧៥

*ភគវតោ អាយុសង្ខារោស្សជ្ជនកថា* ........................................ ២៨០

### ចាសាទកម្បនវគ្គោ

*ពោធិសត្តស្ស បរិវិតក្កោ* ........................................ ២៨២

*ឥទ្ធិបាទភាវនាកថា* ........................................ ២៨៣

*ភគវតោ មិគារមាតុប្បាសាទេ វិហារកថា* ........................................ ២៩៤

# សន្លឹកចង្អុលប្រាប់មាតិកា


មាតិកា លេខទំព័រ

ពោលអំពីការស្វែងរកមាន ៣ យ៉ាង ........ ២៥២

ពោលអំពីសញ្ញោជនៈជាចំណែកខាងលើ ៥ ........ ២៥៣

## ពលសំយុត្ត

ពោលអំពីពលៈ ៥ ........ ២៥៥

## ឥទ្ធិបាទសំយុត្ត

## បាវាលវគ្គ

ពោលអំពីឥទ្ធិបាទ ៤ ........ ២៥៩

ពោលអំពីព្រះដ៏មានព្រះភាគក្នុងកូដាគារសាលា ........ ២៧១

ពោលអំពីក្រុងវេសាលី គួរជាទីរីករាយនិងនុ◌ិង ........ ២៧២

ពោលអំពីព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទ ........ ២៧៥

ពោលអំពីមារមានចិត្តបាបចូលទៅរកព្រះដ៏មានព្រះភាគ ........ ២៧៥

ពោលអំពីព្រះដ៏មានព្រះភាគដាក់អាយុសង្ខារ ........ ២៨០

## បាសាទកម្បនវគ្គ

ពោលអំពីសេចក្តីត្រិះរិះនៃព្រះពោធិសត្វ ........ ២៨២

ពោលអំពីការចម្រើនឥទ្ធិបាទ ........ ២៨៣

ពោលអំពីព្រះដ៏មានព្រះភាគគង់ក្នុងមិគារមាតុប្រាសាទ ........ ២៩៤

# មាតិកាបត្តានិ

## មាតិកា

អង្កេ

មោគ្គល្លានស្ស មិគារមាតុប្បាសាទស្ស សង្កម្បាបនកថា......... ២៩៥

អានន្ទស្ស ឃោសិតារាមេ វិហារកថា .................................... ២៩៩

ឥទ្ធិបាទភាវនាគាមិនីបដិបទាកថា.............................................. ៣១១

អតិលីនឆន្ទកថា.......................................................................... ៣១៣

## អយោគុឡវគ្គោ

ពោធិសត្តស្ស បរិវិតក្កកថា ..................................................... ៣២៣

អានន្ទស្ស ភគវន្តូបសង្កមនកថា................................................ ៣២៦

តថាគតស្ស ចិត្តេ កាយស្ស សមាទហនកថា .................... ៣២៧

សត្តផលសត្តានិសំសានំ បាតុភាវកថា.................................... ៣៣១

ឥទ្ធិវិធស្ស បច្ចនុភវនកថា ........................................................ ៣៣៦

មហិទ្ធិកតថាគតកថា .................................................................. ៣៤២

## ឥទ្ធិបាទសំយុត្តស្ស តង្គានិបេយ្យាលោ

បាចីននិន្នគង្គានទីកថា .............................................................. ៣៤៥

## អនុរុទ្ធសំយុត្តំ រហោគតវគ្គោ

អនុរុទ្ធស្ស ជេតវនេ អារាមេ វិហារកថា............................. ៣៤៧

ភិក្ខុនោ បដិកូលេ អាកង្ខកថា................................................ ៣៤៩

# សង្ខឹកាចង្អុលប្រាប់មាតិកា


| មាតិកា | លេខទំព័រ |
|---|---|
| ពោលអំពីព្រះមោគ្គល្លានញ៉ាំងមិគារមាតុប្រាសាទឲ្យកម្រើក | ២៩៥ |
| ពោលអំពីព្រះអានន្ទគង់ក្នុងឃោសិតារាម | ២៩៩ |
| ពោលអំពីបដិបទាជាដំណើរទៅកាន់ការចម្រើនឥទ្ធិបាទ | ៣១១ |
| ពោលអំពីឆន្ទៈធ្វើរថយខ្លាំងពេក | ៣១៣ |

## អយោគុឡវគ្គ

| | |
|---|---|
| ពោលអំពីសេចក្តីត្រិះរិះនៃព្រះពោធិសត្វ | ៣២៣ |
| ពោលអំពីការចូលទៅគាល់ព្រះដ៏មានព្រះភាគនៃព្រះអានន្ទ | ៣២៦ |
| ពោលអំពីការតម្កល់កាយក្នុងចិត្តនៃព្រះតថាគត | ៣២៧ |
| ពោលអំពីការកើតប្រាកដនៃផល ៧ ប្រការនិងអានិសង្ស ៥ ប្រការ | ៣៣១ |
| ពោលអំពីការសម្រេចនូវឥទ្ធិវិធៈ | ៣៣៦ |
| ពោលអំពីព្រះតថាគតមានឫទ្ធិច្រើនយ៉ាង | ៣៤២ |

## *ឥទ្ធិបាទសំយុត្ត គង្គាទិបេយ្យាល*

| | |
|---|---|
| ពោលអំពីទន្លេគង្គាមានទំនាបទៅខាងកើត | ៣៤៥ |

## *អនុរុទ្ធសំយុត្ត រហោគតវគ្គ*

| | |
|---|---|
| ពោលអំពីព្រះអនុរុទ្ធគង់នៅក្នុងវត្តជេតពន | ៣៤៧ |
| ពោលអំពីសេចក្តីប្រាថ្នានៃភិក្ខុក្នុងបដិកូលសញ្ញា | ៣៤៩ |

# មាតិកាបត្ថានិ

## មាតិកា

អង្កេ

*ភិក្ខូនំ ចតុស្សតិប្បដ្ឋានានំ អារកនកថា* .................................. ៣៥៣
*មោគ្គល្លានស្ស អនុរុទ្ធស្ស បុច្ឆនកថា* .................................... ៣៥៤

## ទុតិយវគ្គោ

*សម្ពហុលានំ ភិក្ខូនំ អនុរុទ្ធបសង្កមនកថា* ............................ ៣៦៧
*អនេកវិហិតស្ស ឥទ្ធិវិធស្ស បច្ចនុភវនកថា* ............................ ៣៦៨

---

# សង្ខេបចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

ពោលអំពីការបោះបង់នូវសតិប្បដ្ឋាន ៤ នៃពួកភិក្ខុ ................................... ៣៥៣

ពោលអំពីព្រះមោគ្គល្លានសួរព្រះអនុរុទ្ធ ......................................................... ៣៥៤

## ទុតិយវគ្គ

ពោលអំពីការចូលទៅរកព្រះអនុរុទ្ធនៃពួកភិក្ខុច្រើនរូប ...................................... ៣៦៧

ពោលអំពីការសម្រេចឥទ្ធិវិធៈច្រើនប្រការ ....................................................... ៣៦៨

